# ក្រមង៉ុយ និង ស្នាដៃ

# KRAM NGOY ET SES ŒUVRES



រៀបរៀង ដោយ **ឃីង ហុកឌី**

អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រក្រុងប៉ារីស
សមាជិករាជបណ្ឌិតសភាកម្ពុជា

**KHING Hoc Dy**
**Laboratoire SEDET - CNRS**

Editions Angkor

www.elibraryofcambodia.org

ទទួលអំណោយពីលោក ខ្មែរ ឃុនសារ៉េង ដល់ករុណាខ្ញុំ
ដើម្បីទុកដាក់ក្នុង elibrary of Cambodia កក្កដា 2015

# ក្រមង៉ុយ និងស្នាដៃ

រៀបរៀងដោយ


**ឃីង ហុក ឌី**

អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រក្រុងប៉ារីស
សមាជិករាជបណ្ឌិតសភាកម្ពុជា


# KRAM NGOY ET SES ŒUVRES


**KHING Hoc Dy**
Laboratoire SEDET - CNRS



បណ្ណាគារអង្គរ
២០០៨


www.elibraryofcambodia.org

© រក្សាសិទ្ធគ្រប់យ៉ាង

បោះពុម្ពផ្សាយដោយ

គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ ( Editions Angkor )

ISBN - 13 : 978-99950-2-049-1

២០០៨

www.elibraryofcambodia.org

# មាតិការឿង


| | |
|---|---|
| | ទំព័រ |
| - សេចក្ដីផ្ដើម | ៧ |
| - Les recommandations de Kram Ngoy | 19 |
| - Traduction | 26 |
| - បណ្ដាំក្រមង៉ុយ | ៤១ |
| - ឧបសម្ព័ន្ធ | ៦២ |
| - អធិប្បាយកថាសង្ខេបលើស្នាដៃក្រមង៉ុយ | ៦៣ |
| - ស្នាដៃក្រមង៉ុយ | ៨៧ |
| - ច្បាប់ល្បើកថ្មី | ៨៩ |
| - ច្បាប់កេរកាលថ្មី | ១២១ |
| - សេចក្ដីរំលឹកដាស់តឿន | ១៣៤ |
| - ពាក្យកាព្យប្រដៅជនប្រុសស្រី | ១៤៨ |
| - ល្បើកច្បាប់សង្ស | ១៥៩ |
| - បញ្ជីឯកសារយោង | ១៧៣ |
| - រូបភាព | ១៧៩ |


www.elibraryofcambodia.org

# ស្នាដៃអ្នកនិពន្ធ ដដែល ជាសៀវភៅ
## DU MÊME AUTEUR

- *Contes et légendes du pays khmer*, Paris, Cilf, 1989.
- *Contribution à l'histoire de la littérature khmère. L'époque "classique" (XVe-XIXe siècles)*, vol. 1, Paris, L'Harmattan, 1991.
- *Écrivains et expressions littéraires du Cambodge au XXe siècle*, vol. 2, Paris, L'Harmattan, 1993.
- *Un épisode du Rāmāyaṇa khmer, Rāma endormi par les maléfices de Vaiy Rābṇ*, Paris, L'Harmattan, 1995.
- ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, *Aperçu général sur la littérature khmère*, Paris, L'Harmattan, 1997 (2ème édition, Phnom Penh, Ed. Angkor, 2003).
- មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សទី២០, ភ្នំពេញ, Editions la plus haute tour, ២០០២ ។
- មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សទី១៩, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៣ ។
- កំណត់ពិធីហៅព្រលឹង, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៤ ។
- សាស្ត្រាមហាគ្រឹះសន្ធឹងយកព្រះរាមបាន, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៤ ។
- *Dāv Ek. Introduction, traduction annotée et textes khmers*, Phnom Penh, Ed. Angkor, 2005.
- en coll. avec Jacques NEPOTE, *Samapheari de Rim Kin*, Phnom Penh, Ed. Angkor, 2005.
- សម្បូរកម្មអក្សរសិល្ប៍ខ្មែរ, ឌុច្ឆិស ផុន សាស្ត្រាចារ្យ កេងវ៉ាន់សាក់ ប្រមូលផ្តុំអត្ថបទដោយ ឃីងហុកឌី, ភ្នំពេញ, ២០០៦ ។
- *Un auteur cambodgien et son œuvre: le Bhogakumar du poète Nau (fin 18ème-début 19ème siècles)*, Phnom Penh, Ed. Angkor, 2006.
- en collaboration avec Jacques DOLIAS, *Sin le chauffeur, une nouvelle de 1956 par Im Thok*, Phnom Penh, Ed. Angkor, 2007.
- អក្សរសិល្ប៍ខ្មែរសតវត្សទី២០, កវីនិពន្ធនិងកម្រងអត្ថបទ, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧ ។
- ស្នាកម្មអក្សរសិល្ប៍មិនមែនកម្ពុជានៅសតវត្សទី១៩និងទី២០, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៨ ។



www.elibraryofcambodia.org

# សេចក្តី ផ្តើម[1]

ង៉ុយ ជា អ្នក ចម្រៀង សាដៀវ ប្រជាករ មួយ រូប ដែល ខ្មែរ យើង ជំនាន់ នោះ ស្គាល់ គ្រប់ ជនបទ ។ យើង ស្គាល់ ដឹង ជីវប្រវត្តិ របស់ តា ង៉ុយ នេះ ដោយ សារ ឯកសារ ស្រាវ ជ្រាវ លោក លី-ធាមតេង ដែល ជា អ្នក ស្រាវ ជ្រាវ នៅ វិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ និង ជា សមាជិក អ្នក និពន្ធ ខ្មែរ ។ [2] នៅ ឆ្នាំ ១៩៦០ លី-ធាមតេង បាន សាកសួរ អ្នក ដែល បាន ស្គាល់ កវី ប្រជាករ នេះ ជាពិសេស លោក បណ្ឌិតចាស់ៗ នៅពុទ្ធសាសនបណ្ឌិត្យ ដែល បាន ចូល និវត្តន៍ ដូច ជា លោក ចាប-ពិន, លោក ប៉ុ-ប៉ូ, លោក ជា-យូរ បានទទួល ព័ត៌មាន ខ្លះៗ ស្តីពី អាកប្បកិរិយា, សំលៀកបំពាក់, ពីរបៀប ច្រៀងសាដៀវ, ពីទេពកោសល្យ ក្នុងការ កើតកំណាព្យ ភ្លាមៗ ។

ថ្ងៃ មួយ លោក លី-ធាមតេង បាន ទទួល សក្រា ចាស់ មួយ ចំនួន ៤ សន្លឹក ដែល តា ង៉ុយ ផ្ទាល់ បាន ចារ ពី ប្រវត្តិរូប លោក ដោយ បាន ឃើញ ស្រុក ភូមិ កំណើត

---

[1] អត្ថបទ ជា ភាសាបារាំង ខាង ក្រោយ នេះ បាន ចុះ ផ្សាយ ក្នុង ទស្សនាវដ្តី «សិក្សាមន-ខ្មែរ» លេខ ៧ នៅ សាកល វិទ្យាល័យ ហាវ៉ៃ នៃ សហរដ្ឋ អាមេរិក ក្នុង ឆ្នាំ ១៩៧៨ ។ សេចក្តី ផ្តើម ជា ភាសា ជាតិ នេះ មិន មែន ជា សេចក្តី បក ប្រែ ពី អត្ថបទ ភាសា បារាំង ទាំង ស្រុង ទេ ។ អត្ថបទ នេះ បាន បោះ ពុម្ព ផ្សាយ នៅ «មជ្ឈមណ្ឌល ឯកសារ និង ស្រាវ ជ្រាវ អរិយធម៌ ខ្មែរ» នៅ ក្រុង ប៉ារីស ឆ្នាំ ១៩៨១ មាន ៤២ ទំព័រ ហើយ បានយក កែសម្រួល ឡើងវិញ ។

[2] លី-ធាមតេង, *អ្នកនិពន្ធ ខ្មែរ, ភិរម្យ-ង៉ុយ*, ភ្នំពេញ, បណ្ណាគារ សេង-ងួនហួត, ១៩៦៦, ៦៤ ទំព័រ ។ សូម អាន លី-ធាមតេង, «ព្រះភិរម្យ ភាសា អ៊ូ ក្រមង៉ុយ» ក្នុង សៀវភៅ *អក្សរសាស្ត្រ ខ្មែរ*, ភ្នំពេញ, បណ្ណាគារ សេង-ងួនហួត, ១៩៦០, ទំព័រ ១៩៤-១៩៨ ។



www.elibraryofcambodia.org

ជាហេតុធ្វើឲ្យអ្នកស្រាវជ្រាវរូបនេះទៅស៊ើបសួររកកូនចៅនៅភូមិកំណើតគឺ ឃើញ។ ៦

តាង៉ុយ កើតនៅឆ្នាំ១៨៦៥ នៅភូមិកំពូល ស្រុកភ្នំពេញសព្វថ្ងៃ ស្រុក អង្គស្នួល ក្នុងខែត្រកណ្ដាល។ លោកមាននាមដើម «អ៊ុក-អ៊ូ» ប៉ុន្តែមាតាបិតា លោកហៅក្រៅថាង៉ុយៗ ក៏ជាប់នាមនេះរហូតមក។

បិតានាមអ៊ុក ធ្វើមេឃុំនៅឃុំកំពូល មានគោរម្យងារជា «ចៅពញា ធម្មធារា»។ ឯមាតាជាបុត្រី «ចៅពញាម៉ុក» មេឃុំស្ពានថ្ម ស្រុកខេត្តជាមួយ គ្នា។ មាតាបិតាលោកជាប់ជាបងប្អូនជីដូនមួយនឹងគ្នា។

កាលនៅកុមារបានសំណាក់រៀននឹងលោកចៅអធិការវត្តអង្គបឹងចក នៅស្រុកកំណើតលោក។ កុមារអ៊ុក-អ៊ូ ហៅង៉ុយ ជាក្មេងឧស្សាហ៍រៀនសូត្រ បានបួសជាសាមណេរ ចេះធម៌អាថ៌ជ្រៅជ្រះ។ កាលពេញវ័យ ២១ ឆ្នាំ សាមណេរង៉ុយបំពេញឧបសម្បទាជាភិក្ខុ។ ភិក្ខុអង្គនេះបានសិក្សាធម៌អាថ៌ ស្វះស្វែងរៀនប្រែព្រះត្រៃបិដកដំបូងក្នុងសំណាក់លោកគ្រូអាចារ្យ «ទិត្យ» គង់ វត្តអង្គបឹងចក ភូមិបែកស្អក ឃុំបែកចាន ស្រុកភ្នំពេញ ខេត្តកណ្ដាល។ បន្ទាប់

---

៦.«ទិដ្ឋភាពភូមិនេះមិនជាប្លែកពីអ្វីឡើយ ជាកូនភូមិស្ងាត់ ដែលមាន ផ្ទះនៅទៅព័ទ្ធជុំវិញ ផ្ទះតូចៗ ប្រមាណជា២០ប៉ុណ្ណោះ។ ខ្ញុំសួរអ្នកដើរ ស្វែងរកផ្ទះពូជួង គេនាំទៅបង្ហាញប្រាប់ផ្ទះនោះ។ គ្រានោះ ខ្ញុំឃើញតា ចាស់ម្នាក់មានមាឌទុកពុកមាត់យ៉ាងវែងរីង អង្គុយបិតបន្ទោះនៅក្នុង ទាងប្រហែលនឹងផ្ទះ។ នេះហើយពូជួង ជាកូនប្អូនរបស់លោកតាភិរម្យ ង៉ុយ។ លោកនេះសប្បាយណាស់ កាលបើដឹងថាខ្ញុំទៅស៊ើបសួរពី ព័ត៌មានពីពុកគាត់។ គាត់ហៅកូនចៅគាត់មកជួបជុំជាមួយខ្ញុំ ខ្ញុំសួរព័ត៌មាន សព្វគ្រប់ ដែលគាត់ឆ្លើយមកវិញគ្មានអាក់មួយសំនួរណាទេ។ កូន ប្រុសគាត់ម្នាក់ឈ្មោះ **ជួង-យាន** ជាអ្នកជាជួយបន្ថែមសេចក្ដី។» លី ធាមតេង, *អ្នកនិពន្ធខ្មែរ, ភិរម្យ-ង៉ុយ* (១៩៦៦), ទំព័រ១-១១។



www.elibraryofcambodia.org

ពី ប្រែ ព្រះ ត្រៃបិដក ភិក្ខុ ង៉ុយ ស្វែង រៀន វិបស្សនា កម្មដ្ឋាន ក្នុង សំណាក់ ព្រះអាចារ្យជាច្រើនកន្លែងទៀត ។

ក្រោយ ពី បាន ចាក សិក្ខាបទ មក ជា គ្រហស្ថ លោក បាន រៀប អាពាហ៍ពិពាហ៍ នៅឃុំបែកចានស្រុកភ្នំពេញ ហើយ ប្រកបរបរ ជា អ្នក ស្រែ ធម្មតា ក្នុង ឃុំ នោះ ។ លោក មាន កូន ៦ នាក់ ឈ្មោះ«**ជួង, ចេង, ចា, ចិន, ចុង និង ចេវ**»កូនទី៥ក្រោយមកបានបួសរៀន ជ្រៅជ្រះ ហើយ មានសំនីអាហារ ថ្វីមាត់ ប្រហាក់ប្រហែល និង លោក តា ង៉ុយ ដែរ ។ បន្ទាប់ពីបាន ចាក សិក្ខាបទ មក ជា គ្រហស្ថ អ្នក ស្រុក ប្រសិទ្ធិនាម លោក ហៅ ថា អាចារ្យ «**ចុង**»+ ដែល ជាកវី និពន្ធ មាន ឈ្មោះ ល្បី ខាង សំនួនអាហារ ខ្លាំងក្លា លោកបាន ទទួល អនិច្ចកម្ម ក្នុង គុក នយោបាយ នៅឆ្នាំ១៩៥៥ នា ពេល បោះ ឆ្នោត គណៈបក្សប្រជាធិបតេយ្យ ប្រឆាំង និង គណៈ បក្ស សង្គម រាស្ត្រនិយម ។ លោកអាចារ្យ «ចុង» នេះ ជា សមាជិកសកម្មសំខាន់មួយរូប បាន ជួយ ឃោសនាឲ្យគណៈបក្សប្រជាធិបតេយ្យ ហេតុ នេះ ហើយ បាន ជា អាជ្ញាធរ ជំនាន់ នោះ ចាប់ លោក ដាក់ ពន្ធនាគារ បង្ខាំង លោក មិន ឲ្យ ឃោសនា បន្ត ដើម្បី ជួយ ទ្រទ្រង់ គណៈ បក្ស ដែល ប្រឆាំង នឹង រាជរដ្ឋាភិបាល នាពេល នោះ ។

ក្នុងការរស់នៅជាកសិករ តាង៉ុយ មានប្រជាប្រិយភាពខ្លាំងខាង អាហារនិងល្បិចលើកកំណាព្យភ្លាមៗ ច្រៀង ឡើង ជា មួយ និង សំនៀង

---

+លោក អាចារ្យ នេះ បាន បន្សល់ ទុក ស្នាដៃ ជាកំណាព្យ ខ្លះៗ ដូច ជា៖ អ៊ូ-ចុង, *ច្បាប់ដំបូន្មាន បព្វជិត គ្រហស្ថ*, ភ្នំពេញ, ១៩៥៥, (បោះពុម្ព លើក ទី ៨ នាឆ្នាំ ១៩៥៨) ៣៦ ទំព័រ; អ៊ូ-ចុង, *ច្បាប់គោរពមាតាបិតា*, ភ្នំពេញ, គីមសេង, ១៩៥៥ (បោះពុម្ព លើក ទី ២ នាឆ្នាំ១៩៦៧), ៤៣ ទំព័រ ។ លោក ជា បញ្ញាជន ទំនៀម ដែល ផុស ចេញ ពី ប្រជាជន តែ លោក មាន ឧត្តមគតិ ទំនើប បាន ជួយ ឃោសនា នយោបាយ គណៈបក្សប្រជាធិបតេយ្យ ហើយ អាជ្ញាធរទំនាន់នោះបានចាប់ លោក ដាក់ ពន្ធនាគារ នា ពេល ឃោសនា ដើម្បី បំបិទ មតិ យោបល់ កុំ ឲ្យ ផ្សព្វ ផ្សាយ ពន្យល់លទ្ធិប្រជាធិបតេយ្យដល់ប្រជាជនតូចតាចបាន ។



www.elibraryofcambodia.org

សារដៀវ យ៉ាង ពិរោះ ព្រម ទាំង មាន ចំណេះ ខាង ធម៌ អាថ៌ ខ្ពង់ ខ្ពស់ ដែល ធ្វើ ឲ្យ កសិករឯទៀតរាប់អានស្រឡាញ់ទុកលោកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយ អ្នក ភូមិ ស្រុក ហៅ លោក ថា «ភិរម្យ ង៉ុយ» ។ បន្ទាប់ មក រដ្ឋអំណាច បានតាំង លោក ជា «ក្រម» គឺ ជា ភារៈ ផន ដែល ធ្វើ ទំនាក់ ទំនង រវាង រដ្ឋបាល និង ប្រជាជន ក្នុង ឃុំ ។

ពេល រដូវ រំហើយ ក្រោយពី កិច្ចការ ច្រូត កាត់ ក្រម ង៉ុយ តែង ទេសនា ប្រៀនប្រដៅច្រៀងកំណាព្យបន្ទរដោយសំនៀងសារដៀវដ៏ក្រលួចពីភូមិមួយ ទៅ ភូមិ មួយ ដោយ យំ ស្រណោះ អាណិត ខ្មែរ គ្នាឯងពីភាពខ្សត់ខ្សោយ ក្រីក្រល្ងង់ខ្លៅ ឈ្លោះ គ្នាឯង បែកបាក់ សាមគ្គី, ផុយ និង ទម្ងន់ពន្ធ ដារ នៃ អាជ្ញាធរ បារាំង ភាព រហ័សរហួន ឆ្លាត ការកេងបន្លំ ជនបរទេស មាន ចិនយួន ជាដើម ។ សំនួរល្បី ល្បាញពីកវី សិល្បករ នេះ លេច ឮ ដល់ ទី ក្រុង ហើយ សម្ដេច ចក្រី បាន ហៅឲ្យ ទៅ ច្រៀង ថ្វាយ ស្ដេច ស៊ីសុវត្ថិ ស្ដេច ពេញ ព្រះទ័យ ឲ្យ រង្វាន់ ជា ប្រាក់ កាស និង គោរម្យងារ ជា «ព្រះភិរម្យភាសា» ។

សំនួរ ល្បី ល្បាញ តា ង៉ុយ នេះ ដឹង ដល់ លោក ហ្សក ស៊ឺដេស (George COEDES) សមាជិក សាលា បារាំង ចុង បូព៌ា ប្រទេស ដែល ជាអ្នកប្រាជ្ញ ផ្នែក ខេមរវិទ្យា ឯកទេស ខាង សិលាចារឹក និង ប្រវត្តិវិទ្យា ខ្មែរ សម័យ បុរាណ ដែលជា អ្នកចេះភាសាខ្មែរច្បាស់លាស់ដោយ មានភរិយាខ្មែរថែមទៀតផង, លោក បាន ស្ដាប់ ចម្រៀង លោកតាភិរម្យង៉ុយ ដោយ យកចិត្តទុកដាក់ ហើយ លោក ពេញ ចិត្ត ជា អនេក ។ «ពេល មួយ ដែល លោក មាន បេសកកម្ម ខាង ស្រាវជ្រាវ តម្រូវ ឲ្យ លោក ទៅឯ ក្រុង បាងកក, កាល នោះ លោក ក៏នាំ ទាំង អ្នកចម្រៀង ខ្មែរ រូប នេះ

---

សម្ដេចចក្រីក្នុងរជ្ជកាលហ្លួងស៊ីសុវត្ថិគឺលោកសើន-ឌៀប (សុន-ឌៀប)ដែលជាអ្នកប្រាជ្ញកវី-និពន្ធមួយរូបនៅសម័យ អាណានិគម បារាំង ។ សូមអានឃីង ហុកឌី, «សើន-ឌៀប» ក្នុង *អក្សរសិល្ប៍ខ្មែរសតវត្សទី២០*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧, ទំព័រ ៦៣-៧០ ។ cf. Khing Hoc Dy, "Le voyage de l'envoyé cambodgien Son Diêp à Paris en 1900", in: Claudine Salmon (éd.), *Récits de voyage des Asiatiques. Genre, mentalités, conception de l'espace*, Paris, Publ. EFEO, 1996, p.367-383.



www.elibraryofcambodia.org

ទៅច្រៀងថ្វាយព្រះចៅសៀម ដែលសព្វថ្ងៃឮថានៅសល់ទាំងប្រាក់ដែលស្ដេចសៀមបានប្រទានមកគាត់កាលពីគ្រានោះផង ។ »[6]

លុះត្រឡប់មកពីស្រុកសៀមវិញ គឺនៅក្នុង គ.ស ១៩៣០ លោកហ្សក សឺដេស (George COEDES) បាននាំទៅជួបអ្នកស្រី «ស៊ុយហ្សាន ការប៉ឺឡែស»[7] (Suzanne KARPELES) នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។ អ្នកស្រីនាយកនេះបានឲ្យអ្នកប្រាជ្ញនៅវិទ្យាស្ថាននេះកត់ត្រាសំដីចម្រៀងកំណាព្យតាង៉ុយទាំងអស់ ពេលដែលលោកច្រៀងរឿងៗមួយៗ ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពកំណាព្យតាង៉ុយជាកូនសៀវភៅបួន ។ អ្នកស្រីនាយកបានឲ្យកំរៃជាប្រាក់១រៀលជំនាន់នោះ ។ ប្រាក់១រៀលតិចមែនពិត តែអំណោយនេះសំខាន់តែទុកជាកិច្ចប្រវត្តិសាស្ត្រ បង្ហាញឲ្យឃើញថា បារាំងទាំងអស់មិនមែនសុទ្ធតែអ្នកអាណានិគមមកជិះជាន់ខ្មែរ គឺមានអ្នកប្រាជ្ញខ្លះៗ ស្រឡាញ់រាប់អានវប្បធម៌ អរិយធម៌ខ្មែរ ចង់រក្សាទុកជាស្នាដៃមនុស្សជាតិ ។

ក្រមង៉ុយទទួលអនិច្ចកម្មក្នុងឆ្នាំ១៩៣៦ ក្នុងជន្មាយុ៧១ឆ្នាំ ។

កម្រងច្រៀនប្រដៅទាំងអស់របស់តាង៉ុយមានន័យសេចក្ដីជ្រាលជ្រៅ ដាស់តឿនដល់ខ្មែរទូទៅ ជាពិសេសគឺខ្មែរអ្នកស្រុកស្រែចំការ ដែលខ្សត់ខ្សោយ ដោយទទួលការរំលោភជិះជាន់នៃរដ្ឋអំណាចសម័យនោះ ប្រការកេងបន្លំបំភ័ន្តរបស់ជនបរទេស មានចិន-យួនជាដើម ពីការឈ្លោះប្រកែកគ្នារវាងខ្មែរគ្នាឯងក្នុងការកាន់ពុទ្ធសាសនាធម៌ចាស់-ធម៌ថ្មី ត្រូវខុសគ្នា រំលឹកឲ្យខំធ្វើការ...ដូចមានក្នុងការដកស្រង់ខ្លះៗខាងក្រោមនេះស្រាប់៖

[6] លី ធាមតេង, *អ្នកនិពន្ធខ្មែរ*, *ភិរម្យ-ង៉ុយ*..., ទំព័រ ២៨ ។

[7] សូមអានអត្ថបទ ឃីងហុកឌី, «អ្នកស្រីស៊ុយហ្សានការប៉ឺឡែស និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ», *សិក្សាចក្រ* លេខ ៨-៩, ២០០៦-២០០៧, ទំព័រ ១៨៩-១៩៦ ។



www.elibraryofcambodia.org

**ការ ឈ្លោះ ប្រកែក ពី រឿង ប្រណិប័តន៍ សាសនា៖**

«ពួកចាស់ជឿលទ្ធអ្នកប្រាជ្ញថ្មី    រឿងធម៌បាលីស្ដីប្រមាណ
ប្រមាថទៅមកមិនឈប់ខាន    ហាមប្រាមមិនបានមិនបិទមាត់ ។
ព្រះធម៌ព្រះពុទ្ធតែមួយអង្គ    ព្រះសង្ឃបួសរៀនមានដោយវត្ត
សង្ឃខ្លះចេះស្ទើរមិនចាំស្ទាត់    ភ្លើៗ សូត្រភ្លាត់មិនត្រូវខ្យល់ ។ »

ស្រង់ពី *សេចក្ដីរលឹកដាស់តឿន*

**ការ ទូន្មាន ឲ្យ ចេះ ខិត ខំ រក ស៊ី៖**

«កើតមកជាមនុស្ស    ទាំងស្រីទាំងប្រុស
មិនដែលចេះឯង    បើក្រឲ្យមាន
វិញ្ញាណចេះប្រែង    មិនគ្រប់កន្លែង

កុំដេកតែក្រ ។ »

ស្រង់ពី *ច្បាប់ល្បើកថ្មី* ។

**ទូន្មាន ក្នុង ការ រើស គូ ស្រករ៖**

«កូនចៅប្រុសស្រី    រកប្រពន្ធប្ដី
ឲ្យរកស្រុកជិត    បើរកស្រុកឆ្ងាយ
ឲ្យម្ដាយពិនិត្យ    ឲ្យត្រឹមត្រូវពិត

ពូជពង្សពិតារ ។ »

ស្រង់ពី *ច្បាប់ល្បើកថ្មី* ។

**កិច្ច គោរព មាតា បិតា៖**

«ម្ដាយឪពុកនិងកូន    បីដូចខ្លួននិងស្រមោល
ឃើញខុសកុំដេញដោល    កុំថ្កោលទោសអ្នកមានគុណ
ល្ងង់ខ្លៅត្រូវតែសួរ    ពាក្យឲ្យគួរកុំឲ្យស៊ុន
បេកពាក្យផ្អែមជាមុន    ទន់លំទោនឱនប្រណិប័តន៍ ។



www.elibraryofcambodia.org

ទោះម៉ែឪស្លូតកាច    គួរតែខ្លាចដូចមហាក្សត្រ
ម្ដាយជេរពីរបីមាត់    គួរតែស្ងាត់ស្ងៀមឲ្យឈឹង ។ »

ស្រង់ពី *ច្បាប់កេរ្តិ៍កាលថ្មី* ។

**ការ យល់ ខុស ឬ អាន ខុស -**

«ព្រោះមនុស្សឥឡូវ    យល់ខុសជាត្រូវ
យកឆ្កួតធ្វើជា    អំពើអាក្រក់
ឡើកឡូកពីលោ    ព្រហើនពានពារ

អានមាស អានប្រាក់ ។

អានព្រើល អានប្រផ្លូ    អានកោង អានកាច
អានកាប់ អានចាក់    អានជើង អានដៃ
អានជិះ អានធាក់    អានពុក អានប្រវក់

អានម៉ាស៊ីនកាត់ករ ។ »

ស្រង់ពី *ច្បាប់ល្បើកថ្មី* ។

កម្រងកំណាព្យ តាង៉ុយ ដែល ពុទ្ធសាសនបណ្ឌិត្យ បាន បោះពុម្ព ផ្សាយមាន៖-

- ច្បាប់ល្បើកថ្មី, បោះពុម្ពលើកទី១, រាជបណ្ណាល័យ, ១៩៣២,
- ច្បាប់កេរ្តិ៍កាលថ្មី, បោះពុម្ពលើកទី១, រាជបណ្ណាល័យ, ១៩៣២,
- សេចក្ដីរំលឹកដាស់តឿន, បោះពុម្ពលើកទី១, រាជបណ្ណាល័យ, ១៩៣៣,
- ពាក្យកាព្យប្រដៅជនប្រុសស្រី, បោះពុម្ពលើកទី១, រាជបណ្ណាល័យ, ១៩៣៣–១៩៣៤ (?)[៥]

---

[៥]ច្បាប់ទាំងឡាយរបស់លោកក្រមង៉ុយ នេះពុទ្ធសាសនបណ្ឌិត្យ បានយកបោះពុម្ពឡើងវិញដោយផ្ដុំបញ្ចូលគ្នាជាកម្រងច្បាប់ឲ្យនៅតែមួយសៀវភៅដោយដាក់ចំណងជើងថា៖- *ច្បាប់ក្រមង៉ុយ* (ច្បាប់ល្បើកថ្មី, ច្បាប់កេរកាល, សេចក្ដីរំលឹកដាស់



www.elibraryofcambodia.org

ស្នាដៃមួយទៀតរបស់គាង៉ុយ មានចំណងជើងថា«ល្បើកច្បាប់សង្ស» ដែលពុទ្ធសាសនបណ្ឌិត្យយកមកចុះផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា, ទំព័រ១០៨-១២៨(ឯកសារបាត់ទំព័រកាលបរិច្ឆេទ)។ តាមការសន្និដ្ឋាន *ល្បើកច្បាប់សង្ស* នេះគឺជាស្នាដៃចុងក្រោយរបស់លោកគាង៉ុយ[9]។ នៅសេចក្ដីបញ្ចប់កំណាព្យនេះ ក្រមង៉ុយ បានបង្ហាញជីវប្រវត្តិគាត់ផ្ទាល់៖

«ខ្ញុំទូលបង្គំដើមឈ្មោះអ៊ូ ពូជពង្សអំបូរខ្មែរអ្នកជា
អាពុកឈ្មោះអុកមានសក្តិងារ ចៅពញាធម្មធារាធ្វើមេស្រុក។
ក្នុងខែត្រភ្នំពេញឃុំកំបូល ពូជពង្សត្រកូលម្ចាស់អង្គប៉ុក
អាពុកអ្នកម្ដាយឈ្មោះពញាម៉ុក គាត់ធ្វើមេស្រុកឃុំស្ពានថ្ម។
អ្នកម្ដាយអាពុកបងប្អូនជិត ជីទួតមួយពិតពូជចិត្តល្អ
ដូនតាផ្សំផ្គុំជាដំណ បង្កើតខ្ញុំទូលបង្គំ។
បង្កើតអំពីក្នុងពិទិត ភ័យភិតខ្លាចបាបចង់បានបុណ្យ
ប្អូនច្បាប់ពីមុនជូនភាជការ បានបែកចែកច្បាប់ប្រាប់មហាជន។
ដោះពុម្ពសៀវភៅចែកសព្វសាយ ម៉ាដឺមូប៉ែស្សែល[10]ចាត់ផ្ទាយព្រះករុណា
មិនបានផ្ទាយផ្ទាល់ដល់ហត្ថា សូមទ្រង់មេត្តាប្រោសប្រណី។

---

ពឿន, ពាក្យកាព្យប្រដៅជនប្រុសស្រី, ចំណងជើងជាភាសាបារាំង *Nouveaux conseils aux enfants*, poème composé par Preas Phirom Pheasa OU dit NGOY, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៧៣, ១២០ទំព័រ (បោះពុម្ពលើកទី៣)។ សូមអានបន្ថែមនៅទំព័រ៤៩-៥១ស្ដីពីក្រមង៉ុយក្នុងសៀវភៅលោកវ៉ាន់ឌី-កាអុន មានចំណងជើងថា *Réflexion sur la littérature khmère*, Phnom Penh, 1981.

[9]សូមអានស្នាដៃចុងក្រោយរបស់គាង៉ុយ មានចំណងជើងថា «ល្បើកច្បាប់សង្ស»ចុះផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា, ទំព័រ១០៨-១២៨(ឯកសារបាត់ទំព័រកាលបរិច្ឆេទនិងលេខទស្សនាវដ្ដី)។

[10]Mademoiselle គឺ សំដៅនាងកញ្ញា ស៊ុយហ្សាន ការពឺឡេស (Mademoiselle Suzanne KARPELES)។



www.elibraryofcambodia.org

ឱនកាយ ប្រណម្យសុំអនុញ្ញាត ក្រាប ក្រោមព្រះបាទព្រះបារមី
ថែងច្បាប់បរមត្ថអត្ថបាឡី សេចក្តីថែងចប់ម្ល៉េះហើយ ហោង ។ »[11]

លី-ធាមតេង បានបោះពុម្ពផ្សាយ កម្រងកំណាព្យ តាង៉ុយ មួយ ទៀត នៅបណ្ណាគារ សេង-ងួន ហ៊ួត ភ្នំពេញ នាឆ្នាំ១៩៦៤ មានចំណងជើងថា *បណ្តាំក្រមង៉ុយ*[12] ។ គីម-សេង បានបោះពុម្ពកម្រងកំណាព្យ *បណ្តាំតា ង៉ុយ – ច្បាប់ ដាស់តឿនកូនចៅ*[13] ដោយគ្មានបញ្ជាក់កាលបរិច្ឆេទបោះពុម្ពផ្សាយ ។

*បណ្តាំក្រមង៉ុយ* ចុងក្រោយ នេះដែល យើងយកមកសិក្សានិងបកប្រែជាភាសាបារាំងគឺជាអត្ថបទដែល បានស្រង់កត់ត្រានាឆ្នាំ១៩៣៤ មានទាំងអស់ ៩១ល្បះប្តូរតម្រូវជា៣៦៤ឃ្លាជាបទព្រហ្មគីតិ ។

ក្នុងអត្ថបទបណ្តាំក្រមង៉ុយ នេះ លោកកវី-សិល្បករ យើង ចង់ប្រៀនប្រដៅ ប្រជាជន តូចតាច នៅ ស្រែ ចំការ ស្តី ពី តថភាព សង្គម នា សម័យ អាណានិគម បារាំង ដែល ក្រសួង សិក្សាធិការ បាន ដាក់ ក្នុង កម្មវិធី មធ្យមសិក្សា ថ្នាក់ទី៦នាឆ្នាំ១៩៨៨ ។ [14]

---

[11] សេចក្តី សម្រង់ ទាញ ចេញ ពី «ល្បើក ច្បាប់ សង្ស», ទំព័រ ១២៤-១២៥, ដដែល ។

[12] *បណ្តាំក្រមង៉ុយ*, សម្រាប់កម្មវិធីថ្នាក់ទី៦ទំនើប, ជីវប្រវត្តិអ្នកនិពន្ធដោយ លី-ធាមតេង, ភ្នំពេញ, បណ្ណាគារសេង-ងួនហ៊ួត, ១៩៦៤, ២៣ទំព័រ ។

[13] *បណ្តាំក្រម ង៉ុយ – ច្បាប់ ដាស់ តឿន កូន ចៅ*, សម្រាប់ ថ្នាក់ ទី ៦ ទំនើប នៃមធ្យមសិក្សា, ភ្នំពេញ, បណ្ណាគារ គិម-សេង, គ្មានកាលបរិច្ឆេទ, ៩២ ទំព័រ ។ ចំពោះ «ច្បាប់ដាស់តឿនកូនចៅ» ក្នុងកូនសៀវភៅបោះពុម្ព ដោយ គីម-សេង នេះមិនឃើញឈ្មោះភិក្ខុ អ៊ុំ ហៅង៉ុយ ទេ, បែរជាឃើញឈ្មោះ «ជីម» វិញដូចបានបញ្ជាក់ថា÷ «អាទិតែងតាំងអក្សរ នាមដើមធម្មតា អក្សរ «ជ» ស្រៈ «អ៊ី» ខាងលើផ្សំនិង «ម» នៅមុខតួ «ជ» នោះនាមា» (ទំព័រ ២៩) ។ តើបុគ្គលរូបនេះជាអ្នកណាពិតប្រាកដ? ច្បាប់នេះយើងឥតយកមកសិក្សាទេ ។

[14] សូមអានកម្មវិធីក្រសួងអប់រំឆ្នាំ១៩៨៨ ។



www.elibraryofcambodia.org

ក្រមង៉ុយ មានប្រជាប្រិយភាពខ្លាំងក្លាជាអមត នាគ្រប់សម័យកាល តាំងពីសម័យអាណានិយម, សាធារណរដ្ឋខ្មែរ, សាធារណរដ្ឋប្រជាមានិតកម្ពុជា រហូតមកដល់សម័យនអាណានិយមបច្ចុប្បន្នកាលនេះ គឺលោកជាកវីដែលមានគំនិតស្រឡាញ់ជាតិ ចង់ប្រៀនប្រដៅប្រជារាស្ត្រតូចតាចឲ្យមានលទ្ធភាពរស់នៅបានជាអ្នកជា។ យើងឃើញនៅសម័យសាធារណរដ្ឋខ្មែរ (១៩៧០–១៩៧៥) សមាគមអ្នកនិពន្ធបានបង្កើតជ័យលាភី «ក្រមង៉ុយ» [12] ហើយមានប្រគល់ប្រាក់៥០០០រៀលរូបក្រមង៉ុយទៀតផង។ នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលដឹកនាំដោយបក្សកុម្មុយនិសនិយម ក៏យកស្នាដៃក្រមង៉ុយមកដាក់ក្នុងកម្មវិធីសិក្សាថ្នាក់ទី៧និងថ្នាក់ទី៨ គឺមាន *ច្បាប់ល្បើកថ្មី* និង *ច្បាប់កេរកេរ្តិ៍ថ្មី* (សូមអានក្នុង *អត្ថបទអក្សរសិល្ប៍ ថ្នាក់ទី៧*, ភ្នំពេញ, ក្រសួងអប់រំសាធារណរដ្ឋប្រជាមានិតកម្ពុជា, ១៩៨២, ទំព័រ៥០–៥៦ និងទំព័រ៥៧–៦០ ក្នុង *អត្ថបទអក្សរសិល្ប៍* ដដែល បោះពុម្ពឡើងវិញនៅចុងឆ្នាំ១៩៨២ តែសំរាប់ថ្នាក់ទី៨ មានចំនួនទំព័រនៅដដែល គឺមានដូរតែក្រប បន្តិចដោយដាក់ថា «ក្រសួងអប់រំរដ្ឋកម្ពុជា» វិញ ព្រោះរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាកំពង់តែដូររបបនិងដូររដ្ឋធម្មនុញ្ញ ដើម្បីទទួលបានសន្តិភាពជាមួយភាគីឯទៀត។ នៅបច្ចុប្បន្នកាលនេះទៀតសោត ដើម្បីឧទ្ទិសដល់ឧត្តមគតិកវីប្រជាប្រិយក្រមង៉ុយ សាស្ត្រាចារ្យបណ្ឌិតអ៊ឹម–សាភឿន និងខ្មែរនៅ

---

[12] ប្រលោមលោកដែលបានទទួលរង្វាន់ក្រមង៉ុយឆ្នាំ១៩៧០–៧១មាន – រិន ឯម, *អ្នកទោសកោះត្រឡាច*, ភ្នំពេញ, សមាគមអ្នកនិពន្ធខ្មែរ, ១៩៧២, ២ ភាគ, ២៦៧ទំព័រ (បោះពុម្ពឡើងវិញនៅប៉ារីស, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ, ១៩៨២ ដោយមានលំនាំដើមដោយឃីង ហុកឌី)។ គង់ សុខុម, *ពាស់មីនទាន់ទុំ*, សមាគមអ្នកនិពន្ធខ្មែរ, ១៩៧២, ១៣៨ ទំព័រ (បោះពុម្ពឡើងវិញនៅភ្នំពេញ, បណ្ណាគារអង្គរធំ, ២០០២)។ ប៉ែន ឈុន, *ព្រះចិត្តក្រមុំ*, សមាគមអ្នកនិពន្ធខ្មែរ, ១៩៧២, ១៦៩ ទំព័រ (បោះពុម្ពឡើងវិញនៅភ្នំពេញ, បណ្ណាគារអង្គរធំ, ២០០២)។



www.elibraryofcambodia.org

ប្រទេសមួយចំនួនបានបង្កើតមជ្ឈមណ្ឌលអប់រំហ្វឹកហ្វឺនបច្ចេកទេសវិជ្ជាជីវៈ នៅស្រុកខ្មែរដោយដាក់ឈ្មោះ **«មជ្ឈមណ្ឌល ក្រម ង៉ុយ»** ។ [16] ទិសដៅនៃមជ្ឈមណ្ឌល ក្រម ង៉ុយ គឺធ្វើសកម្មភាពអភិវឌ្ឍន៍ តាមការនាំចូលមកនូវបច្ចេកវិទ្យានិងការបណ្តុះបណ្តាល បច្ចេកទេសវិជ្ជាជីវៈ ដើម្បីឲ្យយុវជនអាចប្រកបការងារក្នុងវិស័យសេដ្ឋកិច្ច ដោយសំឡឹងទៅឆ្ងាយ សំរាប់ពេលយូរ ហើយមានទស្សនៈពិសេស ។ នៅពេលថ្មីៗនេះគឺនាខែកុម្ភៈ ២០០៨ ឯ.ឧ កែប ជុតិមា អភិបាលក្រុងភ្នំពេញបានសម្ពោធរូបសំណាកមួយធ្វើពីសំរិទ្ធតាំងនៅសួនច្បារទល់មុខសណ្ឋាគារកាំបូឌីយ៉ាណា មានតម្លៃ ២០២.០០០ ដុល្លារ[17] ដើម្បីឧទ្ទិសដល់ឧបការគុណកវីជាតិយើង ។ ទាំងនេះបានសេចក្តីថា គំនិតក្រម ង៉ុយ កវីប្រជាប្រិយនេះ ខ្មែរយើងគ្រប់របបរដ្ឋតែងតែលើកតម្កើងគំនិតលោក ដែលជាអ្នកការពារស្រណោះអាណិតជនតូចតាច ហើយទុកលោកជានិម្មិតរូបនៃអ្នកប្រាជ្ញជាតិដ៏ឆ្នើមម្នាក់ ។

ក្រម ង៉ុយ ឬ ភិរម្យ ង៉ុយ នេះដែលយើងធ្លាប់គោរព ស្រឡាញ់និងចាត់លោកជាអ្នកស្នេហាជាតិដ៏ឧដុង្គឧត្តមមួយរូប នាចុងសតវត្សទី ១៩ និងដើមសតវត្សទី២០ ដែលប្រជាជនខ្មែរយើងតែងតែរាប់អាននិងស្គាល់លោក ហើយរដ្ឋអំណាចក៏បានលើកតម្កើងលោកឲ្យសមនឹងឧត្តមគតិលោកដែរ ដូចបានអធិប្បាយខាងលើស្រាប់ ។

ការសិក្សាស្រាវជ្រាវដោយសង្ខេបលើស្នាដៃ ក្រម ង៉ុយ នេះគ្រាន់ទុកជាផ្កាលនិងជាគ្រឹះ ជូនលោកគ្រូអ្នកគ្រូនិងសិក្ខាកាមផងនានា បន្តការរុករកនិងសិក្សាទៅមុខទៀត។ ការបោះពុម្ពនេះយើងបានប្រមូលផ្តុំឯកសារ ដែលបានសន្សំទុកជាង៣០ឆ្នាំមកហើយ ។

---

[16] សូមមើលរូបថតភ្ជាប់ជាមួយនឹងសៀវភៅនេះ ។

[17] សូមអានអត្ថបទឆាយ ច័ន្ទនិដា និងនៅណារិន, «អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរ និងកវីត្រូវបានធ្វើរំលឹកនៅក្នុងរាជធានី», ឌឺខែមបូឌាដេលី ថ្ងៃសុក្រទី២២ខែកុម្ភៈ ឆ្នាំ២០០៨ ទំព័រ៦ និងមើលរូបថតភ្ជាប់ក្នុងសៀវភៅនេះ ។



www.elibraryofcambodia.org

សូមឲ្យគំនិតស្នេហាជាតិរបស់លោកស្ថិតនៅជាអមតៈក្នុងអារម្មណ៍ប្រជាជាតិខ្មែរទាំងមូល ។

អត្ថបទសិក្សាស្រាវជ្រាវនេះ យើងសូមឧទ្ទិស ទៅដល់វិញ្ញាណក្ខន្ធកវីនិពន្ធនិងអ្នកស្នេហាអក្សរសាស្ត្រខ្មែរទាំងអស់នៅក្នុងស្រុកនិងក្រៅស្រុក ។



www.elibraryofcambodia.org

## LES RECOMMANDATIONS DE KRAM NGOY.
Une oeuvre littéraire d'un poète populaire khmer[18]

## INTRODUCTION

Ngoy[19] était un poète-chanteur très connu dans toutes les régions du Cambodge au début du 20ème siècle. Ly Theam Téng, chercheur de l'Institut Bouddhique de Phnom Penh et membre de l'Association des Ecrivains khmers, a fait en 1960 une enquête auprès des membres de la famille du poète et des fonctionnaires en retraite à la Bibliothèque Royale tels que Chap Pin, Bou Po et Chéa You. C'est en grande partie à la biographie[20] qui a résulté de ses recherches que nous connaissons les détails de la vie du poète.

Il est né en 1865 au Khum de Kambaul, Srok de Phnom Penh (actuellement Srok Ang Snuol), dans le Khet de Kandal. Son nom véritable est Ouk Ou, Ngoy étant son surnom. Son père portait le titre de *Cau baññ dhammādhārā* ou chef de commune. Sa mère, cousine[21] de deuxième degré de ce dernier, était la fille du *Cau baññ* Mok, chef de la commune de Spean Thmâ dans le même canton de la même province.

Quand il était enfant, Ngoy fit ses études dans la pagode Ang Piñ Cak de son village natal, dont le chef était son maître. Il était un très bon élève. Dès qu'il sut lire et écrite, celui ci lui fit apprendre le

---

[18] Ce travail a été publié dans la revue *MON-KHMER STUDIES* VII, University Press of Hawaii, 1978, p. 141-181.

[19] La translittération utilisée ici est celle de Mme LEWITZ, S. "Notes sur la translittération du Cambodge", *BEFEO*, LV, 1969: 163-9. L'orthographe de la plupart des noms de personnes ainsi que des toponymes suit l'une ou l'autre des romanisations conventionnelles.

[20] LY Theam Teng. *Bhiramy ñuy*. Collection Anak nibandh khmaer ;Phnom-Penh: Séng Nguon Huot, 1960. Cet ouvrage a été traduit en partie par SAN Sarin sous le titre "Phirum Ngoy, poète khmer d'après LY Theam Teng", *Cambodge Nouveau* 16 (1971): 25-35.

[21] En ce qui concerne les termes de parenté il faut voir NEPOTE, Jacques, *Parenté et organisation sociale dans le Cambodge moderne et contemporain*. Genève, Editions Olizane, 1992, 255 p.



www.elibraryofcambodia.org

*dharm* pour l'admettre dans l'ordre religieux comme *sāmeṇer* ou novice. A l'âge de vingt et un ans, le novice Ouk Ou dit Ngoy devint *bhikkhu*. Après ses études dans l'ordre, conformément à la tradition, il quitta l'habit jaune pour rentrer dans la vie séculière. Il se maria dans le Khum de Bèk Chan, Srok de Phnom Penh, et eut six enfants dont un nommé Acāry Cuṅ (Achar Chong).[22]

Alors même qu'il vivait dans cette commune comme simple paysan, Ngoy gagna la réputation d'être un orateur de grande habilité. Grâce à ses connaissances approfondies de la Loi bouddhique, les paysans le considéraient comme l'érudit de la région.[23] Il se montrait surtout ingénieux et intelligent dans la composition de vers, qu'il faisait avec une grande rapidité, ainsi que dans l'invention musicale. C'est en reconnaissance de son talent pour s'accompagner de sa cithare monocorde (*sātīev*) que les paysans le nommaient Phirum Ngoy.[24] Plus tard, on lui donna le titre de *Kram*, qui distingue une personnalité choisie dans la commune pour faciliter les rapports entre les villageois et l'administration.

*Kram* Ngoy chantait ses poèmes en s'accompagnant de sa *sātīev* de village en village.[25] La nouvelle de son succès auprès des paysans vint jusqu'à la capitale, où il chanta devant le *Samṭec cakrī*

---

[22]Ce fils fut destiné à devenir un révolutionnaire et militant: il mourut dans la prison de Phnom-Penh vers l'année 1955. Comme son père, il était l'érudit de son village, d'où son titre d'*acāry* "maître, précepteur". Il nous a également laissé des recueil de poèmes: le *cpāp' tuṃmūnmān pabbajit grahasth* ou Préceptes pour l'instruction des religieux et des laïcs (Phnom Penh, 1958) et le *Cpāp' gorab mātā pitā* ou Préceptes pour le respect des parents (Phnom-Penh, 1967).

[23]Pour le détail, voir LY Theam Teng, *op.cit.*

[24]*Bhirum* est un titre pour un musicien de talent. La cithare monocorde se compose d'une calebasse creuse faite d'une gourde (*ghlok*) vidée et séchée, à laquelle est attachée un manche (*ṭaṅ*) de bois dur (*krañūn*, *pcḥ* ou *nāṅ nuon*) légèrement courbé en son extrémité en forme de timon de charrette cambodgienne, très souvent sculpté. L'extrémité du manche est mobile et réglable, ce qui permet à l'instrumentiste de modifier la position de la corde (*khsae*) unique, facilitant ainsi le jeu de chaque musicien, qui n'est pas astreint à une position fixée. Une cheville (*pranuot*) de bois permet de tendre la corde de laiton ou d'acier attachée, au tiers environ de l'instrument, au manche par un lien faisant office de chevalet (*yun*), lui-même fixe à la calebasse. Cf. *Musique khmère* (Phnom-Penh): URBA, 1969), p. 52.

[25]"Il est de fait que deux modes de transmission orale semblent pouvoir être distinguées ici. L'une paraît spécifique des conteurs et récitants d'œuvres non accompagnées de musique, l'autre, confiée en général à des chanteurs ou déclamateurs, instrumentistes experts dans l'art du luth *cāpī* ou monocorde *sātīev*, instrument préféré des chanteurs aveugles" (THIERRY, S., *Etude d'un corpus de contes cambodgiens traditionnels: Essai d'analyse thématique et morphologique*, thèse de doctorat d'Etat, Université de Paris V, 1976, pp. 16-7)



www.elibraryofcambodia.org

ou ministre de la guerre. Puis, notre poète-chanteur "fut présenté au roi Sisowath, qui charmé par ses chansons au *satier*, le récompensa par de l'argent. Le roi l'appela Preah Phirum Pheasa."[26]

De nos jours, on considère Kram Ngoy comme un poète révolutionnaire qui a lancé des idée et des réflexions nouvelles et réalistes. [27]Kéng Vannsak, qui était à même de juger son art, a rendu raison de son importance:

*"C'est justement cette tradition de réaliste critique et constructeur qui a permis l'éclosion d'un grand poète national khmer au siècle de la répression coloniale. C'est notre Kram Ngoy, véritable poète populaire et patriote. Les vers coulaient naturellement de sa bouche sous forme de chants qu'il accompagnait lui-même de sa guitare (sic) monocorde. Cette guitare, il la promenait partout avec lui, rythmant ses poèmes qui jaillissaient de son cœur compatissant et de sa conscience douloureuse... Il chantait la misère, la pauvreté et surtout le poids des impôts... Et cela sans aucune haine, mais avec un cri vibrant de douleur devant l'inertie, la paresse, l'ignorance et le manque de solidarité de ses propres compatriotes. Il ne pouvait croire que les Khmers vivant sur leur sol se laissaient dominer et exploiter par les riches commerçants chinois, lesquels "arrivaient de Chine juste avec un pantalon sur les genoux". Tout cela "par la faute des Khmers eux-mêmes qui, par passivité, se contentaient de tout acheter sans rien produire". Il pleurait devant l'abrutissement de ses compatriotes à cause des superstitions et des croyances absurdes entretenues par des personnes intéressées. Il souffrait de voir les religieux eux-mêmes se disputer au nom du nouveau ou de l'ancien dharma et cela pour la même doctrine de Bouddha... Alors il exhortait ses compatriotes à la concorde, au travail, à l'étude, à la*

---

[26]SAN Sarin, *op. cit.*, p. 34.

[27]En 1971 on a créé un prix littéraire nommé "PRIX KRAM NGOY". En 1974 le portrait de ce poète populaire figure sur le nouveau billet de 5.000 riels. Depuis quelques années M. IM Saroeun, docteur-ingénieur, Ancien Recteur de l'Univesité Technique, ancien Directeur de l'Education au Cambodge et ancien Maître de Conférences à l'Université de Montpellier II (France) a fondé au Cambodge, avec ses amis ingénieurs, techniciens, intellectuels et travailleurs cambodgiens de la diaspora, un Centre de formation technique et professionnelle portant un nom de CENTRE KRAM NGOY en hommage à ce poète-chanteur populaire et patriote. En ce qui concerne ce centre, il faut voir le site internet: http://ckn.free.fr



www.elibraryofcambodia.org

*prise de conscience, et surtout à l'union nationale afin de mieux résister aux difficultés de la vie et à la rapacité des étrangers.*"[28]

L'écho du talent de *Kram* Ngoy arriva à G. Cœdès, membre de l'Ecole Française d'Extrême-Orient et grand khmérisant. En 1930 ce dernier le présenta à Suzanne Karpelès[29], alors directrice de l'Institut Bouddhique de Phnom-Penh. Elle fit noter les poèmes par un scribe[30] au moment où Kram Ngoy chantait pendant plusieurs jours devant elle, en compagnie d'autres érudits khmers. Elle accepta de faire publier ces poèmes[31], et en récompense elle donna une piastre à notre poète-chanteur.

"*C'était peu, mais énorme par la signification d'un tel geste presque historique qui montrait que les Français n'étaient pas tous des colonialistes, mais qu'il existait bien parmi eux de savants défenseurs de la culture nationale khmère.*"[32]

Kram Ngoy est décédé en 1936 à l'âge de soixante et onze ans. Les recueils de ses poèmes publiés par l'Institut Bouddhique de Phnom-Penh sont:

- *Sec kṭī raṃlịk ṭās' tīeṅ* ou Exhortations et recommandations.
- *Cpāp' kerti kāl thmī* ou Nouveau *Cpāp' kerti kāl.*
- *Cpāp' lpark thmī* ou Préceptes nouveaux pour l'édification.

---

[28]KENG Vannsak, *Quelques aspects de la littérature khmère*, Phnom-Penh, Faculté des Lettres, p. 21-22. En ce qui concerne Kram Ngoy, il faut lire également VANDY Kaonn, *Réflexion sur la littérature khmère*, Phnom Penh, 1981, p. 49-51.

[29]Cf. KHING Hoc Dy, "Suzanne Karpelès and the Buddhist Institute", *Siksācakr*, n° 8-9 (2006-2007), p. 55-59.

[30]A cette époque il n'existait pas encore d'appareils efficaces pour effectuer l'enregistrement de la voix de notre poète. Nous signalons pourtant qu'au début du 20ème siècle Suzanne Karpelès avait enregistré, sur cylindres pendant l'Exposition Universelle, de la musique cambodgienne. Sa collection est déposée actuellement au Département d'Ethnomusicologie du Musée de l'Homme.

[31]A propos des problèmes de la littérature orale, G. Condominas a noté: "Il arrive même qu'à l'échelle de l'État on tienne la recherche et l'enregistrement de la littérature orale pour une tâche urgente et nécessaire: celle d'empêcher la disparition d'un bien commun, à la fois précieux et fragile. Car la littérature orale est réellement considérée comme appartenant au patrimoine national au même titre que la littérature écrite ou les arts poétiques... On voit par cet exemple qu'il s'agit non seulement de sauvegarder le plus possible une partie importante, mais fragile, du patrimoine national, la littérature orale, mais aussi de la faire connaître à l'ensemble de la collectivité" (CONDOMINAS, G., "Littérature orale: Introduction", *ASEMI*, V (1974), 4, p. 16.

[32]KENG Vannsak, *op.cit.*, p. 22.



www.elibraryofcambodia.org

- *Cpāp' dūnmān jan prus srī* ou Préceptes pour l'instruction des hommes et des femmes.

Ly Theam Teng, cité ci-dessus, a aussi publié un recueil de poème de *Kram* Ngoy.[33] Et puis l'éditeur Kim Séng a sorti un petit livre sans date comportant deux parties: l'une du même nom que le recueil de Ly Theam Teng, l'autre intitulé *Cpāp' tās' tūen kūn cau* ou "Préceptes pour l'instruction des enfants". C'est cette édition du *Paṇṭāṃ kram ṅuy*[34] qui fait l'objet de la présente étude.

Or ce *paṇṭāṃ*[35] a été chanté par *Kram* Ngoy et recueilli en 1935[36]. Il comporte 91 strophes en mètre *brahmagīti*, ce qui fait en tout 364 vers. Ce qui ne sera pas peut-être entièrement clair au lecteur non Khmer, c'est que ce texte, dont le titre manque de toute indication explicite, appartient au genre des *cpāp'* [37]ou code de conduite, à cause de sa structure ainsi que des matières dont il s'occupe. Il s'aligne d'ailleurs avec les *cpāp' thmī*[38] ou nouveaux en considération de sa date de composition, son ton contemporain et l'auditoire qu'il envisage. Sous ces rapports il diffère des *cpāp' cās'* (ou *purāṇ*), les codes de conduite anciens tels que le *Cpāp' kerti kāl*, le *Cpāp' kūn cau*, le *Cpāp' rājaneti*, le *Cpāp' kram* et le *Cpāp' hai mahājan*.[39]. Ce genre de littérature didactique

*"... prit naissance à l'époque moyenne (XIVe - XVIIIe siècles) dans un milieu bouddhiste imprégné d'un ardent prosélytisme et détenteur de*

---

[33]*Paṇṭāṃ kram ṅuy*, Phnom-Penh, Séng Nguon Huot, 1964.

[34]*Paṇṭāṃ kram ṅuy et cpāp' tās' tūen kūn cau* ,Phnom-Penh, Kim Séng, sans date. Le premier poème, correspondant au texte utilisé ici, se trouve de la page 1 à la page 27.

[35]La forme *paṇṭāṃ* "recommandation(s), conseil(s)" est un dérivé par infixation de *phṭāṃ* "implanter, inculquer", elle-même étant un dérivé par préfixation de *ṭāṃ* "planter"

[36]Cf. strophe 82-3.

[37]La forme *cpāp'* est un dérivé par infixation de *cāp'* "saisir; commencer; composer". Du sens général "d'œuvre littéraire" il prit de bonne heure le sens restreint "d'œuvre didactique, texte éthique; collection de règles ou principes". Voir POU, S. et JENNER Philip N., "Les *cpāp'* ou 'codes de conduite' khmers. I: *cpāp'* kerti kāl. *BEFEO*, LXII (1975), p. 369.

[38]Cf. strophe 91.

[39]Quatorze de ces textes, dont plusieurs "nouveaux", ont été publiés sous le titre *Cpāp' phseṅ 2* (Phnom-Penh, Institut Bouddhique, 1966). L'ordre de composition de dix-sept *cpāp'* suggéré par l'analyse des rimes et l'emploi de coefficients rimiques est discuté par JENNER Philip N., "The Relative Dating of Some Khmer Cpāpa", *Austroasiatic Studies* (Honolulu, University Press of Hawaii, 1976), II, pp. 693-710.



www.elibraryofcambodia.org

*la culture khmère, constitué notamment par les religieux des monastères bouddhiques qui composaient ainsi des textes en vers plus ou moins longs destinés à servir de manuels de lecture et de traités de morale pratique et religieuse pour les jeunes enfants des deux sexes.*"[40]

Cette littérature a exercé un puissant attrait sur le peuple khmer jusqu'au XXe siècle.[41]

Il faut remarquer qu'entre les *cpāp'* anciens, qui peuvent être d'une sophistication formidable, et les textes de composition récente existe une distinction plus ou moins nette. Ly Theam Teng a noté dans la préface de sa biographie que les *cpāp' thmī* sont très simples parce que l'auteur parle de la vie courant des paysans: de la pratique de l'agriculture, de la récolte du jus de palme, des procès relatifs à l'héritage, de la dispute entre les partisans du nouveau *dharm* et de l'ancien *dharm*, et ainsi de suite. Ces *cpāp'* nouveaux, dit-il, sont beaucoup plus faciles à retenir que les anciens, qui contiennent des idées profondes tirées des textes bouddhiques et des réflexions philosophiques.[42]

Recueilli, comme nous l'avons vu, une année avant la mort du poète, le *Paṇṭaṃ* de *Kram Ngoy* est censé constituer les dernières recommandations qu'il a adressées au menu peuple khmer. La pertinence du recueil au Cambodge indépendant a été estimée si grande que l'ouvrage est entré dans le programme de l'enseignement secondaire du premier cycle en 1958.[43]

La langue de ce *cpāp'* est rigoureusement moderne, le style de l'auteur étant simple, direct et à la portée du grand public. L'ouvrage fait voir un double aspect: didactique et musical.[44] La versification est riche en allitérations et assonances. Parfois on trouve des redondances d'une espèce ou d'une autre, telles que *kaṃnaet kaet jā manuss* (strophe 3) "naissance – naître + être humain"; *būj khlau min*

[40] POU et JENNER, *op. cit.*, pp. 369-70.

[41] Cf. THIERRY, Solange, "La place des textes de sagesse dans la littérature cambodgienne traditionnelle", *Revue de l'Ecole Nationale des Langues Orientales*, V (1968), pp. 165-84.

[42] LY Theam Teng, *Bhtroung ìny*, *op. cit.*, p. 1-2. Les poèmes didactiques de Kram Ngoy, "qui allaient dominer tout le XXe siècle, reflètent une éthique à la fois conformiste et pragmatiste. Ce sont, en fait, des leçons de morale très pratiques, très utiles dont la pensée repose sur les préceptes bouddhiques illustrés". VANDY Kaonn, *op. cit.*, p. 49.

[43] *Journal officiel du Cambodge*, 37 (numéro spécial), 19 septembre 1958.

[44] Nous n'abordons pas l'aspect musical dans cet article.



www.elibraryofcambodia.org

*sīv prājñ* (str. 7) "ceux de lignée sotte ne sont pas assez intelligents"; *prāp' saṃlāñ' bnok māk mitt gū kan* (str. 50) "dire aux amis + amis + alliés + amis"; et *cūl rūṅ bhnaṃ rūṅ guhā* (str. 76) "entrer dans les creux de montagne et dans les creux de caverne". Le poète a recouru à ces figures rhétoriques à la fois parce qu'il était maître du style khmer et pour que l'auditeur puisse retenir sans peine les idées qu'il voulait avancer. En même temps, il accentue certains points spéciaux en mettant en œuvre son art musical, notamment en joignant la technique instrumentale. C'est le style de la littérature orale[45] populaire: le son et le sens sont associés. Originaire du peuple, *Kram* Ngoy a créé des œuvres littéraires et artistiques pour le peuple.

Quant au contenu de notre texte, le poète ouvre son discours en recommandant aux jeunes gens d'apprendre à être vigilants, à calculer, à lire, à retenir le *dharm* et à réfléchir (str. 1-3). Il aime nous montrer des oppositions dualistes de divers types: entre les ignorants, les sots (*lṅan', khlau*) et les savants, les érudits (*prājñ, anak ceh*); entre les honnêtes (*traṅ'*) et les menteurs (*bhut*); entre les braves parents (*ūbuk mtāy slūt traṅ'*) et leurs enfants sots (*kūn khlau*) (str. 4-8). Il affirme que l'ignorance vient de la paresse (str. 13) en faisant la comparaison entre les religieux du temps du Bouddha et les religieux de nos jours (str. 14-5). De la str. 16 jusqu'à la str. 68, il fait le portrait du paysan khmer et de ses relations avec les Chinois et Vietnamiens. Ensuite il nous recommande de réfléchir dans la vie et de travailler sans arrêt (str. 68). Même pendant le repos il faut réciter le *dharm* conformément aux textes pali (str. 69). Puis vient un discours (str. 70-81) sur les deux sortes de *cas'* (aînés, anciens), d'où il conclut qu'il convient d'écouter et de suivre les anciens ou les parents qui ont des vertus religieuses (*sīladān*). Il faut également respecter les commandements moraux (*sīl prām* "les cinq préceptes") (str. 82). Par la pratique de cette morale bouddhique, nous pourrons éviter la souffrance et la détresse, même après l'expiration du monde actuel, parce qu'il y aura alors le cinquième Bouddha, *Braḥ* sī Āry, qui viendra nous sauver (str. 81-90).

[45] "Il n'y a pas de différence de 'genre' littéraire entre les textes écrits et oraux... L'expression orale a été mise en écrit pour mieux se perpétuer et se trouver intégrée à la tradition nationale. Et l'expression écrite, en retour, n'a jamais été destinée à être lue silencieusement et individuellement, mais à être récitée, modulée, chantée, écoutée..." THIERRY, S., *Etude d'un corpus de contes...*, p. 84.



www.elibraryofcambodia.org

# TRADUCTION

1. Voici le sage mètre *brahm*[46] qui vous instruit/ vous avertit, vous tous les Khmers, hommes et femmes./ Faites bien attention, / soyez diligents.

2. Ne soyez ni trop paresseux ni trop stupides./ Efforcez-vous d'apprendre le calcul et l'écriture, / étudiez toute la Loi bouddhique et ses commentaires;[47] / l'intelligence s'additionne à la sagesse.[48]

3. Etant nés humains, / voyez de loin ou de près avec clairvoyance,[49]/ ayez un savoir vraiment sûr, / vous pourrez réussir dans toutes sortes d'entreprises.

4. Les hommes sots ne réagissent pas, / tels des aveugles, / ayant leur existence sans appui; / ils font des actes grossiers, étant nés stupides.

---

[46] Il s'agit du mètre *brahmagīt* ou "chant de Brahma", qui comporte quatre vers dans chaque strophe. Le premier et le troisième vers ont chacun cinq syllabes, le deuxième et le quatrième six. Ici le poète, avec la forme *brahm*, réduit le nom du mètre à une syllabe afin de satisfaire à ces conditions. A ce sujet voir ROESKE, J. "Métrique khmère, *bat* et *kakabat*", *Anthropos*, VIII (1913), 4-5: 682; JACOB Judith, "Some Features of Khmer Versification", *In Memory of J.R. Firth*, edited by Charles Ernest Bazell et al. (London: Longmans, 1966), 237; KHING Hoc Dy, *L'œuvre littéraire de Nan, auteur cambodgien de la fin du XVIIIe siècle et du début du XIXe*, thèse de doctorat de 3e cycle, Université de Paris III, 1974, pp. 297-310; POU et JENNER, *op. cit.*, p. 373.

[47] Dans ce contexte *ärth*, correspondant au sanskrit *artha* (cf. pali *attha*) "objet, chose, affaire; but, dessein, intention, sens; profit, utilité, avantage; bien, propriété, désigne les *atthakathā* ou commentaires sur la Doctrine bouddhique.

[48] *Gamnit* (<*git* "penser") "pensée, réflexion, raisonnement, jugement".

[49] *Dhluh* (<*luh* "passer, pénétrer") "percer de part en part; transpercer, traverser; être transparent", d'où *mel oy dhluh* "regarder afin de percer (le problème, le secret, le fond)".



www.elibraryofcambodia.org

5. Dans leur race les humains, grands ou petits, / prennent les caractères de leur lignage; / ils sont laids, beaux, blancs ou noirs.[50] / les enfants ressemblent aux ancêtres.[51]

6. Les descendants d'ignorants n'entrent pas au noviciat, / ce que l'on prend pour une faute envers la religion. / Ceux qui y entrent savent la Loi et les commentaires, / et leurs enfants s'efforcent de les étudier.

7. Les descendants de sots ne sont pas intelligents, / ceux de prétentieux et méchants ne sont pas doux, / ceux d'honnêtes restent toujours honnêtes, / ceux de menteurs ne font pas mieux que leurs ascendants.

8. Les parents doux et loyaux / ne veulent pas que leurs enfants deviennent ignorants: / ils leur font des reproches, les frappent, les réprimandent afin que ceux-ci acquièrent du savoir.

9- Les pères sans instruction[52] / ne se fâchent pas contre leurs enfants en les voyant instruits, / en les voyant sérieux et appliqués. / Les pères qui savent cela sont toujours contents.

10. Ils les pressent, leur font des rappels, / en les réprimandant matin et soir de crainte que leurs enfants restent pauvres. / Ils veulent qu'ils soient bien, / ils les supplient afin qu'ils fassent des efforts.

---

[50] Cf. NEPOTE J. et KHING Hoc Dy, "L'organisation du champ de la couleur en cambodgien", in TORNAY S. (ed.), *Voir et nommer les couleurs*, Laboratoire d'ethnologie et de sociologie de Paris X, Nanterre, 1978, pp. 83-107.

[51] Ṭūn tā (ou tā ṭūn), littéralement "grand-mère et grand-père".

[52] *Tamrih* (តម្រិះ) sans l'*anusvāra*, est l'orthographe standard de la forme prémoderne *tamreh* (តំរេះ), c'est sans doute celui-ci que le poète a visé ici pour rimer avec *ceh* (ចេះ) dans le vers suivant.



www.elibraryofcambodia.org

11. Les enfants méchants remplissent de douleur / et de soucis leurs parents. / Les enfants doux savent la politesse, / leurs parents sont comblés d'honneurs et de renom.

12. Vos parents pauvres, / ne les laissez pas dans le déshonneur. / Efforcez-vous d'atteindre un niveau supérieur / pour pouvoir sauver vos parents.

13. Les ignorants par paresse / ne s'intéressent pas à la Loi ni à ses commentaires. Mes enfants, étudiez, / apprenez à lire, garçons et filles.

14. Au temps de l'auguste Maître, / il y avait des *thera* et des *therī*, / des *bhikkhu* et des *bikkhunī*, / qui retenaient très bien la Loi en pāli.

15. [Maintenant] certains bonzes la savent avec hésitation, / la connaissent mal, ce qui les fait se tromper. / [Pourtant,] le Bouddha a fixé / son Enseignement de la discipline jusqu'à maintenant.

16. Selon leur tradition, les Khmers / s'efforcent de cultiver la rizière pour avoir du riz. / Ceux qui étudient tous les codes de conduite[53] / les prennent pour le chemin qui éclaire l'intelligence.

17. Au Siam, au Laos et en France, / tous, hommes et femmes, savent continuellement depuis les aïeux / calculer, lire, / écrire et graver.[54]

18. Les Khmers n'ont pas honte, / ils sont dirigés par des vieux ayant des pensées courtes, / qui savent deux ou trois choses et en ignorent dix, / qui aiment entreprendre des procès sans connaître les lois.[55]

---

[53] *Cpap' khus trov*, littéralement "règles de conduite fausses ou justes", c'est-à-dire préceptes qui nous montrent les côtés à éviter ainsi que les côtés à suivre.

[54] Car "graver au stylet sur des feuilles de latanier". Cf. LY Vou-Ong, "Les manuscrits sur feuilles de latanier", *Annales de l'Université des Beaux-Arts*, Phnom Penh, n° 1 (1967), p. 97-108.

[55] "Le simple fait de borner un terrain pour prendre possession ou de commencer à le défricher et à l'aplatir suffisait à conférer un droit sur le terrain", écrit DELVERT, J., *Le paysan cambodgien* (Paris, Mouton, 1961), p. 489. On a remarqué que pendant cette période les paysans se disputaient souvent au sujet de la limite de leurs propriétés parce



www.elibraryofcambodia.org

19. Ils ne savent ni calculer, ni lire, / ils ont de beaux visages, mais l'intelligence terne; / malgré leurs propres yeux, ils ne se rendent compte de leur nom / que si on le leur récite.

20. Leurs yeux sont saints et valides, / [mais ils] sont sots parce qu'ils ne font pas d'efforts. / Ils se disputent et se mettent en colère, / ils demandent à quelqu'un d'autre d'écrire [leur requête].

21. Les pauvres par paresse / ne regardent même pas devant ou derrière eux. / Certains sont nécessiteux parce qu'ils sont faibles; / ils donnent fréquemment [mais] ils ne travaillent[56] pas souvent.

22. Certains autres sont pauvres par sottises, / ils font du commerce qui tombe en faillite par leur manque de réflexion; / ils achètent cher vendent à bas prix, / ils ne savent que prendre sans comprendre.

23. Les possédants ont des idées, / ils réfléchissent en marchant et couchés, ils sont occupés; / leur intelligence est la racine et la souche / desquelles naît le souci de la richesse.

24. Les ignorants et les savants, / voilà qu'on va réfléchir pour les décrire: / les savants sont illustres, / les ignorants malchanceux rendent terne leur signe du zodiaque. /

25. [Ces derniers] ont un corps et une vie, / [mais] ils ne pensent pas et ne veulent rien connaître; / leur physique est d'un homme, leur caractère d'une femme. / Quand ils osent parler, personne ne les écoute.

---

que le système cadastral ne fonctionnait pas bien. Parfois ils dépensaient toutes leurs ressources pour venir en ville pour des procédures qui duraient des années.

[56] *Rok* "chercher" représente dans ce contexte *rok si*, littéralement "chercher de quoi manger", c'est-à-dire "gagner sa vie, travailler".



www.elibraryofcambodia.org

26. Certains ignorants ont des pouvoirs, / ils sont arrogants, méchants, se vantent de leur cruauté.[57] / se mettent en colère facilement [mais] ne savent pas les lois. / Quand ils meurent, on est content.

27. Les savants ont des connaissances très élevées; / là où les ignorants s'étonnent, eux trouvent une solution sans difficulté; / ils ont un savoir minutieux, un bon cœur; / les cadeaux[58] leur viennent en suffisance.

28. Certains savants ont des pouvoirs; / les sots les redoutent, les saluent respectueusement, les mains jointes; / les fautifs les réprimandent, les insultent; / certains sots se mettent en colère en secret.

29. Certains autres savants qui connaissent tout / commettent des fautes sans s'en rendre compte, / ne pensant pas à observer ni à peser. / Ces savants sévères s'efforcent pourtant de conseiller les autres.

30. Si leurs enfants, petits ou grands, / sont fautifs, vicieux ou dépravés, [ceux-là] les frappent et les réprimandent; / leur conduite est différente des autres, / ils ne réfléchissent pas à leur propre caractère.

31. Mes enfants, filles et garçons, / examinez avec crainte vos actions fausses et justes; / réfléchissez-y de tous les côtés, / à celles que nous tous faisons.

32. Deux yeux sont ouverts et valides / mais voient trop près et superficiellement; / des yeux fermés voient loin, / totalement sans qu'il ne reste rien.

33. Apprenez à faire du commerce,[59] / réfléchissez afin de comprendre la perte et le bénéfice, / pour connaître les affaires à fond;/ alors naîtront les profits chez vous.

---

[57] *Cak' kăp'*, littéralement "poignarder, perforer, couper, trancher".
[58] *Snov dar*, littéralement "tribut, impôt".
[59] *Rak' Si lak' dū* (cf. note 11) "gagner sa vie en vendant et en achetant".



www.elibraryofcambodia.org

34. Apprenez l'arithmétique, / l'addition, la division, la multiplication, de toutes vos forces; / [tenez] la craie et l'ardoise / de crainte que les Chinois et les Vietnamiens ne vous dupent.

35. La balance[60] a des graduations:[61] / regardez-les vraiment sans faire d'estimation / de crainte que ce soit faux et que cela vous fasse perdre sûrement: / n'ayez pas confiance même en ceux que vous connaissez bien.

36. Les yeux de l'homme sont grands et luisants; / les yeux[62] de la balance, on les a faits tout petits. / L'honnête homme pèse avec rigueur / parce qu'il a pitié des Khmers ignorants et sots.

37. Les Chinois sont riches grâce aux échanges et aux ventes / de paddy et de son par le panier[63] et par le boisseau,[64] / d'articles cuits et crus, / de pagnes,[65] de chemises et pantalons noirs ou blancs.

38. Les Khmers se fient au paddy dans leurs coffres, / [et cependant] ils l'échangent à n'importe quel prix, quelle que soit sa qualité; / à bout de paddy, devenus pauvres, / ils supplient les Chinois de leur prêter leur propre paddy.[66]

---

[60]*Luññ bhnaek* "balance à yeux ou graduation", c'est-à-dire la balance romaine à plateau unique et poids mobile; ses graduations pour les grandes unités ont la forme d'un losange qui ressemble à l'œil. *Luññ* est un emprunt au chinois; cf. POU, S. et JENNER Philip N., "Some Chinese Loanwords in Khmer", *Journal of Oriental Studies* (Hong Kong), XI (1973), 1., p. 45.

[61]*Lpiḥ' (<ciḥ'* "entailler") "entaille, incision, encoche"; cf. LEWITZ, S., "The infix /-b-/ in Khmer, *Austroasiatic Studies*, edited by Philip N. Jenner, Laurence C. Thompson, Stanley Starosta (Honolulu, The University Press of Hawaii, 1976) II, p. 756.

[62]C'est-à-dire les graduations.

[63]*Kanttāṅ* (vraisemblement du chinois): espèce de panier mesurant environ dix litres.

[64]*Tau*: boisseau de mesure de vingt litres environ; voir POU et JENNER, "Some Chinese Loanwords...", p. 27.

[65]Sanbat': vêtement inférieur qui enveloppe les reins et se fixe en nouant deux bouts de l'étoffe au niveau du ventre; d'où, pièce d'étoffe (cf. str. 61).

[66]Le troc et l'usure étaient très fréquents au Cambodge. La plupart des usuriers sont des commerçants chinois. Cf. DELVERT, J., *op. cit.*, p. 510-33, et COMTE, M., "Rapports de classes et relations inter-ethniques dans le Cambodge précolonial", *ASEMI*, VII (1976) 1., p. 55-98.



www.elibraryofcambodia.org

39. Le travail de la rizière est très pénible. / Les Chinois restent couchés fièrement à la maison; / ils ont des maisons de deux ou trois sections,[67] / avec une place pour leur grenier à paddy.

40. Les Khmers manquent de jugement: / ils mangent sans réfléchir, sans regarder le faux et le juste;[68] / ils empruntent aux Chinois[69] à chaque saison, / tout l'héritage de leur parents est confisqué par les Chinois.

41. Les Chinois viennent d'un pays lointain, / le baluchon à l'épaule comme seul bien, / ne sachant pas encore le khmer, / sans patrimoine ni champ inondé ou sec.

42. Ils établissent leur foyer[70] / en associant la force avec l'intelligence: / ils portent la palanche sur l'épaule, / avec du bétel[71] et de l'arec comme capital.

43. Ils ont toutes sortes de marchandises, / étalées et rangées selon leurs catégories. / Les Chinois portent deux fardeaux sur l'épaule,[72] jamais un seul;[73] / leurs greniers débordent de paddy.

---

[67] *Lvaeŋ* (<*vaeŋ* "long"), littéralement "étendu": unité structurale, bâtie sur un seul système de pilotis.

[68] Cf. FOREST, A., "Les portraits de Cambodgien", *ASEMI*, IV (1973), 2 : 81-107.

[69] Cf. WILLMOTT, W.E., *The Chinese in Cambodia* (Vancouver, The Athlone Press, 1967) et du même auteur, *The Political Structure of the Chinese Community in Cambodia* (Vancouver: University of British Columbia, 1970).

[70] *Ka ruek cankran chnaŋ*, "bâtir (fonder) sa louche, son fourneau, sa marmite".

[71] Mlūv la liane du Piper betle L. En ce qui concerne le rôle du bétel dans la société cambodgienne il faut voir THIERRY, S., *Le bétel. I - Inde et Asie du Sud-Est* (Paris, Musée de l'Homme, 1969).

[72] *Rek*: porter sur l'épaule au moyen d'une palanche sur laquelle sont fixés deux fardeaux de même poids, un à chaque extrémité. Cf. LEROI-GOURHAN, A. *L'homme et la matière*, 2e édition (Paris, Albin Michel, 1971): 120-1.

[73] *Ban*: porter sur l'épaule à l'aide d'une tige de bois ou de bambou, à une extrémité de laquelle est fixé un seul fardeau.



www.elibraryofcambodia.org

44. S'ils s'arrêtent pour se reposer,[74] / ils comptent leurs pièces de monnaie, qu'ils ramassent et cachent. / Une jarre d'alcool devant eux / sert d'appât pour attraper les Khmers.[75]

45. La plupart des Chinois sont des ennemis méchants:[76] / ils se servent de leurs paniers et boisseaux comme de rizières. / Ils n'ont ni mortier ni pilon, / [mais] le riz cambodgien entre dans les sacs[77] chinois.

46. La plupart des Khmers n'ont pas honte: / ils sont assoiffés d'alcool, en boivent à crédit / sans réflexion sérieuse,[78] / et, en buvant, ne dissipent que leurs propres biens.[79]

47. Leur condition de buveurs d'alcool / les poussant à avoir de nouvelles pensées diverses, / certains ont en tête les jeux de hasard: / ils n'ont pas peur d'être pauvres.

48. Certains ont en tête l'idée de dérober ou de voler, / [mais leur] mauvaise conduite n'apporte rien de bon: / ils boivent en abandonnant leur travail et leur métier, / les Chinois les attrapent et les transforment en domestiques.

49. Ils ne se rendent pas compte qu'ils sont fous: / ils vantent aux membres de leur famille / l'amabilité des Chinois, / qui est telle qu'ils peuvent boire à tout moment, que les Chinois n'en font aucun cas.

---

[74] *jek angui:* se coucher (ou) s'asseoir.

[75] *Dak' ka khmaer*, littéralement "attraper par le lacet le cou des Khmers".

[76] *C'it khmau:* cœur (esprit) noir.

[77] Pav: sac en fibres végétales. Cf. POU et JENNER, "Some Chinese Loanwords..." 18.

[78] *Gamnit git min ch-in* : mot à mot, "pensée + penser + ne pas + cuit".

[79] "Le sage dit qu'il existe trois folies: la folie des femmes, la folie de l'alcool et la folie des jeux insensés..." JENNER Philip N., et POU Saveros, "Les cpap' ou 'codes de conduite' khmers. II: cpap' prus", *BEFEO*, LXIII (1976): 338; cf. KHING Hoc Dy, *op. cit.*, 218-30.



www.elibraryofcambodia.org

50. Ils disent que les Chinois ne sont pas avares,[80] / ils informent leurs amis[81] / et leur camarades proches ou lointains: / ceux-ci rassemblent de plus en plus d'argent pour les Chinois.

51. Avec l'alcool, ils veulent bien manger: / sentant l'odeur de plats sautés au saindoux, / et voyant le riz, la soupe cuits, / ils s'empressent auprès des Chinois pour obtenir le repas.

52. Ils boivent de l'eau dans la noix de coco;[82] / leur conduite est grossière, leur caractère mauvais. / Les Chinois se servent d'eux pour le portage;[83] / [quand] ils viennent souvent manger, les Chinois les méprisent.

53. Les Chinois sont très cupides, / ils pensent sans parler. / La plupart des Khmers ont une conduite dissipée, / qui leur fait perdre leurs biens et qui les rend infortunés.

54. Ils prennent des repas savoureux jusqu'à satiété, / [ce qui] rabaisse leur femme et leurs enfants / et déshonore leurs parents et alliés / jusqu''à leurs ancêtres et la race khmère.

55. Les Chinois ont le teint tout blanc; / il en existe quelques-uns de pauvres, / ils mangent et boivent [avec l'aide] amicale de ceux du même clan;[84] / ils s'abstiennent de manger du riz cambodgien.

56. [S']ils ont une maison avec des plantations, / ils creusent la terre pour planter le moindre recoin / de patates, de taros, de bananiers,

---

[80]*Kiit'* : Énumérer, compter, calculer (GUESDON, Joseph, *Dictionnaire cambodgien-français*, Paris: Plon, 1930, I : 312), réfléchir avec attention (*Vacanānukram khmaer*, Phnom-Penh: Institut Bouddhique, 1967, I : 31) : > *kuññ* "mécontentement, antipathie, haine, rancune", > *kaṃnuññ* "avare, intéressé; avarice" (cf. str. 53).

[81]*Samlañ' bāok māk mitt*. Ces trois termes ont à peu près la même signification : *samlañ'* "ami", *bāok māk* "camarade, copain", *mitt* (pali *mitta*) "ami, allié".

[82]*Pay tralok*: une demi-noix de coco hémisphérique avec un manche.

[83]*Saen raek li* : "porter à deux sur l'épaule" + "porter à la palanche" + "porter sur l'épaule". Cf. LEROI-GOURHAN, *op. cit.*, p. 119-25.

[84]*Sae* : "clan, lignée". Cf. POU et JENNER, "Some Chinese Loanwords...", p. 80.



www.elibraryofcambodia.org

d'ananas, / [et] ce qu'ils ne consomment pas ils le gardent pour le vendre ou l'échanger.

57. La plupart des Khmers sont paresseux, ivrognes, / de caractère prétentieux, vantards de leurs lignées: / [s'][ils manquent d'argent, ils s'associent et se lamentent. / Ils ramassent le paddy [mais] le laissent fuir[85] du grenier.

58. Oh, mes enfants! Pour ce qui est des plantations, / il convient de faire toutes sortes de cultures / sur la terre, l'héritage de vos parents:/ il n'est pas bon de la laisser en jachère.

59. L'administration royale, qui la mesure pour avoir des redevances, / vous la donne en héritage en vous prenant l'empreinte du pouce. / Elle ne la mesure pas pour s'amuser; / elle réfléchit pour prélever des impôts sur chacun.

60. Les cocotiers, les manguiers, la canne à sucre, les bananiers, / ne soyez pas paresseux---ne les attendez pas en dormant. / Le bétel, l'aréquier, le poivrier, l'ail, le tabac, / plantez-les afin que rien ne vous manque.

61. Le *des ack*[86] [est] une étoffe blanche: / plantez les cotonniers dans la belle plaine: / ne soyez pas paresseux comme nos anciens, / [car] les hommes de grande besogne ne sont jamais pauvres.

62. Cultivez toutes sortes de légumes: / conservez-en les graines pour les planter ensuite: / mettez-y de bons engrais: /gardez-les pour faire la soupe quotidienne.[87]

63. Le bétel, l'aréquier, le tabac, l'ail, le poivrier / poussent bien grâce à l'arrosage, / ils portent des fruits ou des feuilles: / ne soyez pas dédaigneux, ce qui vous rendait pauvres.

---

[85]*Paüho* (< *hūr* "couler") "faire couler".

[86]*Des ack*: tissu en coton blanc.

[87]*Lŋāc brik*: littéralement "soir (et) matin".



www.elibraryofcambodia.org

64. Les poissons secs salés, les *ph-ak*,[88] les *prahuk*,[89] / les Khmers de toutes les régions les achètent aux Vietnamiens;[90] / le sel, les baguettes d'encens, les cierges, / on les échange[91] ou les achète depuis nos ancêtres.

65. Echangez-le et faites-en une provision / pour en consommer pendant l'année entière / et pour qu'ils soient pleinement suffisants. / Que vous y gagniez ou que vous y perdiez, n'en achetez pas trop peu.

66. Achetez un *cui*[92] de sel, / remplissez-en vos grandes jarres de l'ouest [de la maison]. / N'en achetez pas enveloppé ou en paquet; / il sera fini aussitôt, vous irez en acheter plus.

67. Une unité de sel pour trois de paddy, / mesurez-les avec une corbeille[93] que vous portez sur la tête ou sur la hanche. / Vous êtes pauvres; ne cherchez pas à mal agir, / ne suivez pas cette conduite.

68. Mes enfants, garçons et filles, / faites bien attention: / soignez votre existence, / réfléchissez longuement et non à la légère.[94]

69. [Pendant] le repos après le travail, / récitez, vous tous, hommes et femmes, la Loi et ses commentaires / afin de vous conformer au pâli,[95] / comme [je] vous l'ai dit dès le début.[96]

---

[88] *Ph-ak* : sorte de pâte de poisson et de riz gluant soumise à la fermentation.

[89] *Prahuk* : pâte de poissons salés et fermentés, un des éléments les plus importants de la cuisine cambodgienne. Voir COMMISSION DES MŒURS ET COUTUMES DU CAMBODGE, *La vie du paysan khmer*, Phnom-Penh, 1969, 37-44.; cf. DELVERT, *op. cit.*, p.147-56.

[90] Cf. KHY Phanra, *La communauté vietnamienne au Cambodge à l'époque du protectorat français (1863-1953)*, thèse de doctorat de 3ème cycle, Université de Paris III, 1974; VOLLMAN, W., "Notes sur les relations inter-ethniques au Cambodge du XIXème siècle", *ASEMI*, IV (1973), 2, p. 171-208.

[91] Cf. DELVERT, *op. cit.*, p. 514-6.

[92] *Cui* = unité de poids équivalent à trente kilogrammes.

[93] *L-i* : panier d'une contenance de cinq litres environ.

[94] *Git khli* , littéralement "penser court". Cf. str. 18.

[95] C'est à dire la Doctrine originale en pâli.

[96] Voir str. 14 et 15.



www.elibraryofcambodia.org

70. Vous tous, hommes et femmes, / vous savez parler parce que vous savez écouter / les parents qui vous corrigeaient et vous informaient. / Les enfants imitent leurs ancêtres.

71. Certains anciens acquièrent des vertus religieuses;[97] / ils ne violent pas la parole du Bouddha. / Leurs enfants, qui ressemblent à leurs parents, / ne s'éloignent pas de leur chemin.

72. Certains anciens accumulent des actes malveillants;[98] / ils détestent les cinq commandements moraux[99] comme des ennemis. / Leurs enfants, qui ressemblent à leurs parents, / sont dans la honte et se détruisent.

73. Ils ne croient ni au *magg* ni au *phal*,[100] / ils tombent dans les quatre mondes inférieurs;[101] / l'ensemble du *karma*[102] les attend avec

[97] *Sâsâna* : le don de transmission des principes de moralité. Cf. JENNER et POU, *op. cit.*, 330.

[98] *Phal kamm* (pali *kammaphala*) "fruits de *karma*", comprend les dix sortes d'actions mauvaises ou bonnes, mais en khmer le terme a plutôt le sens de mauvaises actions.

[99] Voir SAN Sarin, *Les textes liturgiques fondamentaux du bouddhisme cambodgien actuel*, thèse de l'Ecole Pratique des Hautes Etudes, IVème section, Paris, 1975, p. 40 et, sq. 77 et 81.

[100] Le poète a trouvé bon de diviser le terme pali *maggaphala*; voir *Vacanânukram Khmaer*, I: 842-3.

[101] *Apay* (pali et sanskrit *apâya* "départ, disparition, diminution, déclin, décadence") : une des quatre conditions malheureuses dans laquelle l'individu peut entrer après cette existence: celle des animaux, celle des trépassés, celle des démons, l'enfer.

[102] *Kamm* (pali *Kamma*, sanskrit *karma* "travail, action") : actes vus comme produisant le mérite ou le démérite ; au Cambodge le terme désigne en général "acte(s) mauvais". Cf. KHING Hoc Dy, "Quelques traits bouddhiques dans Bhogakulakumâr, roman cambodgien en vers du début du XIXe siècle", *Cahiers de l'Asie du Sud Est*, 1, 1977: 59-77. A propos de ce sujet, Mme S. Thierry a écrit : "La trame, stable et unie, nous la reconnaissons avant tout dans cette sorte de la fatalité que représente pour les Khmers le système de la mort et de la renaissance, ce "fond de décor", cette base sur laquelle les existences successives se dessinent. Mais on pourrait dire aussi que le *karma*, au cours de ses éclosions, détermine les "motifs", les "thèmes", les séquences qui s'enchaînent. Participant à la roue des existences il est l'origine du tissu lui-même et en conditionne la substance et l'aspect" (*Etudes d'un corpus de contes*..., p. 122).



www.elibraryofcambodia.org

rancune; / [même s']ils se détournent ou se cachent, ils ne peuvent pas se dissimuler.

74. Le Bouddha a prononcé la sainte parole / en comparant [ce premier] principe / à des bœufs forts / qu'on choisit pour atteler à une charrette.

75. Qu'on les conduise sur une voie tortueuse ou droite, / ou bien qu'on les conduise pour se détourner ou se cacher, / les roues tournent sans se détacher, / [car] elles restent aux pieds des bœufs sans s'éloigner d'eux.

76. Tous les hommes, petits et grands, / [pourraient] pénétrer dans la grotte de montagne ou la caverne / et prendre de grandes dalles pour se barrer l'entrée, / [mais] leur mauvais *karma* parvient inéluctablement à les poursuivre.

77. L'ensemble de la moralité comporte cinq commandements;[103] / la haine de leur *karma*, en suivant leurs traces, les serre de près; / l'enfer, les trépassés, les animaux / leur interdisent, leur barrent, leur violent le *maggaphala*.

78. Efforcez-vous d'acquérir les vertus religieuses, / prenez le *nirvāṇa* comme rivage et chemin; / tôt ou tard vous y parviendrez, / [car] votre *kusala* [104] vous aidera à quitter ce cycle des renaissances.

79. Mes enfants, réfléchissez bien; / regardez le caractère et l'esprit de vos ancêtres, / qui commettaient des fautes envers la religion. / Evitez leur conduite, ne les imitez pas.

---

[103] Cf. str. 72.

[104] En pāli *kusala* "karmiquement bonnes" sont toutes les volitions karmiques associées à la conscience et aux facteurs mentaux avec l'absence de convoitise, de haine, et en certains cas aussi avec l'absence d'égarement, car étant cause de résultats de *kamma*, elles contiennent les germes de destinée ou renaissance heureuse. NYANATILOKA, *Vocabulaire bouddhique des termes et doctrines du canon pāli*, Paris, Adyar, 1961, p. 116.



www.elibraryofcambodia.org

80. Regardez n'importe quel des anciens sages / qui suivaient la Voie des codes de conduite: / vous devez écouter ce que disent [ces] anciens, / qui vous ont instruits avec rigueur et vous ont conseillé d'être sur vos gardes.

81. Rendez hommage à la vertu des Trois [Joyaux], [105] / récitez le pāli [106] de mémoire, / gardez les cinq commandements moraux, / [et] le mauvaux *karma* ne peut pas vous atteindre.

82. La doctrine durera encore longtemps, / elle vient de dépasser les deux mille [ans]: / de jour en jour ils sont chiffrés et comptés, / elle n'a pas encore cinq cents.[107]

83. Maintenant [c'est l'année] soixante-dix-huit,[108] / il reste encore vingt et un [ans].[109] Mes enfants, ne vous laissez pas / noyer dans le cycle des renaissances.

84. Il y a la parole des anciens qui dit, / "Dans la sainte Doctrine / est la prédiction des traités: / *Cela va diminuer pour s'épanouir de nouveau.*

85. [Pour] cette raison, mes enfans, / que vous soyez ignorants ou sots, / efforcez-vous de répéter [le *dharma*] avec diligence / et d'accomplir la parole prophétique du Bouddha.

86. A partir du présent jour, / apprenez à réfléchir, ne soyez pas dissipés: [car] chez tout enfant qui ne récite pas [le *dharma*] / la douleur ne se dissout ni s'éteint.

[105] C'est plutôt *guṇ kaev dāṃṅ pī*. Le poète a fait abstraction d'un mot pour respecter le nombre permis de syllabes. Ce triple Joyau est le Buddha, le *Dharma* (La Loi) et le *Saṅgha* (la communauté).

[106] C'est-à-dire le *dharma* en pāli.

[107] Les Khmers croient que le bouddhisme va durer pendant cinq mille ans après la mort du Grand Maître : l'année 5.000 de l'ère bouddhique sera la fin de ce monde.

[108] *Cit* représente *cit sip* "soixante dix", encore pour des raisons métriques. L'année visée est 2478 de l'ère bouddhique, soit 1935 A.D.

[109] C'est-à-dire, dans vingt et un ans on arrivera à l'année 2500, la date de la demi-durée de la Doctrine (*bak' kaṇṭāl sāsanā*).



www.elibraryofcambodia.org

87. Quand la Doctrine aura vraiment / cinq mille [ans] dans l'avenir, / la prophétie nous prévient / que les parents détesteront leurs enfants.

88. [Elle] dit qu'il existera une période de massacres;[110] les membres de la famille auront de la rancune et se tueront, ne reconnaissant ni les grands-pères ni les grand-mères; [111] les vertus religieuses seront tout à fait anéanties.

89. Il [vous] appartient de penser pour éviter d'accumuler du mauvais *karma*; / suivez les cinq commandements moraux, retenez-les bien; / efforcez-vous d'acquérir le *maggaphala* / [grâce auquel] vous atteindrez la région de paix et de bonheur.

90. Vous échapperez aux massacres / [et] ne tomberez pas en enfer; [car] *Brah* Sri Arya[112] atteindra l'Illumination dans l'avenir / et dissoudra la souffrance et l'affliction de tous.

91. Ceci a été un *cpap'* de recommandations[113] / en [vers] répétés de cinq et de six syllabes / de mère *brahm*, au total quatre vers / rimés, que [j'ai] fini de composer.

---

[110] En pāli, *antarakappa* "période cosmique intermédiaire", mais en khmer courant ce terme signifie plutôt "l'existence de dispute mutuelle suivie de massacre".

[111] *Narak* (sanskrit *naraka*), correspondant au pāli *niraya* "descente, voie descendante", désigne le monde inférieur que l'on traduit généralement par "enfer". Comme nous avons vu (note *supra*), il fait partie des *caturāpāya* ou quatre conditions mauvaises. Cf. KHING Hoc Dy, *L'œuvre littéraire de Nou...*, p. 284; LECLERE, A., *Le bouddhisme au Cambodge*, Paris, E. Leroux, 1899, p. 105.

[112] Un prêtre catholique qui a visité le Cambodge en 1848-56 a noté la croyance des Khmers en *Brah Srī Ārya*, le cinquième et dernier Bouddha qui apparaîtra après l'expiration de la religion du Bouddha Gautama (note *supra*) : "les Cambodgiens, malgré leur grand respect pour Sommonocodom (Samanagotama), ne le regardent pas cependant comme le comble de la perfection, de la sainteté; beaucoup d'entre eux croient qu'il sera remplacé un jour par Pra Seyar..." Voir BOUILLEVAUX, C.E., *Voyage dans l'Indo-chine (1848-1856)*, Paris, V. Palmé, 1858, p. 209.

[113] *Cpap' paṭam* : code de conduite ou recueil de préceptes qui consiste en des recommandations. Cf. THAY Sok, *Traité de morale des Cambodgiens, du XIVè au XIXè siècle*, thèse de doctorat d'Université, Paris, 1964 ; THIERRY, S., "La place des textes de sagesse..."; POU et JENNER, "...Cpap' kerti kal", p. 370-94; JENNER et POU, "...Cpap' prus", p. 313-50.



www.elibraryofcambodia.org

# អត្ថបទ

## បណ្តាំក្រមង៉ុយ[114]

១- នេះបទព្រហ្មព្រាផ្ទឹប្រែ
ប្រាយប្រាប់ខ្មែរទាំងប្រុសស្រី
ឲ្យប្រិតប្រុងស្មារតី
គួរគប្បីឲ្យឧស្សាហ៍ ។

២- កុំខ្ជិលកុំល្ងង់ពេក
ខំរៀនលេខរៀនអក្ខរា
រៀនគ្រប់សព្វធម៌អាថ៌
ប្រាជ្ញាផ្សៀងនឹងគំនិត ។

៣- កំណើតកើតជាមនុស្ស
មើលឲ្យធ្លុះទោះឆ្ងាយជិត
ចេះស្គាល់ប្រាកដពិត
គិតការអ្វីបានគ្រប់យ៉ាង ។

៤- មនុស្សល្ងង់មិនផ្អើលភ្ញាក់

[114] *បណ្តាំក្រមង៉ុយ*, ឡាប់ផាស់តឿនកូនចៅ, ភ្នំពេញ, បណ្ណាគារគីម-សេង, គ្មានកាលបរិច្ឆេទ, ទំព័រ ១-២៧ ។



www.elibraryofcambodia.org

ដូចភ្នែកខ្វាក់ទាំងសងខាង
មានរូបគ្មានអ្វីអាង
សាងទាបថោកកើតមកខ្លៅ។

**៥-** ពូជមនុស្សទោះខ្ពស់ទាប
កាត់តាមភាពត្រកូលផៅ
អាក្រក់ល្អសខ្មៅ
កាត់កូនចៅដូចដូនតា។

**៦-** ពូជល្ងង់មិនបានបួស
ទុកជាទោសនឹងសាសនា
អ្នកបួសចេះធម៌អាថ៌
កូនសិក្សាខំរៀនសូត្រ។

**៧-** ពូជខ្លៅមិនសូវប្រាជ្ញ
ពូជកោងកាចមិនសូវស្លូត
ពូជត្រង់ៗរហូត
ពូជភរភូតមិនផុតផៅ។

**៨-** ឪពុកម្តាយស្លូតត្រង់
ចិត្តមិនចង់ឲ្យកូនខ្លៅ
ដេរពាយស្តីប្រដៅ
ឲ្យកូនចៅបានចេះដឹង។



www.elibraryofcambodia.org

៩- ឪពុកគ្មានតិះ
ឃើញកូនចេះមិនដែលខឹង
ឃើញកូនខំប្រឹតប្រឹង
ឪពុកដឹងតែងត្រេកអរ ។

១០- ដាស់តឿនក្រើនរំលឹក
ដេរល្ងាចព្រឹកខ្លាចកូនក្រ
ចង់ឲ្យតែកូនល្អ
លោមអង្វរឲ្យកូនខំ ។

១១- កូនកាចបំពេញទុក្ខ
ម្តាយឪពុកមានបារម្ភ
កូនស្លូតដឹងគួរសម
មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ ។

១២- ឪពុកម្តាយខ្សត់ខ្សោយ
កុំបណ្តោយឲ្យអាប់យស
ខំរៀនឲ្យបានខ្ពស់
គ្រាន់សង្គ្រោះដល់មេបា ។

១៣- អ្នកល្ងង់ហេតុពីខ្ជិល
ឥតមន្ទិលរឿងធម៌អាថ៌
គួរកូនទៅសិក្សា
រៀនអក្ខរាទាំងប្រុសស្រី ។



www.elibraryofcambodia.org

១៤- កាលអង្គព្រះសាស្តា
មានថេរាមានថេរី
ភិក្ខុភិក្ខុនី
ធម៌បាលីចេះចាំស្ទាត់ ។

១៥- លោកសង្ឃខ្លះចេះស្ទើរ
ចេះភ្លើៗ ធ្វើឲ្យភ្លាត់
ព្រះអង្គទ្រង់សន្មត
សិក្ខាបទដល់ឥឡូវ ។

១៦- ទម្លាប់ទំនៀមខ្មែរ
ខំធ្វើស្រែចង់បានស្រូវ
អ្នករៀនច្បាប់ខុសត្រូវ
ទុកជាផ្លូវភ្លឺប្រាជ្ញា ។

១៧- ស្រុកសៀមលាវបារាំង
ចេះតាំងពីដូនតា
ចេះលេខចេះអក្សរា
សរសេរចារទាំងប្រុសស្រី ។

១៨- ជាតិខ្មែរមិនចេះខ្មាស
នាំពីចាស់គំនិតខ្លី
ល្ងង់ងប់ចេះពីរបី



www.elibraryofcambodia.org

ចេះផ្ដួញក្ដីមិនចេះច្បាប់ ។

១៩- បិនចេះលេខអក្សរ
មុខមាត់ល្អប្រាជ្ញាអាប់
ឈ្មោះខ្លួនភ្នែកខ្លួនស្រាប់
គេសូត្រប្រាប់ទើបបានដឹង ។

២០- ភ្នែកជាភ្ល័ក្រខ្សែត
ល្ងង់ព្រោះហេតុមិនខំប្រឹង
កើតទាស់មានចិត្តខឹង
ពឹងរកគេសរសេរឲ្យ ។

២១- មនុស្សក្រហេតុពិខ្ចិល
មិនរមិលមើលមុខក្រោយ
ម្យ៉ាងខ្សត់ពីព្រោះខ្សោយ
ញ៉ើកខាងច្បូរនើលរក ។

២២- ម្យ៉ាងក្រពីព្រោះល្ងង់
ផ្ញួលិចលង់មិនវិលយក
ទិញថ្លៃទៅលក់ថោក
ចេះតែយកមិនគិតយល់ ។

២៣- អ្នកមានៗគំនិត
ដេកដើរគិតកើតរល់



www.elibraryofcambodia.org

ប្រាជ្ញាជាឫសគល់
កើតអំពល់អំពីទ្រព្យ ។

២៤- អ្នកល្ងង់និងអ្នកចេះ
បើនឹងវិវាទរៀបរាប់
អ្នកចេះប្រសើរតាប់
ល្ងង់ឥតភ័ព្វអាប់រាសី ។

២៥- មានរូបមានជីវិត
មិនចេះគិតចង់ដឹងអ្វី
រូបប្រុសឬកដូចស្រី
នឹងហ៊ានស្តីគ្មានកេស្តាប់ ។

២៦- ល្ងង់ម្យ៉ាងមានអំណាច
ល្ងង់កោងកាចអួតចាក់ករប់
ឆាប់ខឹងមិនដឹងច្បាប់
កាលណាស្លាប់គេត្រេកអរ ។

២៧- អ្នកចេះតិរិះដល់
អ្នកល្ងង់ឆ្ងល់មិនសល់ក្រ
ចេះល្អិតចិត្តជាល្អ
សួយអាករចូលមិនខ្វះ ។

២៨- ចេះម្យ៉ាងមានអំណាច



www.elibraryofcambodia.org

អ្នកខ្លៅខ្លាចខ្ទិនសំពះ
គេខុសដេរដៀលត្មះ
អ្នកខ្លៅខ្លះគេលបខឹង។

២៩- ប្រាជ្ញម្យ៉ាងចេះសព្វសុស
ប្រព្រឹត្តខុសនោះមិនដឹង
មិនគិតពិនិត្យថ្លឹង
ប្រាជ្ញប្រិតប្រឹងប្រដៅគេ។

៣០- កូនចៅទោះធំតូច
ខុសខិលខូចខឹងរាយដេះ
មារយាទខ្លួនខុសគេ
មិនគ្មាន់គ្មេរកិរិយាឯង។

៣១- កូនចៅទាំងប្រុសស្រី
ការត្រូវខុសគួរគិតក្រែង
គិតគ្រប់សព្វកន្លែង
តែងនឹងមានរាល់រូបកាយ។

៣២- ភ្នែកបើកភ្លឺមែនពិត
មើលឃើញជិតៗវៀងអាយ
ភ្នែកផ្លូចមើលឃើញឆ្ងាយ
សព្វសុសសាយមិនសេសសល់។



www.elibraryofcambodia.org

៣៣- រៀនរកស៊ីលក់ទិញ
ខាតចំណេញគិតឲ្យដល់
ឲ្យដឹងការកិច្ចកល
ទើបកើតផលប្រយោជន៍ខ្លួន ។

៣៤- ឲ្យរៀនលេខនព្វន្ត
បូកហាគុណឲ្យមាំមួន
ដីសនិងក្ដារឆ្នួន
ក្រែងចិនឃួនបំបាត់បាន ។

៣៥- ជញ្ជីងរំភ្នកមានល្បាក់
មើលឲ្យដាក់កុំប្រមាណ
ក្រែងខុសខាតមិនខាន
ធ្លាប់រាប់អានកុំទុកចិត្ត ។

៣៦- ភ្នែកមនុស្សធំលើង
ភ្នែកជញ្ជីងតែចុចល្អិត
អ្នកល្អថ្លឹងប្រឹងប្រិត
ព្រោះអាណិតខ្មែរល្ងង់ខ្លៅ ។

៣៧- ចិនមានពីដូរលក់
ស្រូវកន្តក់កន្តាំងតៅ
របស់ទោះឆ្អិនឆៅ
សំពត់អាវខោខ្មៅស ។



www.elibraryofcambodia.org

៣៨- ខ្មែរអាងស្រូវក្នុងដោក
ដូរថ្លៃថោកអាក្រក់ល្អ
អស់ស្រូវទៅជាក្រ
អង្វះចិនជឿស្រូវឯង ។

៣៩- ធ្វើស្រែនឿយហត់ណាស់
ចិននៅផ្ទះដេកចាំខែង
ផ្ទះចិនពីរបីល្វែង
មានកន្លែងជង្រុកស្រូវ ។

៤០- ជាតិខ្មែរឥតគំនិត
ស៊ីមិនគិតមើលខុសត្រូវ
ជឿចិនភាល់រង្វូរ
កេរ្តិ៍ម៉ែឪចិនអូសអស់ ។

៤១- ចិនមកពីស្រុកទាយ
មានសំពាយជារបស់
មិនទាន់ចេះខ្មែរសោះ
គ្មានកេរ្តិ៍កោះស្រែចម្ការ ។

៤២- កំរែកចង្ក្រានឆ្នាំង
ផ្សំកំលាំងនឹងប្រាថ្នា
អំប្រែកដិះលើស្មា



www.elibraryofcambodia.org

មានម្លូស្លាជាដើមទុន ។

៤៣- ទំនិញមានគ្រប់មុខ
ផ្លាល់ផ្ទេរទុកដាក់ដោយធុន
ចិនរែកមិនដែលពុន
ស្រុះដោរជន់ពេញផង្រុក ។

៤៤- ឈរប់រែកដេកអង្គុយ
រាប់កាក់លុយប្រមូលទុក
ឱ្យទិនស្រាពីមុខ
ទុកជាធ្នាក់ទាក់កខ្មែរ ។

៤៥- ចិនច្រើនខ្លាំងចិត្តខ្មៅ
កន្លាំងតៅធ្វើជាស្រែ
គ្មានត្បាល់គ្មានអង្រែ
អង្ករខ្មែរចូលប៉ោះចិន ។

៤៦- ជាតិខ្មែរច្រើនឥតខ្មាស
ស្រេកស្រាណាស់ផឹកជឿសិន
គំនិតគិតមិនឆ្អិន
ផឹកបង្ហិនតែទ្រព្យឯង ។

៤៧- កំណើតអ្នកផឹកស្រា
បែកប្រាជ្ញាច្រើនកន្លែង



www.elibraryofcambodia.org

អ្នកម្យ៉ាងបែកខាងល្បែង
មិនគិតក្រែងខ្លាចខ្លួនក្រ ។

៤៨- អាម្យ៉ាងបែកលួចឆក់
មារយាទអាក្រក់មិនបានល្អ
ផឹកចោលការរបរ
ចិនទាក់កធ្វើខ្ញុំបាន ។

៤៩- មិនដឹងខ្លួនជាឆ្កួត
និយាយអួតប្រាប់សន្ដាន
ថាចិនធ្លាប់រាប់អាន
ផឹកច្រើនម៉ានចិនមិនគិត ។

៥០- ថាចិនមិនចេះកាញ់
ប្រាប់សំឡាញ់ពួកម៉ាកមិត្ត
គូកនទោះឆ្ងាយជិត
រិតប្រមូលលុយឲ្យចិន ។

៥១- ត្រូវស្រាចង់ស៊ីឆ្ងាញ់
ធុំឆាខ្លាញ់បក់ឆ្អួលក្លិន
ឃើញបាយសម្លឆ្អិន
ផ្គាប់ចិត្តចិនយកបាយស៊ី ។

៥២- ផឹកទឹកបាយត្រឡោក



www.elibraryofcambodia.org

មារយាទទាបថោកបុកសៀធី
ចិនប្រើសែងរែកលី
ស៊ីញយៗ ចិនមើលងាយ ។

៤៣- ជាតិចិនកំណាញ់ស្វិត
នឹកក្នុងចិត្តមិននិយាយ
មារយាទខ្មែរច្រើនរាយមាយ
រលាយទ្រព្យអភ័ព្វខ្លួន ។

៤៤- ស៊ីឆ្ងាញ់ឆ្អែតស្កប់ស្កល់
ទាបថោកដល់ប្រពន្ធកូន
អាប់យសទាំងបងប្អូន
ដល់តាដូនពូជពង្សខ្មែរ ។

៤៥- ជាតិចិនសុទ្ធសឹងស
មានទ័លក្រខ្សត់ខ្លះដែរ
ស៊ីផឹកស្និទ្ធតាមសែ
តមបាយខ្មែរមិនស៊ីសោះ ។

៤៦- មានផ្ទះមានដំណាំ
កាប់ដីដាំដោយគៀនគោះ
ដំឡូងត្រាវចេកម្នាស់
ស៊ីមិនអស់ទុកលក់ដូរ ។



www.elibraryofcambodia.org

៥៧- ខ្មែរច្រើនខ្ជិលប្រមឹក
កែងកោងបុកអួតអំបូរ
ខ្វះលុយអង្គុយថ្ងូរ
កើបបង្គូរស្រូវជង្រុក ។

៥៨- កូនអើយរឿងដំណាំ
ក្តួរតែដាំឲ្យគ្រប់មុខ
ដីកេរ្តិ៍ម្តាយឪពុក
មិនត្រូវទុកចោលទំនេរ ។

៥៩- រាជការរាស់បានថ្លៃ
ផ្តិតមេដៃផ្តាច់ជាកេរ្តិ៍
មិនរាស់លេងទេ
ទើរយកពន្ធរាល់គ្នា ។

៦០- ដូងស្វាយអំពៅចេក
កុំខ្ជិលពេកដេកប្រចាំ
ម្លូស្លាម្រេចខ្ទឹមថ្នាំ
ត្រូវតែដាំកុំឲ្យខ្វះ ។

៦១- ទេសឯកសំពតស
ដីរាលល្អដាំកប្បាស
កុំខ្ជិលតាមចាស់ៗ
មនុស្សឿយណាស់មិនដែលក្រ ។



www.elibraryofcambodia.org

៦២- បន្លែដាំឲ្យគ្រប់
យកគ្រាប់ទុកដាំបន្ត
ចាក់ជីជាតិល្អ
បង្ការស្លូពេលល្ងាចព្រឹក ។

៦៣- ម្លូស្លាថ្នាំខ្ទឹមម្រេច
លូតលាស់លេចពីស្រោចទឹក
បានផលផ្លែឫស្លឹក
កុំឆ្អើងឫករាក្រខ្លួន ។

៦៤- ត្រីងៀតផ្អកប្រហុក
ខ្មែរគ្រប់ស្រុកទិញដូរយួន
អំបិលធូបក្រមួន
ពីតាដូនតែងដូរទិញ ។

៦៥- ដូរទុកដាក់ដំកល់
ស៊ីឲ្យដល់ខួបខែវិញ
ឲ្យបរិបូណ៌ពោរពេញ
ខាតចំណេញកុំទិញតិច ។

៦៦- អំបិលទិញមួយចុង
ច្រកពេញអុងអាងខាងលិច
កុំទិញក្តោបខ្ចប់រេច



www.elibraryofcambodia.org

អស់រំពេចគេចទិញទៀត ។

៦៧- អំបិលមួយស្រូវបី
រាល់នឹងល្អីទូលករណ្តៀត
ខ្លួនក្រត្រដរឆ្លៀត
មារយាទយ៉ាងហ្នឹងកុំប្រព្រឹត្ត ។

៦៨- កូនចៅទាំងប្រុសស្រី
គួរគប្បីប្រុងគំនិត
ចិញ្ចឹមជន្មជីវិត
គិតឲ្យវែងកុំគិតខ្លី ។

៦៩- ទំនេរល្ហែធ្វើការ
សូត្រធម៌អាថ៌ទាំងប្រុសស្រី
ឲ្យត្រឹមត្រូវបាលី
ដូចស្រដីខាងដើមស្រាប់ ។

៧០- រាល់រូបទាំងប្រុសស្រី
កាលចេះស្តីព្រោះចេះស្តាប់
ម៉ែឪតម្រូវប្រាប់
កូនចៅត្រាប់តាមដូនតា ។

៧១- ចាស់ម្យ៉ាងសាងសីលទាន
មិនបំពានខុសពុទ្ធដីកា



www.elibraryofcambodia.org

កូនកាត់តាមមេឮ
មិនទៅណាឆ្ងាយពីផ្លូវ ។

៧២- ចាស់ម៉្យាងសាងផលកម្ម
ស្អប់សីលប្រាំដូចសត្រូវ
កូនកាត់តាមម៉ែឪ
អាស្រូវភាសវិនាសខ្លួន ។

៧៣- មិនជឿមគ្គជឿផល
ធ្លាក់ទៅដល់អបាយបួន
កងកម្មចាំគុំគួន
គេចរេះពួនមិនកំបាំង ។

៧៤- ព្រះអង្គមានពុទ្ធដីកា
ប្រៀបឧបមាជាទីតាំង
ដូចគោបានកំលាំង
សំរាំងទុកទីមរទេះ ។

៧៥- នឹងបរផ្លូវវៀចត្រង់
ឬនឹងចង់បរគេចរេះ
កង់វិលមិនរបេះ
ដឹះជើងគោមិនឃ្លាតឃ្លា ។

៧៦- រាល់រូបទោះតូចធំ



www.elibraryofcambodia.org

ចូលរូងភ្នំរូងគុហា
យកថ្មផ្ទាំងរាំងទ្វារ
កម្មអោតោងតាមបាន ។

៧៧- កងសីលមានអង្គប្រាំ
អោកម្មដិតដោយដាន
នរកប្រេតតិរច្ឆាន
ខានឃាត់ខាំងបាំងមគ្គផល ។

៧៨- គួរខំសាងសីលទាន
យកនិព្វានជាត្រើយផ្តល់
យូរឆាប់គង់តែដល់
កុសលជួយចាកសង្សារ ។

៧៩- កូនចៅអើរគិត
មើលគំនិតចិត្តដូនតា
ប្រព្រឹត្តខុសសាសនា
គេចកិរិយាកុំធ្វើត្រាប់ ។

៨០- មើលចាស់ណាត្រឹមត្រូវ
ចុះក្នុងផ្លូវគន្លងច្បាប់
ចាស់ស្ដីគប្បីស្ដាប់
ប្រិតប្រៀងប្រាប់ឲ្យប្រុងចាំ ។



www.elibraryofcambodia.org

៨១- គោរពគុណទាំងបី
សូត្រធ្មាណីតាមចំណាំ
រក្សាអង្គសីលប្រាំ
កម្មវេរាតាមមិនទាន់ ។

៨២- សាសនានៅវែងឆ្ងាយ
កន្លងប្លាយផាងពីរពាន់
សព្វថ្ងៃលៃគ្នេរគ្នាន់
មិនទាន់គ្រប់ជាប្រាំរយ ។

៨៣- ឥឡូវចិតប្រាំបី
នៅម្ភៃមួយខាងក្រោយ
កូនចៅកុំបណ្តោយ
ឲ្យលិចលង់ក្នុងសង្សារ ។

៨៤- មានពាក្យចាស់ដំណាល
ថាកណ្តាលព្រះសាសនា
ទំនាយក្បួនតម្រា
ថានឹងរលះហើយរីកវិញ ។

៨៥- ហេតុនេះអស់កូនចៅ
ទោះល្ងង់ខ្លៅយ៉ាងណាមិញ
ខំឧស្សាហ៍ទន្ទេញ
បំពេញពាក្យពុទ្ធទំនាយ ។



www.elibraryofcambodia.org

៨៦- តំណពីថ្ងៃនេះ
រៀនតិះកុំរាយមាយ
កូនណាមិនស្វាធ្យាយ
មិនរលាយរលត់ទុក្ខ

៨៧- ដល់សាសនាគ្រប់គ្រាន់
ជួបប្រាំពាន់ទៅខាងមុខ
ទំនាយរាយទំនុក
ថាឪពុកម្ដាយស្អប់កូន ។

៨៨- ថាកើតអន្តរកប្ប
កុំសម្លាប់គ្នាបងប្អូន
មិនដឹងតាដឹងដូន
សូន្យសីលទានមិនមានសល់ ។

៨៩- គួរគិតកុំសាងកម្ម
កាន់សីលប្រាំចាំដឹកល់
ខំសាងមគ្គសាងផល
នឹងបានដល់ឋានសាន្តសុខ ។

៩០- នឹងរួចពីកាប់ចាក់
មិនបានធ្លាក់ទៅនរក
ព្រះសិអារ្យត្រាស់ខាងមុខ



www.elibraryofcambodia.org

រសាយទុក្ខសោករាល់ថ្ងៃ ។

៩១- នេះហៅច្បាប់បណ្ដាំ
ជាពាក្យប្រៀបមួយផ្ទួន
បទព្រហ្មគ្រប់ឃ្លាប្អូន
ជូនថែងចប់ម្ល៉េះហើយហោង ។



www.elibraryofcambodia.org

# ឧបសម្ព័ន្ធ



www.elibraryofcambodia.org

# អធិប្បាយកថាសង្ខេប លើ ស្នាដៃ ក្រមង៉ុយ

ការវិភាគ អត្ថបទ អក្សរសិល្ប៍ យើងត្រូវពឹងផ្អែក ជាពិសេស ទៅលើ ធាតុសំខាន់៣គឺ៖

-អត្ថបទ

-អ្នកនិពន្ធ

-សង្គមបរិយាកាស[115]

**១- អត្ថបទ**

អត្ថបទស្នាដៃ ក្រម ង៉ុយ ដំបូង ជា អត្ថបទសំដីដែល អ្នកប្រាជ្ញ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានកត់ត្រាតាមការណែនាំដោយ អ្នកស្រី ស៊ុយ ហ្សាន ការ៉ុ ទៀស ជាចាងហ្វាងវិទ្យាស្ថាន នេះ ហើយ អ្នកស្រី បាន យក មក បោះពុម្ព ផ្សាយ ជាលំដាប់លំដោយ រៀង មក ទាំង អស់ មាន ៥ ច្បាប់ គឺ ៖ «ច្បាប់ល្បើក ថ្មី, ច្បាប់ កេរកាល, សេចក្តីរំលឹកដាស់តឿន, ពាក្យកាព្យប្រដៅជនប្រុសស្រីនិងល្បើកច្បាប់សង្ឃ» ។ នៅពេល ដែល ស្នាដៃ ក្រមង៉ុយ បញ្ចូល ក្នុង កម្មវិធីសិក្សា ថ្នាក់ ទី ៦ ទំនើប នា ឆ្នាំ ១៩៤៨ មកបណ្ណាគារគីម-សេងបានបោះពុម្ពកូនសៀវភៅមួយ មានចំណងជើងថា *បណ្តាំក្រមង៉ុយ – ច្បាប់ដាស់តឿនកូនចៅ* ចែក ចេញ ជា ២ ច្បាប់ ប៉ុន្តែយើង យកមកសិក្សាតែ ច្បាប់ទី១ដែល យើងយល់ថាជាស្នាដៃលោកប្រាកដមែន ។ បណ្ណាគារគីម-សេង ពុំ មាន បញ្ជាក់កាលបរិច្ឆេទ បោះពុម្ព និង ប្រភព យក ចេញ ពី ទី ណា

[115]ចំពោះការសិក្សាលើ អត្ថបទវិជ្ជា សូម អាន ឃីងហុកឌី, «បទពិសោធន៍ ខ្លះៗ នៃការសិក្សាលើអត្ថបទវិជ្ជា», *សមូហកម្មអក្សរសិល្ប៍នូហាធ*, លេខ១២, ២០០៤, ទំព័រ ៩២-៩៦ ។



www.elibraryofcambodia.org

ឡើយ ។ លោក លី-ធាមតេង ក៏ បាន បោះ ពុម្ព បណ្ដាំក្រមង៉ុយ មួយ ទៀត នៅ បណ្ណាគារ សេង-ងួន-ហួត នៅ ឆ្នាំ ១៩៦៤ តែ ច្បាប់ នេះ ដូច គ្នា បេះ បិទ នឹង «ពាក្យកាព្យប្រដៅជនប្រុស-ស្រី» បោះពុម្ពផ្សាយ ដោយ ពុទ្ធសាសនបណ្ឌិត្យ ។[116] ស្នាដៃទាំងអស់របស់ភិរម្យង៉ុយ ជា អត្ថបទកំណាព្យ មាន បទកាកគតិ, ព្រហ្មគីតិ និង បទពាក្យ៧ ។

## ២- អ្នកនិពន្ធ

ប្រវត្តិរូបកវី-និពន្ធ នេះ យើង នឹង ឡើង ចេញ ពី ការស្រាវជ្រាវ នាឆ្នាំ១៩៦៦ របស់លោកលី-ធាមតេងជាអ្នកប្រាជ្ញទំនៀមខ្មែរ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែល លោកបាន ទៅស៊ើប អង្កេតផ្ទាល់ ជាមួយ នឹង គ្រួសារ ភិរម្យង៉ុយ ពោល គឺ លោក បាន ទៅ ជួប កូន ច្បង របស់ តាង៉ុយ នាម «ជួង» និង ចៅ លោក ឈ្មោះ «ជួង-យាន» ដែល នៅរស់ ជីវិត នាពេល នោះ ។ ជាពិសេស ទៅទៀត លោក លី-ធាមតេង បាន អង្កេតជាមួយ អ្នកប្រាជ្ញខ្មែរនានាដែលស្គាល់និងបានកត់ត្រាសំនៀងវោហារតាង៉ុយ ផងនោះ គឺមាន លោកចាប ពិន, លោក ប៉ុ-ប៉ូ, លោក ជា ឃុ ។ ល ។ យើងក៏បាន ប្រវត្តិបន្ថែមទៀតតាមរយៈស្នាដៃលោកដូច មាន សេចក្ដីបញ្ជាក់ស្រាប់ ក្នុង សេចក្ដី ផ្ដើម និង បញ្ចប់នៃ ច្បាប់ល្បើកថ្មី-

ក្នុងសេចក្ដីផ្ដើម÷

«អ្នកព្រះភិរម្យ ភាសាឈ្មោះខ្ញុំ បង្គំនឹកគុណ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន គុណតាប់មហាធ្ងន់
មាតាបិតា ។
ឧបជ្ឈាយ៍ ដាជី កាល ចាប់ដៃខ្ញុំ ឲ្យធម៌កែសា
អនុសាវន ព្រះកម្មវាចា គុណគ្រូអគ្គា

[116] សូមអានបញ្ជីឯកសារនៅខាងក្រោយ ។



www.elibraryofcambodia.org

ទាំងសាមសិបបី ។ »[117]

ក្នុងសេចក្ដីបញ្ចប់ ៖

«នេះគឺហៅច្បាប់ ជាទីសណ្ដាប់ សន្ដានទាំងឡាយ
កូនចៅប្រុសស្រី កុំបីនឿយណាយ សង្ខេបបរិយាយ
ទិដ្ឋិតាំងថែងចប់ ។
អ្នកព្រះភិរម្យ អាចារ្យខ៊ុយខ្ញុំ បង្គំប្រមាមដប់
លើសលេសឆ្គាំឆ្គង រំលងពុំគាប់ ពុំគួរសមសព្វ
សុសសាយសេចក្ដី ។ »[118]

ក្នុង *ច្បាប់កេរកាលថ្មី* ក៏ បានប្រាប់នាមដើម និងឈ្មោះដែលគេហៅក្រៅដែរ ៖

«អ្នកប្រាជ្ញភិរម្យល្បី លើកច្បាប់ថ្មីអស់ល្បត់ល្បង
ឈ្មោះអ៊ូ ហៅខ៊ុយផង ចងជាច្បាប់សម្រាប់ជន ។ »[119]

ក្នុង *សេចក្ដីរំលឹកដាស់តឿនកវី* យើងក៏បានប្រាប់នាមខ្លួននិងគោរម្យងារដូចខាងក្រោមនេះ ៖

«អ្នកព្រះភិរម្យភាសាអ៊ូ លើកដៃទាំងគូប្រណម្យផ្គង់
បង្គំព្រះពុទ្ធគ្រប់ព្រះអង្គ ព្រះធម៌ព្រះសង្ឃប្រសើរសាយ ។
ព្រះគុណគ្រូឧបជ្ឈាយាចារ្យ មាតាបិតាបង្កើតកាយ
បង្កើតប្រាជ្ញាថ្លាវែងឆ្ងាយ ខ្ញុំសូមអធិប្បាយថែកពាក្យជូន ។ »

---

[117] «ច្បាប់ល្បើកថ្មី», ក្នុង សៀវភៅ *ច្បាប់ក្រមង៉ុយ*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៧៣, បោះពុម្ពទី៧, ទំព័រ១ ។

[118] *ដដែល*, ទំព័រ ៦០ ។

[119] «ច្បាប់កេរកាលថ្មី», *ដដែល*, ទំព័រ ៨០ ។



www.elibraryofcambodia.org

នៅសេចក្ដីបញ្ចប់ *សេចក្ដីរំលឹកដាស់តឿនដដែល* នេះ លោក បាន ប្រាប់ នាម ដើម លោក, នាម មាតាបិតា ព្រម ទាំង គោរម្យងារ ហើយ លោក បាន បញ្ជាក់ពូជផៅ លោក ទៀតផងដូចមាន សេចក្ដីស្រង់ខាងក្រោម នេះ៖

«ភិរម្យខ្ញុំបាទដើមឈ្មោះ**អ៊ី**　　ពូជពង្សអម្បូរខ្មែរអ្នកជា
អាពុកឈ្មោះ **អ៊ុក**មានសក្ដិងារ　　ចៅពញាធម្មធារាមេស្រុក ។
ក្នុងខេត្តភ្នំពេញឃុំកំបូល　　ពូជពង្សត្រកូលម្ចាស់អង្គ**ប៉ុក**
ជីតាខាងម្ដាយឈ្មោះពញា**ប៉ុក**　　គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
អ្នកម្ដាយអាពុកបងប្អូនជិត　　ជិទួតមួយពិតពូជចិត្តល្អ ។
ដូនតាផ្សំផ្គុំជាតំណ　　បង្កើតមកជាខ្ញុំបាទ ។
ពូជខាងអាពុកមានប្រាជ្ញា　　ច្រើនរចេះសាស្ត្រាចាក្បួនខ្នាត
ត្រកូលខាងម្ដាយប្រាជ្ញាឆ្លាត　　រូបរាងច្រើនស្អាតគ្មានគេស្អប់ ។ »[120]

ក្នុង *ពាក្យកាព្យប្រដៅ ជន ប្រុស-ស្រី គិរី* យើង បាន បញ្ជាក់ ប្រវត្តិរូប ក្នុង សេចក្ដីបញ្ចប់ដែរ៖

«អ្នកម្ដាយឪពុកឲ្យឈ្មោះ**អ៊ី**　　ពូជពង្សអំបូរខ្មែរអ្នកជា
អាពុក ឈ្មោះ **អ៊ុក**មានសក្ដិងារ　　ចៅពញាធម្មធារាធ្វើមេស្រុក ។
ក្នុងខេត្រភ្នំពេញឃុំកំបូល　　ជាប់ផៅត្រកូល ម្ចាស់អង្គ**ប៉ុក**
អាពុកអ្នកម្ដាយ ឈ្មោះពញា**ប៉ុក**　　គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
អ្នកម្ដាយអាពុកបងប្អូនជិត　　ជិទួតមួយពិតពូជចិត្តល្អ

---

[120] ដដែល, ទំព័រ១០៤ ។ ក្នុង សេចក្ដី បញ្ចប់ បញ្ជាក់ ថា ក្រមង៉ុយ ជាប់ ត្រកូល ពូជពង្ស«ម្ចាស់អង្គប៉ុក» បានសេចក្ដី ថាលោក ប្រហែល ជាប់ពូជពង្សត្រកូល ញាតិ ផៅស្ដេចដែរ គួរ មានការស្រាវជ្រាវបន្តទៅទៀត ។

ចាស់ទុំផ្សំផ្គុំជាដំណ　　　　បង្កកើតខ្ញុំទូលបង្គំ ។ »[121]

ក្នុង សៀវភៅច្បាប់សង្ស ភិរម្យង៉ុយ ក៏បានបញ្ជាក់ប្រវត្តិរូបលោក ដូចច្បាប់ឯទៀតដែរដូចជា៖

«ខ្ញុំទូលបង្គំនាមដើមឈ្មោះ**អ៊ុ**　　ពូជពង្សអំបូរខ្មែរអ្នកជា
អាពុកឈ្មោះ**អុក** មានសក្តិងារ　　ចៅពញាធម្មធារាធ្វើមេស្រុក ។
ក្នុងខេត្តភ្នំពេញឃុំកំបូល　　ពូជពង្សត្រកូលម្ចាស់អង្គ**ម៉ុក**
អាពុកអ្នកម្តាយឈ្មោះពញា**ម៉ុក**　　គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
អ្នកម្តាយអាពុកបងប្អូនជិត　　ដឹទូតមួយពិតពូជចិត្តល្អ
ជូនគាផ្សំផ្គុំជាដំណ　　បង្កកើតខ្ញុំទូលបង្គំ ។ [122]
បង្កើតអំពីក្នុងគំនិត　　ភ័យភិតខ្លាចបាបចង់បានបុណ្យ
បានបែកចែងច្បាប់ប្រាប់មហាជន　　ប្អូនច្បាប់ពីមុនផ្ទុនភេគាះ ។
បោះពុម្ពសៀវភៅចែកសព្វសាយ　　ម៉ាដឺម៉ូហ្សែល[123]ចាត់ថ្វាយ ព្រះករុណា
មិនបានថ្វាយផ្ទាល់ដល់ហត្ថា　　សូមទ្រង់មេត្តាប្រោសប្រណី ។
ខ្ញុំនករាបប្រណម្យសុំអនុញ្ញាត　　ក្រាបក្រោមព្រះបាទព្រះបារមី

---

[121] «ពាក្យកាព្យប្រដៅផនប្រុស-ស្រី», ក្នុង សៀវភៅ *ច្បាប់ក្រមង៉ុយ*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៧៣, បោះពុម្ពទី៧, ទំព័រ១១៩-១២០ ។

[122] ភិរម្យង៉ុយ ចែងថា«ទូលបង្គំ» បានសេចក្តីថា«ទូលកន្លោរអាចម៍» ស្តេចគឺជារាជសព្ទមានន័យ ជាពាក្យធម្មតាថា «ខ្ញុំ» ហើយសព្វថ្ងៃរាជសព្ទនេះគេកែមកជា «ទូលបង្គំ»វិញ ។

[123] Mademoiselle គឺពាក្យបារាំងសម្គាល់នារីមិនទាន់មានប្តី គឺសំដៅនាងកញ្ញា ស៊ុយហ្សាន ការប៉ឺឡែស ជាចាងហ្វាងវិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ, សូម អាន ឃើងហុកឌី, «អ្នកស្រីស៊ុយហ្សាន ការប៉ឺឡែស និងវិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ», *សិក្សាចក្រ*លេខ៨-៩, ២០០៦-២០០៧, ទំព័រ១៨៩-១៩៦ ។



www.elibraryofcambodia.org

ចែងច្បាប់បរមត្ថអត្ថបាឡី     សេចក្ដីចែងចប់ម្ល៉ោះហើយហោង ។ »[124]

### ៣-សង្គមបរិយាកាស

#### ក) ទីកាល

គឺជាកាល កំណត់ពីពេល តែងនិពន្ធ, ពេល កំណើត អ្នកនិពន្ធ, ពេល សំដែង អត្ថបទអក្សរសិល្ប៍ (សូម អានសេចក្ដីផ្ដើមខាងលើ) ។

កំណត់កាល ពេល វេលា នេះ មាន ប្រយោជន៍ សំខាន់ ដើម្បី ជាពន្លឺ ឆ្លុះ មើល សម័យ ប្រវត្តិសាស្ត្រ ដែល នាំឲ្យ ស្នាដៃ អ្នកនិពន្ធបាន ចាប់កំណើតដែល ថ្លែងសំដែង ឡើង ។

ព្រះភិរម្យ ង៉ុយ កើតនាសម័យ អាណានិគម បារាំងដូច មាន សេចក្ដី បញ្ជាក់ ទីកាល ដោយ ការផ្ដល់ក្នុងស្នាដៃខ្លះៗ ឧទាហរណ៍ ដូចជា÷

ក្នុង *ច្បាប់ល្បើកថ្មី*បញ្ជាក់ទីកាលនៅលើសេចក្ដីផ្ដើម÷

«ខែចេត្រឆ្នាំចេ     ចត្វាស័កក     កគិតកាព្យថ្មី
លើកច្បាប់ប្រដៅ     កូនចៅប្រុសស្រី     តូចក្ដីធំក្ដី
ចូរស្ដាប់គ្រប់គ្នា ។ »[125]

---

[124]«ល្បើកច្បាប់សង្ឃ», *កម្ពុជសុរិយា*, ១៩៣២-៣៤ ( ? ), លេខ ( ? ), ទំព័រ ១២៤-១២៥ ។

[125]«ច្បាប់ល្បើកថ្មី», ដដែល, ទំព័រ ១ ។



www.elibraryofcambodia.org

ឆ្នាំចចត្វាស័កនៅដើមសតវត្សទី ២០ គឺត្រូវនឹងព.ស. ២៤៦៥ហើយស្រប នឹងគ.ស. ១៩២២[126]។

ក្នុង *ច្បាប់កេរកាលថ្មី*ភិរម្យង៉ុយក៏បានបញ្ជាក់ប្រាប់ទីកាលដែរ ៖

«នេះច្បាប់កេរកាលថ្មី　　អស់សេចក្ដីតែប៉ុណ្ណឹង
កូនប្រុសអ្នកខំប្រឹង　　សំឡឹងចាំតទៅមុខ ។
ពីឆ្នាំចតទៅ　　ខំធ្វើស្រូវដាក់ជង្រុក
អាស្រ័យពាក្យអាពុក　　ទុកឲ្យកូនចៅគ្រប់គ្នា ។
អាពុកកាន់តែចាស់　　ស្ដាយខ្លួនណាស់ចូលជរា
ពាក្យពិតប្រាំយឃ្លា　　ជាសូរចម្លើរឯងហោង ។ »[127]

ទាំងនេះបានសេចក្ដីថាលោកតាក់តែង *ច្បាប់កេរកាលថ្មី*នេះនៅឆ្នាំច ចត្វាស័កព.ស. ២៤៦៥គឺត្រូវនិងគ.ស. ១៩២២នេះឯង ។

ក្នុង *សេចក្ដីរំលឹកដាស់តឿន*ភិរម្យង៉ុយក៏បានបញ្ជាក់ទីកាលដែរ ៖

«ព្រះពុទ្ធសករាជព្រះសាសនា　　អតិកន្ដាកន្លងផុន
ពីរពាន់បួនរយចិតសិបបួន　　ជួនខែនិងថ្ងៃគ្មានកន្លង ។
ដើមឆ្នាំមមែកក្នុងត្រីស័ក　　ពិសាខភ្លៀងធ្លាក់កាត់ទឹកម្ដង
មួយរោចថ្ងៃសៅរ៍កើតសៅហ្មង　　ក្ដាពាក្យអ្នកផងទាស់ទែងគ្នា ។ »[128]

---

[126]សូមអានឌិក-គាម. *ប្រតិទិន១០៦ឆ្នាំ, សុរិយាគតិនិងចន្ទគតិ*, ភ្នំពេញ, ១៩៦៥, ទំព័រ៣៨ ។ ក្លូង-នួន. *បញ្ជាក់សករាជពីព.ស. ១ទៅ៥០០០វស្សា*, ភ្នំពេញ, ១៩៤៧, ទំព័រ៤២ ។ ចៅ-សំអាន, *ប្រតិទិនបារាំង-ខ្មែរ*, ភ្នំពេញ, ១៩៦៧ ។

[127]«ច្បាប់កេរកាលថ្មី», *ដដែល*, ទំព័រ៨០ ។

[128]«សេចក្ដីរំលឹកដាស់តឿន», *ដដែល*, ទំព័រ៨៩ ។



www.elibraryofcambodia.org

ទាំងនេះបានសេចក្ដីថា លោកបានតាក់តែងកំណាព្យនេះឡើងនាថ្ងៃសៅរ៍ ១រោចខែពិសាខឆ្នាំមមែ ត្រីស័ក ព.ស.២៤៧៤ គឺត្រូវនឹង គ.ស.១៩៣១ ។[129]

ចំពោះ *ពាក្យកាព្យប្រដៅជនប្រុសស្រី* កវី ភិរម្យងុយ បានប្រាប់តែជីវប្រវត្តិ ប៉ុន្តែមិនបានបញ្ជាក់ទីកាលទេ ។

ក្នុងច្បាប់ *បណ្ដាំក្រមងុយ* បោះពុម្ពដោយបណ្ណាគារគីម-សេង មានបញ្ជាក់ទីកាល តែឥតមាននាមអ្នកនិពន្ធទេ៖

«សាសនានៅវែងឆ្ងាយ　　កន្លងបួយ ជាងពីរពាន់
សព្វថ្ងៃលៃ ត្នេរត្នន់　　មិនទាន់គ្រប់ជាប្រាំរយ ។
ឥឡូវចិតប្រាំបី　　នៅម្ភៃមួយខាងក្រោយ
កូនចៅកុំបណ្ដោយ　　ឲ្យលិចលង់ក្នុងសង្សារ ។ »[130]

បានសេចក្ដីថា *បណ្ដាំក្រមងុយ* នេះតាក់តែងឡើងនា ព.ស.២៤៧៨ គឺត្រូវនឹង គ.ស.១៩៣៤ ។

ស្នាដៃលោកទាំងអស់ផលិតឡើងរវាង គ.ស.១៩២២ និង ១៩៣៤ គឺនៅក្រោមនិយមអាណានិគមបារាំងសេស ។

### ខ) ទីកន្លែង

កវី ភិរម្យងុយ កើតនៅឃុំស្រុកមិនឆ្ងាយពីទីក្រុងភ្នំពេញ ដូចមានសេចក្ដីបញ្ជាក់នានាក្នុងអត្ថបទកំណាព្យរបស់លោក ។ បានសេចក្ដីថា លោកកើតក្នុងត្រកូលមេឃុំ គឺជាគ្រួសារខ្មែរមធ្យម ហើយបានបួសរៀនយ៉ាងជ្រៅជ្រះ ដែលប្រជារាស្ត្រយើងជំនាន់នោះទុកលោកជាអ្នកប្រាជ្ញមួយរូប មានគំនិតចំរើននិយម

[129] សូមមើល ឌឹក-គាម, ដដែល, ទំព័រ ៨៧ ។ ចៅ-សំអាន, ដដែល, ឆ្នាំ១៩៣១ ។
[130] *បណ្ដាំក្រមងុយ*, ដដែល, ទំ.២៤-២៥ ។



www.elibraryofcambodia.org

ចង់ឲ្យស្ថាន ប្រជាជនខ្មែរ ទូទៅ តាំងពីកូនសេដ្ឋី, ព្រះសង្ឃ រហូតដល់ ជនតូចតាច ឲ្យរួចពីទុក្ខព្រួយ នានា ឆ្ពោះទៅរកវឌ្ឍនភាពក្នុងភូមិ ឃុំ ស្រុក ស្រែ ចំការ ច្បារ ដំណាំ ពោលគឺនៅកម្ពុជា យើងទាំងមូល ។

## គ) ទីបរិយាកាស

កម្រង «ច្បាប់» ជាកំណាព្យ ទាំង ៦ ដែល បាន ស្រង់ ដាក់ ក្នុង សៀវភៅ នេះ និពន្ធ ឡើង នៅសម័យអាណានិគមនិយម ភិរម្យងុំយ មាន បំណង ចង់ ប្រដៅ ខ្មែរ ទូទៅជាពិសេស ខ្មែរ តូច តាច អ្នកស្រែ ចំការ លើក លែង តែ ច្បាប់ ចុង ក្រោយ គឺ «ល្បើកច្បាប់សង្ឃ» ។ ល្បើក នេះ ភិរម្យ ងុំយ ចង់ ឲ្យស្ថាន ដាស់ តឿន ព្រះសង្ឃ ខ្មែរ ឲ្យ គោរពវិន័យ សង្ឃ ។ ប្រសិនបើ អ្នកអាន ចង់ ឲ្យ យល់ ច្បាស់ ពី «ល្បើក ច្បាប់ សង្ឃ» ត្រូវតែអានវិន័យសង្ឃ ទើបយល់អស់សេចក្ដី ។ [៣]

នៅសម័យ អាណានិគម នោះ ក្រមងុំយ សង្កេត ឃើញ ក្នុង សង្គម ខ្មែរ នូវ សភាពការណ៍ និងវិបត្តិជាច្រើនតែយើង ស្រង់គោល ខ្លះៗ មកពណ៌នា៖

– **ការឈ្លោះ គ្នា រវាង អ្នក កាន់ ធម៌ ចាស់ និង ធម៌ ថ្មី វត្ត ធម្មយុត្តិ, វត្តមហានិកាយ លោក បាន ថែង ក្នុង «សេចក្ដី រំលឹក ដាស់ តឿន»៖**

«៨- មិនបានកាប់ចាក់ដល់បាក់បែក ថ្ងៃនេះផដែកថ្ងៃស្អែកជា
ចាក់ដោតការលោលពេលណា ទិន្នដៀលត្រូះចាស់បុរាណ ។

---

[៣] គីម-ប៊ិល (ធម្មកោសលោ), *វិនយសង្គហៈ*, កំពង់ចាម, ១៩៨២, ១៤១ ទំព័រ ។ ជួន-ណាត (ព្រះគ្រូសង្ឃសត្ថា), ហួត-តាត (ព្រះគ្រូសង្ឃវិជ្ជា), អ៊ុំ-ស៊ូរ (ព្រះគ្រូវិមលប្បញ្ញា), *សមណវិន័យ*, ភ្នំពេញ, ព្រះរាជបណ្ណាល័យ, ១៩២៨, ៦៤ទំព័រ ។ អ៊ុំ-ស៊ូរ (ព្រះគ្រូវិមលប្បញ្ញា), និង ជួន-ណាត (ព្រះគ្រូសង្ឃសត្ថា), *ព្រះប្រណាមសង្ខេបនិងគិហិវិន័យសង្ខេប*, ភ្នំពេញ, ១៩៦៦, ៩៦ទំព័រ (បោះលើកទី២០) ។



www.elibraryofcambodia.org

៦-ពួកចាស់ជឿលត្ថះអ្នកប្រាជ្ញថ្មី      រឿងធម៌បាលីស្ដីប្រមាណ
ប្រមាថទៅមកមិនឈប់ខាន      ហាមប្រាមមិនបានមិនបាត់មាត់ ។
៧-ព្រះធម៌ព្រះពុទ្ធតែមួយអង្គ      លោកសង្ឃបួសរៀនមានដោយវគ្គ
សង្ឃខ្លះចេះស្ទើរមិនចាំស្ទាត់      ភ្លើៗ សូត្រភ្លាត់មិនត្រូវខ្សល់ ។
៨-គេប្រាប់ថាខុសប្រកាន់ខឹង      មិនដឹងថាខ្លួនរៀនមិនដល់
មិនដែលសួរគេព្រោះមិនឆ្ងល់      សម្គាល់ថាខ្លួនត្រូវមិនខុស ។
៩-អ្នកប្រាជ្ញលោកសូត្រចំបាលី      ថាគេធម៌ថ្មីស្ដីបន្ទុះ
បន្ទោសទៅមកឆ្លើយឆ្លងឈ្លោះ      មិនព្រមចំណុះខុសពំណាំ ។
១០-ចំណែកចំណោះចេះរាល់ខ្លួន      បារាជិកបួនវិន័យប្រាំ
មហាវគ្គចុល្លវគ្គអាទិកម្ម      ព្រះអង្គគ្មានផ្ដាំឲ្យឈ្លោះគ្នា ។
១១-ផ្ដាំឲ្យតែកាន់សិក្ខាបទ      អ្នកបួសរាល់វត្តត្រូវសាមគ្គា
ព្រះពុទ្ធបរាលវិហារ      វន្ទាគោរពរាល់យប់ថ្ងៃ ។
១២-នមស្ការបង្គំធម៌បីបទ      សូត្រហាហបមាត់ឡើយជើងដៃ
មិនដឹងប្រាកដរតនត្រ័យ      មិនចេះសង្ស័យសួរអ្នកណា ។
១៣-អ្នកប្រាជ្ញលោកសូត្រចំបាលី      ប្រែចេញសេចក្ដីឲ្យពិស្ដារ
អ្នកខ្លៅមិនស្ដាប់ពុទ្ធដីកា      គេថាខ្លួនខុសប្រកាន់ខឹង ។
១៤-ធម៌សម្មុទ្ទេសូត្រលាន់ៗ      ព្រះពុទ្ធឲ្យពាន់ខ្លះមិនដឹង
ជឿផាត់ថាចេះចប់ប៉ុណ្ណឹង  មិនប្រឹងរៀនប្រែបកបរិយាយ ។
១៥-ចេះហើយមិនដឹងខ្លួនខុស      មិនព្រមចំណុះអ្នកប្រាជ្ញព្រាយ
បាលីប្រឡំពាក្យនិស្សាយ      និកស្ដាយបែបចាស់មិនផ្លាស់ចេញ ។
១៦-គេថាសូត្រធម៌មិនចេះប្រែ      បានបុណ្យខ្លះដែរតែមិនពេញ
បើចេះប្រែផងបានចំណេញ      ខ្លួនវិតទន្លេញតែបែបចាស់ ។
១៧-បចេសទទឹងរឹងជំនែក      ប្រកឹងប្រកែកប្រកួកម្នះ[132]

[132]ដែលត្រឹមត្រូវគឺ «ហាទន» (កំណត់ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពទី៧, ១៩៧៣)



www.elibraryofcambodia.org

ម្នាំ[133]សូត្រនឹងធម៌ព្រះ ជាតិក្រោយក្រឡាស់ជាល្ងង់ខ្លៅ ។
១៨-មានកាលក្រឡប់ជាគថ្លង់ មម៉េងមម៉ងឆ្កួតមួយប៉ៅ
ពិព្រោះមិនស្តាប់ប្រាជ្ញប្រដៅ ហ្នឹងហៅចេះហើយមិនប្រលប់ ។
១៩-ប្រសិនបើខិនខ្លួនខ្លបខ្លាច អ្នកប្រាជ្ញកាលណាលោកនឹងស្អប
ធម៌អាថ៌អ្នកណានឹងចេះចប់ កុំកាន់ទម្លាប់ទម្លោយខ្លួន ។
២០-ទម្លាប់ឲ្យទាបសុភាពវិរិយ ព្រះសូត្រវិន័យធំជាងក្បួន
ព្រះអភិធម្មជាមាំមួន ចេះហើយប្រឆ្លួនគួររៀនទៀត ។
២១-ពាក្យពីបុរាណជាពាក្យងាយ ពាក្យក្បួនទូលាយស្រណុកជៀត
ឯពាក្យគម្ពីរទីចង្អៀត គួរឆ្លៀតជ្រើសរកយកឲ្យបាន ។
២២-ឲ្យបែកគំនិតគិតច្រើនផ្លូវ មួយខុសមួយត្រូវជាពីរស្ថាន
គេប្រាប់ថាខុសគួរឈប់ខាន ឃើញត្រូវប៉ុន្មានប្រមូលយក ។
២៣-ព្រះឱស្ឋព្រះអង្គទ្រង់ទេសនា អ្នកប្រាជ្ញចែងចារចងទុកមក
ព្រះសូត្រវិន័យលោកលៃលក ប្រែសព្ទសៀតស័កច្រើនប្រការ ។
២៤-ពាក្យពិតប្រាកដបទបាលី ប្រែចេញសេចក្តីឃើញពិស្តារ
គួរស្តាប់ឲ្យស្ទែងសិនសុំថា កុំអាងតម្រាតម្រាប់ចាស់ ។
២៥-តម្រាយបុរាណយូរអង្វែង មិនលែងច្រឡំមានលើសខ្វះ
អ្នកប្រាជ្ញជំនុំឃើញខុសណាស់ ចោលខ្លះទុកខ្លះដោយពិស្តារ ។
២៦-យ៉ាងធម៌តិរោគ[134]ពីបុរាណ មិនដឹងជាបានពីគ្រូណា
សូត្រលាយចម្រុះខុសអក្ខរា មិនបានជាការប្រយោជន៍អ្វី ។
២៧-អ្នកប្រាជ្ញឃើញខុសច្រើនអន្លើ ខំរើរៀបចំឲ្យបាលី

---

[133] «មិននៅ» ។ កវីបានបង្រួញឲ្យនៅតែមួយព្យាង្គដើម្បីគោរពជើងកាព្យ ។

[134] ឈ្មោះសូត្រ ១ក្នុងព្រះសុត្តន្តបិដក ហៅថា តិរោកុឌ្ឍគណ្ឌ ក៏បាន, ឬ ហៅដោយខ្លី តាមទម្លាប់ស្រួលមាត់ត្រឹមតែតិរោកប៉ុណ្ណោះក៏បាន, ក្នុងប្រទេសខ្មែរយើងប្រើជាធម៌សម្រាប់សូត្រដារឧទ្ទិសចំណែកបុណ្យ។ *វចនានុក្រមខ្មែរ*, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, ទំព័រ ៣៤៤-៣៤៦។



www.elibraryofcambodia.org

អ្នកខ្លៅហៅធម៌គិតពាក្យថ្មី សម្តីបែបឡកចំអកខឹង ។
២៨-សង្ខេបរឿងសូត្រធម៌ត្រូវខុស កូនចៅប្រុសៗ គួរខំប្រឹង
ប្រយ័តអ្នកប្រាជ្ញប្រិតឲ្យដឹង សម្លឹងអក្ខរាឲ្យប្រាកដ ។ »[135]

- ការទូន្មាន ឲ្យ ខំ ស្វះស្វែង រកស៊ី ដូច មាន សម្រង់ ចេញ ពី «ច្បាប់ល្បើក ថ្មី»ខាង ក្រោម នេះ÷

«៤៧-កើតមកជាមនុស្ស ទាំងស្រីទាំងប្រុស មិនដែលចេះឯង
បើក្រឲ្យមាន ញៀណរេចេះក្រែង គិតគ្រប់កន្លែង
កុំដេកតែក្រ ។
៤៨-កុំប្លន់កុំលួច កុំឆ្អិលកុំខូច កុំហកឆ្លូវឆ

---

[135] ចំពោះទំនាស់វិបត្តិរវាង ធម៌ ចាស់-ធម៌ ថ្មី នៅ ជំនាន់ នោះ សូម អាន សៀវភៅ សម្តេចព្រះមហាសុមេធាធិបតី ហួត-តាត, *កល្យាណមិត្តរបស់ខ្ញុំ*, ភ្នំពេញ, ១៩៧០, ៧០ ទំព័រ ។ សម្តេចហួត តាត បាន ថែង បញ្ជាក់ ក្នុង ទំព័រ ១២ ថា៖ «តាម ការពិត ពាក្យ ថា «ធម៌ចាស់ ធម៌ថ្មី» នេះ មិន គួរ បង្កើត ឲ្យ មាន សោះ ព្រោះ ធម៌ ដែល ព្រះពុទ្ធជាម្ចាស់ ទ្រង់បានសម្តែងទុកមកទាំងប៉ុន្មានសឹងមានចារឹក នៅក្នុងគម្ពីរ ក្បួន ច្បាប់ ទាំង អស់ ។ អ្នកដែល ខំ ប្រឹង ស្រាវ ជ្រាវ រិះ រក ផ្លូវ ប្រតិបត្តិ ក្នុង ព្រះពុទ្ធសាសនាគឺខំប្រឹងពិនិត្យមើលគម្ពីរដីកា ហើយ ស្រង់យកមក ។ ផ្លូវប្រតិបត្តិ ត្រង់ណាដែល មានការ ឃ្លៀង ឃ្លាត ខ្លះក៏កែតម្រូវឲ្យ បាន ត្រឹម ត្រូវឡើង ត្រង់ណា ដែល គួរ ប្រែ ជាភាសាជាតិក៏ប្រែ ទៅដើម្បីឲ្យ អ្នកប្រតិបត្តិបានដឹងសេចក្តីច្បាស់ លាស់ កុំឲ្យ ភាន់ច្រឡំក្នុងការ ប្រតិបត្តិតែប៉ុណ្ណោះឯងគ្មានបានបង្កើតធម៌ថ្មីឯណា សោះឡើយ ។

ពាក្យថា«ធម៌ចាស់ធម៌ថ្មី»នេះជាពាក្យអពមង្គលមួយដ៏ជាក់ស្តែងជាពាក្យ នាំឲ្យមានការបាក់បែកសាមគ្គីរវាងសង្ឃនិងសង្ឃរវាងគ្រហស្ថនិងគ្រហស្ថឬរវាង សង្ឃនិងគ្រហស្ថឬផងរវាងពុទ្ធបរិស័ទរួមជាតិជាមួយគ្នាតែម្តង ។ »



www.elibraryofcambodia.org

បោកប្រាស់យកប្រាក់ ច្រវាក់ជាប់ក កាន់មារយាទល្អ
សុចរិតត្រឹមត្រូវ ។

៤៩- កូនអើយកស៊ី កកាយធរណី ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា បាតាមតែឪ លើកភ្លឺជិតផ្លូវ
កុំស្រាស់បន្លា ។

៥០- គេដើរយប់ថ្ងៃ មុតជើងមុតដៃ និងចៀសទៅណា
ចៀសចុះជាន់ស្រូវ ហើយជេរផ្តាសា កូនថ្លាយអាណា
ស្រាស់ដើរមិនរួច ។

៥១- កុំយកគល់ឈើ ទៅដាក់ពីលើ ទោះធំទោះតូច
ជំពប់ជើងគេ គេផាងងខូច ជេរដៀលដល់ពូជ
ប្រដូចមេបា ។

៥២- លើកភ្លឺឲ្យធំ បង្ហាប់ឲ្យមាំ គាប់ក្នុកទេវតា
ស្មើបានសង់ស្ពាន នឹងមានផលា កើតសាធុកា
អាយុយឺនវែង ។

៥៣- កូនអើយធរណី បើតាមគម្ពីរ ដែលលោកសម្តែង
កុំចង់បានធំ ក្រមុំឆ្វៀងឆ្វែង កុំលើកដីឯង
លបដាក់ស្រែគេ ។

៥៤- អំពើអាក្រក់ មួយចំរៀកសក់ ធ្លាក់ទៅនិរយេ
បច្ចុប្បន្នលោកិយ កើតក្តីវាយជេរ មិនដែលសុខទេ
ព្រោះដីមួយហត្ថ ។

៥៥- កុំឆ្នួញចង់ទាស់ ខូចខាតរបស់ អស់ទ្រព្យសម្បត្តិ
ចង់គង់ប្រយោជន៍ ឲ្យគេប្រយ័ត្ន ពាក្យឪមួយម៉ាត់
ឲ្យគិតមួយម៉ាង ។

៥៦- សំអាតផ្ចិតផ្ចង់ លើកភ្លឺឲ្យត្រង់ កុំលើកឲ្យគោង
អ្នកកុំប្រហែស ក្រែងមានប្រហោង លើកមើលទំនង
ទំនាបទឹកហូរ ។



www.elibraryofcambodia.org

៥៧- ចំនួនទឹកស្និង   ទឹកព្រែកទឹកបឹង   ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ   ត្រូវបើកបង្ហូរ   អ្នកក្រោមកុំថ្នូរ
បន្ទូរហួសទៅ។
៥៨- រាំងរែងថ្ងៃយប់   ឆាប់លើកឆប់ទប់   កុំឲ្យបាក់ជ្រៅ
កក្កិកចេញខ្យល់   តម្កល់ទឹកនៅ   បើចង់បានស្រូវ
ស្រេចនៅត្រឹមថៃ។
៥៩- កុំយកគ្រាប់ត្នោត   ទៅដាំទៅដោត   ពីលើភ្លឺស្រែ
ចិត្តគិតប្រមាណ   ចង់បានផ្កាផ្លែ   ដាំដុះបង្វែ
បង្កិនខ្លួនឯង។
៦០- ដល់ត្នោតឡើងគល់   ឡើងកើតនាំទូល់   ធាងលូតឡើងវែង
ភ្លុះរាស់ផប់នឹម   ក្របីផាប់ស្នែង   ទទើសទទែង
ភ្ជួរឆ្វេងមិនត្រូវ។
៦១- ដល់ត្នោតរាធំ   មានស្លឹករាទុំ   រាជ្រុះក្នុងស្រូវ
ស្រែឆ្ងាយពីផ្ទះ   ឃ្លាតណាស់ពីផ្លូវ   ទំរាំតែទៅ
ល្ហយស្រូវអស់។
៦២- កូនអើយកុំឆោត   បើចង់បានត្នោត   ដាំដោយរៀនកោះ
ដីទួលចំការ   ឯណាចន្លោះ   ដាំផារបោះ
ដោយផ្លូវរបង។
៦៣- របៀបចំការ   ថែទាំរក្សា   យូរៗស្រាស់ម្តង
ស្រាស់ឲ្យត្រូវផ្ទះ   មើលគួរសមផង   កុំបើកបុជឆ្លង
ទៅស្រាស់ខាងក្រៅ។ »

- មាតាបិតា ប្រដៅបុត្រធីតា ឲ្យ ចេះ ត្រិះរិះ កុំ ឲ្យ យល់ ខុស ឬ អាង

ខុស ៖

៥៤- ដ្បិតមនុស្សឥឡូវ   យកខុសជាត្រូវ   យកឆ្គងធ្វើជា
អះអាងក្រក់   ឡិកឡក់លីលា   ព្រះហើនពានពារ



www.elibraryofcambodia.org

| | | |
|---|---|---|
| | អាងកាស អាងប្រាក់ ។ | |
| ៥-អាងព្រើល អាងប្រាជ្ញ | អាងកោង អាងកាច | អាងកប់ អាងទាក់ |
| អាងជើង អាងដៃ | អាងវាយ អាងធាក់ | អាងគុកច្រវាក់ |
| | អាងម៉ាស៊ីនកាត់ក ។ | |
| ៦-អាងសុទ្ធតែខុស | កូនអើយចាំចុះ | អាងនោះមិនល្អ |
| អ្នកគិតឲ្យល្អិត | ល្បិតស្រុកលោកក្រ | ប្រមាណដំណើ |
| | តទៀតទៅមុខ ។ | |
| ៧-សាសនានៅឆ្ងាយ | វែងបានសប្បាយ | មានតែកើតទុក្ខ |
| កើតទាន់លោកិយ | ឮតែទំនុក | ដំណែលអាពុក |
| | ចុះចាំគ្រប់គ្នា ។ | |
| ៨-អ្នកជឿពាក្យចាស់ | ជឿចាំឲ្យណាស់ | កុំធ្វើបំពាន |
| អ្នកហ៊ានស្បែកដាច | អ្នកខ្លាចស្បែកជា | មនុស្សចោរប្រោហៀ |
| | កុំយកខ្លួនបៀត ។ | |
| ៩-ឃើញបុកគេល្អ | ទោះបើមានក្រ | យកគេជាញាតិ |
| គួររាប់អ្នកក្រៅ | ផៅអ្នកឯទៀត | រាប់រើសមារយាទ |
| | សុចរិតត្រឹមត្រូវ ។ | |
| ១០-រៀនបទរៀនបាទ | កុំគោងហួសខ្នាត | កុំភ្លាត់ហួសផ្លូវ |
| កុំភ្លើនភ្លេចម៉ែ | កុំប្រែហួសឪ | ឃើញចាស់សក់ស្កូវ |
| | កុំសួរមើលងាយ ។ | |
| ១១-បន្ទន់អត្តា | ខ្លាចមេខ្លាចបា | ខ្លាចតាខ្លាចយាយ |
| បំរើមពាក្យគ្រូ | ប្រយ័ត្នស្ដេចទាយ | ពាក្យពិតទំនាយ |
| | រលាយកេរ្តិ៍ឈ្មោះ ។ | |
| ១២-ពាក្យស្ដេចពាក្យគ្រូ | មានប្រែមានដូរ | កម្រពីរោះ |
| ជូនទាយឲ្យទាប | ជូនទាយឲ្យខ្ពស់ | ទាយឲ្យសក្តិយស |
| | ទាយចុះកុំខឹង ។ | |
| ១៣-បម្រើមើលភេទ | ចំណាំព្រះនេត្រ | ហេតុខ្លួនឲ្យដឹង |



www.elibraryofcambodia.org

ខ្លួនខ្ជិលហៃពើល    លោកមើលសំឡឹង    សំឡក់ឲ្យប្រឹង
ទំប្រឹកស្រូតរៀន ។

១៤-បម្រើមើលពុក    ប្រាជ្ញាឲ្យមុត    ស្មារតីឲ្យមាន
បើខ្លៅឲ្យប្រាជ្ញ    បើខ្លាចឲ្យហ៊ាន    ចង់បានរៀន
កុំរៀនកុំខ្មាស ។

១៥-ពុកលោកជាធំ    ជ្រងោប៉ុនភ្នំ    ឯងមើលមិនច្បាស់
បម្រើលោកណា    លោកហ្នឹងជាម្ចាស់    លោកស្អប់អ្វីណាស់
ប្រាសចោលឲ្យឆ្ងាយ ។

១៦-កុំឈមឈរជិត    កុំយកធ្វើមិត្រ    ភ្លាត់ខ្លួនអន្តរាយ
បើប្រពន្ធកូន    បងប្អូនចៅហ្វាយ    អាពុកឬម្ដាយ
ឱនកាយប្រតិបត្តិ ។

១៧-អ្នកកុំមើលងាយ    ឃើញគេរីករាយ    ព្រួញខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ    កូនចៅមហាក្សត្រ    ស្មើថ្លើមប្រមាត់
ប្រមាថមិនបាន ។

១៨-ទោះអ្នកដទៃ    អ្នកព្រៀងអ្នកព្រៃ    ដែលលោករាប់អាន
កុំថាតែមនុស្ស    ទោះសត្វតិរច្ឆាន    ឯងស្អប់ប៉ុន្មាន
កុំហ៊ានប្រមាថ ។

១៩-របស់ឬទ្រព្យ    ដែលជាសំអប់    កុំបាច់សំអាត
ទ្រព្យណាសំឡាញ់    អស់អញឱហាត    ចូរចៅសង្កាត
ជួយថែរក្សា ។

២០-កុំជិះកុំជាន់    ស្មៅផ្លូវអាចម៍មាន់    ពាក្យចាស់ឧបមា
បុរាណហៅផ្លូវ    ពីរបីប្រការ    កុំស៊ីត្រង់ណា
ជុះដាក់ត្រង់ហ្នឹង ។

២១-សាច់សាលោហិត    កុំផ្ដួលផ្ដេកផ្ដិត    ផ្ដុំទោសកើតប៉ុង
អាពុកផ្ដែផ្ដាំ    ចូរចាំចេះថ្លឹង    សាច់ថ្លើមស្ងួតឆ្អឹង
និងស្បែកខាងក្រៅ ។



www.elibraryofcambodia.org

២២-សាច់ស្អុតក្នុងខ្លួន　ទុកស្មើបងប្អូន　ប្រពន្ធកូនចៅ
សរសៃនិងស្បែក　ចែកជាញាតិនៅ　ខ្ញុំស្រីខាងក្រៅ
ជាស្មៅអាចម៍មាន់ ។
២៣-ស្រីខ្ញុំកំដរ　បើឃើញរូបល្អ　កុំលលូនលាន់
កុំលួចលបលេង　ក្រែងម្ចាស់គេទាន់　កុំភប់កុំភន់
អាប់អន់អាត្មា ។
២៤-បើអ្នកមានយស　មានសក្តិខ្ពង់ខ្ពស់　ពាប់និងរាជការ
ធ្វើធំធ្វើថី　មន្ត្រីមានត្រា　ព្រះហ្លួងឱកញ៉ា
សាលាកុង្ស៊ុយ ។
២៥-ចេះឲ្យរប់ពារាំង　កុំភ្លេចសច្ចំ　កតញ្ញូខន្តី
កុំភ្លើងហួសមាឌ　ភ្លេចញាតិប្រុសស្រី　ជំនុំគាត់ក្តី
យកឧបេក្ខា ។ ...»

- **សេចក្តី ទូន្មាន ក្នុង ការរើស គូ ស្រករ ÷**

«៧៩-កូនអើយអ្នកចាំ　កុំជឿខែឆ្នាំ　កុំជឿតម្រា
ពាក្យក្បួនតម្រាយ　កើតពីមនុស្សចារ　ពីដូនពីតា
ចារតាមសម្គាល់ ។
៨០-អ្នកជឿតែពូជ　អម្បូរធ្លាប់ខូច　រខូចរៀងរាល់
ពូជមានរមាន　ពូជទាល់រទាល់　កុសលអកុសល
យើងមើលមិនដាក់ ។
៨១-ប្រពន្ធនិងប្តី　អាយុវែងខ្លី　យើងមើលឃើញច្បាស់
កុំយកពូជល្បែង　ពូជភ្លេងអាក្ខ　បើម្ល៉ែបង់ប្រាក់
រកអាយុវែង ។
៨២-អម្បូរពង្សពូជ　ត្រកូលធ្លាប់ខូច　រខូចមិនលែង



www.elibraryofcambodia.org

ពូជទោរស្រៀ　យកប្ដីចិត្តឯង　មិនគិតកោតក្រែង

ខ្លាចចិត្តមេបា ។

៨៣- កូនចៅស្រៀ　បើនឹងយកប្ដី　ឲ្យមើលកិរិយា

មួយភ្លេងអារក្ខ　មួយអ្នកបាណា　មួយអ្នកផឹកស្រា

មួយអ្នកចង់ស៊ី ។ »(ច្បាប់ល្បើកថ្មី)

- ការពាក់ព័ន្ធ ទំនាក់ទំនង រវាង ខ្មែរ យើង និង ជន បរទេស មាន ចិន-យួន ជា ដើម ដូច មាន សម្រង់ ពី «បណ្ដាំ ក្រមង៉ុយ» (បណ្ណាគារ គីម-សេង):-

«៣៨- ខ្មែរអាងស្រូវក្នុងដោក
ដូរផ្លែផោកអាក្រក់ល្អ
អស់ស្រូវទៅជាក្រ
អង្ករចិនជឿស្រូវឯង ។

៣៩- ធ្វើស្រែនឿយហត់ណាស់
ចិនទៅផ្ទះដេកចាំខែង
ផ្ទះចិនពីរបីល្វែង
មានកន្លែងជង្រុកស្រូវ ។

៤០- ជាតិខ្មែរឥតគំនិត
ស៊ីមិនគិតមើលខុសត្រូវ
ជឿចិនរាល់រឿង
កេរ្តិ៍ម៉ែឪចិនរូសអស់ ។

៤១- ចិនមកពីស្រុកនាយ
មានសំពាយជារបស់
មិនទាន់ចេះខ្មែរសោះ
គ្មានកេរ្តិ៍កោះស្រែចម្ការ ។



www.elibraryofcambodia.org

៤២- កកើតចង្ក្រានឆ្នាំង
ស៊ីកំបោរនិងប្រាផ្លា
អម្រែកជិះលើស្មា
បានម្លូស្លាជាដើមទុន ។

៤៣- ទំនិញមានគ្រប់មុខ
ផ្សាល់ផ្ទះទុកដាក់ដោយធុន
ចិនរីកមិនរំលងតុន
ស្រូវពោតផន់ពេញជង្រុក ។

៤៤- ឈប់រីកដេកអង្គុយ
រើបកាក់លុយប្រមូលទុក
ឳទិនស្រាពីមុខ
ទុកជាផ្អាក់ទាក់កខ្មែរ ។

៤៥- ចិនច្រើនខ្លាំងចិត្តខ្មៅ
កន្លែងតៅធ្វើជាស្រែ
គ្មានក្បាលគ្មានអង្រែ
អង្ករខ្មែរចូលប៉ោះចិន ។

៤៦- ជាតិខ្មែរច្រើនឥតខ្លាស
ស្មុកស្រាណាស់ផឹកជឿសិន
គំនិតគិតមិនឆ្អិន
ផឹកបន្តិនតែទ្រៀងង ។

៤៧- កំណើតអ្នកផឹកស្រា
បែកប្រាជ្ញាច្រើនកន្លែង
អ្នកប្រឹងបែកខាងល្បែង
មិនគិតក្រែងខ្លាចខ្លួនក្រ ។

៤៨- អាម្យ៉ាងបែកលួចឆក់
ប៉ះយាទអគ្រក់មិនបានល្អ



www.elibraryofcambodia.org

ផឹកពោលការបរ
ចិនទាក់កធ្វើខ្ញុំបាន ។
៤៩- មិនដឹងខ្លួនជាឆ្កួត
និយាយអួតប្រាប់សន្តាន
ជាចិនធ្លាប់រាប់អាន
ផឹកស្ទើរម៉ាន់ចិនមិនគិត ។
៥០- ជាចិនមិនចេះកាញ់
ប្រាប់សំនុញពួកម៉ាកមិត្ត
គូកនទោះឆ្ងាយជិត
តែប្រមូលលុយឲ្យចិន ។
៥១- ត្រូវស្រាចង់ស៊ីឆ្ងាញ់
ផុំឆាខ្លាញ់បក់ឆ្អុលក្លិន
ឃើញបាយសម្លឆ្អិន
ឆ្អប់ចិត្តចិនយកបាយស៊ី ។
៥២- ផឹកទឹកបាយត្រឡោក
មះយាទទាបថោកបុកសៀធី
ចិនប្រើតែងរំកលី
ស៊ីញយៗ ចិនមើលងាយ ។
៥៣- ជាតិចិនកំណាញ់ស្វិត
និកក្នុងចិត្តមិននិយាយ
អាយ៉ាទខ្មែរច្រើនរាយមាយ
លោភទ្រព្យអភ័ព្វខ្លួន ។
៥៤- ស៊ីឆ្ងាញ់ឆ្អែតស្កប់ស្កល់
ទាបថោកដល់ប្រពន្ធកូន
អាប់យសទាំងបងប្អូន
ដល់តាដូនពូជពង្សខ្មែរ ។



www.elibraryofcambodia.org

៨៥- ជាតិចិនសុទ្ធសឹងស
មានទល់ក្រឡុតខ្លះដែរ
ស៊ីផឹកស៊ុទ្ធតាមខែ
គមព្វាយខ្មែរមិនស៊ីសេះ ។
៨៦- មានផ្ទះមានដំណាំ
កាប់ដីដាំដោយគៀនកោះ
ដំឡូងត្រាវទេកម្ចាស់
ស៊ីមិនអស់ទុកលក់ដូរ ។ »[136]

- ទំនាក់ទំនងខ្មែរនឹងជនជាតិយួន -

«៦៤- ត្រីងៀតផ្អកប្រហុក ខ្មែរគ្រប់ស្រុកទិញដូរយួន
អំបិលធ្លប់ក្រមួន ពិតាដូនតែងដូរទិញ ។ »[137]
(បណ្ដាំក្រមង៉ុយ)

-ទំនាក់ទំនងខ្មែរនឹងជនជាតិចិន-យួនៈ

«៩៩- អ្នកខ្លិយគេជឿសំលមាំមួន ពាក្យក្បួនតម្រាគេមិនរាប់
គេថាមិនរស់ពីព្រោះធ្លាប់ មិនងាប់ពីព្រោះមិនធ្វើធ្មេញ ។
១០០- យ៉ាងដូចចិនយួននៅងាក់ផ្សារ ស្រុកចំស្រែចំការក្រុងភ្នំពេញ
កើតឡើងដុះសក់មិនកោរវិញ រស់ដូរទិញអង្គុយលក់ ។
១០១- ប៉ុន្តែជាតិចិនល្មោភស៊ីសាច់ តមដាច់មិនដែលស៊ីព្រហក់
ខ្មែរៗប្រហែលខ្ទះម្លេសជ្រក់ ទូលស្រូវកន្ទក់ទៅដូរចិន ។

[136] ចំពោះប្រធានបទចិននៅកម្ពុជា សូមអាន៖ SIN Kim Suy, *Les Chinois du Cambodge: Etude sociologique*, thèse de doctorat de 3ème cycle, Paris, INALCO, 1985, 302 p.; WILLMOTT W.E., *The Political Structure of Chinese community in Cambodia*, Univesity of London, The Athlone Press,1970, 231 p., *id. The Chinese in Cambodia*, Vancouver, University of British Columbia, 1967, 111 p.

[137] ចំពោះប្រធានបទយួននៅកម្ពុជា សូមអាននិក្ខេបបទ KHY Phanra, *La communauté vietnamienne au Cambodge à l'époque du protectorat français (1863-1955)*, thèse de doctorat de 3ème cycle, Université Paris 3, 1974, 556 p.



www.elibraryofcambodia.org

១០២-ហេតុតែជាខ្មែរសម្បុរខ្មៅ គំនិតគិតនៅមិនសូវឆ្អិន
រកស៊ីមិនឆ្អែតជឿតែសិន អាថិករកិនទារទាល់បាន»
(សេចក្ដីរំលឹកដាស់តឿន)

## - ការពាក់ព័ន្ធ នឹង អាករ ពន្ធដារ ដីធ្លី÷

«១៨០-កាលមុននេះមក ខែបុស្សឆ្នាំរកា លែងមានព្រាផ្សា
បានតែមេស្រុក រាស់បែងក្រឡា ដីមួយហិកតា
ត្រូវសែសិបចាំង ។[138]
១៨១-វង្វាន់មេស្រុក ត្រូវហុតមួយទុក ដប់ជូនបារាំង
ទោះលល់ប៉ុយវ៉ឺ បង្ខូរដាក់ឃ្លាំង ពូជពីរកន្លាំង
កំជាប់ពន្ធដែរ ។
១៨២-គ្មានធូរគ្មានតឹង កូនអើយទំប្រឹង ជាតិឯងជាខ្មែរ
ក្មេងប្រុសដំទង់ នៅក្នុងឪម៉ែ រាជការប្រែតប្រែ
ចាំឲ្យបង់ប្រាក់ ។
១៨៣-កូនចៅប្រុសស្រី កើតមកលើដី ទំរកលុយកាក់
បានហើយប្រឹងខំ ផ្គុំគ្នាទុកដាក់ គ្រាន់ទិញស្លៀកពាក់
បង់ថ្លៃរាជការ ។ »(ច្បាប់ល្បើកថ្មី)

ទាំងនេះបានសេចក្ដីថា នាឆ្នាំ គ.ស. ១៩២០-១៩២១ នោះ រដ្ឋអំណាចអាណានិគម ចាប់គាស់រំលែងដីធ្លីឲ្យប្រជាកសិករខ្មែរ បង់ពន្ធដារ បំពេញឃ្លាំងរដ្ឋបាលបារាំងសម័យនោះ ។ ពន្ធអាករនេះទៀតសោត ហាក់ដូចជាធ្ងន់ធ្ងរដល់ប្រជារាស្ត្រខ្មែរជាខ្លាំង ដែលជាហេតុនាំឲ្យមានការបះបោរប្រឆាំងនឹងរដ្ឋអំណាចបារាំង ហើយប្រជាជននៅឃុំក្រាំងលាវបានសម្លាប់លោក បារដេស ជារេស៊ីដង់នៅខែត្រកំពង់

[138] ឆ្នាំរកាទីនេះគឺត្រូវនឹង គ.ស. ១៩២០ ឬ ១៩២១ ព្រោះភិរម្យង៉ុយ គាត់តែងច្បាប់នេះនៅឆ្នាំចគឺត្រូវនឹង គ.ស. ១៩២២ ។ ឯឆ្នាំរកាគឺ ២ ឆ្នាំមុនឆ្នាំចដូចនេះត្រូវនឹង គ.ស. ១៩២០ ឬ ១៩២១ ។



www.elibraryofcambodia.org

ឆ្នាំង ហើយ និង អ្នកបកប្រែ ភាសា ម្នាក់ទៀត ឈ្មោះ សួន ព្រម ទាំង ទាហាន រក្សា ស្រុក ម្នាក់ ឈ្មោះ ឡាច ដែល តាម បារាំង នាថ្ងៃ ១៨ មេសា ១៩២៥ នោះ ។ «ព្រឹត្តការណ៍ ១៨ មេសា ១៩២៥» របស់ ប្រជាជន នៅ ឃុំ ក្រាំងលាវ ក្នុង ខេត្ត កំពង់ឆ្នាំង ក៏ បាន បន្សល់ ទុក នូវ អនុស្សាវរីយ៍ ដ៏ជូរចត់ មួយ ដែរ ដល់ អ្នកស្រុក ក្រាំង លាវ ព្រោះ ចាប់ ពី ព្រឹត្តិការណ៍ នោះ មក ឃុំ ក្រាំង លាវ ក្លាយ ឈ្មោះ ជា «ភូមិតិរច្ឆាន» រហូត ដល់ ថ្ងៃ ១៣ រោចខែមេឃ ឆ្នាំឆ្លូវ សប្តស័ក (ត្រូវនឹងថ្ងៃ៩កុម្ភៈ១៩២៦) ។ [139]

## - ក្រមង៉ុយ នឹង ព្រះពុទ្ធសាសនា

គោល ធំ បំផុត ដែល ដុះ ជាប់ ក្នុង អារម្មណ៍ គំនិត និង ចំណេះ ចេះដឹង របស់ ភិរម្យ ង៉ុយ គឺ ព្រះពុទ្ធសាសនា ។ ហេតុ នេះ ហើយ ស្នាដៃ លោក ទាំង អស់ ឈរ លើ មនោគមវិជ្ជាពុទ្ធសាសនា ជាពិសេស គឺពុទ្ធសាសនា ថេរវាទ បែប ទំនើបនិយម ដែល មាន ព្រះគ្រូសង្ឃសត្ថា ជួន-ណាត, ព្រះគ្រូសង្ឃវិជ្ជា ហួត-តាត និង ក្រុម នៅ ពុទ្ធសាសនបណ្ឌិត្យ ជា អ្នកគាំទ្រ យ៉ាង មុត មាំ ជំនាន់ នោះ ជា ហេតុ នាំឲ្យ មាន ទំនាស់ ទំនុយ នឹង សម្តេច សង្ឃរាជ ព្រះនាម ទៀង និង ពួក ធម៌ «ចាស់» ។ [140] ហេតុ នេះ ហើយ បាន ជា លោក តាក់ តែង កំណាព្យ ជា ច្បាប់ ពិសេស មួយ សម្រាប់ ទូន្មាន ប្រៀន ប្រដៅ ព្រះសង្ឃ ផ្ទាល់ តែម្តង មាន ចំណង ជើង ថា «ល្បើក ច្បាប់សង្ឃ» ។ យើង ត្រូវ អាន បន្ថែម ខ្លះៗ នូវ *សមណវិន័យ* និង *វិនយ បិដក* ដើម្បី និង អាច យល់ និង ពន្យល់

---

[139] សូម អាន ឌិក-គាម និង ឡើក-អំ, *ភូមិ តិរច្ឆាន*, ភ្នំពេញ, ១៩៧១, ៩៣ ទំព័រ (បោះពុម្ព ឡើង វិញ ដោយ ក្រសួងអប់រំ ភ្នំពេញ, គ្រឹះស្ថាន បោះពុម្ពផ្សាយអប់រំ, ១៩៨៧) ។ CHANDLER David P., "The Assassination of Resident Bardez (1925): A Premonition of Revolt in colonial Cambodia", *Journal of The Siam Society*, 1982, vol. 70 parts 1+2, p. 35-49.

[140] សូម អាន ហួត-តាត, *កល្យាណមិត្តរបស់ខ្ញុំ*, ភ្នំពេញ, ១៩៧០, ៧០ ទំព័រ ។



www.elibraryofcambodia.org

ល្បើកច្បាប់ នេះ ឲ្យ ស៊ី ជម្រៅ ច្បាស់លាស់ ទៅ បាន ។ [141] តាម ការសង្កេត យើង ឃើញថា «ល្បើកច្បាប់សង្ឃ» នេះ មាន សេចក្ដីដូចគ្នា ដោយ អន្លើ នឹង «ពាក្យកាព្យ ប្រដៅជនប្រុស-ស្រី» ខាងលើ ។

[141] សូម អាន ៖ គិម-ប៊ិល (ធម្មកោសល្លោ), *វិនយសង្គហៈ*, ដដែល ។ ជួន-ណាត (ព្រះគ្រូសង្ឃសត្ថា), ហួត-តាត (ព្រះគ្រូសង្ឃវិជ្ជា), អ៊ុំ-ស៊ូរ (ព្រះគ្រូ វិមលប្បញ្ញា), *សមណវិន័យ*, ដដែល ។ អ៊ុំ-ស៊ូរ (ព្រះគ្រូ វិមលប្បញ្ញា), និង ជួន-ណាត (ព្រះគ្រូសង្ឃសត្ថា), *ក្រែប្រណាមសង្ខេបនិងគិហិវិន័យសង្ខេប*, ដដែល ។



www.elibraryofcambodia.org

# ស្នារដៃក្រមង៉ុយ



www.elibraryofcambodia.org

# ច្បាប់ ល្បើក ថ្មី

១-ចំអ្នកព្រះភិក្ខុ ភាសារ៉ូខ្ញុំ បង្គំនឹកគុណ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន គុណគាប់មហាធ្ងន់
មាតាបិតា ។

២-ឧបជ្ឈាយ៍ ជាធំ កាលចាប់ដៃខ្ញុំ ឲ្យធម៌កេសា
អនុសាសន៍ ព្រះកម្មវាចា គុណគ្រូអក្សរា
ទាំងសាមសិបបី ។

៣-ខែចេត្រឆ្នាំថោះ ចត្វាស័កក កត់គិតកាព្យថ្មី
លើកច្បាប់ប្រដៅ កូនចៅប្រុសស្រី តូចក្តីធំក្តី
ចូរស្តាប់គ្រប់គ្នា ។

៤-ឆ្អឹកមនុស្សឥឡូវ យកខុសជាត្រូវ យកឆ្គងធ្វើជា
អំពើអាក្រក់ ឡើកឡក់លីលា ព្រហើនពានពារ
អាងកាស អាងប្រាក់ ។

៥-អាងព្រើល អាងប្រាជ្ញ អាងកោង អាងកាច អាងកាប់ អាងចាក់
អាងជើង អាងដៃ អាងវាយ អាងធាក់ អាងគុកច្រវាក់
អាងម៉ាស៊ីនកាត់ក ។

៦-អាងសុទ្ធតែខុស កូនអើយចាំចុះ អាងនោះមិនល្អ
អ្នកគិតឲ្យល្អិត ឆ្អឹកស្រុកលោកក្រ ប្រមាណដំណ
កទៀតទៅមុខ ។

៧-សាសនានៅឆ្ងាយ លែងបានសប្បាយ មានតែកើតទុក្ខ
កើតទាស់លោកិយ ឮតែទំនុក ដំណែលអាពុក
ចូរចាំគ្រប់គ្នា ។



www.elibraryofcambodia.org

៨- អ្នកជឿពាក្យចាស់ ជឿចាំឲ្យណាស់ កុំធ្វើបំពាន
អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកជា មនុស្សចោរប៉ោរប៉ៀ
កុំយកខ្លួនបៀត ។

៩- ឃើញឫកគេល្អ ទោះបីមានក្រ យកគេជាញាតិ
គួររាប់អ្នកក្រៅ ជាងអ្នកឯទៀត រាបរើសមារយាទ
សុចរិតត្រឹមត្រូវ ។

១០- រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ហួសផ្លូវ
កុំភ្លើនភ្លេចម៉ែ កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ
កុំសូរមើលងាយ ។

១១- បន្ទន់អាត្មា ខ្លាចមេខ្លាចបា ខ្លាចតាខ្លាចយាយ
បំរើមហាក្សត្រ ប្រយ័ត្នស្តេចទាយ ពាក្យពិតទំនាយ
រលាយកេរ្តិ៍ឈ្មោះ ។

១២- ពាក្យស្តេចពាក្យគ្រូ មានប្រែមានដូរ កម្រពីរោះ
ជួនទាយឲ្យទាប ជួនទាយឲ្យខ្ពស់ ទាយឲ្យសក្តិយស
ទាយចុះកុំខឹង ។

១៣- បម្រើមើលភេទ ចំណាំព្រះនេត្រ ហេតុខ្លួនឲ្យដឹង
ខ្លួនខ្មួលហៃព្រើល លោកមើលសំឡឹង សំឡក់ឲ្យប្រឹង
ខំប្រិតសូត្ររៀន ។

១៤- បម្រើមើលពុត ប្រាជ្ញាឲ្យមុត ស្មារតីឲ្យមាន
បើខ្លៅឲ្យប្រាជ្ញ បើខ្លាចឲ្យហ៊ាន ចង់បានរបៀន
កុំអៀនកុំខ្មាស ។

១៥- ពុតលោកជាធំ ជ្រងោប៉ុនភ្នំ ឯងមើលមិនច្បាស់
បម្រើលោកណា លោកហ្នឹងជាម្ចាស់ លោកស្អប់ស្អីណាស់
ប្រាសចោលឲ្យឆ្ងាយ ។



www.elibraryofcambodia.org

១៦-កុំឈមឈរជិត	កុំយកធ្វើមិត្រ	ភ្លាត់ខ្លួនអន្តរាយ
បើប្រពន្ធកូន	បងប្អូនទៅហើយ	អាពុកឬម្ដាយ
ឱនកាយប្រតិបត្តិ ។

១៧-អ្នកកុំមើលងាយ	ឃើញគេរីករាយ	ជ្រួញខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ	កូនចៅមហាក្សត្រ	ស្មើថ្លើមប្រមាត់
ប្រមាថមិនបាន ។

១៨-ទោះអ្នកដទៃ	អ្នករៀងអ្នកព្រៃ	ដែលលោករាប់អាន
កុំថាតែមនុស្ស	ទោះសត្វតិរច្ឆាន	ឯងស្គាល់ប៉ុន្មាន
កុំហានប្រមាថ ។

១៩-របស់ឬទ្រព្យ	ដែលជាសំអប់	កុំបាច់សំអាត
ទ្រព្យណាសំឡាញ់	អស់អញ្ញឱហាត	ចូរចៅសង្កាត
ជួយថែរក្សា ។

២០-កុំផិះកុំផាន់	ស្មៅផ្អិអាចម៍មាន់	ពាក្យចាស់ឧបមា
បុរាណហៅផ្អី	ពីរបីប្រការ	កុំស៊ីត្រង់ណា
ផុះដាក់ត្រង់ហ្នឹង ។

២១-សាច់សាលោហិត	កុំផ្ដួលផ្ដេកផ្ដិត	ផ្ដួចទោសកើតប៉ុង
អាពុកផ្ដែផ្ដាំ	ចូរចាំចេះថ្លឹង	សាច់ថ្លើមសួតឆ្អឹង
និងស្បែកខាងក្រៅ ។

២២-សាច់សួតក្នុងខ្លួន	ទុកស្មើបងប្អូន	ប្រពន្ធកូនចៅ
សរសៃនិងស្បែក	ថែកជាញាតិផៅ	ខ្ញុំស្រីខាងក្រៅ
ជាស្មៅអាចម៍មាន់ ។

២៣-ស្រីខ្ញុំកំដរ	បើឃើញរូបល្អ	កុំលលួនលាន់
កុំល្មួចលបលេង	ក្រែងម្ចាស់គេទាន់	កុំគប់កុំភាន់
អាប់អន់អាត្មា ។


www.elibraryofcambodia.org

| | | |
|---|---|---|
| ២៤-បើអ្នកមានយស | មានសក្តិខ្ពង់ខ្ពស់ | គាប់នឹងរាជការ |
| ធ្វើធំធ្វើធី | មន្ត្រីមានត្រា | ព្រះហ្លួងឧកញ៉ា |
| | សាលាកុង្ស៊ីយ៍ ។ | |
| ២៥-ផេះឡាប់បារាំង | កុំភ្លេចសច្ចំ | កតញ្ញូខន្តី |
| កុំឆ្មើងហួសមាឌ | ភ្លេចញាតិប្រុសស្រី | ជំនុំកាត់ក្តី |
| | យកឱ្យបេក្ខា ។ | |
| ២៦-កុំកាន់ស័ហលោ | កុំកាន់លោភា | ទោសាមោហា |
| កុំជក់អាភៀន | កុំឃ្លានផឹកស្រា | កុំស្តាប់ខាងណា |
| | សច្ចាយកត្រង់ ។ | |
| ២៧-លួងលោមពិសោធ | កុំឆបញ្ឆោត | បញ្ចូលឲ្យបង់ |
| ឲ្យបែកឲ្យបាក់ | ពាក្យសត្យពាក្យសង្ឃ | កូនអើយផ្ចិតផ្ចង់ |
| | តម្រង់ស្មារតី ។ | |
| ២៨-កុំភ្លើនឃើញប្រាក់ | កុំភ្លើភ្លាត់សក្តិ | ធ្លាក់ទៅអវិចី |
| កាន់ធម៌ទសពិធ | រីតឡើងរាសី | គាប់ពីលោកិយ |
| | ដល់បរលោកនាយ ។ | |
| ២៩-អ្នកក្តីជាភ្លើង | កុំកាត់កាន់ជើង | អ្នកម្ខាងមើលងាយ |
| ចៅក្រមដាទិក | រពុករំលាយ | កុំជេរកុំវាយ |
| | បង្ខំនាំខុស ។ | |
| ៣០-ចោរខូចលួចប្លន់ | រីចោរស្ម័គ្រស្មន់ | តណ្ហាស្រីប្រុស |
| កុំស្តាប់ខាងណោះ | បញ្ចេះខាងណោះ | លួងលោមបញ្ចុះ |
| | បញ្ចូលចិត្តក្តី ។ | |
| ៣១-កុំដុតឲ្យក្តៅ | បើឃើញគ្នាខ្លៅ | ប្រាជ្ញាគ្នាខ្លី |
| កុំឃ្លានប្រាក់ប្រុស | បន្ទុះខាងស្រី | បើកាន់ច្បាប់ថ្មី |
| | កុំចោលច្បាប់ចាស់ ។ | |



www.elibraryofcambodia.org

៣២-កុំដៀលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រឡាស់
ក្រឡេកឃើញគុណ ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់
កុំគ្រោះអ្នកក្រ ។

៣៣-អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូសូត្រអក្សរ
កុំចាប់ដៃទាញ គំនាប់ងក់ក កុំជជែកត
ស្មើមិត្រសំឡាញ់ ។

៣៤-វាស្ត្រូវគ់ចូលជ្រក សួរសាកទៅមក កុំអើឯងអញ
ពាក្យពុំពីរោះ គេកើតមួកួញ់ គេដៀលផ្អាលផ្ដាញ់
អន្តរាយកេរ្តិ៍ឈ្មោះ ។

៣៥-កុំឆ្មើងអាងបុណ្យ ស្រដីឲ្យទន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនឹងថ្កើង និងឡើងសក្តិយស កុំឆ្លៀតនាំឈ្លោះ
ព្រះញូងអ្នកធំ ។

៣៦-កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួរគិតប្រមុំ
ទោសគ្នាតិចតួច ផ្ទួចឡើងជាធំ ផ្សែងពូតជាដុំ
ផ្ទុះឆេះជាភ្លើង ។

៣៧-កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន កុំចោលខ្មែរយើង
កុំធ្វើក្រអឺត កុំពើតកុំពើង កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ ។

៣៨-ដោះប្អូកដាក់ឆត្រ ខិនកាយប្រតិបត្តិ លំអុតឱនអង្គ
កុំស៊ីតាមឃ្លាន កុំហ៊ានតាមចង់ កាន់ច្បាប់ស្រុកហ្វូង
កុំបង់សាសនា ។

៣៩-កុំចង់ថ្កើងពេក កុំលើកដំណេក ហួសមេហួសពា
តែងខ្លួនឲ្យល្មម មើលពូជពង្សា សង្កេបនិន្ទិតា
ឡើងផ្កាប់បុណ្យសក្តិ ។



www.elibraryofcambodia.org

៤០- បើទៅជាអាស្ត្រ ប្រាជ្ញាវៃឈ្លាស គួរតែសន្លកឆ្លាក់
ឲ្យឆ្លៀតរកពុន បើធូនសុំដាក់ ទំរកមាសប្រាក់
ឲ្យគ្រាន់ទាន់ចាយ ។

៤១- អជបាវិសេស កូនកុំប្រហែស កុំថ្នមរូបកាយ
ដើរគិតដេកគិត ផ្សញជិតផ្សញឆ្ងាយ បើចង់សប្បាយ
ស្រេចនៅមានទ្រព្យ ។

៤២- អាផ្សហ្លួងពីមុន រកស៊ីរកពុន មានក្រតមេភ័ព្វ
អាផ្សលោកឥឡូវ ត្រូវខំឲ្យញាប់ តែខ្ជិលច្រើនជាប់
ខ្មោះជើងខ្មោះដៃ ។

៤៣- តាំងពីឆ្នាំច ចាំជាដំណ ទំនិញឡើងថ្លៃ
ចងក្បិនឲ្យតឹង ប្រឹងកុំសំចៃ សញ្ជឹងយប់ថ្ងៃ
កុំឲ្យក្រខ្សត់ ។

៤៤- បើចង់ស្រោលខ្លួន រៀនសូត្រឲ្យមួន ឲ្យមាំឲ្យស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងើល្ងើតតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ ។

៤៥- កុំថ្នមកម្លាំង កាប់ជីកចូកចាំង កុំថាវងាក្តៅ
រៀនស៊ូឲ្យអ៊ឹន កុំឲ្យខ្លាចនៅ កុំដេកតែខ្លៅ
ក្រក្រៀសណ្ដាប់ ។

៤៦- បើល្ងង់ឲ្យចេះ រករៀនតម្រិះ រិះរកតម្រាប់
ឥន្ទ្រីយឆ្វេងស្តាំ កុំចាំគេប្រាប់ រៀនស្ដីរៀនស្ដាប់
រៀនមើលឲ្យស្ពង ។

៤៧- កើតមកជាមនុស្ស ទាំងស្រីទាំងប្រុស មិនដែលចេះឯង
បើក្រឲ្យមាន វិញ្ញាណចេះប្រែង គិតគ្រប់កន្លែង
កុំដេកតែក្រ ។



www.elibraryofcambodia.org

៤៨- កុំប្លន់កុំលួច
កុំខ្ជិលកុំខូច
កុំហកឆ្វេរឆ
បោកប្រាសយកប្រាក់
ច្រវាក់ជាប់ក
កាន់មារយាទល្អ
សុចរិតត្រឹមត្រូវ ។

៤៩- កូនអើយកេស៊ី
កកាយធរណី
ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា
ឬតាមតែឪ
លើកភ្លឺជីកផ្លូវ
កុំស្រាស់បន្លា ។

៥០- គេដើរយប់ថ្ងៃ
មុតជើងមុតដៃ
ដឹងចៀសទៅណា
ចៀសចុះជាន់ស្រូវ
ហើយជេរផ្តាសា
កូនម្តាយអាណា
ស្អាសដើរមិនរួច ។

៥១- កុំយកទល់ពេជ
ទៅដាក់ពីលើ
ទោះធំទោះតូច
ជំពប់ជើងគេ
គេថាឯងខូច
ជេរជៀលដល់ពូជ
ប្រដូចមេបា ។

៥២- លើកភ្លឺឲ្យធំ
បង្ហាប់ឲ្យមាំ
គាប់ភ្នែកទេវតា
ស្មើបានសង់ស្ពាន
និងមានផលា
កើតសាធុការ
អាយុយឺនវែង ។

៥៣- កូនអើយធរណី
បើតាមគម្ពីរ
ដែលលោកសម្តែង
កុំចង់បានធំ
ក្រមុំឆ្មៀងឆ្វេង
កុំលើកដីឯង
លបដាក់ស្រែគេ ។

៥៤- អំពើអាក្រក់
មួយចំរៀកសក់
ធ្លាក់ទៅនិរយ
បច្ចុប្បន្នលោកិយ
កើតក្តីរាយជេរ
មិនដែលសុខទេ
ព្រោះដីមួយហត្ថ ។

៥៥- កុំផ្ទួញចង់ទាស់
ខូចខាតរបស់
អស់ទ្រព្យសម្បត្តិ
ចង់តាំងប្រយោជន៍
ឲ្យចេះប្រយ័ត្ន
ពាក្យឪមួយម៉ាត់
ឲ្យគិតមួយម៉ោង ។



www.elibraryofcambodia.org

៥៦-សំអាតផ្តិតផ្តង់ លើកភ្លឺឲ្យត្រង់ កុំលើកឲ្យគោង
អ្នកកុំប្រហែស ក្រែងមានប្រះហោង លើកមើលទំនង
ទំទាបទឹកហូរ ។

៥៧-ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹករលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្ងូរ
បន្ធូរហួសទៅ ។

៥៨-រាំងរឹងថ្ងៃយប់ ឆាប់លើកឆាប់ទប់ កុំឲ្យបាក់ជ្រៅ
កត្តិកចេញខ្យល់ តម្កល់ទឹកនៅ បើចង់បានស្រូវ
ស្រេចនៅត្រឹមថែ ។

៥៩-កុំយកគ្រាប់ត្នោត ទៅដាំទៅដោត ពីលើភ្លឺស្រែ
ចិត្តគិតប្រមាណ ចង់បានផ្កាផ្លែ ដាំដុះបង្កៃ
បង្អិនខ្លួនឯង ។

៦០-ដល់ត្នោតឡើងគល់ ឡើងកើតនាំខ្វល់ ធាងលូតឡើងវែង
ភ្ជួររាស់ជាប់នឹម ក្របីជាប់ស្នែង ទទើសទទែង
ភ្ជួរឆ្វេងមិនត្រូវ ។

៦១-ដល់ត្នោតរាធំ មានស្លឹករាទុំ រាជ្រុះក្នុងស្រូវ
ស្រែឆ្ងាយពីផ្ទះ ឃ្លាតណាស់ពីផ្លូវ ទំរាំតែទៅ
រលួយស្រូវអស់ ។

៦២-កូនអើយកុំឆោត បើចង់បានត្នោត ដាំដោយកៀនកោះ
ដីទួលចំការ ឯណាចន្លោះ ដាំជារបោះ
ជាយផ្លូវរបង ។

៦៣-របៀបចំការ ថែទាំរក្សា យូរៗស្រាស់ម្តង
ស្រាស់ឲ្យត្រូវផ្លូវ មើលគួរសមផង កុំបើកមុជឆ្លង
ទៅស្រាស់ខាងក្រៅ ។



www.elibraryofcambodia.org

៦៤- មិនគាប់ប្រសើរ  របងរារើ  អ្នកម្ខាងរាក្ដៅ
កើតក្ដីកើតក្ដាំ  អស់ខោអស់អាវ  និងអស់ញាតិផៅ
ពីព្រោះចំការ ។

៦៥- មួយទៀតរបង  ជិតផ្លូវអ្នកផង  គេទៅណាៗ
ធ្វើឲ្យទូលាយ  កុំរាយបន្លា  កាប់ឆ្កើសទាត់ឆ្ការ
ឲ្យឆ្ងាយពីផ្លូវ ។

៦៦- កុំធ្វើចង្អៀត  ក្រែងយប់អធ្រាត្រ  ខ្លះមកខ្លះទៅ
ចៀសគ្នាមិនរួច  បើកបរកាត់ស្រូវ  ដេរម្ដាយតាមផ្លូវ
រហូតដល់ផ្ទះ ។

៦៧- កូនអើយអ្នកចាំ  អ្នកកុំចងកម្ម  មានពៀរច្រើនណាស់
ជាតិក្រោយខ្វាក់ខ្វិន  ភខ្វះកខ្វាស  ស្ងួរចោលដីខ្លះ
មិនខាតប៉ុន្មាន ។

៦៨- កុំខ្លាចតែក្រ  ធ្វើបុកមិនល្អ  ច្រើនកើតវិស្ពាន
រអែករអាក  បាត់ញាតិសន្ដាន  ឥតគេរាប់អាន
មានតែគេស្អប់ ។

៦៩- កាន់បុកឲ្យខ្ពស់  ឲ្យខ្ពើមពាក្យឈ្លោះ  ទើបបានជាគាប់
យកឆោតដាក់ខ្លួន  ច្រើនមានគេរាប់  បើខ្លួនឥតទ្រព្យ
កុំផ្ទាប់ហ៊ានខ្ចី ។

៧០- គ្រប់ការសារពើ  ចង្អេរកញ្ចើ  កន្ត្រាំងតៅល្អី
រនាស់រទេះ  គោសេះក្របី  បើបានជាខ្ចី
ខ្ចីប្រាក់គេទិញ ។

៧១- យកមករកស៊ី  ខែមួយខែពីរ  សងប្រាក់គេវិញ
របស់បានយើង  ជាដើងផ្ញួញចេញ  ឯទ្រព្យនោះមិញ



www.elibraryofcambodia.org

ពេញជាទ្រព្យឯង ។

៧២-កុំខ្ចីគេប្រើ តែមួយដំណើរ មិនយូរអង្វែង
ជួនជាបាក់បែក ដំផែកទាស់ទែង សងគេមិនលែង
ចាស់ផ្លាស់ជាថ្មី ។

៧៣-កើតមកជាប្រុស គិតឲ្យសព្វសុស កុំឲ្យសល់អ្វី
បួសរៀនធម៌អាថ៌ សាស្ត្រាបាលី បរលោកលោកីយ
កុំបីចន្លោះ ។

៧៤-សឹកមករកស៊ី កកាយធរណី ធ្វើជាគ្រហស្ថ
កុំហាក់ជឿបុល បំណុលរុំកោះ ច្រើនគេដាក់ខ្នោះ
អស់ស្រែចំការ ។

៧៥-ធ្វើរាស្ត្ររកស៊ី ចិញ្ចឹមគោញី ថែទាំព្យាបាល
ក្រហេតុពីខ្ជិល មានដៀតឱស្សាហ៍ អ្នកមានប្រាជ្ញា
មិនស្មើគំនិត ។

៧៦-កំណើតសំណាង សំណូមសូមសាង កកើតពីគិត
ពីកាលជាតិមុន បុណ្យព្រេងអតីត កើតប្រែគំនិត
ទើបកើតសំណាង ។

៧៧-ឯមនុស្សសំណល់ ល្ងង់ល្ងើងើងឆ្ងល់ ទាស់ទែងក្តុងក្តាំង
ដប់ឆ្នាំនេះហើយ ប្រកាន់ម្យ៉ាងៗ ខ្លះអួតសំណាង
ខ្លះអាងគំនិត ។

៧៨-កូនចៅប្រុសស្រី រកប្រពន្ធប្ដី ឲ្យរកស្រុកជិត
បើរកស្រុកឆ្ងាយ ឲ្យម្ដាយពិនិត្យ ឲ្យត្រឹមត្រូវពិត
ពូជពង្សគេការ ។



www.elibraryofcambodia.org

៧៩-កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា
ពាក្យក្បួនតម្រាយ កើតពីមនុស្សចារ ពីដូនពីតា
ចារតាមសម្គាល់ ។

៨០-អ្នកជឿតែពូជ អម្បូរធ្លាប់ខូច វាខូចរឿងរាល់
ពូជមានវាមាន ពូជទាល់វាទាល់ កុសលអកុសល
យើងមើលមិនជាក់ ។

៨១-ប្រពន្ធនិងប្ដី អាយុវែងខ្លី យើងមើលឃើញច្បាស់
កុំយកពូជល្បែង ពូជភ្លេងអារក្ខ បើម្ដែបង់ប្រាក់
រកអាយុវែង ។

៨២-អម្បូរពង្សពូជ ត្រកូលធ្លាប់ខូច វាខូចមិនលែង
ពូជចោរស្រើប យកប្ដីចិត្តឯង មិនគិតកោតក្រែង
ខ្លាចចិត្តមេបា ។

៨៣-កូនចៅស្រី បើនឹងយកប្ដី ឲ្យមើលកិរិយា
មួយភ្លេងអារក្ខ មួយអ្នកបាណា មួយអ្នកផឹកស្រា
មួយអ្នកចង់ស្រី ។

៨៤-មួយអ្នកក្រមាច់ លេងឆោមលេងអាចម៍ អាយុច្រើនខ្លី
ប្រកាច់ដាច់លក្ខណ៍ ដាន់អារក្ខព្រៃ មួយតឹមន្ត្រី
ធ្វើក្រមជំទប់ ។

៨៥-ជំទយតែដើរ មេស្រុកគេប្រើ ទាំងថ្ងៃទាំងយប់
មានម្នាក់ខ្វះឆ្អែត កម្រមានគ្រប់ មួយទៀតកុំភប់
ជួញប្រាំប្រការ ។

៨៦-ប្រាកដជាខុស លក់សត្វទាំងរស់ បិនចេះអនិច្ចា



www.elibraryofcambodia.org

សព្វសត្វអ៊ឹៗ បក្សីបក្សា ព្រាត់មេព្រាត់បា
ទេវតាលោកលក់ ។

៨៧- លោកិយនេះខ្សត់ យមបាលគេកត់ នៅស្ថាននរក
មួយឫស អាប៉ាំង ប៉ោះបៀគ្រប់មុខ កុនអើយចាំទុក
ក្រគ្រប់ប្រាំបី ។

៨៨- ឯអ្នកទាំងអស់ រកស៊ីម៉េះម៉ស់ ច្រើនជាងស្រីៗ
ប្រាជ្ញានោះវែង គំនិតនោះខ្លី ប្រពន្ធជេរស្ដី
អាងល្បោះបំពាន ។

៨៩- នេះពូជអ្នកក្រ រស់ទាំងគ្រដះ ទាំងអត់ទាំងឃ្លាន
ធ្វើគុណនឹងគេ រកគេសងគ្មាន ហេតុនេះកុំរៀន
ទាំងប្រាំបីផ្លូវ ។

៩០- យ៉ាងនេះនេសាទ មិនដែលសង្វាត ធ្វើស្រែបានស្រូវ
ប្រព្រឹត្តសាងកម្ម ប្រចាំរដូវ វង្វេងខុសត្រូវ
ព្យាយាមសម្លាប់ ។

៩១- អន្ទាក់ជង់ទុក អង្រុតឈ្នាងឆ្នក់ គ្រប់គ្រឿងប្រដាប់
ផ្លុកបៀព្រាំង ទប់បាំងបានចាប់ ចោលស្រូវកណ្ដាប់
កណ្ដៀវកាត់អស់ ។

៩២- កំពប់ខ្ចាត់ខ្ចាយ ខូចខាតអន្តរាយ មិនស្ដាយស្រណោះ
យប់រស់ប្របក់ ចង់បានត្រីរស់ ខែភ្លឺរស់ឆ្លុះ
ដើរដេញសំពោច ។

៩៣- រក់តែសប្បាយ ដើរដេញទន្សាយ ដើរចងសន្ទូច
អំពើអស់នោះ ច្រើនខុះស្រូវពូជ ធ្វើបានតិចតួច



www.elibraryofcambodia.org

អាងជឿគេស៊ី ។

៩៤-កូនអើយបំណុល ទងការជឿបុល មួយឡើងជាពីរ
អ្នកក្លែងអាត្មា ច្រើនទឹមគោញី ធ្វើស្រែមួយពីរ
ធ្វើសោះតែខាន ។

៩៥-ថ្ងៃដេកក្រភ្នាក់ យប់លៀងអាត្មា ឈឺម្កាលសន្តាន
គេស្ដីគេពីង នឹងលេបពុំបាន គេរករាប់អាន
កាលមានធុរៈ ។

៩៦-ផ្ទុំប៉ីក្ដុតទ្រ ស្រែកច្រៀងរយស្ពរ មិនបានលុយកាក់
ឯងពឹងគេវិញ គេគ្មានជំពាក់ ពឹងបានម្ដងៗ
ដោយសារឲ្យថ្លៃ ។

៩៧-ឡើងត្នោតភ្ជួរស្រែ កម្រទាន់គេ ដៀតដេកដល់ថ្ងៃ
ប្រកកាត់ចង់ឆាប់ ផ្ដួលគេពេញថ្លៃ ចំណោះចង្រៃ
នាំខាតធ្វើការ ។

៩៨-ខ្មោចអាត្មា ស្លាប់ដប់រស់ម្នាក់ ផ្ទុយចេកផ្ទុយស្រា
សំពះនឹកគុណ ខ្មោចប្រេតដូនតា មិនដែលអ្នកណា
នឹកគុណអ្នកក្លែង ។

៩៩-ឯអ្នកប្រមឹក ប្រមូលកនផឹក ធ្វើភ្លើននឹងក្មេង
សំដីច្រើនពីង ស្រវឹងវង្វេង ជំហរអ្នកក្មេង
មិនចេះក្រឡត់ ។

១០០-អ្នកទាំងបីពាន ផឹកម៉្លៃលុយមាន ផឹកម៉្លៃលុយអត់
ឯងចេះតែកិន ចិនចេះតែកត់ ផឹកដល់កំណត់
យកស្រែបញ្ចាំ ។



www.elibraryofcambodia.org

១០១-សល់ផ្កាល មួយពីរ　　រយ គោស្វាស៊ី　　មិនគិតខ្លាចកម្ម
ផឹកផ្ទុល ហួសល្បត់　　អត់បាយរាល់ឆ្នាំ　　អស់ស្រែ បញ្ចាំ
បញ្ចាំកូនទៀត ។

១០២-កំណើត ផឹកស្រា　　ផឹកផុតមេត្តា　　ផឹកផ្ទុល ហួសមាឌ
អ្នកមួយ ផឹកស្ទើរ　　ល្វីល្វើ ចេះឡៀត　　ម្យ៉ាងផឹកផុតមារយាទ
ច្រើននៅខ្ញុំចិន ។

១០៣-ចេកទឹកពុះអុស　　រទុញរទុះ　　ចាក់កែវផឹកសិន
ស៊ីឯកខ្ញុំអត់　　សំពត់ខើចក្បិន　　ទំរាំបាយឆ្អិន
មិនដួសហៅស៊ី ។

១០៤-ឆ្ងាញ់តែម្នាក់ឯង　　ឆ្អែតហើយខ្ញុំស្វែង　　ខ្ញុំលើកខ្ញុំលើ
ផងទឹកស្រាចគ្រប់　　ស្រាចខ្ទឹមម្ទេះដី　　ខ្ញុំចិនម៉ៃពីរ
រលេទៅរំងផ្ទះ ។

១០៥-ឯអ្នកចង់ស្រី　　ប្រពន្ធពីរបី　　ចាំងឯអ្នកណាស់
គង់ឯសំពត់　　តែមួយបន្លាស់　　ពាក់អាវចំណាស់
កម្រមានថ្មី ។

១០៦-ផ្ទះលេចរាលល្វើង　　ជញ្ជាំងចងហ៊ីង　　ស្លាផេរបាយស៊ី
ខ្ជិចប្រេងក្រមួន　　ប្ដីស្លាបាទី　　កំឡោះពីរបី
ចោមរោមរៀនស្នេហ៍ ។

១០៧-ឆ្កឿនស្នាល់នេនស្អិទ្ធ　　កើតក្ដីពីក្ដិត　　ព្រួយចិត្តឪម៉ែ
កូនអើយប្រពន្ធ　　អាងមន្តពូកែ　　ក្រៀវឆ្លុតដប់ខែ
អស់ស្រែត្រពាំង ។

១០៨-ធម្មតាប្រពន្ធ　　បានដោយសិល្បមន្ត　　ដោយស្ងាត់កំបាំង



www.elibraryofcambodia.org

គេស៊ីសៀនភ្នែក  បានរែកខ្វះឆ្នាំង  បានឃ្មើកន្លាំង
នៅខ្វះចង្កេះ ។
១០៩-បាននេះខ្វះនោះ  ក្រហេតុពីព្រោះ  អាពុកម្តាយផេះ
បើចុលជំនុំ  មិនរម្យដូចគេ  អង្គុយរេះរេរ
មិនហ៊ានហាលមុខ ។
១១០-នេះពុតអ្នកក្រ  ចាំជាតំណ  តជាទំនុក
ប្រយ័ត្នដំនៀល  គេដៀលអាពុក  កូនអើយចាំទុក
ចាំតកូនចៅ ។
១១១-រក្សាពូជពង្ស  បើខ្លួនល្ងិតល្ងង់  ស្តាប់ចាស់ប្រដៅ
កុំស្អប់អ្នកប្រាជ្ញ  កុំខ្លាចអ្នកខ្លៅ  បើមនុស្សឆោតឆៅ
កូនឯងកុំភប់ ។
១១២-កុំភ័យខ្លាចអត់  មើលឲ្យប្រាកដ  គួរយកគួរឈប់
គួរឈានគួរឈោង  គោងមើលឲ្យគ្រប់  កុំចេះតែងប់
មិនស្គាល់ឪម៉ែ ។
១១៣-រកប្តីប្រពន្ធ  ឲ្យគិតឲ្យគន់  ឲ្យមើលជូនថៃ
ត្រកូលក្រខ្សត់  ប្រាកដតាមខ្សែ  បើដូចឈើផ្លែ
មិនដែលចេះក្លាយ ។
១១៤-ផ្ទះផ្លែមធំតូច  ដើមក្រូចផ្លែក្រូច  ដើមស្វាយផ្លែស្វាយ
ពូជស្រីចោរក្បត់  មិនអត់សាហាយ  ពូជស្រីមេម៉ាយ
ពីម្តាយដល់កូន ។
១១៥-រើសពូជមិនខុស  ពូជសរាំងនឹងប្រុស  ទាំងបងទាំងប្អូន
ពូជសែនមេបា  ពីតាដល់កូន  ពូជល្អសុទ្ធសូន្យ



www.elibraryofcambodia.org

ពីដូនដល់ចៅ ។

១១៦-កេរ្តិ៍មិនក្រ  អាក្រក់ហើយស  មានយាទណ្ឌហើយខ្មៅ
ស្រីក្មេងមានខ្នាស  ចាស់ចង់ប្រដៅ  ប្រដូចកាបផៅ
មិនសួរខុសខាន ។

១១៧-ពាក្យចាស់លោកថា  ធ្វើស្រែធំការ  ស្លាប់មហាសង្ក្រាន្ត
ធ្វើម្តងខុសខាត  ធ្វើម្តងទៀតបាន  ធ្វើតាមប្រមាណ
ប្រមើលទឹកភ្លៀង ។

១១៨-កេរ្តិ៍ប្រពន្ធ  ចូរគយចូរគន់  រើសកេរ្តិ៍របវាង
ពូជថ្លៃល្អមយក  ពូជផោកល្អមវាង  រូបល្អឫកស្លៀង
នាងកុំប្រសព្វ ។

១១៩-ជាតិស្រីនិងប្រុស  បើបានជាខុស  ខុសទាល់ចាស់ងាប់
បើបានរូបល្អ  កម្រមានភ័ព្វ  មានខុសមិនគាប់
ដូរស្រែធំការ ។

១២០-មួយទៀតអ្នកចាំ  អាពុកចំណាំ  ទុកជាគម្រោ
កុំយកគម្រាប់  កុំស្តាប់អាចារ្យ  បើនឹងរៀបការ
កុំការប្រផ្នូន ។

១២១-ប្រផែងលោហ  ឮស្គរឆ្លើយគ្នា  ប្រទប់ប្រទូន
ស្រុកផែកគូបំផង  របងដោយខ្លួន  អាចារ្យអាងក្បួន
ថាសុខសប្បាយ ។

១២២-កូនអើយអ្នកចាំ  យូរណាស់៤ឆ្នាំ  គ្រាត់ប្រាសអន្តរាយ
ច្រើនស្លាប់៣នាក់  រស់ម្នាក់មេម៉ាយ  កូនឃើញតែម្តាយ
មិនឃើញអាពុក ។



www.elibraryofcambodia.org

១២៣-មានកាលស្លាប់ស្រី ស្លាប់ចោលកូនខ្ចី ប្ដីនៅវេងទុក្ខ
យកប្រពន្ធទៀត កប្រពេញមុខ កូននិងអាពុក
បែកគ្នាខ្ចាត់ខ្ចាយ ។

១២៤-កូនចៅស្រីៗ បើនឹងយកប្ដី កុំយកពោះម៉ាយ
ស្វះនៅម្នាក់ឯង បន្ទោងនឹងម្ដាយ អាណិតរូបកាយ
ស្ដាយខ្លួនក្រមុំ ។

១២៥-ហៅប្រុសអភ័ព្វ ប្រពន្ធដើមស្លាប់ មានកូនតូចធំ
យកឯងជាចុង បំរុងតែយំ ច្រើនឈ្មោះជំនុំ
ព្រួយចិត្តម៉ែឪ ។

១២៦-ហៅប្រុសចិត្តពីរ ពិបាករកស៊ី រញ្ជៀរញ្ជូះ
ឯងនឿយស្ទើរស្លាប់ ផ្ដាប់ចិត្តមិនត្រូវ បីបួនរដូវ
ខ្លួនឯងស្លាប់ទៀត ។

១២៧-ចង្រៃខាងប្រុស កូនអើយចាំចុះ កុំយកខ្លួនបៀត
ស្រីណាខំយក ស្រីនោះបង់មារយាទ ប្រុសព្រួយខ្ចប់ធាតុ
ខ្ចប់គ្រប់ទាំងបី ។

១២៨-យកទៀនជាបួន គ្រោះដល់ស្លាប់ខ្លួន មេម៉ាយខាងស្រី
ប្រាកដមិនខុស ប្រុសក្នុងលោកិយ ស៊ូនៅអត់ប្ដី
ស្លាប់រស់រូបមួយ ។

១២៩-បើខ្លួនកំព្រា ពឹងមិនមា រកស៊ីមិនព្រួយ
កាន់មារយាទល្អ មិនក្រគេជួយ បងប្អូនកូនក្មួយ
រត់ចូលឲ្យប្រើ ។

១៣០-ពោះម៉ាយមានបី កុំយកធ្វើប្ដី មិនគាប់ប្រសើរ



www.elibraryofcambodia.org

អាមួយស្រីលែង | ស្រីគេគ្រាន់បើ | ពោះម៉ាយក្លាយដើរ
អាងលែងប្រពន្ធ ។

១៣១-ពោះម៉ាយទាំងអស់ | កុំយកឲ្យសោះ | ហៅប្រុសទូរជន
ទូរជាតិអប្រិយ | ស្រីកើតទុក្ខធ្ងន់ | ហៅមួយជំនាន់
ចំណាំមិនខុស ។

១៣២-កំឡុះចាស់យូរ | ចាស់ទុំគេប្តូរ | ល្មមព្រមយកចុះ
រកស៊ីមានបាន | សុខសាន្តឥតឈ្លោះ | ចំរើនរូបរស់
អាយុយឺនយូរ ។

១៣៣-កុំយកប្តីប្អូន | ថោកទាសីខ្លួន | រកស៊ីមិនធូរ
គេហៅឯងធំ | សមហៅគេពូ | ច្រើនខ្ជិលមូទូ
ម៉េះមស់នឹងល្បែង ។

១៣៤-រាប្រើនមើលងាយ | ហៅស្តីនិយាយ | ហៅហងហៅឯង
ខ្លួនយើងជាស្រី | ស្រដីឥតក្រែង | យល់គេប្អូនឯង
ឯងមើលងាយដែរ ។

១៣៥-ពាក្យចាស់លោកចង | ប្តីទុកស្មើបង | ប្រពន្ធស្មើប៉ែ
មើលងាយរាល់ថ្ងៃ | ចង្រៃរាល់ខែ | រកសុំផ្ញើស្រែ
ច្រើនខាតគ្រាប់ស្រូវ ។

១៣៦-គួរយកប្តីបង | ពាក្យចាស់លោកចង | ទុកប្តីស្មើឪ
ខ្លួនឯងប្រមាថ | ប្រតិបត្តិឲ្យត្រូវ | រាសីគង់នៅ
ទេព្រក្សរក្សា ។

១៣៧-ប្រពន្ធនិងប្តី | ជំស្រេចនឹងស្រី | គត់គង់កិរិយា
ឈ្លោះហើយច្រើនខ្សត់ | ស្រីអត់លក្ខណា | ប្តីខ្ជិលឧស្សាហ៍



www.elibraryofcambodia.org

ព្រោះបុកប្រពន្ធ ។

១៣៨- ជាតិស្រីមានលក្ខណ៍ ទេវតាពីនាក់ កបកើតទ្រព្យធន
ប្រទេពផេរាយ ចៀស្រទូវផន ផ្គជាតិលើសលន់
លើសលុបលើប្រុស ។

១៣៩- ហៅគាឡូកិណី វាយកូនជេរស្តី មិនដឹងត្រូវខុស
បើមានភ្ញៀវមក រឹតរករឿងឈ្លោះ អសោចសាយសុស
ស្តោះធនធាន ។

១៤០- អកស្រីមានឃាតខ្ពស់ ចេះខ្ចីមពាក្យឈ្លោះ ចេះទ្រាំអត់ឃ្លាន
ចេះស្លូតចេះកាច ចេះខ្លាចចេះហ៊ាន ចេះខ្មាសចេះអៀន
កាចមានព្រំផ្លា ។

១៤១- កូនចៅស្រីប្រុស ចំណាំទុកចុះ ទុកជាគម្រោ
គួរយកតម្រាប់ គួរស្តាប់ពុទ្ធដីកា ព្រះអង្គទេសនា
គាថាបួនបទ ។

១៤២- រៀនក្រាប់អ្នកប្រាជ្ញ បើចង់ឈ្នះកាច យកស្លូតសង្កត់
ចង់ឈ្នះមនុស្សខឹង ឲ្យប្រឹងទ្រាំអត់ រាពេររាហេត
រស្សូថលែងខឹង ។

១៤៣- ចង់ឈ្នះអសុរោរ ស្តីលេងខ្លះខ្លោះ កុំធ្វើជាដឹង
ឃើញស្តីត្រង់ណា ឲ្យទៅត្រង់ណឹង ឃើញបុកឃើងវិង
ខ្លាចឃើងខាងក្រោយ ។

១៤៤- ចង់ឈ្នះកំណាញ់ ក្រដក្រដាញ់ សំរ៉ូមិនឲ្យ
បើបានចំណី បុចអាញយ ៗ តិចដោយច្រើនដោយ
ក្នុងកែវាដឹង ។



www.elibraryofcambodia.org

១៨៤-នេះមន្តព្រះពុទ្ធ ប្រាថ្នាឲ្យមុត ឲ្យគិតថ្លែងថ្លឹង
កុំការខុសខ្នាត កើតខាតផ្សិតខឹង កូនអើយខំប្រឹង
កាន់ច្បាប់ទាំងបួន ។

១៨៦-កុំជួញរស់ កុំតបតទល់ កើតទាស់គុំគួន
កូនណាកាន់បាន កូននោះសុខខ្លួន ទោសទាស់លែងជួន
លែងជួបមួយជាតិ ។

១៨៧-បើមនុស្សអែកទូល មកនៅចំណូល ញោះញស់ធ្វើញាតិ
ឲ្យមើលលែលក កុំយកខ្លួនបៀត ទៅទូលទៅទៀត
អសារឥតការ ។

១៨៨-ចំណីចំណុក បើឲ្យស៊ីចុក ឲ្យដោយមេត្តា
កុំឲ្យជើខ្ជី ក្រែងខុសសន្យា កើតទាស់កាលណា
ដើរកែរត់បាត់ ។

១៨៩-មនុស្សគ្មានកន្លែង ខុសពីមារយាទឯង មិនប្រុងប្រយ័ត្ន
តាមទាន់តឹងទារ ខឹងក្ដៅក្ដាត់ គុំគួនដោយស្ងាត់
បំភ្លាត់ឯងបាន ។

១៩០-ហេតុនេះគួរគិត គួរកូនពិនិត្យ ច្បាស់ស៊ុំរាប់អាន
គួរឲ្យស៊ីឲ្យ គួរខានឲ្យខាន ផ្សិតពាក្យបុរាណ
មានពីរចំណែក ។

១៩១-ចងទុកជាក្បួន ចិត្តល្អក្រខ្លួន នេះពាក្យមួយប៉ែក
មួយទៀតចិត្តល្អ មិនក្រយូរពេក ឆ្នាំនេះឆ្នាំភ្លែក
ក្នុងតែនឹងមាន ។

១៩២-ចិត្តល្អក្រខ្លួន ចាំទុកជាក្បួន ជាក្បាលនិទាន



www.elibraryofcambodia.org

ឃើញអ្នកទូរគត កំសត់អត់ឃ្លាន មិនស្គាល់ពោះវៀន
ហ៊ានឲ្យជឿខ្ចី ។

១៨៣-ទៅទារមិនឲ្យ តឹងតឿនញយៗ ខឹងប្តឹងកើតក្តី
ខាតទាំងទ្រព្យចាស់ អស់ទាំងទ្រព្យថ្មី ស្តុមគោក្របី
រល់ក្តីខាតថៃ ។

១៨៤-ចិត្តល្អមួយទៀត មេត្រីជាញាតិ សំដីខ្ចីស្រែ
បានស្រួលស៊ីស្កប់ ត្រឡប់កាច់កែ រំលងឆ្នាំខែ
ដកហូតមិនបាន ។

១៨៥-ឯងប្តឹងគេ ក្តីទាល់តែក្រ អស់ឆ្នាំងអស់ចាន
របស់ក៏ខាត របរក៏ខាន ដឹងអស់ប៉ុន្មាន
ទំរាំចាញ់ឈ្នះ ។

១៨៦-ទ្រព្យធនអ្វីៗ ចងការជឿខ្ចី មើលមុខឲ្យច្បាស់
កុំភោពច្បាប់ខ្មែរ កុំភ្លេចច្បាប់ព្រះ តាមតែប្រទះ
ប្រទាញសងខាង ។

១៨៧-ចាំចិត្តកណ្តាល បើនឹងឈើឆ្កាល សប្បុរសមើលយ៉ាង
រៀនស្លូតរៀនប្រាជ្ញ កាចកុំក្អេងក្អាង ព្រៀងគ្រោះសំណាង
ខ្មោចខាងរាស្អប់ ។

១៨៨-ល្អមិនក្រយូរ ស្វែងរៀនរកគ្រូ ស៊ូកុំស្តាយទ្រព្យ
ត្រូវយកកុំខឹង ឲ្យប្រឹងខំផ្តប់ ចេះបន្តសាយសព្វ
ត្រឡប់ជាមាន ។

១៨៩-ធម្មតាអ្នកចេះ អ្នកស្វែងចំណេះ ពេះដ្បិតខំរៀន
ធ្លាក់ក្នុងក្បួនក្បាច់ សាច់សិល្បរបៀន អ្នកខ្សត់អត់ឃ្លាន



www.elibraryofcambodia.org

ព្រោះចិត្តអាក្រក់ ។

១៦០-ខូចមិនល្អង់ខ្លៅ ត្រូវដេះប្រដៅ ទឹងលបសំឡក់
របេញរបុញ ភូតភរកុហក ស៊ីប្លន់លួចឆក់
មិនខំធ្វើស្រែ ។

១៦១-អ្នកប្លន់អ្នកលួច ឆក់បានតិចតួច បានគ្រាន់បើដែរ
ដល់គេឃើញមុខ ត្រូវគុកច្រើនខែ អាក្រក់ដល់ម៉ែ
ខូចកេរ្តិ៍ដល់ឪ ។

១៦២-ចង់ខ្ពស់បានទាប ចរចើងចង់លាភ[13] រឹងបាក់ធន់ទៅ
ពាក្យពីបុរាណ លោកមានដំនូរ បូកមនុស្សឥឡូវ
ត្រូវតាមតម្រាយ ។

១៦៣-អ្នកលួចអ្នកប្លន់ ចង់បានប្រពន្ធ ចេញជួញស្រុកឆ្ងាយ
វិញរកមេស្រុក សូកធ្វើចៅហ្វាយ ចង់ធ្វើងសប្បាយ
ចាយប្រាក់ជេការ ។

១៦៤-អញ្ជើងបំបាត់ លួចបានដោយស្ងាត់ អាចមានប្រាជ្ញា
ក្រឡេកថ្ពាល់ដៃ កាន់ឡេបោះត្រា ទាស់ក្មេកទេរតា
រក្សាផែនដី ។

១៦៥-អួយទៀតទូរផង ធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី
ទោសទៅចងជាប់ កាប់ឥតប្រណី បានបុណ្យមន្ត្រី

---

[13]ក្នុងច្បាប់ពុទ្ធសាសនបណ្ឌិត្យសរសេរ «ចរចើងចង់លោក» តែយើងបានកែជា «ចរចើងចង់លាភ» វិញ ដើម្បីឲ្យចួននឹងព្យាង្គមុន ហើយមានន័យត្រឹមត្រូវទៀតផង ។ នេះប្រហែលជាកំហុសការរៀបពុម្ពទេ ។



www.elibraryofcambodia.org

ព្រោះបុណ្យធ្វើបាប ។

១៦៦-អំពើទាំងអស់ កុំសាងឲ្យសោះ ចៀសវាងដរាប
កាន់សីលព្រះពុទ្ធ ខិតលុតលុនក្រាប បើក្រដុនដរាប
មានទេវតាជួយ ។

១៦៧-កូនអើយទេវតា ស្ថិតសព្វព្រឹក្សា រងោករទួយ
មនុស្សប្រុស្តបុស្សា ឯណានីមួយ ទេវតាពុំជួយ
ចំណាំស្គាល់មុខ ។

១៦៨-មិនដែលកំបាំង រាជការបាំង គេចាប់ដាក់គុក
ដល់ខ្លួនស្លាប់ទៅ នៅវែងសោយទុក្ខ សោយទោសនរក
ទាំងពីរកន្លែង ។

១៦៩-នរកបាំង មានខ្មោយមានខ្លាំង មានខ្លីមានវែង
នរកយមបាល គេផ្ទាលឥតក្រែង ព្រះអង្គសំដែង
ថាលានកោដិឆ្នាំ ។

១៧០-ហេតុនេះត្រូវវាង ត្រូវចោលត្រូវវាង ត្រូវចងត្រូវចាំ
ត្រូវកុំធ្វើបាប ដរាបខ្លាចកម្ម ត្រូវកាន់សីលប្រាំ
បណ្តាំសាសនា ។

១៧១-ហៃកូនចៅអើយ ក្រឡាប់អស់ហើយ មិនដូចដូនតា
ភ្លៀងជន់ខែប្រាំង រាំងខែវស្សា ឆ្នាំអកា
ព្រឹតរកែទេវឯង ។

១៧២-វានោចផល្គុន រកាពីមុន ឯកសក់ជាក់ស្តែង
ក្នុងខ្នើតផល្គុន ជន់គ្រប់កន្លែង ទាំងគេទាំងឯង
ធ្វើស្រែបានផល ។



www.elibraryofcambodia.org

១៧៣-ឆ្នាំរោងឆស័ក វិសាខភ្លៀងធ្លាក់ ពីររោចសំគាល់
យប់ថ្ងៃអាទិត្យ ងងឹតព្យុះខ្យល់ ភ្លៀងជន់ពេញថ្នល់
ពេញវាលតូចធំ ។

១៧៤-ពេញស្លូវពេញជ្រោះ ដើមឈើទាបខ្ពស់ រលុះរលំ
ឫស្សីស្រុកយើង រលើងទាំងគុម្ព ទើបគ្រាប់វាទុំ
ផ្តួចដុះជាថ្មី ។

១៧៥-ឆ្នាំចកុរផុត រាំងរីងរហូត គ្រប់ឆ្នាំទាំងបី
កើតទាំងជម្ងឺ ស្លាប់មនុស្សប្រុសស្រី ខាលចោះអស់ភ័យ
ធ្វើស្រែស្រូវបាន ។

១៧៦-ភ្លៀងឆ្នាំម្សាញ់ រលើងក្បាលក្រាញ់ ត្រូវតាមបុរាណ
កត្តិកជន់វាល វាលសព្វស្មសាន អ្នកស្ទឹងប៉ុន្មាន
រលួយស្រូវអស់ ។

១៧៧-ដាច់ថ្នល់ខាងជើង រាជការគេប្រើ ទាំងចាស់កំឡោះ
បម្រើរងកម្ម បញ្ចាំកេរ្តិ៍កោះ គ្មានអ្វីស៊ីសោះ
ដាច់ពោះក្សិណក្ស័យ ។

១៧៨-ខែចេត្រឆ្នាំវក ស្រឡះពពក កើតមានសម័យ
ជាហេតុអស្ចារ្យ សុរិយាព្យាចថ្ងៃ ឧក្សាកចង្រៃ
ឃើញសត្វអ្វីហោះ ។

១៧៩-ពីជើងទៅត្បូង ចាស់ក្មេងមើលច្រូង បានឃើញទាំងអស់
មើលមិនស្គាល់ជាក់ ធ្លាក់ចំចន្លោះ ព្ញាក់ឈឹងសូន្យសោះ
មិនដឹងទៅឯណា ។

១៨០-កាលមុននោះមក ខែបុស្សឆ្នាំវក រំលងមានប្រាថ្នា
មានតែមេស្រុក វាស់បែងក្រឡា ដីមួយហិតា



www.elibraryofcambodia.org

ត្រូវសែសិបថាំង ។

១៨១-រង្គាន់មេស្រុក ត្រូវហូតមួយទុក ដប់ជូនបារាំង
ទៅដល់ប៉ុយរ៉ូ បង្ខូរដាក់ឃ្លាំង ពូជពីរកន្លាំង
ក៏ជាប់ពន្ធដែរ ។

១៨២-គ្មានធូរគ្មានតឹង កូនអើយខំប្រឹង ជាតិឯងជាខ្មែរ
ក្មេងប្រុសដំទង់ នៅក្នុងឪម៉ែ រាជការប្រិតប្រែ
ថាឲ្យបង់ប្រាក់ ។

១៨៣-កូនចៅប្រុសស្រី កើតមកលើដី ខំរកលុយកាក់
បានហើយប្រឹងខំ ផ្សំគ្នាទុកដាក់ គ្រាន់ទិញស្លៀកពាក់
បង់ថ្លៃរាជការ ។

១៨៤-ភទ្របទឆ្នាំច ចាប់គោខ្មៅស ដុតដែកបោះត្រា
ដល់គុរផូតឆ្លូរ ដំរូវយ៉ាងណា នឹងកើតអស្សារ្យ
រហូតរាល់ឆ្នាំ ។

១៨៥-នគរថ្កើងប្លែក សប្បាយតែភ្នែក ក្នុងចិត្តរងកម្ម
កូនប្រុសបណ្តាច់ កុំភ្លេចបណ្តាំ កប្បាសសូត្រថ្នាំ
ត្រីម៉ាំលែងថោក ។

១៨៦-ដូងស្លាអំពៅ អំបិលស្ករស្រូវ មានទៅមានមក
មានចុះមានឡើង រាស្ត្រយើងល្មមរក ល្មមរលៃលក
គួរយកគួរខាន ។

១៨៧-កប្បាសនិងថ្នាំ គួរដាស់ដីដាំ ធ្វើដែងឯងបាន
កុំអាងខ្ជិលពេក កុំដេកឈប់ខាន កុំចោលបុរាណ
ម៉ែឪដូនតា ។

១៨៨-ដីគេគរគោក កុំអាងខ្ជិលដោក ទៅឈ្មោកចិនផ្សារ
កូនចៅស្រីៗ ខំរៀនធ្វើការ បើគ្មានប្រាជ្ញា



www.elibraryofcambodia.org

មានម្នាក់ចេះស្តី ។

១៨៩-ឲ្យសួរចាស់ៗ  រៀនពោះកប្បាស  ថ្លៃចបុរសឡើ
រៀនក្បួនរៀនការ  គ្រួសារពាក់រង  ហួសគេមគាតក្តី
កុំបីចន្លោះ ។

១៩០-រៀនផ្ទះរៀនត្បាញ  ឲ្យចាស់បង្ហាញ  បង្ហាត់ទាំងអស់
សំពត់បែបបងាយ  លាយសូត្រអម្បោះ  កុំទិញគេសោះ
ល្បោះការជាស្រី ។

១៩១-ទិញផ្ទះតែលាក់  អញ្ចូលចេសចាក់  ព្រហ្មតជាបី
ឆ្នាញឈើឈ្នាន់ស្ទឹ  ក្តារមូរក្តារកី  ត្រល់ខ្នារបុស្ស៊ី
មុខប្តីជាប្រុស ។

១៩២-តាំងពីឆ្នាំថ  ការអ្វីក្រៗ  ខំរៀនទៅចុះ
ទាន់មានចាស់នៅ  ស្គាល់ត្រូវស្គាល់ខុស  ចាស់ស្លាប់រលស់
គ្មានមនុស្សចេះដឹង ។

១៩៣-កសុីឲ្យញ៉ុក  ដេកយប់រលិក  រិកក្បៀនឲ្យតឹង
បើភ្លាក់គេបេណា  កាន់ការកាលនឹង  កូនអើយខំប្រឹង
ទាំងប្រុសទាំងស្រី ។

១៩៤-រមៀតស្លឹកគ្រៃ  ដំរម្លួសខ្ទឹមខ្ញី  មានដីដាំចុះ
ដាំដើមអ្វីៗ  ចំណើត្រប់ឈ្មោះ  គ្រឿងស៊ីឆ្អែតពោះ
ដុំចោលទទេ ។

១៩៥-ផ្ទះទិសខាងជើង  ផ្ទះដាក់ដីយើង  កុំផ្ទះដីគេ
កុំផ្ទះដាក់ស្នូរ  ត្រូវហាត់ក្មេងដេរ  ដីរលល់ទទេរ
ល្អមរហាត់ផ្ទះទៅ ។

១៩៦-សក់មួយជាដប់  ជ្រើសសក្តិឲ្យសព្វ  កុំឲ្យសល់ទៅ
បើប្រាថ្នាក់  ចាក់ចិត្តឲ្យជ្រៅ  ដាំចេកអំពៅ



www.elibraryofcambodia.org

ដុះស្រូវអង្ករ ។

១៩៧-កើតមកជាមនុស្ស មួយព្រួយចង់រស់ មួយព្រួយចង់ល្អ
ពីរនេះជាធំ នាំឲ្យក្រ ចាំផាត់ណា
តជាទំនុក ។

១៩៨-មនុស្សបារាយរាទមិនប៉ុន កូននៅខ្ញុំចិន ព្រោះម្ដាយឪពុក
ធ្វើស្រែមិនត្រូវ គ្មានស្រូវផង្រុក កូនអើយចាំទុក
នេះមុខបេក្រ ។

១៩៩-មេខជាធំ កំឡោះក្រមុំ ស្លៀកពាក់ចង់ល្អ
បើបានបែបខ្មៅ ផានៅបែបស ទើបគ្រាន់អន់ក្រ
គ្រដះចង់ឡើង ។

២០០-ក្រឡាប់នគរ វឹងវឹតកើតចោរ ច្រើនឡើងច្រើនឡើង
កាលវឹងក្រអឺត ចើតម៉ឺតចើតម៉ឺង ក្រដាស់យ៉ាងស្អឹង
ចាយវំហែកនៅដៃ ។

២០១-ប្រាក់ចាស់អស់ទៅ ព្រោះមនុស្សកំឡូះ ឱក្បាតចង្រៃ
ជាតិខ្មែរប្រែភេទ ក្រខ្មែតក្រខ្មែ ក្រឡាស់សារសើរសែយ
សព្វសត្វនានា ។

២០២-ជាតិខ្មែរប្រែខុស ស្រីក្លែងធ្វើប្រុស ប្រុសក្លែងធ្វើផ្កា
យកប្ដីប្រពន្ធ មិនស្គាល់អឺងមា បុណ្យទានការងារ
កាប់គ្នាឥតក្រែង ។

២០៣-ល្ងង់ប៉ុកធ្វើចេះ គោចងគ្រដោកសេះ ប្រុសៗដុះស្វែង
ស្រីពាក់អាវខ្លី ប្រុសពាក់អាវវែង សោរុងបៀរកែង
ធ្វើឯងអ្នកគ្រាន់ ។

២០៤-កាន់ចិត្តសីហយោ សេះទីបនឹងគោ ចាក់ហោពាន់ៗ
រកស៊ីមួយថ្ងៃ ចង់បានមួយពាន់ បរគោផលមាន់



www.elibraryofcambodia.org

ចាក់កាប់ដាប់តុក ។

២០៥-ទីល្បែងបៀរជ្រៅ ច្រើនទៅជាចោរ ប្រកាសហាមទុក
ចូរកូនប្រយ័ត្ន ប្រយោជន៍ទៅមុខ ចាំជាទំនុក
តំណាកូនចៅ ។

២០៦-អ្នកកុំប្រហែស រាជការនិរទេស កំចាត់ចេញទៅ
រាជការអាណិត ខំប្រឹងប្រដៅ កុំលោភល្ងង់ខ្លៅ
ទោកនៅត្រកូល ។

២០៧-ប្រយ័ត្នក្រែងក្រ ផ្លូវឡប់ល្អៗ អ្នកទំប្រមូល
ផ្លូវវៀចអាក្រក់ អ្នកកុំដើរចូល ហៅផ្លូវមិនស្រួល
លង់ផុតគំនិត ។

២០៨-ដើរផ្លូវកណ្តាល ស្រឡាញ់សិទ្ធស្មាល ឈឺផ្លាលដោយពិត
បត្តផលសីលទាន ឈានចូលឲ្យជិត យកធម៌ជាមិត្ត
មិនឥតអំពើ ។

២០៩-មនុស្សម្នាក់ច្រើនឆោត ច្រើនគ្មានគេកោត ឈឺគ្មានគេមើល
ស្លាប់ឥតគេព្រួយ គេជួយទាំងស្ទើរ មិនដែលឡើងលើ
ច្រមុះចុះក្រោម ។

២១០-កូនចៅស្រីៗ ក្រមុំសារខ្ចី រៀនឆោតឲ្យល្អម
ប្រុសស្ទើបែបថ្មី ឆ្កួតឆប្រលោម មើលរូបមើលឆោម
កុំព្រមដោយងាយ ។

២១១-កុំគិតក្នក់ក្តាញ់ បើចិត្តស្រឡាញ់ កុំចេញនិយាយ
បើស្អប់កុំប្តឹង បើខឹងកុំធ្លោយ កុំពោះកុំវាយ
កុំងាយផ្តើសិទ្ធ ។

២១២-កុំដើរប្រាប់គេ កុំអាងអួតផេរ ក្រែងប្រុសឈឺចិត្ត
នៅក្បែតែនិង កុំរលំផ្តើសិទ្ធ ប្រុសនឹងអាណិត



www.elibraryofcambodia.org

គិតចូលដណ្ដឹង ។

២១៣-បើប្រើឱ្យ មើលមុខមើលក្រោយ អាក្រក់ខ្មៅឆ្អឹង
ប្រកែកដោយស្ងាត់ កុំខ្លាចម្ដាយខឹង កើតកូនមកតឹង
ពិបាកចាយណាស់ ។

២១៤-កុំឃ្លានចំណី កុំខ្លាចអត់ប្ដី កុំភ័យខ្លាចចាស់
មើលមុខឯងផង កុំរើសឥតខ្មាស ខ្លួនល្អស្រឡះ
មិនខ្វះគេស្ដី ។

២១៥-បើបានជាខូច ទាន់ផើមនៅតូច ខែពីរខែបី
រៀនឆ្លើយប្រញាប់ ប្រាប់គ្នាស្រីៗ កុំលាក់ធ្វើអ្វី
ក្នុងតែគេដឹង ។

២១៦-កុំមាយាបេះក្រូច មារយាទបេះតែខូច មាត់បេះតែខឹង
គេថាត្រង់ណា ដេរគេត្រង់ហ្នឹង ដេរហើយខំប្រឹង
យកថ្នូសង្កត់ ។

២១៧-រំលាយរំលូត អាក្រក់តែគូទ ស្អុតល្អតែមាត់
មានគេឃើញច្បាស់ ម្ចុះរឹងហានស្បថ ទោសនេះនឹងភ្លាត់
ធ្លាក់ទៅអវិចី ។

២១៨-ចោរកាចល្ងង់ខ្លៅ ប្រាជ្ញប្រាមប្រដៅ ហៅបុរាដិកស្រី
មេបាកាច់គេ ស្លាប់ពីរស្លាប់បី រំលូតកូនខ្ចី
ស្មើរំលាយព្រះ ។

២១៩-មានកាលមិនក្ស័យ ខ្ទិនជើងខ្ទិនដៃ កខ្វះកខ្វាស
ខ្វាក់ភ្នែកអន្ធការ អនិច្ចារូបណាស់ អាក្រក់កេរ្តិ៍ខ្មាស
តកូនតទៅ ។

២២០-អសោចិ៍សុសសាយ សុសសព្វដល់ម្ដាយ ដល់ពូជពង្សផៅ
ស្លាប់ទៅរងទុក្ខ នរកឋានក្ដៅ គេស្រុសទឹកក្ដៅ



www.elibraryofcambodia.org

ស្លាប់ទៅរស់ទៀត ។

២២១- ស៊ីខ្នុរណោមឯង ព្រះអង្គសម្តែង ថាម៉ឺនសែនជាតិ
ឡើងមកជាប្រេត ហេតុកម្មមិនឃ្លាត អត់ឃ្លានគ្មានញាតិ
ហែកកូនឯងស៊ី ។

២២២- ព្រះពុទ្ធលែងប្រោស ធម៌លែងសណ្តោស សោយទុក្ខរកី
ហេតុចិត្តឫស្យា មិច្ឆាទិដ្ឋិ កើតជាជ្រូកញី
គេត្រៀរគេចាក់ ។

២២៣- អសង្ខេយ្យឆ្នាំ ហេតុផលសេសកម្ម កើតជាមនុស្សខ្វាក់
មនុស្សខ្វិនទ្រេមទ្រម ជាគមជាគាក់ ខ្ទើយឆ្កួតអបលក្ខណ៍
ជាអ្នកឥតប្តី ។

២២៤- បើម្តាយជួយព្រួត ជួយជាន់រំលូត លោយកូនខ្ចី
នរកប្រេតព្រមគ្នា មិនឃើញរស្មី ដឿតចិត្តក្តៀយ
ទាំងម្តាយទាំងកូន ។

២២៥- ហេតុនេះគួរខ្លាច ធម្មតាចោរកាច មិនដែលស្គាល់សូន្យ
អសោចិកើ្តឈ្មោះ ទាំងអស់បងប្អូន មេបាតាដូន
កាត់កាយលែងរាប់ ។

២២៦- គួរប្រុងឥរិយា កើតទាន់សាសនា ហៅបមាមានភ័ព្វ
ទាំងប្រុសទាំងស្រី កុំបីឲ្យធ្លាប់ គួរខំរៀនស្តាប់
បរលោកលោកីយ ។

២២៧- ឯខុសនឹងគាប់ បើនឹងរៀបរាប់ រាល់រូបប្រុសស្រី
គាប់ខុសនៅចិត្ត ខុសគាប់នៅស្តី តំរប់ជាបី
ខុសត្រូវនៅកាយ ។

២២៨- កូនប្រុសប្រព្រឹត្តិ ការកើតឲ្យជិត គំនិតឲ្យឆ្ងាយ
កើតមកជាខ្មែរ កុំប្រែក្លែងក្លាយ ធម្មតាសប្បាយ



www.elibraryofcambodia.org

វាតែងឲ្យទុក្ខ

២២៩-ឲ្យទោសទាស់ទែង ទាស់តែម្នាក់ឯង ដល់ម្ដាយឪពុក
រឹងរឿងទោស មានតែពីរមុខ មួយទៅនរក
មួយនាលោកិយ ។

២៣០-លោភៈទោសៈ កើតពីមោហៈ រាល់រូបប្រុសស្រី
គួរកាន់មេត្តា កតញ្ញូខន្តី នេះគឺបាលី
ទៅកាន់បរលោក ។

២៣១-ពាក្យពិតប្រដៅ ឲ្យអស់កូនចៅ ប្រព្រឹត្តរៀនយក
កូនណាមិនរៀន កូននឹងមានយាទទោក នឹងធ្លាក់ជ្រុលជ្រក
ក្នុងចតុរាបាយ ។

២៣២-ធំស្រេចនៅស្លូត សុខខ្លួនរហូត ដរាបរៀងឆ្ងាយ
ខន្តីអំណត់ សង្កត់ក្នុងកាយ ជាតិជនទាំងឡាយ
កប្រកាន់បាន ។

២៣៣-ចេះហើយមិនដឹង ចិត្តនៅមួរវឹង ប្រឹងរកកម្មដ្ឋាន
រកធម៌បំនយល់ ខ្ជិលខ្ជល់ពេលខាន បន្ទោសបុរាណ
ថាគ្មាននិស្ស័យ ។

២៣៤-វិបាកនិងបុណ្យ មានចិត្តជាមុន មាត់ជាបច្ច័យ
នាំចុះនាំឡើង ពីជើងពីដៃ សន្សំសព្វថ្ងៃ
ឈ្មោះហៅសំណាង ។

២៣៥-កើតក្នុងលោកិយ រាល់រូបប្រុសស្រី មានចិត្តជាអាង
កុសលអកុសល ប្រទាញសងខាង រូបនៅតេងតាង
តែងតាមទៅមក ។

២៣៦-មគ្គផលសីលទាន បើល្ងង់ឲ្យរៀន បើគ្មានឲ្យរក
យល់ល្អសាងល្អ សង្កេតប្រៀតជ្រក ជ្រើសរើសរៀនយក



www.elibraryofcambodia.org

រក្សារូបកាយ ។

២៣៧-នេះគឺហៅច្បាប់ ជាទីសណ្ដាប់ សន្ដានទាំងឡាយ
កូនចៅប្រុសស្រី កុំបីនឿយណាយ សង្ខេបបរិយាយ
និដ្ឋិតចែងចប់ ។

២៣៨-អ្នកព្រះភិរម្យ អាចារ្យង៉ុយខ្ញុំ បង្គំប្រាមដប់
លើសលស់ឆ្នាំឆ្លង រំលេងពុំគាប់ ពុំគួរសមសព្វ
សុសសាយសេចក្ដី ។

២៣៩-កាយកម្មវចីកម្ម ល្មោះច្បាប់បណ្ដាំ កូនចៅប្រុសស្រី
ជាបរមត្ថក្រៅ មិនហៅបាលី បរលោកលោកិយ
ទាំងពីរកន្លែង ។

២៤០-បើលោកឯណា មេះចៅធម៌អាថ៌ ប្រាកដជាក់ស្ដែង
ឃើញខុសត្រង់ណា កុំថាជាល្បែង ដៀតពាក្យខ្ញុំតែង
ឲ្យក្មេងរាភ័យ ។

២៤១-មិនមែនភរភូត កុំថាខ្ញុំអួត ប្រាជ្ញាខ្ញុំរៃ
ឃើញមនុស្សវង្វេង ខ្ញុំតែងច្បាប់ថ្មី អស់អាថ៌សេចក្ដី
ឯរំចប់ហោង ។



www.elibraryofcambodia.org

# ច្បាប់ កិរកាលថ្មី

១-នេះបទព្រហ្មច្រាផ្ទុប្រាយ ខ្ញុំអធិប្បាយលើកល្បត់ល្បែង
ប្រដៅកូនចៅផង ចងជាច្បាប់ខុសនិងត្រូវ ។
២-កត្តិកខ្នើតត្មេរត្មាន់ ក្នុងរស្សន្តរដូវ
ទឹកស្រែជន់លិចស្រូវ នៅសំណល់សំណាបខ្ចី ។
៣-កិរកាសពីព្រេងព្រឹទ្ធ ដើមគំនិតពីសេដ្ឋី
ខ្ញុំលើកកិរកាលថ្មី ថ្លែងសេចក្តីជាបរមត្ថ ។
៤-ក្នុងថ្ងៃពេញបូណ៌មី ម៉ោង៨ព្រលប់ស្ងាត់
ឆ្នាំចចត្វាក្សត្រ ផាក់សករាជកន្លងឆ្ងាយ ។
៥-សាសនាព្រះសមណៈ បានពីររពាន់បួនរយប្លាយ
ហុកសិបកំចាយ ប្តាត់អធិប្បាយពីខុសត្រូវ ។
៦-កិរកាលដំណាលទុក ជាទំនុកដំណែលនៅ
ដំណាតរៀងទៅ តម្រូវចិត្តជនប្រុសស្រី ។
៧-កូនអើយពាក្យអាពុក ជាទំនុកទំនើបថ្មី
អធិស្រាយរាយបាលី អាពុកស្តីឲ្យកូនស្តាប់ ។
៨-គួរស្តាយកេរ្តិ៍ម៉ែឪ កិរិយាត្រូវឲ្យខំគ្រាប់
កិរិយាណាខុសច្បាប់ គួរក្រឡាប់ក្រឡាស់ចោល ។
៩-ម្តាយអាពុកនិងកូន បើដូចខ្លួននឹងស្រមោល
ឃើញខុសកុំដេញដោល កុំថ្កោលទោសអ្នកមានគុណ ។
១០-ល្អង់ខ្លៅត្រូវតែសួរ ពាក្យឲ្យគួរកុំឲ្យស៊ុន
យកពាក្យផ្អែមជាមុន ទន់លំទានឱនប្រតិបត្តិ ។



www.elibraryofcambodia.org

១១- ទោះម៉ែឪស្លូតកាច | គួរតែខ្លាចដូចមហាក្សត្រ
ម្តាយដេរពីរបីម៉ាត់ | គួរតែស្ងាត់ស្ងៀមឲ្យឈឹង ។
១២- ប្រដៅត្រូវតែស្តាប់ | យកតម្រាប់កុំទទឹង
ម្នាម្នះចចេសរឹង | នឹងហើយហៅកូនសេសកម្ម ។
១៣- ធំអាចចេះតែភ្លេច | ដេរប្រទេចចេះតែថា
ឪពុកពត់ទៅស្តាំ | អកុសលកម្មទាញទៅឆ្វេង ។
១៤- អវជាតបុត្រ | ខូចបំផុតតាំងពីក្មេង
ប្រព្រឹត្តល្មើសផ្សេងៗ | បើលេងអ្វីស្អីមិនស្តាប់ ។
១៥- មិនស្តាយជាតិកំណើត | ល្ងង់ស្អុតស្អិតដល់ចាស់ស្លាប់
ត្រឹមត្រូវមិនសូវស្តាប់ | ព្រួយគេប្រាប់ទាំងយប់ថ្ងៃ ។
១៦- បើឪមានគុណណាស់ | មិនសំពះខ្មាសអៀនដៃ
បើអ្នកក្រៅដទៃ | វិស័យសោះសំពះបាន
១៧- ឆ្លើយបាទចាះចាំខ្ញុំ | រាបទាបទមនិងសន្តាន
ម៉ែឪឯងក្នុងបាន | បានឆ្លើយអឺអញអីអើ ។
១៨- អនុជាតបុត្រ | ស្លូតបំផុតស្រណុកប្រើ
ប្រកបការប្រសើរ | ដើរតែតាមលំអានឪ ។
១៩- ប្រដៅទទួលយក | ចេះវៃរកស្តាប់ខុសត្រូវ
ស្រណុកញាក់ឆ្លាក់ផ្លូវ | មិនសូវភ្លេចដំបូន្មាន ។
២០- អភិជាតបុត្រ | ល្អបរិសុទ្ធស្អាតសីលទាន
នាំឪទៅនិព្វាន | ឈានទៅរកកន្លែងសុខ ។
២១- ចេះលើសគេឯងភាព | ជឿបុណ្យបាបប្រែតនរក
មិនល្មោភនិងមុក្ខពាមក | ភ័យនឹងភក់ភពសង្សារ ។
២២- នេះតើដើមបាលី | បុត្រទាំងបីបែបកិរិយា
ស្រឡាញ់ណាស្អប់ណា | តាមសញ្ញាចូលចិត្តចុះ ។



www.elibraryofcambodia.org

២៣-អរធ្លាក់ផ្លូវក្រោម / ប្រព្រឹត្តព្រមតែខាងខុស
អតិជាតិមារយាទខ្ពស់ / អនុនោះយ៉ាងកណ្តាល ។
២៤-អតិ១០០មានមួយ / ក្នុងតែសួយដាក់លើក្បាល
អរគឺស្រើបស្រាល / ត្រូវអាលយកតែពីរយ៉ាង ។
២៥-អតិជាតិកំណើត / ត័និតកើតពីកសាង
កុសលតម្កល់ខាង / សំណាងកើតពីត័និត ។
២៦-អនុអានាងអើយ / ខ្លួនធំហើយឲ្យចេះគិត
ចេះការស្គាល់ឆ្ងាយជិត / ប្រព្រឹត្តយកតែខាងត្រូវ ។
២៧-រៀនវិរកទ្រព្យធន / យកប្រពន្ធមើលធុនថ្មី
ធុនថោកជ្រកខុសត្រូវ / អ្នកកុំទៅខ្លាចបន្ទា ។
២៨-ផ្លូវវៀចកុំបោះបង់ / ផ្លូវព្រៃត្រង់កុំយាត្រា
ឈានឈរពិចារណា / ឆ្ការឲ្យស្អាតសឹមដើរទៅ ។
២៩-កុំដើរភ្លើភ្លេចខ្លួន / ខ្លាចរំព្រងជួនធ្លាក់ជ្រោះជ្រៅ
ជ្រកម្លប់សំណាក់នៅ / កុំបោះពៅផ្តប់គល់ឈើ ។
៣០-ឆេះខ្លោចសំបកក្រោម / ស្រពោនញមស្លោកស្លឹកលើ
មានភ្នែកឲ្យចេះមើល / កុំល្ងើល្ងើល្ងង់ល្ងិតពេក ។
៣១-រៀនដើរឲ្យមើលផ្លូវ / ធ្វើស្រែស្រូវឲ្យមើលមេឃ
ម្លប់ឆ្លកធ្លាប់ជ្រកដេក / ជាដំណេកអ្នកដំណើរ ។
៣២-ដំណែលដែលគេដាក់ / ជាដំណាក់ទំនួលផ្ញើ
ចំណាំចាំគ្រាន់បើ / ដើរក្រោយៗគ្រាន់ជ្រកទៀត ។
៣៣-ឈើណាទោសសត្រូវ / ដុះជិតផ្លូវនាំចង្អៀត
ដំពប់យប់អធ្រាត្រ / ឆ្លៀតកាប់ចេញកុំទុកវា ។
៣៤-បន្លាគាប់ផ្គត់ / កន្លែងផុតតែភ្នែកជា
ដើរយប់ដំពប់ពារ / ក្រែងគ្រោះគ្នាអ្នកដើរក្រោយ ។



www.elibraryofcambodia.org

៣៥-ឆ្មាមុតកុំចាំផ្ទាន់ ឃើញគួរផាន់កុំបណ្តោយ
បណ្តើរមើលខ្លាំងខ្សោយ ឲ្យពិនិត្យពិចារណា ។
៣៦-ពាក្យពិតត្រង់ប្រាកដ ក្រួរច្រើនបទច្រើនប្រការ
ប្រកបជាប្រស្នា ប្រាជ្ញាអាប់ស្លាប់និងឆ្ងល់ ។
៣៧-ផ្លូវពិតទាំងជិតឆ្ងាយ សព្វសុសសាយមិនសេសសល់
អ្នកណាប្រាជ្ញាដល់ ដឹងយោបល់ច្រើនកន្លែង ។
៣៨-កូនអើយការកេរ្តិ៍ឈ្មោះ កុំចង់រស់តែម្នាក់ឯង
គិតអ្វីគិតឲ្យវែង ក្រែងក្រក្រោយស៊យគំនិត ។
៣៩-កំណើតពាល់រូបកាយ ចេញជួញឆ្ងាយស្ពាយជួញជិត
ចិញ្ចឹមជន្មជីវិត គិតឲ្យស្រេចទើបបានស្រួល ។
៤០-ធ្វើស្រែចង់បានស្រូវ ដើមរដូវធ្វើស្រែទួល
ស្រែទាបមើលទំនួល លើកទំនប់ឲ្យមាំមួន ។
៤១-កូនអើយកេរ្តិ៍មេបា ចាំរក្សាមើលថែជួន
ទុញថប់ថយទៅខ្លួន ជួនជាខ្សត់គេថាខ្សោយ ។
៤២-ស្រូវខ្សោយអង្ករថ្លៃ លក់សំចៃទុកឆ្នាំក្រោយ
អ្នកក្រកញ្ជៀយៗ ឲ្យអ្នកសុំផងអ្នកខ្ចី ។
៤៣-សប្បុរសពេកថយធន មួយទុជនថយរាសី
ប្រពន្ធល្អច្រើនអាប់ប្តី ពាក្យអប្រិយចាញ់អាត្មា ។
៤៤-ឈើផ្លែចាញ់សន្លឹក ត្រីរាំកទឹកមិនថ្លា
កំណាញ់ក្រៀតម្រា សោតស៊ីងអាប់ប្រយោជន៍យស ។
៤៥-និងឲ្យៗមើលភាព ឲ្យអ្នកទាបផងអ្នកខ្ពស់
អ្នកទិញឈប់សិនចុះ ក្នុងតែរស់មិនស្លាប់ងាយ ។
៤៦-កំណាញ់ហួសកំណត់ ពាក្យអ្នកខ្សត់ឡប់និយាយ
ទេវតាត្អូញទាយ រលាយអស់រលស់ឯង ។



www.elibraryofcambodia.org

៤៧-សទ្ធាមើលធន់ធាន
ជាតិអ្នកមានមិនអង្វែង
កំណាញ់ដោយកន្លែង
ទំព្រងគ្រោះក្រដល់ឆ្នាំក្រោយ ។

៤៨-អ្នកក្រខ្ជិលនេះកុំ
អ្នកមានស៊ីនេះគួរចូរ
អ្នកប្រាជ្ញអង្គាសញ្ញយ
អស់ក៏ដោយឲ្យទៅចុះ ។

៤៩-អ្នកក្របានផាហោម
ពិបាកតាមទៅឯណោះ
ទាល់ទឹកចូលច្រមុះ
ច្រើនកើតឈ្លោះពីព្រោះយល់ ។

៥០-អ្នកមានគេមានខ្មាស
សងហើយមិនអំពល
ជួនយើងមានរលំ
គេស្គាល់មុខស្រណុកខ្ញុំ ។

៥១-អ្នកក្រ ទាំងចិត្ត
ស្រូវឆ្នាំល្អិតឲ្យមើលល្អ
រាល់ល្អកន្លាំងបី
ទាន់ស្រូវថ្មីទាវឆាប់បាន ។

៥២-ជួនទំព្រងឯងក្រវិញ
ទោរទោរទិញមើលប្រមាណ
ដើរប្រុលខ្ចីសន្ទាន
កុំហ៊ានពារកញ្ចើធំ ។

៥៣-ខ្លួនក្រកុំចង់ធាត់
កុំងាយហាត់អាងតែស៊ី
ដើរខ្ចីល្អីក្រមុំ
ស្រូវឯងទុំស្រណុកសង ។

៥៤-បើដើរខ្ចីគេឲ្យ
កុំទៅញយគេឲ្យខ្នង
(--)ឯណោះផង
កុំច្រើនដងគេមើលងាយ ។

៥៥ ក្រលុយកុំងុយដេក
ចូលដំណេកកុំនិយាយ
សំពត់ញាត់សំពាយ
រាយរើសរៀបញាត់សំពៀត ។

៥៦-រៀបដេកសំពះគុណ
កុំដេកស៊ុនឲ្យប្រុងស្មៀត
ភ្លើងឆេះយប់អង្រួត
កណ្តៀតទូលប្រមូលរត់ ។

៥៧-ខ្លួនរាស្ត្រក្រមាសប្រាក់
កើចកន្លាក់អាងសំពត់
ទំរាំភ្លើងរលត់
ស្បៀកផ្លង់ផ្កត់សោះខ្មាសគេ ។

៥៨-កូនអើយគិតឲ្យគ្រប់
រៀងរាល់យប់កុំទំនេរ
ផងដេកលក់ទទេ
យល់សព្វផេះបីសាចក្រៅ ។



www.elibraryofcambodia.org

៥៩-ទំលាប់មាត់មមើ ស្រែកផាយើៗ អៀៗ
ថោះខ្លាំងខ្ទេចចិត្តខ្មៅ ហៅមេខ្មែរឲ្យខ្ញុក ។
៦០-ដេកផ្អៀងជាងអង្គុយ ល្ហាល្ហាន់ល្អុយកុំទ្រាំងក់
ពិល្បាចដេកកុំលក់ មាន់រងាវដក់ស៊ីម្លូស្លា ។
៦១-ជាងល្បិតឥតអំពើ ឥតអ្វីធ្វើសូត្រធម៌អាថ៌
បើច្បាស់វិបស្សនា ស្មាស្មារតីស្ទុំងប្រឹងឲ្យស្មោះ ។
៦២-គងខ្នើយដេកកើយស្ពុត គ្របេច្យស្លុខសូត្រអម្បោះ
កុំដាក់ដោយទៀនគោះ អស់នឹងសត្វកណ្ដៀរគោរ ។
៦៣-កណ្ដុរកន្លះកកាត់ ដល់កំណាត់ខាន់ដេរខោ
ផ្នូនកាលមានអាចោរ លលបលួចរើទៅបាត់ ។
៦៤-កុំដាក់ឆ្ងាយប្រយោល ទុកជាចោលមិនប្រយ័ត្ន
ប្រយោជន៍យប់យាមស្ងាត់ បង្កាត់ភ្លើងបង្គោលគោ ។
៦៥-បង្ការព្រៃកងមូសខាំ ត្រូវចំណាំខ្យល់ជំនោរ
បាយកកផ្ដកម្ហូបដោះ ឲ្យអាពោស៊ីចាំសេះ ។
៦៦-កំណើតឆ្អែញញ្ញោល ដេកចំណុចតែនិងផេះ
រៀនប្រើមើលចំណេះ វិះចំណាំតាមកិរិយា ។
៦៧-ទោះបើកូនតូចធំ ប្រុសប្រើខ្ញុំឲ្យធ្វើការ
ធ្វើកលយល់ប្រាជ្ញា អាណាហ៊ានប្រើទៅឆ្ងាយ ។
៦៨-អាន្លាចប្រើតែដឹក ឥតគំនិតប្រើរឿងអាយ
ខុសម្ដងកុំជេរម្ដាយ ពេលដួសបាយកុំនាំឈ្លោះ ។
៦៩-មនុស្សឃ្លានអាហារស្ញើយ ស៊ីរួចហើយមន្ទោសចុះ
បានឆ្អែតប៉ោងពេញពោះ ស្ដីខុសត្រូវមិនសួរទឹង ។
៧០-កូនអើយពាក្យអាពុក ចំណាំទុកពីត្រឹមណឹង
ធ្វើប្រុសឲ្យខំប្រឹង រៀនឲ្យដឹងស្គាល់ពុតស្រី ។



www.elibraryofcambodia.org

៧១-មារយាទនិងមាយា ម្យ៉ាងចិត្តជាចេះថ្នមប្ដី
ប្ដីស្លាប់រស់វាហើ យកពីរបីនេះមិនបាន ។
៧២-កុំលោភច្រើនៗព្រួយ យកតែមួយសុខក្សេមក្សាន្ត
ចិត្តស្រីទាំងប៉ុន្មាន ហ៊ានប្រមូលម៉ៅមិនខុស ។
៧៣-មិនខូចគ្រប់តែស្រី ល្អពីរបីជឿចាំចុះ
ជាតិស្រីលោភលើប្រុស នោះមិនខុសស្រីណាមួយ ។
៧៤-ខ្លាំងខ្សោយកុំឲ្យខ្សត់ ទោះនឿយហត់កុំលំអួយ
ធ្វើប្រុសតែងតែព្រួយ ស្រីមិនជួយកុំត្អូញត្អែរ ។
៧៥-ខ្លួនខ្លាំងកុំគិតខ្លាច ស្រីៗកាចស្លូតដោយខែ
រដូវធ្វើស្រូវស្រែ ថែប៉ប្រែស្ដីលើប្រុស ។
៧៦-ខែស្ទូងនិងខែច្រូត កាចរហូតដល់ខែបុស្ស
ខែបែនបោករលស់ រលីងអស់អំពីដី ។
៧៧-ជញ្ជូនដាក់ជង្រុក ពូជពេញទុកស្បៀងពីរបី
ដំណើមបួនដប់ល្អី ស្រីៗស្លូតហើយខែនឹង ។
៧៨-ស្លូតផុតនៅខែមាឃ ស្ដីធ្ងន់ពាក្យមិនសូវខឹង
បើប្រុសៗមិនដឹង ប្រឹងតែព្រួតស្អប់ស្រីៗ ។
៧៩-អឺអើតែមាត់ក្រៅ ចិត្តមួម៉ៅគ្មានត្រជាក់
ត្រីសាច់ល្អល្អួចលាក់ ដាក់តែឆ្អឹងឲ្យឯងស៊ី ។
៨០-បញ្ចោរចេះបញ្ចើ បញ្ឆោតប្រើឯងរកី
អើកព្រួតប្រុសពីរ ស៊ីទាល់ងាប់គាប់សងខាង ។
៨១-មួយទៀតជិតកំឡោះ ស្រឡាញ់ស្មោះស្ម័គ្រអស់យ៉ាង
លោមប្ដីលាសំណាង ទាស់ក្មេងក្មាងទារសំបុត្រ ។
៨២-បើប្ដីមិនព្រមលែង លបជំទែងជំទយរត់
មួយទៀតខូចបំផុត មកឲ្យប្រុសសម្លាប់ប្ដី ។



www.elibraryofcambodia.org

៨៣-ម្យ៉ាងទៀតបារយាទជា មានច្រើនគ្នាក្នុងលោកិយ
ប្រាកដពេញជាស្រី ប្រុសពីរបីស្នាលាកម្ម ។
៨៤-ស្លាប់រស់មួយនិងមួយ មិនចង់ព្រួយយកប្រុសថ្មី
ប្តីស្លាប់ប្អូនដប់ឆ្នាំ ចាំសើយទានមិនមានទៀត ។
៨៥-ធ្វើបុណ្យឡុងសទ្ធា សុំប្រាថ្នាជួបរាល់ជាតិ
ដូចធ្លាប់ដេកឱបធាតុ កណ្ដៀតចៅកោះកាន់ទុក្ខ ។
៨៦-និយាយពីពុតប្រុស ចូរចាំផ្ទុះជាទំនុក
ដំណាលទៅមុខ អាពុកប្រាប់ឲ្យស្រីចាំ ។
៨៧-ប្រពន្ធមួយមិនស្កប់ ប្រពន្ធដប់គ្រាន់តែស្កាំ
រះចស្តួតរហូតឆ្នាំ រាំតរាបរាល់រដូវ ។
៨៨-កាចម្យ៉ាងខាងល្បាចព្រឹក រឿងបាយទឹកថ្នាំម្លូស្លា
កាចម្យ៉ាងរឿងធ្វើការ ម្យ៉ាងទៀតណារឿងប្រចណ្ឌ ។
៨៩-ប្រជុំជាតិចិត្តប្រុស ត្រូវនឹងខុសជាគំណាន់
ដំនិតល្អសំខាន់ ប្រកាន់មើលតវិយាបថ ។
៩០-ប្រចណ្ឌរស់រាល់ឈ្មោះ ច្រើនកើតឈ្លោះទៅជាខ្សត់
មួយឃើញជាក់ប្រាកដ ប្រកៀកចាប់ធ្វើទោសបាន ។
៩១-លក់លែងតែខាងប្រុស ប្រពន្ធខុសបង្អង់ខាន
ខូចម្តងខាតប៉ុន្មាន រាប់អានឱបក្រសោបទៀត ។
៩២-ប្តីលក់លែងទាំងពីរ នៅរកស៊ីដោយសារញាតិ
ស្រីមាយាគ្មានមារយាទ ស្មាលោះជាតិមិនឲ្យជួន ។
៩៣-ប្រចណ្ឌទាំងបីបទ គួរគួចកត់ទុកក្នុងខ្លួន
លក់ពីរពេញចំនួន គួនកុំទុកយកជាច្បាប់ ។
៩៤-ប្រចណ្ឌហើយយកទៀត ហៅជួជាតិមាត៍ទាំងអាប់
កូនណាយកតម្រាប់ ស្លាប់និងស្រីៗមើលងាយ ។



www.elibraryofcambodia.org

៩៥-ទោសតិចកុំទាញផ្សំ ឃើញមិនធំកុំនិយាយ
កុំចាប់ស្ទើរស្ទើរវាយ នាំឲ្យរស់អំពល់ចិត្ត ។

៩៦-ពុកប្រុសនឹងពុកស្រី ចប់សេចក្តីពីក្បត់ផិត
រឿងរើសណាសុខចិត្ត គិតសំគាល់រាល់រូបកាយ ។

៩៧-បើមានកូនក្រមុំ ត្រូវតែកុំបណ្តោយឆ្ងាយ
ឲ្យមើលនាយមើលអាយ ត្រូវចទៅម្តាយរក្សាកូន ។

៩៨-ប្រយ័ត្នកុំឲ្យឃ្លាត ភ្លាត់បាវយាទ្ធមិនសុខស្ងួន
កុំទុកចិត្តបងប្អូន ជីដូនមួយជួយរក្សា ។

៩៩-ក្រមុំមានប្រពាក់មិត្រ មេមួយគិតនាំកិច្ចការ
កុំជឿចិត្តនរណា មើលកិរិយានៃកូនឯង ។

១០០-ទោះស្លូតដកយប់ថ្ងៃ ដើរយកដៃដាច់សង្វែង
ប្រុសខូចល្អបន្លែង តែទាស់ភ្នែកបែកបេក្ខា ។

១០១-ច្រើនណាស់តែសែនខ្លោច គ្រឿងអាសោចផុតអាសា
នាំអូនឡើងសាលា គេថាឲ្យផ្ញីចិត្ត ។

១០២-បើមានកូនប្រុសា មិនទាន់ការគួរឲ្យប្រិត
កុំឲ្យបំភើផ្តិត អាណិតរាៗ សងគុណ ។

១០៣-យប់ថ្ងៃចូលប្រតិបត្តិ គាត់ក្រវាត់រត់រកពុន
អាចនឹងច្រើនជឿបុន ស៊ីនអំពីឪពុកម្តាយ ។

១០៤-រក្សាកូនប្រពន្ធ រកទ្រព្យធនចង់ធូរចាយ
ផ្តួញដឹកគំនិតឆ្ងាយ ផ្តួញរៀងអាយរក្សាគុណ ។

១០៥-អំពើបាបកុំរៀន កុំអៀនប្រៀនក្នុងការបុណ្យ
លាងទោសចេញជាមុន ទើបធ្វើបុណ្យចំរើនផល ។

១០៦-បើនឹងចងគង់ទ្រព្យ កុំទំលាប់សាងអកុសល
ហើញបុញរៀចកាចកល់ ទេវតាផ្តល់ផ្តាច់ធនធាន ។



www.elibraryofcambodia.org

១០៧-កុំឈ្នានីសអ្នកខ្សត់ កុំបំភ្លាត់ទ្រព្យអ្នកមាន
បើខ្លួនខ្សត់អត់ឃ្លាន រៀនតែរកតាមទៀងត្រង់ ។
១០៨-ជួញខាតកុំឈប់ខាន បើចង់បានកុំខ្លាចបង់
ខ្លាចបាត់ឲ្យផ្ចិតផ្ចង់ ប្រុងថែទាំឲ្យមាំមួន ។
១០៩-កុំភ្លើផ្ដើផាភ្លេច ភ្ញាក់បន្តិចខ្លាចក្រែងជួន
ក្រែងចោរចូលមកពួន លួនលបលួចយកទ្រព្យទៅ ។
១១០-ប្រហែសតែងតែបាត់ ប្រុងប្រយ័ត្នតែងតែនៅ
គិតសព្វគ្រប់ដោយផ្លូវ សូរទ្រាំនឿយកុំទ្រាំក្រ ។
១១១-នៅផ្ទះស្រះរបង របាចងឲ្យជាប់ល្អ
ប្រើប្រាស់ខ្ញុំកំដរ ឲ្យបរិភោគដោយខ្លួនឯង ។
១១២-នឹងប្រើទៅហៅមក កុំគំហកយកកំហែង
កុំហារឡើងហេងឯង ក្រែងកំហល់ទល់កំហឹង ។
១១៣-កុំប្អូសពាក្យសម្ដី ការអ៊ីៗឲ្យចេះថ្លឹង
កុំប្រើគ្រួកលើប្រឹង ក្រែងកើតនឹងវានវែខាត ។
១១៤-មនុស្សខឹងច្រើនៗខុស មនុស្សច្រើនឈ្លោះច្រើនប្រមាថ
ការល្អច្រើនភ្លួរខ្លាត យើងចង់ស្អាតកុំខ្លាចយូរ ។
១១៥-ចង់ប្រាជ្ញឲ្យខំប្រឹង ចងក្បៀនតឹងរកស៊ីនូវ
គំនិតមុនគំនូរ រៀនមានគ្រូមានគេរាប់ ។
១១៦-បំរើឪពុកម្ដាយ អ្នកនៅឆ្ងាយគេច្រើនគាប់
អ្នកណាបំរើខ្ជាប់ ធ្លាប់តែខុសមិនដែលត្រូវ ។
១១៧-ជាតិមនុស្សមានខ្ពស់ទាប មិនចោលភាពពីម៉ែឪ
ពាក្យមនុស្សវែងជាងផ្លូវ ស្រូវច្រើនខួបខូចអង្ករ ។
១១៨-របស់ទ្រព្យថោកថ្លៃ ទុកសំចៃលៃឲ្យល្អ
អុងអាងពាងក្រឡ ត្រដរទិញកុំឲ្យខ្វះ ។



www.elibraryofcambodia.org

១១៩-កើតមកខ្លួនជាអាស្ត្រ ក្រព្រាក់មាសឲ្យមានខ្នាស
សារពើគ្រឿងប្រើប្រាស់ ឲ្យមានចាស់ឲ្យមានថ្មី ។

១២០-ពូថៅនិងកាំបិត ពន្លាកខ្វិតចបជែងខ្លី
ខ្សែរសេះគោក្របី ឫស្សីផ្តៅកាច់សង្រែក ។

១២១-ការងារកុំឲ្យក្រ អាក្រក់ល្អមានដោយខ្លែក
ថ្ងៃនេះរបេះបុកបែក ស្អែកខិអើធ្វើជាឆាប់ ។

១២២-ឈ្មោះការប្រើលើដី កុំចាំស្រីតឿនប្រើប្រាប់
ឲ្យមានគ្រប់ប្រដាប់ សំរាប់រាល់ឲ្យសល់ប្រើ ។

១២៣-កុំខ្ជិលច្រូងខ្លៅពេក ចូរចេះដេកឲ្យចេះដើរ
ចេះសព្វគាប់ប្រសើរ កុំចង់បើរហួសភាពខ្លួន ។

១២៤-ចងក្តីឲ្យរៀនច្បាប់ រស់និងស្លាប់ឲ្យចេះក្បួន
ចេះអ្វីចេះឲ្យមួន កុំបន្លំផ្សំនឹងគេ ។

១២៥-កុំដេកចាំសំណាង កុំក្មេងក្មាងចាំបុព្វេ
អំរកកុំទំនេរ រៀនវិះចេះឲ្យគ្រប់ ។

១២៦-នឹងដើរស្វែងរកផល មិនទាន់ដល់កុំអាលឈប់
ឈានខ្លាំងពេកជំពប់ បើដេកយប់ឲ្យស្គាល់យាម ។

១២៧-កុំដេកយូរទ្របិក លក់ហួសព្រឹកខុសទំនៀម
តែភ្លឺឡើងភ្ញាក់ភ្លាម ច្រហាមឡើងក្រោកធ្វើការ ។

១២៨-ជាតិមនុស្សទោះប្រុសស្រី រាស្ត្រមន្ត្រីជាធម្មតា
ពេលព្រឹកតែងឧស្សាហ៍ ថ្ងៃក្តៅល្ងាចខ្ជិលល្អិតល្អឹង ។

១២៩-ចង់ធំទំពីតូច បើខ្លាចខូចកុំឆាប់ខឹង
ការអ្វីឲ្យចេះទ្រឹង កុំប្រឹងផុះតាមដើរ ។

១៣០-កុំចង់ខ្ពស់ស្មើមេឃ កុំងឹងពេកអាប់រាសី
ទោះដើរនិយាយស្តី ពៃឲ្យល្អមតែគួរសម ។



www.elibraryofcambodia.org

១៣១-យល់ឆ្ងាយកុំណាយគិត ទោះយល់ជិតកុំអាលខំ
មិនដាក់មើលឲ្យធំ ក្រែងច្រឡំសជាខ្មៅ ។
១៣២-ទម្លាប់នំផាងឲ្យរាប់ បើរៀនត្រាប់កុំត្រាប់ខ្លៅ
ត្រាប់ប្រាជ្ញអាចប្រដៅ ស្តីកូនចៅស្តីឲ្យស្មោះ ។
១៣៣-ស្ទឹងស្ទើលសើលរបៀន ឲ្យគេរៀនកុំឲ្យអស់
ស្រឡាញ់កុំញ៉េះញ៉ោះ បើខឹងទាស់កុំឲ្យទាយ ។
១៣៤-ទំនួញព្រះកុំព្រួយពេក ឃើញខ្មែរដេកកុំមើលងាយ
កំណាប់ដប់សំពាយ កុំនិយាយប្រាប់សំឡាញ់ ។
១៣៥-សំឡឹងមើលឲ្យសព្វ បើនឹងស្អប់កុំអាលប្រាញ់
ក្តីឈ្មោះគេចុះចាញ់ កុំក្រាញ់តាមផ្តន្ទាទៀត ។
១៣៦-បើខឹងកុំរំលោភ បើនឹងល្មោភឲ្យល្អបអោឌ
កុំមាត់ក្រែងភ្លាត់ស្មៀត ភតហួសរង់ផុងគំនិត ។
១៣៧-កំណើតអាក្រក់ល្អ មាននិងក្រគឺគំនិត
ពីកាលបុព្វពិត ងងឹតពេកមើលមិនយល់ ។
១៣៨-ដាំដូងឲ្យខំថែ ចង់ស៊ីផ្លែឲ្យដុតគល់
បើដូនសំណាងដល់ រស់តែស៊ីឆ្ងាញ់ពិសា ។
១៣៩-ប្រាជ្ញប្រើតប្រៀនប្រដៅ ចូរកូនចៅពិចារណា
ពឹងក្នុងប្រាជ្ញា ស្រាយបញ្ហានេះឲ្យដឹង ។
១៤០-នេះច្បាប់គេរកាលថ្មី អស់សេចក្តីតែប៉ុណ្ណឹង
កូនប្រុសអ្នកខំប្រឹង សំឡឹងចាំតទៅមុខ ។
១៤១-ពីឆ្នាំចតទៅ ខំធ្វើស្រូវដាក់ជង្រុក
អាស្រូវពាក្យអាពុក ទុកឲ្យកូនចៅគ្រប់គ្នា ។
១៤២-អាពុកកាន់តែចាស់ ស្តាយខ្លួនណាស់ចូលជរា
ពាក្យពិតប្រើយល្បា ផាស្រូវចេញ្ញើរឯងហោង ។

១៤៣-អ្នកប្រាជ្ញភិរម្យល្បី លើកច្បាប់ថ្មីអស់ល្បត់ល្បង
ឈ្មោះអ៊ុំហៅប៉ុយផង ចងជាច្បាប់សម្រាប់ជន ។
១៤៤-ខ្ញុំសូមផ្សងសច្ចា កើតជាតិណាសូមមានបុណ្យ
មួយកូនមួយប្រពន្ធ ធនសម្បត្តិសម្បូរបាយ ។
១៤៥-ស្មាលោ ក្រលំបាក សូមជៀសចាកចតុរាយបាយ
សូមល្អពង្សរូបកាយ កុំឲ្យឆ្ងាយពីព្រះពុទ្ធ ។
១៤៦-ប្រាថ្នាកុំទើសទាល់ ចេះអាថ៌ធម៌ឲ្យមាំមុត
សូមជាប់សីលបរិសុទ្ធ រលត់ទុក្ខសោករោគភ័យ ។
១៤៧-អានិសង្សបុណ្យខ្ញុំបាន សាងប៉ុន្មានក្នុងលោកិយ
សម្បត្តិសួគ៌ាល័យ កុំបីឃ្លាតរាតរែងឆ្ងាយ ។
១៤៨-ពីជាតិនេះទៅមុខ មួយអាពុកជួបមួយម្តាយ
បងប្អូនកុំខ្ចាត់ខ្ចាយ អធិប្បាយថែងចប់ឯទ ។



www.elibraryofcambodia.org

# សេចក្ដី
# រំលឹកដាស់តឿន

១-អ្នកព្រះភិរម្យភាសាអ៊ូ
លើកដៃទាំងគូប្រណម្យផ្ទង់
បង្គំព្រះពុទ្ធគ្រប់ព្រះអង្គ
ព្រះធម៌ព្រះសង្ឃប្រសើរសាយ ។
២-ព្រះគុណគ្រូឧបជ្ឈាយាចារ្យ
មាតាបិតាបង្កើតកាយ
បង្កើតប្រាជ្ញាថ្លាវែងឆ្ងាយ
ខ្ញុំសូមអធិប្បាយចែកពាក្យជូន ។
៣-ព្រះពុទ្ធសករាជព្រះសាសនា
អតិក្កន្តាកន្លងផ្ទួន
ពីរពាន់បួនរយចិតសិបបួន
ជូនខែនិងថ្ងៃគ្មានកន្លង ។
៤-ដើមឆ្នាំមមែក្នុងត្រីស័ក
ពិសាខភ្លៀងធ្លាក់កាត់ទឹកម្ដង
មួយកេចថ្ងៃសៅរ៍កើតសៅហ្មង
ឮពាក្យអ្នកផងទាស់ទែងគ្នា ។
៥-មិនបានការប់ចាក់ដល់បាក់បែក
ថ្ងៃនេះផងដែកថ្ងៃស្អែកជា
ចាក់ដោតរាលរោលពោលពណ៌នា
និន្ទាដៀលត្មះចាស់បុរាណ ។
៦-ពួកចាស់ដៀលត្មះអ្នកប្រាជ្ញថ្មី
រឿងធម៌បាលីស្ដីប្រមាណ
ប្រមាថទៅបកមិនយប់ខាន
ហាមប្រាមមិនបានមិនបាត់មាត់ ។
៧-ព្រះធម៌ព្រះពុទ្ធតែមួយអង្គ
លោកសង្ឃបួសរៀនមានដោយវត្ត
សង្ឃខ្លះចេះស្ទើរមិនចាំស្ទាត់
ភ្លើៗ សូត្រភ្លាត់មិនត្រូវខ្យល់ ។
៨-គេប្រាប់ថាខុសប្រកាន់ខឹង
មិនដឹងថាខ្លួនរៀនមិនដល់
មិនដែលសួរគេព្រោះមិនឆ្ងល់
សម្គាល់ថាខ្លួនត្រូវមិនខុស ។
៩-អ្នកប្រាជ្ញលោកសូត្រចំបាលី
ថាគេធម៌ថ្មីស្ដីបន្ទុះ
បន្ទោសទៅមកឆ្លើយឆ្លងឈ្លោះ
មិនព្រមចំណុះខុសចំណាំ ។
១០-ចំណែកចំណេះចេះរស់ខ្លួន
បារាជិកបួនវិន័យប្រាំ



www.elibraryofcambodia.org

មហាវគ្គចុល្លវគ្គអាទិកម្ម    ព្រះអង្គគ្មានផ្ដាំឲ្យឈ្លោះគ្នា ។
១១-ផ្ដាំឲ្យតែកាន់សិក្ខាបទ    អ្នកបួសរាល់រូបត្រូវសាមគ្គា
ព្រះពុទ្ធរូបរាល់វិហារ    វន្ទាគោរពរាល់យប់ថ្ងៃ ។
១២-នមស្ការបង្គំធម៌បីបទ    សូត្រហាហបមាត់ឡើយដើងដៃ
មិនដឹងប្រាកដរតនត្រ័យ    មិនចេះសង្ស័យសួរអ្នកណា ។
១៣-អ្នកប្រាជ្ញលោកសូត្រចំបាលី    ប្រែចេញសេចក្ដីឲ្យពិស្ដារ
អ្នកខ្លៅមិនស្ដាប់ពុទ្ធដីកា    គេថាខ្លួនខុសប្រកាន់ខឹង ។
១៤-ធម៌សម្មុទ្ទេសូត្រលាន់ៗ    ព្រះពុទ្ធឃពាន់ខ្លះមិនដឹង
ជឿជាក់ថាចេះចប់ប៉ុណ្ណឹង    មិនប្រឹងរៀនប្រែបកបរិយាយ ។
១៥-ចេះហើយមិនដឹងខ្លួនខុស    មិនព្រមជំណុះអ្នកប្រាជ្ញប្រាយ
បាលីច្រឡំពាក្យនិស្រាយ    នឹកស្ដាយបែបចាស់មិនផ្លាស់ចេញ ។
១៦-គេថាសូត្រធម៌មិនចេះប្រែ    បានបុណ្យខ្លះដែរតែមិនពេញ
បើចេះប្រែផងបានចំណេញ    ខ្លួនរឹតទន្ទេញតែបែបចាស់ ។
១៧-ចចេសទទឹងរឹងជជែក    ប្រកឹងប្រកែកប្រកូកម្នះ[143]
ម្នៅ[144]សត្រូវនឹងធម៌ព្រះ    ជាតិក្រោយក្រឡាស់ជាល្ងង់ខ្លៅ ។
១៨-មានកាលក្រឡប់ជាគថ្លង់    មម៉េងមម៉ងឆ្កួតមួរម៉ៅ
ពីព្រោះមិនស្ដាប់ប្រាជ្ញប្រដៅ    ហ្នឹងហៅចេះហើយមិនប្រសប់ ។
១៩ ប្រសិនបើឱនខ្លួនខ្លបខ្លាច    អ្នកប្រាជ្ញកាលណាលោកនឹងស្ដាប់
ធម៌អាចអ្នកណានឹងចេះចប់    កុំកាន់ទម្លាប់ទម្លោយខ្លួន ។
២០-ទម្លាប់ឲ្យទបសុភាពវ័យ    ព្រះសូត្រវិន័យធំជាងក្បួន
ព្រះអភិធម្មជាមាំមួន    ចេះហើយប្រឆ្លូនគួររៀនទៀត ។

---

[143] ដែលត្រឹមត្រូវគឺ «មានះ»(កំណត់ពុទ្ធសាសនបណ្ឌិត្យ, បោះពុទ្ធទី៧, ១៩៧៣)
[144] «មិននៅ» ។ កវីបានបង្រួញឲ្យនៅតែមួយព្យាង្គដើម្បីគោរពជើងកាព្យ ។



www.elibraryofcambodia.org

២១-ពាក្យពីបុរាណជាពាក្យងាយ ពាក្យក្បួនទូលាយស្រណុកជៀត
ឯពាក្យគម្ពីរទីចង្អៀត គួរឆ្លៀតជ្រើសរកយកឲ្យបាន ។
២២-ឲ្យបែកគំនិតគិតច្រើនផ្លូវ មួយខុសមួយត្រូវជាពីរស្ថាន
គេប្រាប់ថាខុសគួរឈប់ខាន ឃើញត្រូវប៉ុន្នុះនប្រមូលយក ។
២៣-ព្រះឱស្ឋព្រះអង្គទ្រង់ទេសនា អ្នកប្រាជ្ញថែងចារចងទុកមក
ព្រះសូត្រនៃវិន័យលោកលៃលក ប្រែសព្ទសៀតសំកច្រើនប្រការ ។
២៤-ពាក្យពិតប្រាកដបទបាលី ប្រែចេញសេចក្ដីឃើញពិស្ដារ
គួរស្ដាប់ឲ្យស្ទែងសិនសុំថា កុំអាងគម្រោតម្រាប់ចាស់ ។
២៥-គម្រាយបុរាណយូរអង្វែង មិនលែងច្រឡំមានលើសខ្វះ
អ្នកប្រាជ្ញជំនុំឃើញខុសណាស់ ចោលខ្លះទុកខ្លះដោយពិស្ដារ ។
២៦-យ៉ាងធម៌ «តិរោក»[145]ពីបុរាណ មិនដឹងជាបានពីគ្រូណា
សូត្រលាយចម្រុះខុសអក្ខរា មិនបានជាការប្រយោជន៍អ្វី ។
២៧-អ្នកប្រាជ្ញឃើញខុសច្រើនអន្លើ រុះរើរៀបចំផ្សំបាលី
អ្នកខ្លះហៅធម៌តិរោកថ្មី សម្ដីបែបឡកចំអកខឹង ។
២៨-សង្ខេបរឿងសូត្រធម៌ត្រូវខុស កូនចៅប្រុសៗគួរខំប្រឹង
ប្រាប់រកអ្នកប្រាជ្ញប្រិតឲ្យដឹង សម្លឹងអក្ខរាឲ្យប្រាកដ ។
២៩-ប្រការមួយទៀតចាស់ជាន់មុន ធ្វើបុណ្យអភិសេកបែបច្រើនបទ
ច្រើនបែបរាប់អានគ្មានកំណត់ សន្មតថាធ្វើតាមបុរាណ ។
៣០-អាចារ្យមួយប៉ែកអភិសេកខ្ពិល បន្ទិលពពិលរំពេចបាន

[145] ឈ្មោះសូត្រ១ក្នុងព្រះសុត្តន្តបិដកហៅថាតិរោកុឌ្ឍសូត្រក៏បាន, ឬហៅដោយខ្លីតាមទម្លាប់ស្រួលមាត់ត្រឹមតែតិរោកប៉ុណ្ណេះក៏បាន, ក្នុងប្រទេសខ្មែរយើងប្រើជាធម៌សម្រាប់សូត្រដោះឧទ្ទិសចំណែកបុណ្យ (វចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, ទំព័រ៣៨៥-៣៨៦) ។


www.elibraryofcambodia.org

អាចារ្យមួយចាំធ្វើតាមដាន
លំអានគម្ពីរបឋមក្រាស់ ។

៣១-ទេសន៍ទសជាតក៏ចប់អភិសេក
ព្រឹកស្អែករៀបចំមធុបាយាស
មានមារលើកពលច្បាំងដេរដាស
ធ្វើប្រាសត្រឡប់ក្រោយជាមុន ។

៣២-បើធ្វើឲ្យត្រូវតាមសាស្ត្រា
នាងនាថសុជាតាគេមានគុណ
ថ្វាយមធុបាយាសព្រះមានបុណ្យ
និមន្តទៅផ្សងបីដងក្រាស់ ។

៣៣-ទេវតាផ្អើលចុះពេញផែនដី
គ្រប់ទិសប្រាំបីមីរដេរដាស
កក្រើកញាប់ញ័រទាំងអាកាស
អរណាស់ថ្វាយសព្ទសាធុការ ។

៣៤-ហេតុនេះអ្នកចេះចាំនិទាន
ធ្វើរោងធ្វើរានថ្វាយទេវតា
អ្នកប្រាជ្ញចេះធ្វើត្រដីថា
អាចារ្យនាំធ្វើខាតប្រយោជន៍ ។

៣៥-អាកាសទេវតានៅស្ថានខ្ពស់
គេខ្ពើមជាតិមនុស្សក្លិនអសោច
ឱស្សាហ៍ដាក់នំឲ្យហិនហោច
ចំណោញស្រមោចចោមរោមស៊ី ។

៣៦-អាចារ្យមួយទៀតចេះរៀបចំ
ប្រណម្យសំពះក្រុងពាលី
ព្រះឥសូរព្រះនារាយណ៍មានរិទ្ធី
ពេញទីចោលត្រៃសរណគមន៍ ។

៣៧-ចំណីចំណែកចែកដាក់ពែ
ចំណេញបានឆ្អែតវាស៊ីនំ
នាងហ៊ីងធរណីថាជាធំ
សូមសុំទឹកដីសាងកុសល ។

៣៨-អាចារ្យជាន់ចាស់ដោះសង្ស័យ
ថារតនត្រ័យគេតម្កល់
តម្កើងលើកឡើងជាដើមផល
ប្តឹងដល់ទេវតាជាសាក្សី ។

៣៩-សសង្ខារករលើកគុណ
ធ្វើបុណ្យអភិសេកព្រះពុទ្ធថ្មី
បូជាភ្លើផ្កាស្លាបារី
គ្រប់ទិសប្រាំបីសឹងឲ្យមាន ។

៤០-អភិសេកព្រះពុទ្ធតាំងកសាង
តំណាងព្រះពុទ្ធដ៏ទ្រង់ញាណ
លើកទេវតាជាប្រធាន
ប្រាថ្នាទិព្វានស្ថានផុតទុក្ខ ។

៤១-ចាស់បើទេវតាខ្ពើមចំណី
ស្អប់ស្លាបារីមិនចង់ជក់
បិសាចស្ទើរៗ មិនលែងភ្លក់
អារុក្ខទេវតាមិនលែងសោយ ។

៤២-ទំនែកចំណីឆ្អែតស្អប់ស្អល់
សេសសល់បានប្រេតគ្នាស៊ីក្រោយ ។



www.elibraryofcambodia.org

ស៊ីគ្រាន់រូបរស់ព្រោះគេឲ្យ បានដោយមគ្គផលកុសលដារ ។
៤៣-លោកសូត្រតិរោកតែរាល់ព្រឹក យកិញ្ញីច្រួចទឹកថែមយបា
បញ្ជូនអានិសង្សដល់ដូនតា ប្រាថ្នាដូចម្តេចក៏សឹងបាន ។
៤៤-ក្រែងដូនតាណាទៅជាប្រេត ឬមួយអណ្តែតជាតិរច្ឆាន
លើសខ្លះប៉ុណ្ណោះខុសប៉ុន្មាន រាប់អានទេវតាប្រាថ្នាសុខ ។
៤៥-ថាបើទេវតាមិនព្រមសោយ កុំឲ្យតែខុសចុះនរក
នរុកើតកាន់ផុតពីភក់ វិកក្នុងវាលវដ្តសង្សារ ។
៤៦-មិនដាច់សង្ស័យដូចអរហន្ត លោកកាត់កាមគុណនិងតណ្ហា
ត្រង់ភ្លឺងមិនងាកពឹងទេវតា ប្រាថ្នានិព្វានគ្មានត្រឡប់ ។
៤៧-ឃើញផ្លូវមិនផុតភពទាំងបី ធម៌អាថ៌បាលីចេះមិនចប់
មិនចោលសីល៥កម្មបថ១០ រាងរៀបឲ្យសព្វកុំឲ្យសល់ ។
៤៨-សម្បត្តិសួគ៌សុខកើតពីទាន ឈោងយកនិព្វានឈានមិនដល់
មិនដើរហួសសោតាបត្តិផល គម្កល់និព្វានទុកដោយឡែក ។
៤៩-នេះចប់ចម្លើយអ្នកប្រាជ្ញចាស់ ប្រាជ្ញថ្មីចង់ពន្យល់ប្រឹងប្រកែក
ព្រោះនិព្វានជាស្ថានឯក បំបែកសោតាក្នុងតែបាន ។
៥០-ប្រែថ្មាធ្វើបុណ្យក៏ធ្វើចុះ ទានណាខាតខុសត្រូវឲ្យខាន
អាត្មាអត្ថកុំរាប់អាន ជាស្ថានទាបថោករកធ្វើអ្វី ។
៥១-សង្ខេបរឿងសូត្រធម៌ត្រូវខុស កូនចៅស្តាប់ចុះទាំងប្រុសស្រី
អ្នកប្រាជ្ញពួកចាស់និងពួកថ្មី គប្បីថ្លឹងចិត្តជឿពួកណា ។
៥២-បើរឿងសូត្រធម៌អាថ៌បាលី ពួកចុលប្រាជ្ញថ្មីខំសិក្សា
ប្រយោគប្រធានបានមាត្រា រាជការបានគីប្រឡងជាប់ ។
៥៣-ប្រាជ្ញចាស់ជាន់មុនធ្វើបុណ្យទាន ធ្វើរានទេវតាដោយសារធ្លាប់
អ្នកជោគល្បង់ខ្លៅគ្នាខ្លាចងាប់ អាចារ្យបង្គាប់គ្នាធ្វើទៅ ។
៥៤-បើប្រែជាខានមិនបានសុខ មិនបានធ្លាប់ចុះនរកជ្រៅ



www.elibraryofcambodia.org

បើធ្វើទេវតាមិនផ្ទុកនៅ ស្ថានគេសន្មៅសន្និងហោះ ។
៥៥-ហេតុនេះគួរគិតគួររំពឹង ផញ្ញឹងកុំឲ្យសល់ចន្លោះ
ចាស់មុនមានគុណរាប់មិនអស់ មិនឲ្យពោលសោះក៏មិនបាន ។
៥៦-គួរគិតឲ្យគ្រប់សព្វអន្លើ គួរធ្វើឬគួរបង្អង់ខាន
បើធ្វើមិនខានបង់ប៉ុន្មាន បើខាតក៏គ្មានទោសទាស់អ្វី ។
៥៧-ប៉ុន្តែមិនបាត់ពាក្យចាក់ដោត ដ្បិតមនុស្សច្រើនឆោតទាំងប្រុសស្រី
ពោលថាធ្វើបុណ្យតាមប្រាជ្ញថ្មី អាយុថយខ្លីជាងដូនតា ។
៥៨-ពាក្យនេះសង្ខេបស្លួរមួយប៉ែក មានឈ្មោះប្រកែកច្រើនប្រការ
មិនចាំប្រាកដគម្ពីរណា ពោលថាទឹកដីនេះគ្មានគុណ ។
៥៩-អ្នកប្រាជ្ញនាំឲ្យអ្នកខ្លៅឆ្ងល់ សាយសុសសួរដល់ពួកអ្នកមុន
អ្នកមួយទេវារង់ចែកពុន មិនទាន់ចូលស៊ុនស៊ប់ម្នាក់ៗ ។
៦០-អ្នកក្រោយបណ្តោយសួរអ្នកមុន ថាដីមានគុណប៉ុន្មានយ៉ាង
សម្តេចពោលអ្វីជាតឹកតាង មានអាងឃើញក្នុងគម្ពីរណា ។
៦១-អ្នកប្រាជ្ញថាអាងនគរកាយ បរបក្ខអធិប្បាយក្នុងសាស្ត្រ
ធាតុទឹកក្នុងអង្គអាត្មា ជាគុណមាតាពីដណ្តប់ ។
៦២-ធាតុទឹករំលឹកពីសេដ្ឋិ ហាំយកធំហូតរប់
ធាតុដីភេសាវស់សំសព្វ បញ្ចប់ចិត្តគុណបិតា ។
៦៣-អ្នកបេះបិទកស្លឹយបីផង ថានេះជាកងពួកកេសា
ហៅធម៌អាចម៍នោមក៏ល្មមល្អា អ្នកណារំលឹកគ្មានប្រយោជន៍ ។
៦៤-អ្នកមួយថាភានោកុំឈប់ ជាទិអសុភផ្លូវអសោច
អសារះឥតការស្លាប់ជាខ្មោច គេដុតឆេះខ្លោចគ្មានខ្លឹមសារ ។
៦៥-គួរគិតកុំស្តាយកុំស្រណោះ រូបកាយទាំងអស់ជាអនិច្ចា
អនិច្ចំមិនទៀងល្មៀងសង្ខារ សង្ខេបរូបនេះមិនបាន ។
៦៦-សរសៃសាច់ស្បែកសង្វែគគ្រប់ ជាសាកអសុភកម្មដ្ឋាន



www.elibraryofcambodia.org

របស់ខាងក្នុងទាំងប៉ុន្មាន មុខជាមិនខានរលាយបាត់ ។

៦៧-ទឹកដីខាងក្រៅក៏មានគុណ ព្រោះដីកើតមុនទើបកើតសត្វ
កើតសត្វរូបកាយអធិប្បាយកាត់ លើកឡាត់លះឃ្លាឲ្យយ៉ាងខ្លី ។

៦៨-គម្ពីរត្រៃភេទដើមសាសនា ត្រៃយុគត្រៃតាគ្រប់ជាបើ
ព្រះពុទ្ធចេញសាងអាងទឹកដី សន្សំបារមីក្នុងភទ្ទកប្ប ។

៦៩-ភទ្ទកប្បនេះមានព្រះពុទ្ធ៥ បានរៀនចេះចាំជាសណ្តាប់
សម្តែងថាចុះនរកមួយកប្ប លោកប្រាប់ថាព្រោះដេរទឹកដី ។

៧០-អ្នកម្នាងថាអាងរៀនសាស្ត្រា ប្រែអស់គាថាបទបាលី
ព្រះពុទ្ធទតគ្រប់ភពទាំងបី ត្រង់គុណទឹកដីមិនឃើញមាន ។

៧១-កេសាអក្ខរាទាំង៤តួ មិនគួរបើយកមកសន្និដ្ឋាន
យើងចេះដឹងដែរតែមិនហ៊ាន ដូចពាលបំពានហួសពុទ្ធដីកា ។

៧២-ពាក្យនេះអ្នកខ្លះកើតសង្ស័យ សព្វថ្ងៃនៅក្នុងឧបក្កា
មិនទាន់ដាច់ស្រេចទៅខាងណា មិនឃើញពិស្តារស្តាប់មិនបាន ។

៧៣-មួយទៀតប្រាជ្ញថ្មីស្តីដៀលត្មះ ចង្ហាន់ថ្វាយព្រះថាឲ្យខាន
ព្រោះព្រះមិនឆាន់នៅពេញចាន របស់ប៉ុន្មានបានអាចារ្យ ។

៧៤-របៀបរាប់បាត្រមានកន្លោង មួយពោងពីរពោងហៅបាយដាប
បាយដាក់ហ្មឹងតើឲ្យអ្នកណា អសារឥតការឥតប្រយោជន៍ ។

៧៥-ព្រះពុទ្ធមិនឆាន់មិនចេះស្តី យើងអាងបាលីឧទ្ទិសដល់
តម្លើងចង្ហាន់លើកតម្កល់ សេសសល់ប្រគេននេនសាមណេរ ។

៧៦-សមណៈបួសរៀនមានសីលដប់ ប្រសប់ប្រសើរគ្រាន់បើដែរ
បញ្ជូនមគ្គផលដល់ឪម៉ែ បង្វែឧទ្ទិសតាមប្រាថ្នា ។

៧៧-អ្នកវេតំនិតគិតតែកាញ់ ចូលបទកំណាញ់ក្រៅតម្រា
ទុកស៊ីម្នាក់ឯងឆ្ងាញ់ពីសា ខ្លាចបានអាចារ្យស៊ីខាតទុន ។

៧៨-អ្នកម្នាងថាអាងដាក់ឲ្យប្រេត ដោយហេតុគ្មានឃ្លានគ្មានហិនហោច



www.elibraryofcambodia.org

ក្អាស៊ីខ្ទុះឈាមក្លិនអសោច    បិចបោចរែកទានគ្នាស៊ីផង ។
៧៩- ឬបកត្រូវជាញាតិឪបិតាពាក    គ្នាបានដើបមកព្រោះគេផ្សង
បានស៊ីដោយសារដងម្ដងៗ    បានរួចបំណងបំណាច់នឹក ។
៨០- ចង្អុលផ្កាយព្រះត្រូវបូជា    អាចារ្យទន្ទាស្មូត្ររំលឹក
ព្រះពុទ្ធមានគុណបុនលោកភិក្ខុ    បាយទឹកជាទានមានមគ្គផល ។
៨១- ម្យ៉ាងទៀតប្រាថ្នាថ្មីស្រដីផ្ដាច់    ថាពូនភ្នំខ្សាច់មិនបានបុណ្យ
ដក់ដីលៀនភ្នែករែកពូន    ដឹងបានជាគុណប្រយោជន៍អ្វី ។
៨២- នាំគ្នាអុជធូបបែរទក្សិណ    អាចារ្យនោះឆ្អិនខាងបាលី
ហើយមានចេះធម៌បួសដី    មិនដឹងជាដីឆ្លើយថាម្ដេច ។
៨៣- អ្នកប្លុយថាពូនភ្នំខ្សាច់ស្ពាង    តំណាងចេតិយព្រះសព្វេជ្ញ
ព្រះសរីរិកធាតុយើងមិនភ្លេច    ខ្សត់បុណ្យយើងតិចទៅមិនដល់ ។
៨៤- បើធ្វើដោយពលកណ្ដាលថ្ងៃ    គង់ជាប់និស្ស័យបានកុសល
បើដើមពោធិ៍ពិតទិតបានផល    តម្កល់ដើមពោធិ៍យកជាម្លប់ ។
៨៥- ពូនភ្នំតម្កើងពោធិ៍ព្រឹក្ស    រលឹកដល់អង្គព្រះធមភព
ស្រះក្ដារ៤ផ្លាំងបង្គាំងផ្លប់    កុំឲ្យកំពប់ហៀរហូរដី ។
៨៦- បើចេះរំលឹកបានបុណ្យណាស់    ជឿចុះប្រាថ្នាចាស់កុំជឿថ្មី
ប្រាថ្នាចាស់ក៏ចេះប្រែបាលី    បរលោកលោកិយក៏ចាស់ដឹង ។
៨៧- ចាស់ម្យ៉ាងចាស់ពិតគំនិតពាល    ចាក់ដោតពោលពាលនាំក្មេងខឹង
ចាស់ប៉្រាំងផឹកស្រាគ្នាស្រវឹង    ចាស់ហ្នឹងហៅក្មេងក៏ស៊ីងបាន ។
៨៨- ចាស់ជាន់ពីមុនច្រើនខ្លាចច្បាប់    ធ្វើតាមតម្រាប់ចាស់បុរាណ
ហុីនតាធ្លាប់រាប់អាន    តែទានខ្លាចខុសក្បួនតម្រា ។
៨៩- ច្រើនជឿតម្រាប់ក្បួនលោកិយ    មានក្បួនប្រុសស្រីត្រូវរៀបការ
សម្លាប់ជ្រូកមាន់ស៊ីហ៊ីហា    ផឹកស្រាលៀនភ្នែកជំរែកឈ្លោះ ។
៩០- បណ្ដោយឲ្យយកគ្នាទទេ    មេបាធ្វើតេក្រែងបិនរស់

នាំកូនសែនខ្មោចអសោចឈ្មោះ ពីព្រោះមានប្តីមិនរៀបការ ។
៩១-រៀបកិច្ចមង្គលមានច្រើនយ៉ាង ពួកចាស់ច្រើនអាងក្បួនតម្រា
បើតាមតម្រាយព្រះសូត្រថា មេបានាំកូនចុះនរក ។
៩២-បុត្តទារស្មេរសង្គហោ ហើនោគារមោធម៌អ្នកស្រុក
សង្គ្រោះកូនផុងទៅក្នុងភក់ ហ្នឹងហៅអាពុកពន្លិចកូន ។
៩៣-បើធ្វើមង្គលឲ្យរួចបាប រួចរៀងរាបអស់តាដូន
មង្គលយ៉ាងល្អបរិសុទ្ធសូន្យ ប្រមូលបងប្អូនស៊ីម្លូស្លា ។
៩៤-ជ្រូកមាន់កុំចាំបាច់សម្លាប់ តែសាកមានស្រាប់ទិញពីផ្សារ
ឲ្យកូនប្រុសស្រីគាល់មេបា អាចារ្យប្រមូលអស់ចាស់ទុំ ។
៩៥-ប្រុសស្រីអង្គុយកាន់ពពិល បង្វិលប្រាំបួនដណ្តប់ជុំ
ធ្វើកិច្ចមង្គលក្នុងជំនុំ ឲ្យផ្តុំកូនប្រុសនិងកូនស្រី ។
៩៦-ចាស់ៗធ្វើច្រើនធ្វើក្នុងឆោត ចង់ឲ្យគេកោតក្នុងលោកិយ
យើងធ្វើយ៉ាងតិចក្រឡេកខ្លី បានប្តីប្រពន្ធដូចៗគ្នា ។
៩៧-ហៅកូនសង្គ្រោះម្តាយអាពុក រួចទោសរួចទុក្ខអស់មីងមា
អាពុកសង្គ្រោះគ្មានអោ អាពាហ៍វិវាហមង្គល ។
៩៨-មិនគួរបង្គាប់ឲ្យគេរជុក ហេតុម្តាយអាពុកនាំរលំ
អាចារ្យតែងក្បួនឲ្យរំពល់ ពន្យល់អ្នកល្ងង់ឲ្យបង់ទ្រព្យ ។
៩៩-អ្នកខ្ជិលគេជឿស៊ីលមាំមួន ពាក្យក្បួនតម្រាគេមិនរាប់
គេថាមិនរស់ពីព្រោះធ្លាប់ មិនរាប់ពីព្រោះមិនធ្វើធ្លេញ ។
១០០-យ៉ាងដូចចិនយួនទៅដាក់ផ្សារ ស្រុកស្រែចំការក្រុងភ្នំពេញ
កើតឡើងដុះសក់មិនកោរវិញ រស់ដូរទិញអង្គុយលក់ ។
១០១-ប៉ុន្តែជាតិចិនល្មោភស៊ីសាច់ គមដាច់មិនដែលស៊ីប្រហុក
ខ្មែរៗប្រហែលខ្វះម្ទេសជ្រក់ ទូលស្រូវកន្ធក់ទៅដូរចិន ។
១០២-ហេតុតែជាខ្មែរសម្បុរខ្មៅ គំនិតគិតឆៅមិនសូវឆ្អិន



www.elibraryofcambodia.org

រកស៊ីមិនឆ្អែតជឿថៃសិទ អាថ៌កភាគិនទារទាល់បាន ។
១០៣-១កើតអស្សុជសម្លាប់មាន ចំអិនគ្រប់គ្រាន់ជួសដាក់ចាន
រៀបសែនព្រះភូមិតាមបុរាណ ថាខានខុសក្បួនប្រពៃណី ។
១០៤-ហ៊ឹងហៅពាសឆេះឆេងក្មេងព្រើល ហែកមាត់មាន់មើលចង្កាពឹះ
អាដែងព្រះភូមិមានឈ្មោលញី ថាសែនរកស៊ីបានផលស្រួះ ។
១០៥-បានដូនដូនតាទៅស្រុកប្រេត បណ្តែតសំប៉ានច្រានសំពៅ
សំពះអាក្អួជខាងឪ ខាងម៉ែក៏ត្រូវមិនសូវខុស ។
១០៦-ថ្វាយចេកថ្វាយស្រាដាវង្វាន់ ខ្មោចចូលជិះជាន់រូបស្រីប្រុស
កូនចៅអើយជឿពុទ្ធដីកាចុះ រូបស្លាប់ពីព្រោះតែផលកម្ម ។
១០៧-រូបសុខដោយសារតែផលបុណ្យ កាលពីជាតិមុនខ្ជាប់សីល៥
ជាតិនេះអាយុអង្វែងឆ្នាំ កូនចៅអ្នកចាំជឿឲ្យជាក់ ។
១០៨-ឲ្យចេះពិចារណាចិត្តឯងផង ស្តាប់ធម៌ម្តងៗគួរឲ្យភ្ញាក់
កុំផ្ញើរូបកាយនឹងអាត្មា ក្រែងធ្លាក់ទៅក្នុងចតុរាបាយ ។
១០៩-បើចង់អាយុវែងយឺនយូរ គោរពគុណគ្រូអាពុកម្តាយ
បើចង់រកស៊ីសុខសប្បាយ ផ្ញើកាយនឹងគុណរតនត្រ័យ ។
១១០-នមស្ការបង្គំពេលល្ងាចព្រឹក ភាវនារំលឹករាល់យប់ថ្ងៃ
កុំថាធម៌ណាថោកណាថ្លៃ សង្ស័យត្រូវសួររាជបណ្ឌិត ។
១១១-កុំឲ្យមន្ទិលធម៌ថ្មីចាស់ មួយធម៌ក្រដាសមួយស្លឹករឹត
រាជការជំនុំរួមគំនិត រិះគិតតម្កើងព្រះសាសនា ។
១១២-តម្កល់សីលប្រាំសីលប្រាំបី ឲ្យមនុស្សប្រុសស្រីរួមរក្សា
ផ្ចាត់ផ្ចៀងខ្លាចល្មើងព្រះពុទ្ធដីកា ពិនិត្យអក្សរាយកត្រឹមត្រូវ ។
១១៣-ជំនុំបោះពុម្ពដាក់ក្រដាស ជាការរហ័សធ្វើសៀវភៅ
ឲ្យមានសូត្ររៀនច្រើនតទៅ ទុកនៅជាកេរ្តិ៍អង្វែងឆ្ងាយ ។
១១៤-សព្វថ្ងៃអ្នកខ្លៅស្អប់អ្នកប្រាជ្ញ ពោលខ្លាំងគិតខ្លាចពួសុសសាយ



www.elibraryofcambodia.org

ថាធម៌សៀវភៅធម៌ក្លែងក្លាយ អធិប្បាយឱ្យបែៗ ហែក្នុងឯង ។
១១៥-ឲ្យស្ទៀមពីថ្ងៃនេះតទៅ ឯធម៌សៀវភៅផែនដីតែង
មិនមែនអ្នកប្រាជ្ញណាហ៊ានក្លែង ខ្លាចក្រែងរាជការចាប់ដាក់គុក ។
១១៦-គម្ពីរស្លឹករឹតជាគំរូ តម្កល់ក្នុងទូចាក់សោទុក
គម្ពីរសៀវភៅប្រើគ្រប់មុខ ទំនុកបម្រុងក្នុងសាសនា ។
១១៧-ចាស់ៗ ជាន់មុនមានគំនិត គម្ពីរស្លឹករឹតផ្ទាល់គេចារ
ពុំនោះជាតេដោយជ្រះថ្លា ច្រើនមានប្រាជ្ញាគិតអ្នកចេះ ។
១១៨-សង្ខេបបទបែបរឿងប្រដៅ ទុន្នានអ្នកខ្លៅឈប់ទុកស្លេះ
សុំក្រើនអ្នកប្រាជ្ញមានតម្រិះ កុំតិះដៀលគ្រូចាស់ជាន់មុន ។
១១៩-កុំថាចាស់ល្ងីល្ងង់ល្ងើល្ងើ ក្រែងពារទៅលើអ្នកមានគុណ
កុំពោលថាចាស់ថយថោកធុន ក្រែងសុនទៅលើគ្រូអាត្មា ។
១២០-ដ្បិតសិស្សនិងគ្រូមិនអ្នកក្រៅ ជាក្មួយជាចៅជាជីតា
ជាសាច់ខាងមាតាឬបិតា ព្រះកម្មវាចាចារ្យខ្លះជាបង ។
១២១-ខ្លះត្រូវជាន់ខ្លះជាមា ជាគ្រូឧបជ្ឈាយ៍បំបួសផង
ប្រដៅសព្វថ្ងៃរាយម្តងៗ ព្រោះលោកបំណងចង់ឲ្យចេះ ។
១២២-ដល់ខ្លួនរៀនចាំជាក់ច្បាស់ ឡើងពាក្យសម្តីអាងតម្រិះ
តម្រូវខាងណោះខុសខាងណេះ ដៀលត្មិះថាគ្រូខ្លួនខ្លៅល្ងង់ ។
១២៣-លោកមិនដឹងព្រើងតែអរ ទំនើរអង្គរបុរការុង
ស្អកក្អមស្អកស្រាក់លាក់មិនគង់ ចង់ឡើងពួដពង្សល្បីកេរ្តិ៍ឈ្មោះ ។
១២៤-ខ្លួនចេះបន្តិចក៏ប៉ុនឡើង ចចើងចចេសជំជែកឈ្មោះ
ចេះកប់ពពកយកកំពស់ បន្ទុះបន្ទន់គុណទាបទៅ ។
១២៥-បើចិត្តចង់ធំកុំចចើង ខំលើកតម្កើងគុណទុកទៅ
ទោសនោះធ្លាក់ចុះនរកជ្រៅ ម្នៀៗ ឲ្យបាបពីព្រះមាត់ ។
១២៦-ព្រោះមាននិទានពុទ្ធឃោសា អាងចេះសាស្ត្រាគម្ពីរស្ទាត់



www.elibraryofcambodia.org

ផាចេះលើសគ្រូៗ បំភ្លាត់ បំប្លែងកំផាត់ឲ្យទណ្ឌកម្ម ។
១២៧- ប្រដូចនិទានតែប៉ុណ្ណេះ អស់លោកក៏ចេះបានរៀនចាំ
ផ្តួចផ្តើមមួយឃ្លាជាពាក្យផ្តាំ ដូចមានចំណាំចំណោទជូន ។
១២៨-ទំនុកបុរាណមានប្រាជ្ញា ចេះចែងបញ្ហាសាស្ត្រាក្បួន
ទុកឲ្យអ្នកក្រោយដោះសំនួន បើគិតឲ្យមួនគួរមានភ័យ ។
១២៩-ចំណោទចាស់គួបងោខោ អង្គុយមែកឈើស៊ីផ្លែជ្រៃ
បុរសខុសផ្លូលគ្មានពក់ពៃ្ធ បង់គោក្របីទាំងមេកូន ។
១៣០-បុរសម្នាក់ទៀតឡើងដើមឈើ បេះផ្លែខាងលើចែកបងប្អូន
ស៊ីផ្អែកបន្តិចភ្លេចគល់សូន្យ បុរសម្នាក់បានកូនភ្លេចគុណម្តាយ ។
១៣១-ចំណោទទីបីចំណែកនេះ គួររិះឲ្យជិតកុំគិតឆ្ងាយ
កុំឆ្ងល់នឹងពាក្យពោលអធិប្បាយ ប្រឹងគិតដោះស្រាយប្រាជ្ញាស្រាប់ ។
១៣២-និយាយដើមគ្រូដោយកំបាំង មានឱ្យបមានខ្លាំងពោលបង្អាប់
បង្អើលឲ្យអ្នកដទៃស្តាប់ បង្អន់ដូចកាប់គាស់ឫសគល់ ។
១៣៣-ស៊ីផ្លែឆ្ងាញ់ផ្អែមតាមទំនើ ឫសលិចក្នុងដីមើលមិនយល់
មិនយកដីចាក់កប់គុណទល់ អំពល់ឲ្យបាបអំពីមាត់ ។
១៣៤-ពីមុនកាលកើតមានរូបកាយ អ្នកម្តាយចិញ្ចឹមបានធំធាត់
នាំយកទៅទុកឲ្យនៅវត្ត រៀនចេះចាំស្ទាត់បំភ្លាត់គុណ ។
១៣៥-ភ្លេចគោក្របីទាំងមេកូន សាបសូន្យកុសលដែលសាងមុន
សាងក្រោយសាងឲ្យតែខាតទុន ពីព្រោះបាបស៊ុនសិរយតិចិត្ត ។
១៣៦-ពិចារណាគួរតែកោតខ្លាច ខ្លួនបានជាប្រាជ្ញព្រោះគ្រូប្រឹត
ប្រឹងប្រៀនប្រដៅច្បាប់ក្រមក្រឹត្យ អាណិតដល់គុណធ្ងន់អនេក ។
១៣៧-អនាគតកាលទៅខាងមុខ ចូរចងចាំទុកដល់ស្អែកៗ
កុំស្អប់ចាស់ថ្មីស្តីដោយទ្វេក មើលចែកចាត់ចិត្តថ្លឹងឬស្រី ។
១៣៨-ធ្វើបុណ្យឲ្យស្មោះកុំអើស្វ៊ែក បាលើបីថ្នាក់ចាំហើយតើ



www.elibraryofcambodia.org

មនោសន្តិចិត្តប្រសើរ ប្រសប់គ្រាន់បើធ្វើបុណ្យបាន ។
១៣៩-ប្រាជ្ញថ្មីធ្វើតិចធ្វើតាមចុះ កុំថាគេខុសហើយឈប់ខាន
ប្រាជ្ញចាស់ច្រើនធ្វើតាមបុរាណ ច្រើនលើសប៉ុន្មានបានដោយបទ ។
១៤០-កុំធ្វើដោយរាប់អានស្រឡាញ់ ទុកជាកំណាញ់ហួសកំណត់
កំណើតមគ្គផលផ្ញើប្រាកដ សន្មតថាបានច្រើនប្រការ ។
១៤១-កុំធ្វើប្រកាន់ដោយយល់មុខ ហៅបុគ្គលិកទានគ្មានផលា
តាំងចិត្តចុះផ្លូវឧបេក្ខា រក្សារូបសុខដល់សួគ៌នាយ ។
១៤២-សួគ៌នោះបើចង់ឲ្យបានឆាប់ដល់ សាងមគ្គសាងផលកុំរាយមាយ
ឃើញគេសុខចិត្តកុំមើលងាយ កុំពោលនិយាយកាន់ម្ខាងៗ ។
១៤៣-អ្នកប្រាជ្ញទេះថ្មីត្រូវដោយខ្សែក ចំណែកប្រាជ្ញចាស់ត្រូវដោយយ៉ាង
កាន់យកទាំងពីរជាទីអាង សន្សំខំសាងនឹងបានសុខ ។
១៤៤-ពីថ្ងៃនេះទៅនៅឲ្យដឹង ស្ងៀមមាត់ឲ្យឃើញខ្លាចនរក
ពីព្រោះឈ្លោះគ្នារឿងរាល់ស្រុក បឹងថ្លុកត្រពាំងរាំងប្រេះដី ។
១៤៥-មិនឈ្លោះពីរឿងក្តីរឿងគោះ ឬទ្រព្យរបស់គោក្របី
នេះឈ្លោះពីធម៌ចាស់ធម៌ថ្មី ក្តៅចិត្តកើតក្តីរកចាញ់ឈ្នះ ។
១៤៦-បើក្តីពីស្រែពីចម្ការ ទៅក្រុមសាលាងាយជម្រះ
នេះក្តីពីធម៌ថ្មីធម៌ចាស់ នោះរឹតក្រែងតែព្រះទើបកាត់បាន ។
១៤៧-ទៅក្រុមសព្វថ្ងៃឱបាសក ចេះខ្លួចបិដកព្រះកម្មដ្ឋាន
កាត់ក្តីត្រូវច្បាប់អប្បាលម៉ាន អ្នកក្តីមិនខានប្តឹងឧទ្ធរណ៍ ។
១៤៨-អាំដែងមនុស្សខ្លះរឹងចចេស បានតែនិរទេសក្រៅនគរ
តែទុកគេនៅគាននរិះ ដំហររឹតរឹងទទឹងច្បាប់ ។
១៤៩-សង្ខេបបទបែបរឿងប្រយៅ អ្នកល្ងិតល្ងង់ខ្លៅខ្លះតែស្តាប់
អ្នកចេះសូត្រធម៌មិនស្គាល់សព្ទ ក្តះត្រាប់អ្នកប្រាជ្ញចេះបាលី ។
១៥០-ធ្វើបុណ្យធ្វើទានកុំចោលចាស់ ចោលចេញទុកខ្លះក្បួនលោកិយ



www.elibraryofcambodia.org

សូត្ររៀនតាមបែបអ្នកប្រាជ្ញថ្មី កុំបីភ្លេចគុណចាស់បុរាណ ។
១៨១-ធម៌អាថ៌ប្រពៃកុំប្រឡែត ពាក្យពោលចាក់ដោតឲ្យឈប់ខាន
រួមចិត្តសះសាបានសុខសាន្ត នឹងឲ្យរុងរឿងរីកសាសនា ។
១៨២-កុំឲ្យរៀរលោយតែរងកម្ម រាំងរីងរាល់ឆ្នាំវស្សា
ស្បៀនរដូវត្រូវមនុស្សថា រំដួលទេវតាក្ដៅក្រហាយ ។
១៨៣-មនុស្សភ្លុកកុហកឆក់ឆរបោក ឆ្នាំនេះស្រូវថោកវាស្ដុកអត់បាយ
ក្រលុយក្រភាក់ខ្វះប្រាក់ចាយ មហាជនទាំងឡាយកើតវេទនា ។
១៨៤-ភិរម្យខ្ញុំបាទដើមឈ្មោះអ៊ូ ពូជពង្សអម្បូរខ្មែរអ្នកជា
អាពុកឈ្មោះ **អ៊ុក** មានសក្ដិងារ ចៅពញាធម្មធារាមេស្រុក ។
១៨៥-ក្នុងខេត្តភ្នំពេញឃុំកំបូល ពូជពង្សត្រកូលម្ចាស់អង្គ **ម៉ុក**
ជីតាខាងម្ដាយឈ្មោះពញា **ម៉ុក** គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
១៨៦-អ្នកម្ដាយអាពុកបងប្អូនជិត ជីទួតមួយពិតពូជចិត្តល្អ
ដូនតាផ្សំផ្គុំជាតំណ បង្កើតមកជាខ្ញុំបាទ ។
១៨៧-ពូជខាងអាពុកមានប្រាជ្ញា ច្រើនចេះសាស្ត្រាចាំក្បួនខ្នាត
ត្រកូលខាងម្ដាយប្រាជ្ញាឆ្លាត រូបរាងច្រើនស្អាតគ្មានគេស្អប់ ។
១៨៨-ខ្ញុំពួមនុស្សឈ្មោះពីធម៌អាថ៌ គិតក្រែងសាសនាប្រែត្រឡប់
ខ្ញុំចាប់អធិប្បាយពុំសាយសព្វ សន្មតថាចប់ម្ល៉េះឯងហោង ។



www.elibraryofcambodia.org

# ពាក្យ កាព្យ
## ប្រដៅ ផន ប្រុសស្រី[146]
(បទព្រហ្មគីតិ)

១-ខ្ញុំសូមបង្គំព្រះសម្មា- សម្ពុទ្ធណាៗ ក្នុងត្រៃភព
ចំរើនកម្មដ្ឋានក្រោមពោធិ៍ម្លប់ ខ្ញុំសូមគោរពនមស្សការ ។
២-ព្រះធមចក្រពិននរិន្ទបុទ្ធិ ជាម្ចាស់ជីវិតលើសិរសា
សូមថ្វាយបង្គំព្រះករុណា សូមទ្រង់មេត្តាប្រោសប្រណី ។
៣-ឱនកាយបង្គំប្រណម្យនិក សូមក្រើនរំលឹកនាស្ត្រីប្រុសស្រី
ធ្លាប់ដេកពឹងពាក់ព្រះបារមី ឲ្យរៀនបារមីទៅបរលោក ។
៤-សរណគមន៍បីឲ្យប្រតិបត្តិ កំចាយកំចាត់ក្តីទុក្ខសោក
រូបយើងសព្វថ្ងៃថ្លៃមិនថោក បានមកភពភាន់ទាន់សាសនា ។
៥-ស្តួរប្រេតនរកទៅញីកញួយ គួរកុំបណ្តោយតាមតណ្ហា
គួរគិតសង្កេបឃាត់សង្ខារ សង្រឹមព្រះសិរអារ្យនឹងមកត្រាស់ ។
៦-ជម្ពូទ្វីបនេះធំបំផុត មួយម៉ឺនយោជន៍គត់ដំណែលព្រះ
សត្វស្លាប់តាមកម្មមិនចាំចាស់ អាយុខ្លីណាស់ក្រាស់អកុសល ។
៧-ទុច្ចរិតកិច្ចអនត្ថ កើតរូបកាលណាកម្មតាមដល់
តាមដានដារបាបឲ្យផល បាបខ្លះសេសសល់ពីនរក ។
៨-ខ្លះមកពីប្រេតតិរច្ឆាន ខ្លះមកពីស្ថានសួគ៌សោយសុខ

[146]ពាក្យកាព្យប្រដៅផនប្រុសស្រីនេះដូចទាំងស្រុងទៅនឹងបណ្តុំក្រមង៉ុយ បោះពុម្ពដោយលី-ធាមតេង, បណ្ណាគារសេង-ងួន-ហួត, ១៩៦៩, ២៣ទំព័រ ។



www.elibraryofcambodia.org

អោតាមគេបានឃើញមុន    ចុះមករងទុក្ខទទួលកម្ម ។
៩-អ្នកធ្លាប់ទៅវេនរកប្រេត    ដើមហេតុពីព្រោះដាច់សីល ៥
ទឹកក្តៅខ្លះដេកទៅដេកត្រាំ    រាប់លានកោដិឆ្នាំទំរាំរួច ។
១០-មកកើតជាមនុស្សស្ថានកណ្តាល    មិនរាងមិនចាលដល់តិចតួច
ប្រពន្ធកូនគេនៅតែលួច    សត្វធំសត្វតូចរិតសម្លាប់ ។
១១-ស្រាវិតតែផឹកឲ្យស្រវឹង    គុណទោសមិនដឹងប្រឹងចាក់កាប់
ស្រុកឃ្លានបំពានធ្វើលើច្បាប់    មិនស្តាប់ឱវាទដីកាព្រះអង្គផ្តាំ ។
១២-ពិតវីមែនជាមិនឮព្រះឱស្ឋ    ព្រះសង្ឃទ្រង់ប្រោសឲ្យសីល ៥
ទទួលរំពេចភ្លេចមិនចាំ    ប្រព្រឹត្តសាងកម្មមិនព្រមលែង ។
១៣-កើតមកពូជពង្សពេញជាមនុស្ស    សេចក្តីត្រូវខុសចាំដាក់ស្តែង
សម្លាប់រូបសត្វឥតគិតក្រែង    បំពេញខ្លួនឯងឲ្យធំធាត់ ។
១៤-សម្លាប់មិនថាសត្វឈ្មោលញី    យកសាច់មកស៊ីឲ្យឆ្ងាញ់មាត់
ទទួលសីលភ្លើធ្វើឲ្យភ្លាត់    លក់សត្វឲ្យព្រាត់មេព្រាត់កូន ។
១៥-ព្រាត់ក្តីកំសត់ផ្តួសង្សារ    ដូចលក់ជីតាលក់ជីដូន
ពុំនោះលក់បងបំបែកប្អូន    ងងឹតឈឹងស្មុគ្រមើលមិនយល់ ។
១៦-ខ្លះទៅនរកមិនទាន់មក    ខ្លះឃ្លាតទៅជ្រកពួកអសុរ
ជាន់សង្សារឡប់វិលវល់    អំពល់តែកើតស្លាប់កើតស្លាប់ ។
១៧-កម្មគិតតាមខ្លួនមិនដែលឃ្លាត    គ្រប់ប្រាំរយជាតិមិនដែលឆាប់
សត្វជ្រូកមាន់ទាគេចាក់កាប់    សម្រាប់គេស៊ីជាអាហារ ។
១៨-សត្វគោក្របីជិះសេះ    គេជិះគេទឹមជាធម្មតា
គេកាប់លក់សាច់ផ្តាច់សង្ខារ    រកចិត្តមេត្តាករុណាគ្មាន ។
១៩-រូបខន្ធរលត់រលាយទៅ    សល់នៅសង្ខារនិងវិញ្ញាណ
កើតនាសញ្ញាទឹកស្រុកឃ្លាន    សន្និដ្ឋានថាដូចអ្នកមានគុណ ។
២០-សត្វញីសត្វឈ្មោលអន្ទោលទុក្ខ    ឪពុកឬម្តាយពីជាតិមុន



www.elibraryofcambodia.org

ជាតិមកពីរងទោសទុក្ខធ្ងន់
ក្រែងស៊ីនទៅលើសាច់ញាតិឯង ។
២១-ជ្រូកគោក្របីនៅក្នុងស្នារ
គេគៀកគ្រះគ្រៀះឃើញស្ដែងៗ
កើតគគ្រួសព្វគ្រប់កន្លែង
ជួនក្រែងជាតិមនុស្សមកជាសត្វ ។
២២-អ្នកពឹងនឹងអ្នកធ្វើដែនដល់
ចៅក្រមអកុសលជំនុំកាត់
បញ្ជីទាំងពីរឈ្មោះមិនបាត់
គេបាត់ធ្វើទោសទាំងអស់គ្នា ។
២៣-មិនមានអ្នកណាធ្ងន់ណាស្រាល
យម្ពបាលរះគ្រៀះគ្រប់វេលា
មានលោកយមរាជរាជសភា
ជំនុំគិតគ្នាមើលបញ្ជី ។
២៤-បញ្ជូនអ្នកធ្វើចុះនរក
ជំនុំឃុំទុក្ខអ្នកទិញស៊ី
ទិញសត្វស្លាប់រស់ទោះឈ្មោលញី
ទាំងពីរចំណែកចំណាំមុខ ។
២៥-អ្នកមួយទិញស៊ីមិនរួចខ្លួន
ត្រឹមឯត្រីអួនយួនដូរលក់
អណ្ដែងក្រាញ់ឆ្តោរឆ្ដៀបរស់ផ្ទក់
ចង់ទិញស្ងោរជ្រក់ទៅតថ្លៃ ។
២៦-ឃើញឲ្យសៅជារស់មិនទាន់ងាប់
អង្គុយបង្គាប់ឲ្យយួនរើ
រកខ្យល់ច្រឡោតដេកញ័រដៃ
ឃើញក្បីយស្រាប់ៗមិនទិញយក ។
២៧-អានេះបន្ទុះលែងមិនបាន
ត្រូវចំធាក់ប្រាណឲ្យជ្រុលជ្រក
ទម្លាក់ឲ្យជ្រៅរងទុក្ខសោក
លែងលកអ្នកទោសរឿងអ្នកទិញ ។
២៨-អ្នកទៅឃើញត្រីនៅប្រែះ
វេទនាចិត្តណាស់ព្រួសដើរចេញ
អ្នកនេះត្រូវលែងឲ្យទៅវិញ
មានសែហ្វូលិញតិញក្នុងនរក ។
២៩-ឲ្យជូនខ្លាចក្រែងវង្វេងផ្លូវ
ត្រួតមើលខុសត្រូវគ្រប់ភូមិស្រុក
បើកក្រាំងសៀវភៅកត់ឈ្មោះទុក
បញ្ជីពីមុខបាបនិងបុណ្យ ។
៣០-ប្រគល់យមរាជយម្ពបាល
ដាក់ស្រាលដោយស្រាលធ្ងន់ដោយធ្ងន់
អ្នកសាងមគ្គផលស្គាល់ទោសគុណ
ទៅសោយសុខមុនតាមទុនទាន ។
៣១-អ្នកសាងធ្ងន់ទាបភាពអកុសល
មិនចង់បានផលសួគ៌និព្វាន
ប្រព្រឹត្តអាក្រក់រកល្អគ្មាន
មិនហ៊ានកាន់សីលថាខ្លួចដាច់ ។
៣២-មិច្ឆាទិដ្ឋិចូលពេញទី
បញ្ញើសប្រាំងតាំងសម្រេច



www.elibraryofcambodia.org

ចុះវង្សអាធឹកភ្លុក្សស៊ីអាចម៍ ព្រោះពោលបង្អាប់ព្រះពុទ្ធដីកា ។
៣៣-ទើបទុច្ចរិតមានគ្រប់យ៉ាង ទានសីលមិនសាងអាងដឹកស្រា
ព្រួលោកសម្ដែងធម៌ទេសនា ពុំអោះពុំស្ដារមិនចេះស្ដាប់ ។
៣៤-អស់យើងគួរស្ដាយជាតិកំណើត សំណាងមកកើតក្នុងភទ្ទកប្ប
អតារវិន័យព្រះប្រញាប្ត ជាប្រុសគល់ច្បាប់គួររក្សា ។
៣៥-សីល៥ចង់ចាំឲ្យប្រាកដ កុសលកម្មបថ១០ប្រការ
កុំឈ្លោះប្រកែកពីធម៌អាថ៌ ប្រកាន់សាសនាឲ្យប្រាកដ ។
៣៦-កើតមកជាមនុស្សមានសខ្មៅ មានប្រាជ្ញមានខ្លៅមានក្រខ្វក់
មានខ្លាំងមានខ្សោយដោយបែបបទ សន្ដតចាល្អក់ក៏មិនបាន ។
៣៧-ជម្ពូទ្វីបនេះមនុស្សកម្មក្រាស់ ព្រះពុទ្ធតែងត្រាស់មិនដែលខាន
ហេតុនេះមហាជនទាំងប៉ុន្មាន សម្រាកសម្រាន្តសម្រួលចិត្ត ។
៣៨-បំណាច់សម្ដេចព្រះទ្រង់ញាណ កាលហៀបនិព្វានមានកំរិត
ផ្ដាំបរអានន្ទឲ្យអាណិត អនុជអ្នកប្រិតប្រោសសត្វផង ។
៣៩-សត្វផុងទៅក្នុងជ្រោះជ្រៅជ្រៅ តថាគតនៅនាំចំឡង
ដាក់ដល់និព្វានអស់ហ្មត់ហ្មង រួចពីចំណងវដ្ដសង្សារ ។
៤០-ទោះរស់សង្ស័យសត្វខាងក្រោយ នន្ទអើយទុកឲ្យព្រះសិអារ្យ
អាណិតសត្វលោកណាស់ណាអ្នកណា តថាគតជិតនិព្វានហើយ ។
៤១-ព្រះឱស្ឋព្រះអង្គល្អមស្រណោះ សប្បុរសទាំងអស់កុំកន្ដើយ
ប្រែខ្នងដេកលើកន្ទេលខ្មើយ កុំស្ងៀមមាត់ឡើយរំលឹកគុណ ។
៤២-ខ្លួនខ្ញុំកំណើតរាស្ត្រអ្នកស្រែ ខុចខិលខ្ជិលដែរកាលពីមុន
កាលមោហ៍បាំងបាត់ងងឹតស៊ុន ធ្វើបាបនឹងបុណ្យទម្ងន់ស្មើ ។
៤៣-មិនស្មោះតែរួចចត្រុះប្រាយ អស់លោកទាំងឡាយកុំសរសើរ
ខ្ញុំផុនដំណឹងតាមដំណើរ ព្រោះខ្ញុំគ្រាន់បើជាងអ្នកល្ងង់ ។
៤៤-ជាតិក្រោយកុំឲ្យខ្ញុំល្ងិល្ងើ ជាតិនេះចាស់ស្ទើរខ្ញុំប្រឹងស្ទង់



www.elibraryofcambodia.org

ព្រះភក្ត្រស្រួលបព៌អន្លង់ ភ័យភិតខ្លាចផុងទៅក្នុងភក់ ។
៤៥-ក្នុងភពសង្សារខ្ញុំសង្ស័យ សព្វថ្ងៃខ្ញុំភ័យខ្លាចនរក
ម្យ៉ាងទៀតខ្ពើមជាតិអាជីរក ជាតិល្មោភរូបល្មក់ព្រោះល្មើសគុណ ។
៤៦-ច្រើនល្មើសបន្ទូលបន្ទោសព្រះ ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន
ខ្ញុំសូមស្មារលាទោសពីមុន សូមបុណ្យជួយបាំងបាបឲ្យបាត់ ។
៤៧-ឲ្យបានទាន់ព្រះសិអារ្យ ឲ្យបែកប្រាជ្ញាឆ្លាតបរមត្ថ
ព្រះអង្គទេសនាទ្រង់ប្រោសសត្វ សូមលុះអរហត្តដូចបំណង ។
៤៨-បំណាច់ខ្ញុំស្រាយច្បាប់រំលឹក អស់លោកជួយទឹកសទ្ធាផ្សេង
ផ្ញើបុណ្យចែកផលដល់ខ្ញុំផង នឹកឈ្មោះម្តងៗដូចធម្មតា ។
៤៩-សប្បុរសប្រុសស្រីតប្បិស្តាប់ ឈ្មោះច្បាប់កន្លងព្រះឱង្ការ
ឱកាសឲ្យគិតប្រឹតប្រាជ្ញា ទាន់ព្រះសិអារ្យទាំងប្រុសស្រី ។
៥០-កុំហ៊ានព្រហើនប្រហែសធ្វេស កើតក្នុងប្រទេសរាជបុរី
ឲ្យមានបារម្ភភ្ញាក់ស្មារតី សីល ៥ ប្រាំបីខំសិក្សា ។
៥១-ជាតិមនុស្សជាន់ខ្ពស់ពីបុរាណ គេបានជួបជាក់ឃើញភក្ត្រា
បានត្រងរងគ្រាប់ព្រះពុទ្ធដីកា បានលុះសោតាអរហត្តហោះ ។
៥២-បើងទាន់ត្រឹមតែពាក្យបណ្តាំ បណ្តុលសីលប្រាំជាគ្រឿងការ
កិច្ចការកងកម្មចាំមិនអស់ របស់ប្រុសគល់គួររក្សា ។
៥៣-នេះចប់ចាំណែកខាងបាសក កុំធ្វើអាក្រក់រាល់រូបា
ពីងក្រែងជួបព្រះសិអារ្យ ឧបស្សការគោរពរំលឹកគុណ ។
៥៤-ព្រះធម៌វង្សមុនីនាថ កំពូលផុតជាតិជាងមហាជន
ទ្រង់សោយសម្បត្តិសម្បើមបុណ្យ សម្បូណ៌លន់លុប (លើ) លោកា ។
៥៥-លោកីយនិងគួរកោតខ្លាច ទ្រង់មានអំណាចព្រះចេស្តា
គួរស្តាប់ព្រះរាជឱង្ការ បន្ទូលត្រូវគ្រាគួរត្រង់គ្រាប់ ។
៥៦-ព្រះទេព័រទ្រង់ត្រេកត្រសឡាញ់សង្ឃ ប្រមាណសែនអង្គក្នុងភទ្ទកប្ប



www.elibraryofcambodia.org

ព្រះពុទ្ធទ្រង់ប្រិតប្រាមប្រញប្តិ
ឈ្មោះច្បាប់បាដិមោក្ខសំវរសីល ។
៥៧-ចែកចេញជាកងសិក្ខាបទ
កំណត់ពីររយម្ភៃប្រាំពីរ
មិនឲ្យមានមោះហ្មងមន្ទិល
អ្នកបួសកុំខ្ជិលកាន់ឲ្យខ្ជាប់ ។
៥៨-បាណោអទិន្នាជាបឋម
ជាតិរូបទៀតឲ្យគ្រប់ជាដប់
លោកសង្ឃឥឡូវកាន់មិនសព្វ
កាន់ក្នុងបន្ទប់លាយបន្លំ ។
៥៩-បន្លំចពុយកាត់លាក់សម្ងាត់
ទោសត្រូវអាបត្តិលាក់សម្ងំ
បាសកធ្វើទានគ្មានបារម្ភ
សន្សំតែទ្រព្យក្តៅក្រហាយ ។
៦០-ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ
មិនបានធម្មយុត្តិមហានិកាយ
បើចេះខ្លាចក្រែងមិនក្លែងក្លាយ
សមសុខសប្បាយមិនទាស់គ្នា ។
៦១-លោកសង្ឃគ្រប់វត្តមានធំតូច
សង្ឃខ្លះឱយខូចសង្ឃខ្លះជា
បរិស័ទពុលទោសគ្រូឧបជ្ឈាយ៍
មានពាក្យនិន្ទាគេរាល់វត្ត ។
៦២-បារាជិកពីររយម្ភៃប្រាំពីរ
អ្នកល្ងង់ហើយខ្ជិលចាំមិនស្ទាត់
កងបាចិត្តិយនិងទុក្កដ
ចូលមាត់ចូលកមិនដឹងខ្លួន ។
៦៣-កងបាចិត្តិយកៅសិបពីរ
និស្សគ្គិយ៍សាមសិបបារាជិកបួន
បើចេះហើយចាំឲ្យមាំមួន
ល្អបរិសុទ្ធស្លួនមិនសាយសុស ។
៦៤-ប៉ុន្តែសិក្ខាមិនសូវទៅ
ចំណាំត្រង់ណោះចោលត្រង់ណោះ
ត្រង់ណាដែលដឹងថាខ្លួនខុស
ហ៊ានឈ្មោះពីព្រោះគេមិនដឹង ។
៦៥-សង្ឃាទិសេសប្រហែលបាន
ដប់បីសន្តានប្រមាណថ្លឹង
បើធ្លាប់សង្រួមឲ្យយ៉ាងតឹង
មិនអរមិនខឹងមិនខាតខុស ។
៦៦-ឥន្ទ្រិយ៍ប្រាំមួយនាំឲ្យភ្លាត់
បាចិត្តិយ៍ទុក្កដហោយចំរុះ
ឥន្ទ្រិយ៍ត្រចៀកភ្នែកច្រមុះ
ភ្នែកមើលនេះណោះឃើញសុសសាយ ។
៦៧-សោតិន្ទ្រិយសូវតែខ្លាំង
ចក្ខុន្ទ្រិយ៍ឃើញជិតឆ្ងាយ
ជិវ្ហិន្ទ្រិយពោលនាយអាយ
សើចលេងសប្បាយចំអន់គ្នា ។
៦៨-បរិសុទ្ធអាបត្តិទុក្កដញឹក
បារាជិកច្រើនណាស់តែឧបជ្ឈាយ៍



www.elibraryofcambodia.org

ទ្រព្យក្នុងសំបាច់សំបុណ៌ហៀរ
ត្រូវទោសអទិន្នាទានុភណ្ឌ ។
៦៩-ទ្រព្យសង្ឃជាដើមគឺចីវរ
អាហារម្ហូបប្រាំចាំគ្រូគ្នាន់
ឱបទុកខ្លះខ្វែងក្រែងមិនគ្រាន់
អាហារប្រាំផាន់បាយផឹក ។
៧០-យ៉ាងទៀតទ្រព្យសង្ឃក្នុងចំណែក
គិបទុកមិនចែកឲ្យលោកភិក្ខុ
គ្រឿងយាជើកកាលិក
ទុកខួបល្ងាចព្រឹកម៉ោតែឯង ។
៧១-យ៉ាងទ្រព្យគេហែចូលវិហារ
បាសកបុជាដល់គម្ពែង
គេរកបាលីអានខ្លីវែង
គេតែងនិងជាសង្ឃស្ស ។
៧២-ប្រកាសប្រគេនជំនុំសង្ឃ
ចំពោះគ្រប់អង្គផងទេមៈ
លោកសង្ឃសាធុគ្មានសល់ម្នាក់
សង្ឃរាជទុកដាក់មិនចែកចាយ ។
៧៣-ខ្ញុំបាទចែកតាមខ្ញុំចេះចាំ
អាហារម្ហូបប្រាំមែកបរិយាយ
នេះសុទ្ធតែសីលផ្ទុសអន្តរាយ
លោកសង្ឃទាំងឡាយកុំប្រព្រឹត្ត ។
៧៤-ពីព្រោះឥន្ទ្រីយ៍ទាំង៦
លោកណាមិនព្រួយមិនប្រុងគិត
លោភោមោហោបាញ៉ាំងដិត
សិស្សមានគំនិតមិនហ៊ានថា ។
៧៥-សូមទានសន្តោសសម្តែងច្បាប់
ព្រះសង្ឃកុំចាប់ចងទោសា
ខ្លួនខ្ញុំសូមសុំបវារណា
ប្រោសប្រណីមេត្តាបណ្តាសង្ឃ ។
៧៦-ខ្ញុំមិនមានពោលពាក្យបង្អាច់
ខ្លាចសីលលោកដាច់ខ្ញុំតម្រង់
តម្រូវតែតាមច្បាប់ព្រះអង្គ
ព្រះឱស្ឋត្រឹមត្រង់ត្រូវមាត្រា ។
៧៧-គាប់អង្គសម្តេចព្រះចមភព
បន្ទូលប្រាប់ឮគ្រប់ប្រការ
ប្រកាសប្លែកបទសិក្ខា
ប្រញ្ញត្តបញ្ញត្តមហាបរិស័ទ្យ ។
៧៨-ភិក្ខុភិក្ខុនីអស់អរហន្ត
អានន្ទមិនទាន់បានអរហត្ត
ព្រះធម៌វិន័យកុំឲ្យបាត់
ប្រយ័ត្នឲ្យត្រង់ប្រយោជន៍យូរ ។
៧៩-ក្រោយនេះព្រះអង្គចូលនិព្វាន
អរហន្តហោះឡានមានជាគ្រូ
មិនមានអក្ខរណាដាក់ទូ
ទេសនាបង្ហូរពីព្រះឱស្ឋ ។
៨០-ព្រះអគ្គសាវកគ្រប់ព្រះអង្គ
ព្រះទ័យស្រោចស្រង់ទ្រង់សន្តោស



www.elibraryofcambodia.org

សម្ដែងធម៌អាថ៌បេត្តាប្រោស     ញាបបុណ្យគុណទោសនិងសីលទាន ។
៨១-ឈ្វេងយល់ថាធម៌និងសុន្យស្ងាត់     អរហន្តអរហត្តចូលនិព្វាន
សង្ឃាសេក្ខបុគ្គលមិនទ្រង់ញាណ     មិនមានអក្ខរាណាតែងទុក ។
៨២-ព្រះធម៌ប៉្រាំបីម៉ឺនបួនពាន់     ស្រេចហើយអានន្ទចាំទំនុក
ដរែណែលព្រះអង្គនឹងគ្រប់មុខ     ផង្រុកធម៌អាថ៌មហាអានន្ទ ។
៨៣-ជាព្រះអនុជអាណិតសត្វ     ក្រែងបាត់បិដកមិនគ្រប់គ្រាន់
ព្រះធម៌ប៉្រាំបីម៉ឺនបួនពាន់     គ្មេះគ្មាន់ខ្វះខ្វែងបាត់ចែងចារ ។
៨៤-ចេះចប់អភិធម្មចាំរហូត     វិន័យព្រះសូត្រប្រាំប្រការ
ប្រកាសអស់អង្គអរហន្តា     បិដកឯណាជាប្រុសគល់ ។
៨៥-បរមត្ថព្រះសូត្រអានន្ទចាំ     វិន័យទាំង៥ឧបាលីយល់
អរហន្តទាំងអស់កើតរវល់     អំពល់អំពីរឿងធម៌អាថ៌ ។
៨៦-ព្រះបាទអជាតសត្រូវ     ជួយគិតតម្រូវព្រះសាសនា
សម្មតិឲ្យឈ្មោះហៅក្សត្រា     ព្រោះព្រះមហាក្សត្រិយ៍ចូលគំនិត ។
៨៧-និយាយឲ្យដឹងដើមកំណើត     កកើតអក្ខរាចារស្លឹករឹត
បកប្រែបាលីសេចក្ដីពិត     ពិនិត្យត្រឹមត្រូវតាមពុទ្ធដីកា ។
៨៨-ទសជាតក៍ទាំង១០មានគ្រប់វត្ត     ប្រែត្រូវប្រាកដព្រះគាថា
ព្រះធម៌សូត្រមន្តប្សូត្រដារ     អ្នករៀនអក្ខរាពីរចំណែក ។
៨៩-ចំណេះចំណាំចាំដោយខ្លួន     ខ្លះរៀនអានក្បួនចាស់ចារចែក
បានភ្ញាល់ព្រោះអាងឃើញនឹងភ្នែក     កើតឈ្លោះប្រកែកប្រកួតខឹង ។
៩០-ប្រកាន់តែខាងខុសរហូត     មិនរៀនមេសូត្រឲ្យចេះដឹង
អាងចេះតែ«កកា»ប៉ុណ្ណឹង     ខំប្រឹងចំអើតអួតខ្លួនត្រូវ ។
៩១-ក្ដៅណាស់ពីរឿងយោជាយ៉ា     នាំឡើងភ្នែកស្លោមុខក្រញូវ
ថាធ្លាប់យោនាពីខ្មោចឪ     ឥឡូវយោណាមិនសុខចិត្ត ។
៩២-អ្នកម្ខាងអាងស្រះគួប្រាំបី     ឲ្យដឹងបាលីជាក់រិត



www.elibraryofcambodia.org

ផ្សំក្លួមេសូត្រប្រឹងប្រែប្រឹក ព្រោះរៀតឲ្យត្រឹមត្រូវមាត្រា ។
៩៣-អ្នកបួសគ្រប់វត្តគ្រប់នគរ «ស»ដាក់ជើង«ល»រាប់ស្លស្លា
បើសរជើងមរាប់ស្មស្មា អ្នកមានប្រាជ្ញាល្អបស្តាប់បាន ។
៩៤-កុំល្ងង់ទាល់ងាប់ធ្លាប់មិនដឹង បើខឹងខ្ញុំឃាត់ថាឲ្យខាន
ខដាក់ជើងមពីបុរាណ ក្មេងតូចប៉ុន្មានស្គាល់ខ្មខ្មា ។
៩៥-ជាតិរាស្ត្រចាស់ក្មេងកុំចិត្តខ្លាំង គួរខ្មាសបារាំងអ្នករាជការ
ដើមហេតុអំពីព្រះករុណា ឲ្យសាងសាលាបៃប្រាលី ។
៩៦-ទ្រង់ពាំទំនៀមពីបុរាណ ហើយបានជំនុំព្រមកុងស៊ុល
បំណាច់ធ្វើស្តេចគ្រងផែនដី ទិសទាំងប្រាំបីរីពៃគ្រប់ ។
៩៧-ព្រះកាយពលមិនទះរស់រែក ព្រះទ័យរំពែកទាំងថ្ងៃយប់
ចូលមែនបន្ទីបន្ទប់ បន្ទូលមិនឈប់រាល់វេលា ។
៩៨-មេត្តាព្រោសព្រាណអ្នកបានសក្តិ ព្រះទានលុយកាក់គ្រប់ភ្នាក់ងារ
ទ្រង់ត្រួតស្រីស្ងួរក្រមស្រីង្គារ ក្រែងក្រុនរងាមិនបានសុខ ។
៩៩-ព្រះទ័យមេត្តាសព្វមនុស្សសត្វ សោយរាជសម្បត្តិសម្បើមស្តុក
ព្រះកាយប្រកបគ្រប់ស្រណុក ព្រះទ័យរិតក្តជាធម្មតា ។
១០០-មួយព្រួយនឹងឱបព្រះនគរ ពីរព្រួយនឹងពព្រះសាសនា
បព្វជិតលោកសង្ឃកាន់សិក្ខា សង្រួមកិរិយាមិនបរិសុទ្ធ ។
១០១-ទើយណាស់ព្រះនេត្រព្រះករុណា ព្រះឱស្ឋត្រួតត្រាច្រើនបំផុត
ទាស់តឿនបរិភ័យព្ទួកកុលបុត្រ ឲ្យប្រុងលំអុតសង្រួមកាយ ។
១០២-បានចេញប្រកាសដាក់ព្រាកដ ប្រគេនគ្រប់វត្តទោះជិតឆ្ងាយ
លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងឡាយគ្រប់ចំពូក ។
១០៣-មិនត្រូវចំពោះស្តាប់តន្ត្រី កុំបីមើលរាំនាំភ្លុក
កុំដើរភ្លឿៗមើលអុំទូក អ្នកបួសធ្វើលោកមិនត្រូវការ ។
១០៤-បើមានត្រូវកិច្ចដើរយប់ថ្ងៃ សង្ឃបងនិស្ស័យចាស់វស្សា



www.elibraryofcambodia.org

កុំដើរទីផ្សារទៅណាៗ អ្នកចេះសិក្សាគេទាស់ភ្នែក ។
១០៥-លោកនេនកុំសុំលុយចិនចាយ បិណ្ឌបាតតែបាយម្នាក់១វែក
គ្រឿងម្ហូបចំណីបាសកកំផែក កុំស្ពាយពុនរែកបំផោកឫក ។
១០៦-របស់បាសកគេប្រគេន ប្រគល់លោកនេនបានលោកភិក្ខុ
ចិញ្ចឹមជីវិតនឹងបាយទឹក បិណ្ឌបាតតែព្រឹកយប់សូត្ររៀន ។
១០៧-លោកណាត្រឹមត្រូវមិនសូវខុស សៀមស្ងាត់ទៅចុះកុំអន់អៀន
លោកណាមិនចេះកុំរេះអៀន ពាក្យរៀនប្រដៅឲ្យផ្ដើលភ្ញាក់ ។
១០៨-ពីព្រោះព្រះអង្គបានផ្ដាំផ្ញើ វិន័យស្ថិតលើស្ដេចមហាចក្រ
ព្រះមហាចមពង្សទ្រង់ជំពាក់ ចំពោះធុរៈនឹងសាសនា ។
១០៩-ពីត្រឹមនោះរៀងដរាបមក ដល់ស្រុកគោកធ្លកមានសារតារ
ប៉ុន្តែរាជ្យហើយមិនដឹងថា ដល់មកករុណាយើងសព្វថ្ងៃ ។
១១០-ហេតុនេះលោកសង្ឃប្រុងពិនិត្យ សៀវភៅស្លឹករឹតមានរាល់ដៃ
ផ្ទៀងមើលសិបផុកវិនិច្ឆ័យ បើនៅសង្ស័យឲ្យសាក្សា ។
១១១-លោកសង្ឃចាស់ខ្ចីគប្បីស្ដាប់ ឈ្មោះច្បាប់ក្នុងព្រះពុទ្ធដីកា
បង្គំថ្វាយដល់ព្រះករុណា សូមទ្រង់មេត្តាជ្រាបព្រះទ័យ ។
១១២-ទើបក្រងជួបប្រទះពាក្យឆ្គាំឆ្គង ពុំត្រូវទំនងក្រឹត្យវិន័យ
សូមមានសន្ដោសអត់ទោសពៃរ៍ ក្ដួញក្រាបសិរសីក្រោមព្រះបាទ ។
១១៣-ព្រះសង្ឃទាំងអស់ទោះតូចធំ អភ័យទោសខ្ញុំសូមអនុញ្ញាត
ពាក្យខ្ញុំមិនមានគោលប្រមាទ សង្ឃជាល្អស្អាតខ្ញុំមិនថា ។
១១៤-ខ្ញុំពោលតែលោកធ្វើអាក្រក់ បើខ្ញុំកុហកខូចមុសា
ហេតុនោះខ្ញុំសូមបរិណា និន្ទិតាសង្ខេបតែប៉ុណ្ណោះ ។
១១៥-ក្មេងណាប្រាថ្នាបួសធ្វើសង្ឃ ឲ្យស្វែងតម្រង់រៀនតម្រិះ
ឲ្យមើលតម្រាប់លោកអ្នកចេះ កុំដេកតែអេះគិះដៀលគ្នា ។
១១៦-អ្នកម្ដាយឪពុកឲ្យឈ្មោះអ៊ឹម កូនពង្សអំបូរខ្មែរអ្នកជា



www.elibraryofcambodia.org

អាពុកឈ្មោះ **អ៊ិក** បានសក្តិងារ ចៅពញាធារាធ្វើមេស្រុក ។
១១៧-ក្នុងខែត្រភ្នំពេញឃុំកំបូល ជាប់នៅត្រកូលម្ចាស់អង្គប៉ុក
អាពុកអ្នកម្តាយឈ្មោះពញា **ម៉ុក** គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
១១៨-អ្នកម្តាយអាពុកបងប្អូនជិត ជីទួតមួយពិតពុជចិត្តល្អ
ចាស់ទុំឡុំផ្តុំជាតំណ បង្កកើតខ្ញុំទូលបង្គំ ។
១១៩-បង្កើតអំពីដើមកំនិត ភ័យភិតខ្លាចបាបចង់បានបុណ្យ
បានបែងចែងច្បាប់ប្រាប់មហាជន បួនច្បាប់ពីមុនជូនរាជការ ។
១២០-បោះពុម្ពសៀវភៅចែកសព្វសាយ បណ្ណាល័យចាត់ថ្វាយព្រះករុណា
មិនបានថ្វាយផ្ទាល់ដល់ហត្ថា សូមទ្រង់មេត្តាប្រោសប្រណី ។
១២១-ឱនកាយប្រណម្យសូមអនុញ្ញាត ក្រាបក្រោមព្រះបាទព្រះបារមី
ចែងច្បាប់បរមត្ថអត្ថបាលី សេចក្តីចែងចប់ប្លែះហើយហោង ។



www.elibraryofcambodia.org

# ល្បើក ច្បាប់ សង្ឃ

របស់ក្រមង៉ុយ[147]

១- ខ្ញុំសូមបង្គំព្រះសម្មា　　សម្ពុទ្ធណាៗ ក្នុងត្រៃភព
ចំរើនកម្មដ្ឋានក្រោមពោធិ៍ម្លប់　　នមស្ការគោរពរំឭកគុណ ។
២- ព្រះចមចក្រពង្សវង្សមុនីនាថ　　កំពូលផុតជាតិជាងមហាជន
សោយរាជសម្បត្តិសំបើមបុណ្យ　　សំបូណ៌លើសលន់លុបលោកា ។
៣- លោកិយដឹងហើយគួរគោរពខ្លាច　　ទ្រង់មានអំណាចព្រះចេស្តា
គួរស្តាប់ព្រះរាជឱង្ការ　　បន្ទូលត្រូវត្រាគួរត្រងត្រាប់ ។
៤- ព្រះទ័យទ្រង់ត្រេកស្រឡាញ់សង្ឃ　　ប្រមាណសែនអង្គក្នុងភទ្ទកប្ប
ព្រះអង្គបានទ្រង់ត្រាស់ប្រញត្តិ　　ឈ្មោះច្បាប់បាដិមោក្ខសំវរសីល ។
៥- ចែកចេញជាកងសិក្ខាបទ　　កំណត់ពីររយម្ភៃប្រាំពីរ
មិនឲ្យមានមោះម៉ងមន្ទិល　　អ្នកបួសកុំខ្ជិលកាន់ឲ្យខ្ជាប់ ។
៦- បាណាអទិន្នាជាបឋម　　ជាគរុបទៀតផ្សំត្រូវជា១០
លោកសង្ឃឥឡូវកាន់មិនសព្វ　　កាន់ក្នុងបន្ទប់លាយបន្លំ ។
៧- បន្លិចលុយកាក់លាក់សម្ងាត់　　ទោសត្រូវអាបត្តិលាក់សម្ងំ
បាសកផ្ញើទានគ្មានអារម្មណ៍　　សន្សំតែទ្រព្យក្តៅក្របាយ ។
៨- ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ　　មិនមានធម្មយុត្តិមហានិកាយ

---

[147] ល្បើកច្បាប់បោះពុម្ពផ្សាយជាដំបូងក្នុងទស្សនាវដ្តីកម្ពុជសុរិយា, ទំព័រ១០៣-១២៨, ថតចម្លងបាត់កាលបរិច្ឆេទនិងលេខទស្សនាវដ្តី ។ តែតាមការសន្និដ្ឋាន «ល្បើកច្បាប់សង្ឃ» នេះប្រហែលបោះពុម្ពផ្សាយរវាងឆ្នាំ១៩៣០-១៩៣៤ ។ យើងសូមរក្សាអក្ខរាវិរុទ្ធច្បាប់ដើមដោយឥតកែប្រែ ។



www.elibraryofcambodia.org

បើចេះខ្លាចក្រែងមិនក្លែងក្លាយ សមសុខសប្បាយមិនទាស់គ្នា ។
៩-លោកសង្ឃគ្រប់អង្គមានធំតូច សង្ឃខ្លះខិលខូចសង្ឃខ្លះជា
បរិសុទ្ធផ្ដាច់ទោសគ្រូឧបជ្ឈាយ៍ មានពាក្យនិន្ទាតែរាល់អង្គ ។
១០-បាដិមោក្ខពីររយម្ភៃប្រាំពីរ លោកសង្ឃណាខ្ជិលចាំមិនស្ទាត់
កងបាចិត្តិយនិងទុក្កដ ចូលមាត់ចូលកមិនដឹងខ្លួន ។
១១-ពួកបាចិត្តិយកៅសិបពីរ និស្សគ្គិយសាមសិបបារាជិកបួន
បើចេះហើយចាំឲ្យបានម៉ួន ល្អបរិសុទ្ធសុទ្ធមិនសាយសុះ ។
១២-ប៉ុន្តែសិក្ខាមិនសូវចាំ ចំណាំត្រង់ណោះចោលត្រង់ណោះ
ត្រង់ណាដែលដឹងជាខ្លួនខុស ហ៊ានល្មោះពីព្រោះគេមិនដឹង ។
១៣-សង្ឃាទិសេសប្រហែសបាន ដប់បីសង្ខានប្រមាណថ្លឹង
បើធ្លាប់សង្រួមឲ្យយ៉ាងតឹង មិនអរមិនខឹងមិនបានខុស ។
១៤-អង្គុយប្រមូលអាល្បឹភ្លាត់ បាចិត្តិយទុក្កដលាយចំរុះ
ត្រចៀកអណ្ដែតភ្នែកប្រមុះ ភ្នែកមើលណោះណោះឃើញសុះសាយ ។
១៥-សោតិន្ទ្រិយស្ដាប់គិតខ្លាំង ចក្ខុន្ទ្រិយមើលជិតឆ្ងាយ
ឃានិន្ទ្រិយាពាលនាយអាយ សើចលេងសប្បាយចំអន់គ្នា ។
១៦-បរិសុទ្ធអាបត្តិទុក្កដញឹក បារាជិកច្រើនណាស់តែឧបជ្ឈាយ៍
ទ្រព្យក្នុងសម្បុត្ត(*)សម្បូណ៌ហៀរ ត្រូវទោសអទិន្នាគរុភណ្ឌ ។
១៧-ទ្រព្យសង្ឃជាដើមគឺដំណាំ អាហារម្ហូបប្រាំចាំខ្មេរគ្នាន់
ឱបទុកខ្លះខ្មែងក្រែងមិនគ្រាន់ អាហារប្រាំដាន់បារាជិក ។
១៨-របស់បានច្រើនក្នុងចំណែក គិបទុកមិនចែកឲ្យលោកភិក្ខុ
គ្រឿងយានជិះកប្បកាលិក ទុកខួបណ្ដាចព្រឹកម៉ៅតែឯង ។

---

(*)សម្បាច់ឬសំបាច់ សំស្ក្រឹត; សម្បាច «ទទួល, រក្សាទុក»)÷ ទ្រព្យគេដ្ឋី, មរតក ។

១៩- ម៉្យាងទៀតគេបែរចូលវិហារ បាសកបូជាដល់តម្កើង
គេរៀនបាលីមានខ្លីវែង គេតែងនឹងថាសង្ឃស្ស ។

២០- ប្រកាសប្រគេនជំនុំសង្ឃ ចំពោះគ្រប់អង្គថាទេមះ
លោកសង្ឃសាធុមិនសល់ម្នាក់ សង្ឃរាជទុកដាក់មិនចែកចាយ ។

២១- ខ្ញុំចាត់ចែងតាមខ្ញុំចេះចាំ អាហារម្ហូបប្រាំបែកបរិយាយ
នេះសុទ្ធតែសីលផ្ទុសអន្តរាយ លោកសង្ឃទាំងឡាយកុំប្រព្រឹត្ត ។

២២- ពីព្រោះពន្ធ័យទាំងប្រាំមួយ លោកណាមិនព្រួយមិនប្រុងគិត
លោកអាមោះហោប៉ាំងងងឹត សិស្សមានគំនិតមិនហ៊ានថា ។

២៣- សង្ឃរាជគ្រូសិស្សបរិស័ទ គួរប្រុងប្រតិបត្តិតាមពុទ្ធដីកា
ពួកបាចិត្តិយសេក្ខិយា កម្រសង្ឃណារក្សាបាន ។

២៤- ញឹកញាប់តែហ្វូងកងទុក្កដ មិនដឹងកំណត់បាត់ប៉ុន្មាន
លោកសង្ឃចូលសិងមិនដឹងប្រាណ ទុក្កដសំរានសំរាកចាំ ។

២៥- ក្រវែលដល់ពេលបាយសំឡ ចូលមាត់ចូលកពីឆ្វេងស្ដាំ
កងសេក្ខិយាធិតសិបប្រាំ បាចិត្តិយបួនឆ្នាំលើទុក្កដ ។

២៦- លោកសង្ឃស្រណុកនឹងរួចខ្លួន បាដិទេសទាំងបួនសិក្ខាបទ
បារាជិកបួនមិនកំណត់ បើកាន់ប្រាកដប្រកែកបាន ។

២៧- ក្រឡេកមើលឃើញស្រណុកគេច កុំឲ្យតែភ្លេចផ្លូវកម្មដ្ឋាន
សង្គ្រមសុចរិតប្រិតប្រុងប្រាណ អបត្តិមិនហ៊ានចូលមកជិត ។

២៨- សង្ឃរាជគ្រូសូត្របរិសណ្ឋាន ម្យ៉ាងបួសចង់បាននិព្វានពិត
ម្យ៉ាងបួសចង់ធ្លើងដំឡើងរិទ្ធិ គំនិតចង់ខ្ពស់ក្នុងលោកិយ ។

២៩- ម្យ៉ាងបួសមិនត្រង់ចង់ធ្វើធំ រៀនសិល្បអាគមមន្តបាលី
ធ្វើពេទ្យព្រោះហេតុចង់ឲ្យល្បី ស្តោះផ្លុំប្រុសស្រីឲ្យជារោគ ។

៣០- ស្តោះផ្លុំក្របុំបូមេម៉ាយ មិនដែលស្តោះឆ្ពាយអង្គុយល្ងោក
ដល់មន្តអាគមរាចូលជោគ វែងស្គាល់ជាលោកជាបាសក ។



www.elibraryofcambodia.org

៣១-ម្យ៉ាងទៀតមានយាយស្រីក្រមុំ ពោះធំក្នុងពុតបទអាក្រក់
អាឆើមអាថាអាកើតត្រក់ កុហកលោកត្រូវឲ្យច្រកថ្នាំ ។
៣២-ច្រកទាល់តែផ្ដួលរោគស្លួយ រលាយរូប១នឹងខន្ធ៤
នេះហៅបួសក្រៅបន្ទូលផ្ដាំ ប្រព្រឹត្តសាងកម្មឲ្យអន្តរាយ ។
៣៣-ធ្វើពាឡប់ពានពាក្យព្រះពុទ្ធ រលត់រលាងរាងរូបកាយ
ម្លឹងហើយមិនសិក្សានៅនឹកស្ដាយ សប្បាយចិត្តណាស់ផ្លប់ធ្វើធំ ។
៣៤-ព្រះពុទ្ធមិនហាមឲ្យដាច់សោះ បើរោគបុរសឲ្យស្ដោះផ្លុំ
កុំភ្លើច្រកថ្នាំស្រីក្រមុំ រូបកន្ធផ្ដើមផ្ដុំរលាយស្លាប់ ។
៣៥-សង្ឃរាជម្យ៉ាងទៀតគ្រប់ជាបី បើកណានលោកិយធម៌ក្រៅច្បាប់
ចេញភាសបរិយាយអធិប្បាយប្រាប់ ឲ្យរៀបប្រដាប់តាមចំណាំ ។
៣៦-មានប្រាក់១រៀលសំពត់ស អង្ករនឹងទៀន៤ធូប៤
បាយសីស្លាធម៌អបឆ្វេងស្ដាំ ឧបាសឃើញពៀរកម្មនិងបុណ្យបាប ។
៣៧-គ្រោះថ្នាក់យ៉ាងណាមិនកំបាំង ជម្ងឺតិចខ្លាំងដឹងដរាប
ស្លាប់រស់ដូចម្ដេចស្រេចនូវខាប ខ្មោចប្រែតព្រាយអាបឃើញទាំងអស់ ។
៣៨-ឃើញត្រូអក្ខរធំប្ដូរផ្ដូរ ឃើញនរកឃើញសួគ៌គ្មានចន្លោះ
ឃើញសាយសុរសព្ទទ្រព្យរបស់ ដិតឆ្ងាយតៀនកោះធ្លុះក្នុងដី ។
៣៩-អ្នកខ្លះឲ្យយកកូនស្លាប់ ហៅឲ្យមកចាប់កំណើតថ្មី
រំលងឆ្នាំពីរឬឆ្នាំបី ប្រុសមកជាស្រីខុសប្រាថ្នា ។
៤០-នេះឯងធម៌ក្លែងក្រៅគម្ពីរ ឧត្តរិពេញទីខុសសិក្ខា
វិន័យមិនកាន់ៗតម្រា ពុទ្ធដីកាប្រឹតប្រាមមិនព្រមស្ដាប់ ។
៤១-សង្ឃរាជស្លូតត្រង់មានច្រើនអង្គ សូត្រធម៌ចាំស្ទាត់មិនចាំច្បាប់
បើមានអ្នកចេះលើកប្រាប់ ចាំធ្វើតែត្រាប់តាមគ្រូមុន ។
៤២-ប៉ុន្មានតមកដល់ឥឡូវ និងលើកត្រូវដូចភ្លេចគុណ
ល្ងង់ហើយមានះចចេសស៊ីន ព្រួសកធ្វើបុណ្យរាល់ផ្ទះ ។



www.elibraryofcambodia.org

៤៣- បំបួសខែជេស្ឋខែអាសាឍ ចីវរនិងបាត្រខ្វាតមិនត្រូវ
ឃើញមិនលក់ចេកទិញយកទៅ មិនសូវរិះគិតពិនិត្យខ្វាត ។
៤៤-របស់ពុំឡូវផ្លាស់ប្តូរគ្នា បាត្រស្ពាន់ដីដែកៗ ស៊ីឡាត
ទំផាងផ្តិលបាយហៅថាបាត្រ បានថ្មីល្អស្អាតក៏យកដែរ ។
៤៥-គ្រូសូត្រៗញត្តិតាមបន្ទូល បាសកលួនចូលប្រគេនតែ
លោកសង្ឃអង្គុយរៀងបង្អែ បាសកចិនខ្មែរទាំងក្មេងចាស់ ។
៤៦-អង្គុយជ្រុករៀតនិងលោកសង្ឃ មិនចង់ឲ្យឆ្ងាយឲ្យស្រឡះ
ហុតក្រាបប្រណម្យឱនសំពះ អន្តរាយហត្ថបាសតូចលោកសង្ឃ ។
៤៧-អ្នកបួសមិនកើតឧបសម្បទ បរិសទ្យអង្គុយនឿយគ្រប់អង្គ
គ្រូសូត្រឡើយសូត្រគួរផ្ចិតផ្ចង់ ប្រឹងប្រើតដប្រេងដម្រូវខ្យល់ ។
៤៨-ច្បាប់បួសសត្រូវគ្នាទឹងកឋិន តែចេះមិនផ្ចិនមិនឡើងផល
គួររៀនឲ្យសព្វកុំឲ្យឆ្ងល់ បើរៀនចេះដល់ត្រូវសមគ្នា ។
៤៩-លោកសង្ឃវត្តក្រៅទៅជួយបុណ្យ បើបាននិមន្តចូលវិហារ
ត្រូវគង់ប្រជុំរួបរួមគ្នា កុំឲ្យឃ្លាតឃ្លាពីហត្ថបាស ។
៥០-លោកសង្ឃរៀបសូត្រអង្គកឋិន បាសកខ្មែរចិនទាំងក្មេងចាស់
ត្រូវថយឲ្យឆ្ងាយឲ្យស្រឡះ កុំឲ្យពាល់ប៉ះនឹងលោកសង្ឃ ។
៥១-សូត្រសេចក្តីស្រេចសូត្រសន្មត ឲ្យឮប្រាកដលោកគ្រប់អង្គ
មិនត្រូវសូត្រឡប់ខ្លាចគេថ្លង់ ត្រូវឲ្យអស់សង្ឃដឹងទាល់គ្នា ។
៥២-សូត្រក្រាលក៏ដូចសូត្រសន្មត ឲ្យឮប្រាកដក្នុងវិហារ
មានកាលលោកគ្រូធំឧបជ្ឈាយ៍ ចិត្តជាចែកឲ្យគ្រូសូត្រគ្រង ។
បើគ្មានលោកគ្រូមានលោកចាស់ គោរពសំពះទុំរំលង
ត្រូវសូត្រកន្ទុតាមទំនង ក្រាលគ្រប់ពីរផងប្រាប់បរិសទ្យ ។
៥៣-លោកចាស់វស្សាមិនបានគ្រង គ្រាន់តែត្អូញត្អែងទៀបចែកចាក់
អាទិសង្ឃកឋិនបាំងអាបត្តិ បង្អាត់សូត្រធម៌ឲ្យល្អបគ្នា ។



www.elibraryofcambodia.org

៥៥-ក្រោយគ្រប់ឈប់ស្លេះស្រាប់ក៏ បាសកប្រគេនអស់ភិក្ខុការ
ឲ្យពោះរាល់អង្គក្នុងវិហារ អាមិសបូជាគ្រប់ប្រដាប់ ។
៥៦-ប្រគេនរួចហើយចូលជិតចុះ ទាំងស្រីទាំងប្រុសមិនខុសច្បាប់
ប៉ុន្តែអ្នកឆ្ងាយច្រើនប្រញាប់ មិនសួរចាំស្តាប់លោកយថា ។
៥៧-សូមទានសន្តោសសម្តែងច្បាប់ ព្រះសង្ឃកុំចាប់ចងទោសា
ខ្ញុំភ័យខ្លាចអាប់ព្រះសាសនា ប្រោសប្រាណបន្តាបណ្តាសង្ឃ ។
៥៨-ខ្ញុំពោលមិនមានពាក្យបង្អាច ក្រែងសិលលោកដាច់ខ្ញុំដម្រង់
ដម្រុះតែតាមច្បាប់ព្រះអង្គ ព្រះឱស្ឋត្រឹមត្រង់ត្រូវមាត្រា ។
៥៩-កាលអង្គសម្តេចព្រះចមភព ជាមួយមនុស្សសត្វនិងទេវតា
ជិតចូលនិព្វានមានពុទ្ធដីកា ផ្តាំផ្ញើសាសនាមហាបរិសទ្យ ។
៦០-ភិក្ខុភិក្ខុនីអង្គអរហន្ត អានន្ទមិនទាន់បានអរហត្ត
ក្បួនវិន័យកុំឲ្យបាត់ ប្រយ័ត្នឲ្យមានប្រយោជន៍យូរ ។
៦១-ក្រោយនោះព្រះអង្គចូលនិព្វាន អរហន្តហោះឆ្ងានមានជាត្រូ
មិនមានអក្ខរាណាដាក់ទុក ទេស្នាបង្គួរពីព្រះឱស្ឋ ។
៦២-ព្រះអគ្គសាវកពាល់ព្រះអង្គ ព្រះទ័យស្រោចស្រង់ទ្រង់សន្តោស
សម្តែងធម៌អាធិមេត្តាប្រោស ពាបបុណ្យគុណទោសនិងសីលទាន ។
៦៣-យើងយល់ថាធម៌នឹងសូន្យស្ងាត់ អស់អង្គអរហន្តចូលនិព្វាន
សង្ឃសេខបុគ្គលមិនទ្រង់ញាណ និងមានអក្ខរាណាតែងទុក ។
៦៤-ព្រះធម៌ប្រាំបីហ្មឺនបួនពាន់ ស្រេចនៅអានន្ទចាំទំនុក
ដំណាលព្រះអង្គដឹងគ្រប់មុខ ផង្រុកធម៌អាថ៌មហាអានន្ទ ។
៦៥-ជាព្រះអនុជអាណិតសត្វ ក្រែងបាត់ធម៌អាថ៌មិនគ្រប់គ្រាន់
ព្រះធម៌ប្រាំបីហ្មឺនបួនពាន់ ក្មេងខ្មាន់ខ្លះខ្វែងចាត់ចែងចារ ។
៦៦-ចេះចប់អភិធម្មចាំរហូត វិន័យព្រះសូត្រ៥ប្រការ
ប្រកាសអស់អង្គអរហន្តា បិដកឯណាជាឫសគល់ ។



www.elibraryofcambodia.org

៦៧- បរមត្ថព្រះសូត្រអានន្ទចាំ    វិន័យទាំង៥ឧបាលិយល់
អរហន្តទាំងអស់កើតរស់    អំពល់អំពីរឿងធម៌អាថ៌ ។

៦៨- ព្រះបាទអជាតសត្រូវ    ជួយតិតដម្រូវព្រះសាស្ដា
សន្ទកឲ្យឈ្មោះហៅក្សត្រា    ព្រោះមហាក្សត្រចូលគំនិត ។

៦៩- និយាយឲ្យដឹងដើមកំណើត    កាលកើតអក្សរាចារស្លឹករឹត
បកប្រែបាលីសេចក្ដីពិត    ពិនិត្យត្រឹមត្រូវតាមពុទ្ធដីកា ។

៧០- ប្រាំរយឆ្នាំគត់ផុតភិក្ខុនី    មនុស្សស្រីលែងបួសខ្លាចសិក្ខា
កំណត់មួយពាន់ប្លាយវស្សា    អស់អរហន្តចូលនិព្វាន ។

៧១- នៅសល់តែសង្ឃបុថុជ្ជន    កិលេសនៅធ្ងន់នៅស្រុកឃ្លាន
សង្ខាតឱហាតចំរើនឈាន    ហោះឆ្ងាយមិនរួចដូចបំណង ។

៧២- កើតមានគម្ពីរនៅលង្កា    ព្រះពុទ្ធឃោសាចារចម្លង
កើតមានបាលីសម្រាយផង    ធ្វើបុណ្យម្ដងៗស្ដាប់ទេស្នា ។

៧៣- ទសជាតិទាំង១០មានគ្រប់វគ្គ    ប្រែត្រូវប្រាកដព្រះគាថា
ព្រះធម៌សូត្រមន្តឬសូត្រដារ    អ្នករៀនអក្សរពីរចំណែក ។

៧៤- ចំណោះចំណាំចាំរាល់ខ្លួន    អ្នករៀនអានក្បួនចាស់ថាវចែក
ហ៊ានភ្លាត់ព្រោះអានឃើញទឹងភ្នែក    កើតឈ្លោះប្រកែកប្រកួតខឹង ។

៧៥- ប្រកាន់តែខាងខុសវបាត    មិនរៀនមេសូត្រឲ្យចេះដឹង
អានចេះតែកកាប៉ុណ្ណឹង    ទំប្រឹងចំអឹតអួតខ្លួនត្រូវ ។

៧៦- សព្វថ្ងៃជំរែកពីយា-យ៉ា    ដំឡើងភ្នែកស្លោមុខក្រញូវ
ផ្ដាប់យោងពីខ្មោចឪ    តាំឡូវយ៉ាណាមិនសុខចិត្ត ។

៧៧- អ្នកម្នាងអានស្រះត្តប្រាំបី    ឲ្យនឹងបាលីដាក់រឹត
ឆ្លុំមេសូត្រប្រឹងប្រែប្រិត    ព្រោះដៀតឲ្យត្រឹមត្រូវមាត្រា ។

៧៨- អ្នករៀនគ្រប់វគ្គគ្រប់នគរ    សង្កាត់ជើងលាប់ស្លូស្លា
បើសនឹងមកាប់ស្នូស្នា    អ្នកមានប្រាជ្ញាគួរស្ដាប់បាន ។



www.elibraryofcambodia.org

៧៩-កុំល្ងង់ទាល់ងាប់ផ្លាប់មិនដឹង បើខឹងខ្ញុំឃាត់ថាឲ្យទាន
ខ្ញុំដាក់ជើងមពីបូរាណ ក្មេងតូចប៉ុន្មានស្គាល់ខ្ញុំខ្ញា ។

៨០-រាល់រាស្ត្រចាស់ក្មេងកុំចិត្តខ្លាំង គួរខ្មាសបារាំងអ្នករាជការ
ដើមហេតុអំពីព្រះករុណា ឲ្យសាងសាលាប្រែបាលី ។

៨១-ទ្រង់ចាំទំនៀមពីបូរាណ ហើយបានជំនុំព្រមកុង្ស៊ុយ
បំណាច់ធ្វើស្តេចគ្រងផែនដី ទិសទាំងប្រាំបីវិពៃគ្រប់ ។

៨២-ព្រះកាយពលមិនរលំរែក ព្រះទ័យរំលែកទាំងថ្ងៃយប់
ចូលទៅទនបន្ទំទីបន្ទប់ បន្ទូលមិនឈប់រាល់វេលា ។

៨៣-មេត្តាជ្រោសប្រោណអ្នកមានសក្តិ ចែកលុយចែកកាក់តបអ្នកងារ
ម្យ៉ាងពួកក្សត្រីស្នំស្រីង្គារ ក្រែងគ្រុនរងាមិនបានសុខ ។

៨៤-ព្រះទ័យមេត្តាសព្វមនុស្សសត្វ សោយរាជសម្បត្តិសំបើមស្តុក
ព្រះកាយប្រកបគង់ស្រណុក ព្រះទ័យរិតក្តជាធម្មតា ។

៨៥-១ព្រួយនិងឱបព្រះនគរ ២ព្រួយនឹងពព្រះសាស្នា
៣ព្រួយលោកសង្ឃទាន់សិក្ខា សង្រួមកិរិយាមិនបរិសុទ្ធ ។

៨៦-នឿយណាស់ព្រះនេត្រព្រះកាយា ព្រះឱស្ឋត្រួតគ្រាកើនបំផុត
ដាស់តឿនបំភ័យពួកកុលបុត្រ ឲ្យចេះសំឱតសង្រួមកាយ ។

៨៧-ទ្រង់ចេញប្រកាសដាក់ប្រាកដ ប្រគល់រាល់វត្តទោះជិតឆ្ងាយ
លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងឡាយគ្រប់ជំពូក ។

៨៨-មិនត្រូវចំពោះស្តាប់តន្ត្រី កុំបីមើលរាំវានាំភ្លូក
កុំដើរភ្លើៗមើលអុំទូក អ្នកបួសធ្វើលោកមិនត្រូវការ ។

៨៩-បើមានត្រូវកិច្ចដើរយប់ថ្ងៃ សង្ឃបងនិស្ស័យចាស់វស្សា
កុំដើរទំបស្សាទៅណាៗ អ្នកចេះសិក្ខាគេទាស់ភ្នែក ។

៩០-លោកនេនកុំសុំលុយចិនចាយ បិណ្ឌបាតតែបាយម្នាក់១រែក
គ្រឿងម្ហូបចំណីបាសកចែក កុំយួរពុនរែករាផ្ទាក់រែក ។



www.elibraryofcambodia.org

៩១-របស់បាសកគេប្រគេន ប្រគល់លោកទេទបានលោកភិក្ខុ
ពិញ្ចឹមជីវិតនឹងបាយទឹក បិណ្ឌបាតពេលព្រឹកយប់សូត្ររៀន ។
៩២-លោកណាត្រឹមត្រូវមិនសូវខុស ស្ងៀមស្ងាត់ទៅចុះកុំអន់អៀន
លោកណាមិនចេះកុំខ្ជិលរៀន ពាក្យប្រៀនប្រដៅឲ្យឆ្លើយភ្លាក់ ។
៩៣-បំណាច់ព្រះអង្គទ្រង់ផ្តាំផ្ញើ សាស្នាឋិតលើស្តេចមហាចក្រ
ព្រះមហាចមពង្សទ្រង់ជំពាក់ ចំពោះធុរៈនឹងសាស្នា ។
៩៤-ពីត្រឹមណោះរៀងដរាបមក ដល់ស្រុកគោកធ្លកមានសារគារ
ប៉ុន្មានរាជ្យហើយមិនដឹងថា ដល់មកករុណាយើងសព្វថ្ងៃ ។
៩៥-ហេតុនេះលោកសង្ឃប្រុងពិនិត្យ សៀវភៅស្លឹករឹតមានរាល់ដៃ
ផ្ទៀងមើលសុភាកវិនិច្ឆ័យ បើនៅសង្ស័យឲ្យសិក្សា ។
៩៦-សព្វសង្ឃចាស់ខ្ចីគប្បីស្តាប់ ឈ្មោះច្បាប់បំពានព្រះពុទ្ធដីកា
បង្គំថ្វាយដល់ព្រះករុណា សូមទ្រង់មេត្តាជ្រាបព្រះទ័យ ។
៩៧-ក្រែងខ្លួនប្រទះពាក្យឆ្គាំឆ្គង ពុំត្រូវទំនងក្រឹត្យវិន័យ
សុំទ្រង់មេត្តាអត់ទោសពៃរ៍ ក្រួញក្រាបសំពះក្រោមព្រះបាទ ។
៩៨-ព្រះសង្ឃទាំងអស់ទោះតូចធំ ខ្ញុំខិនបង្គំសុំអនុញ្ញាត
ខ្ញុំពោលមិនមានពាក្យប្រមាទ សង្ឃជាល្អស្អាតខ្ញុំមិនថា ។
៩៩-ខ្ញុំពោលតែសង្ឃធ្វើអាក្រក់ បើខ្ញុំកុហកខុចមុសា
ហេតុនេះខ្ញុំសុំបវារណា សង្ខេបនិដ្ឋារឿងលោកសង្ឃ ។
១០០-សុំក្រើនរំលឹកឧបាសក ច្រើនចិត្តអាក្រក់ខ្ញុំដម្រង់
ដម្រះតាមផ្លូវច្បាប់ព្រះអង្គ កុំបីលះបង់ចោលសាស្នា ។
១០១-កើតមកពូជពង្សពេញពុទ្ធសាស្ន៍ កុំភ្លើកុំផ្លាស់ភ្លេចសារគារ
មានរូបមានចិត្តមានប្រាជ្ញា គួរពិចារណារកខុសត្រូវ ។
១០២-កាលកើតមិនទាន់ដឹងកើតទុក្ខ បន្ទោរមូត្រល្អក់ដាក់ម៉ែឪ
លាងជុសជ្រះស្អាតផ្អែកទុកនៅ បុកស្រូវអង្ករស្លដណ្តាំ ។



www.elibraryofcambodia.org

១០៣-ដេកឱបត្របក្រុងប្រុងប្រយ័ត្ន    ក្រែងសត្វស្រមោចមូសចុចខាំ
លំបាកឡើយណាស់១៨ឆ្នាំ    ម៉ែឪរងកម្មចិញ្ចឹមកូន ។
១០៤-កំឡោះក្រមុំពេញរូបកាយ    អាពុកនឹងម្តាយចាស់ទ្រមខ្លួន
ក្រមុំរូបល្អបរិសុទ្ធស្ងួន    បានស៊ីជំនូននំចំណី ។
១០៥-រៀបការរកស៊ីរួមបន្ទុក    សូមម្តាយឪពុកប្រពន្ធប្តី
មួយឆ្នាំពីរឆ្នាំកើតកូនខ្ចី    ជីដូនពបីចៅផុះដាក់ ។
១០៦-កាលកូនពីតូចឡើយងូតលាង    ធំពេញរូបរាងខានប្រឡាក់
លាងល្អក់ចោះទៀតឡើងពីរថ្នាក់    កម្មមានជំពាក់ថែមពីរជាន់ ។
១០៧-ចំណែកកូនប្រុសបានបួសភិក្ខុ    ខ្លះបំបួសរពុកសហាយស្មន់
សឹកមកមិនឈប់ទៅរកភ័ក្ត្រ    រៀបការមិនទាន់ពាន់ចិត្តឯង ។
១០៨-អ្នកខ្លះបួសចេះដឹងធម៌អាថ៌    បួនប្រាំវស្សាយូរអង្វែង
សឹកមករកស៊ីខំខ្នះខ្នែង    មិនលែងឲ្យទុក្ខឪពុកម្តាយ ។
១០៩-ព្រួយចិត្តព្រោះដ្បិតរកប្រពន្ធ    ថែមទោសទុក្ខធ្ងន់រាល់រូបកាយ
រកស៊ីនៅជិតមិននៅឆ្ងាយ    កូនផ្ញើខ្ញុំម្តាយៗខ្ញុំកូន ។
១១០-បើមានប្រពន្ធនៅស្រុកឆ្ងាយ    ឪពុកនឹងម្តាយឃ្លាតដោយខ្លួន
បានម្តាយខាងស្រីនៅថែជួន    មិនលែងជីដូនផ្ញើខ្ញុំចៅ ។
១១១-ពីព្រោះរកស៊ីក្នុងបន្ទុក    ចំណីគ្រប់មុខទោះឆ្អិនឆៅ
ស្វាយខ្នុរចេកដូងដំឡូងត្រាវ    របស់នោះមៅក្នុងចំណែក ។
១១២-អាពុកម្តាយចាស់ឈឺទម្ងន់    ចំណីជោរជន់ជូនដាច់ប៉ែក
លើកឡើងប្រគល់ម្តាយប្រកែក    សម្រក់ទឹកភ្នែកស្តាយចំណី ។
១១៣-ចង់ដែរប៉ុន្តែលេបមិនរួច    ដំបបានតិចតួចចោលទៅដី
យ៉ាងនេះគ្រប់មនុស្សទាំងប្រុសស្រី    គប្បីសំគាល់រាល់រូបកាយ ។
១១៤-ពីតូចទាល់ធំពេញធំណាស់    មិនដែលសំពះអាពុកម្តាយ
សំពះម្តងៗតែអ្នកឆ្ងាយ    ត្រង់ម្តាយអាពុកថាអៀនខ្មាស ។



www.elibraryofcambodia.org

១១៥-ម្តាយពេលវេលាណា អាចារ្យស្រោចទឹកលើកចំអាស
ប្រមូលចូលដុសលាងជំរះ ឲ្យក្រាបសំពះបវារណា ។
១១៦-ប្រណម្យសុំទោសម្តាយមិនដឹង គ្រង់អរឬខឹងម្តាយមិនថា
ភ្នានប្រាក់ទាំងជឿទំនិញស្បូវ ខ្លះខ្ចីចងការញាតិសន្តាន ។
១១៧-បានតែកំលាំងតាំងខំរត់ ទៅទិញសំពត់ផ្តិលថាសចាន
គ្រប់គ្រឿងប្រដាប់ទាំងប៉ុន្មាន ឲ្យបានដាក់ស្លុងឲ្យម៉ែឪ ។
១១៨-ដាក់ចោលបោះបង់លោកសង្ឃទស់ បើឲ្យកាលរស់នោះពេញត្រូវ
ដល់វិញ្ញាណចេញអស់ទៅ អ្នកណានឹងទៅនឹងត្រេកអរ ។
១១៩-កាលម្តាយរស់នៅមិនសួរលុះ បាននេះខ្វះនោះចេះតែក្រ
ម្តាយស្លាប់មិនដឹងប្រឹងត្រដរ អង្គរខ្ចីជឿគេធ្វើបុណ្យ ។
១២០-ច្រើនចិត្តអាក្រក់តិចចិត្តល្អ ច្រើនខាងអ្នកក្រតិចអ្នកមាន
កំណាញ់ស្វិតពេកច្រើនស្រេកឃ្លាន គួរគិតសន្និដ្ឋានចូលចិត្តចុះ ។
១២១-កើតមកតែងរកប្រពន្ធប្តី មួយរយមានពីរបីទាំងស្រីប្រុស
បើប្អូនត្រឹមត្រូវមិនសូវខុស ស្លាប់រស់កុំសឹកយកប្រពន្ធ ។
១២២-បើទ្រាំមិនបានហើយសឹកមក ឲ្យគិតពេលករកទ្រព្យធន
ជូនម្តាយអាពុកទុកធ្វើបុណ្យ គោរពតបគុណចំរើនផល ។
១២៣-បើយកប្រពន្ធនៅឲ្យឆ្ងាយ ល្អមម្តាយអាពុកទៅមកដល់
កុំនៅជាមួយកើតអកុសល ព្រោះម្តាយខ្វាយខ្វល់នឹងកូនឯង ។
១២៤-ប្រពន្ធនិងប្តីស្រីនិងប្រុស មិនដឹងទោសខុសគ្រប់កន្លែង
គ្មានប្តីប្រពន្ធគេតាំឆ្វេង អ្នកប្រាជ្ញសំដែងថាសេសបាប ។
១២៥-ឃើញត្រូវតែនៅឃ្លាតដោយខ្លួន ចំណីជំនូនជូនដរាប
កុំនៅជាមួយកើតឆ្អេះឆ្អាប ហេតុក្រាបសំពះកុំខ្មាសគុណ ។
១២៦-កូនចៅខាងក្រោយឲ្យប្រតិបត្តិ ប្រយ័ត្នកុំធ្វើដូចអ្នកមុន
អ្នកមានកូនចៅបានជាស៊ុន ទោសធ្ងន់ឲ្យទុក្ខអាពុកម្តាយ ។



www.elibraryofcambodia.org

១២៧- ស្រួលណាស់តែនាំឃ្លាតឆ្ងាយខ្លួន ឲ្យចេះទីជួនមើលនាយអាយ
ផ្ទះធំស្រណុកសុខសប្បាយ កុំស្ដាយស្រណោះរបស់នៅ ។
១២៨- មេបាសុខចិត្តឲ្យកូនស្រី យើងសង់ផ្ទះថ្មីដូចម៉ែឪ
មេបារៀបការជាត្រឹមត្រូវ ខ្លួននៅមិននៅនេះតាមចិត្ត ។
១២៩- ប៉ុន្តែម៉ែឪត្រូវសប្បុរស ឲ្យទ្រព្យរបស់ព្រោះអាណិត
ធ្វើតាមទំនៀមច្បាប់ក្រមក្រឹត្យ សាច់សាលោហិតមានសង្ស័យ ។
១៣០- យើងខំរកស៊ីមានពេលយប់ ត្រូវឆ្លៀតគោរពទោះយប់ថ្ងៃ
ចំណាំផ្អែមល្ហាបទោះសាបប្រៃ កុំលាក់សំចៃស៊ីភ្លេចគុណ ។
១៣១- ខ្លួនខ្ញុំកំណើតរាស្ត្រអ្នកស្រែ ឆោតឆៅខ្លៅដែរពីកាលមុន
កាលមកពីបួសខំរកពុន ធ្វើបាបនិងបុណ្យទម្ងន់ស្មើ ។
១៣២- ខ្ញុំស្មោះគោរពអាពុកម្ដាយ អស់លោកទាំងឡាយល្អមសរសើរ
ខ្ញុំជូនដំណឹងតាមដំណើរ ព្រោះខ្ញុំគ្រាន់បើជាងអ្នកល្ងង់ ។
១៣៣- ជាតិក្រោយកុំឲ្យខ្ញុំល្ងីល្ងើ ជាតិនេះចាស់ស្ទើរខ្ញុំប្រឹងស្វង់
ប្រឹងស្ទុះឲ្យរួចពីអន្លង់ ភ័យភិតខ្លាចស្ទុងទៅក្នុងផុក ។
១៣៤- ក្នុងភពសង្សារខ្ញុំសង្ស័យ សព្វថ្ងៃខ្ញុំភ័យខ្លាចនរក
ម្យ៉ាងទៀតខ្ពើមជាតិអាជីវក ជាតិល្ងោភោហុបល្អក់ព្រោះល្មើសគុណ ។
១៣៥- ក្រែងខ្ញុំបានល្មើសម៉ែឪខ្លះ ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន
ខ្ញុំសុំសមាទោសពីមុន សុំបុណ្យជួយបាំងបាបឲ្យបាត់ ។
១៣៦- ឲ្យបានទាន់ព្រះស្រីអារ្យ ឲ្យបែកប្រាជ្ញាក្នុងបរមត្ថ
ព្រះអង្គទេសនាទ្រង់ប្រោសសត្វ សុំលុះអរហន្តដូចបំណង ។
១៣៧- ចំណែកខ្ញុំស្លាប់ច្បាប់រំលឹក អស់លោកជួយទឹកសប្ដាស្បង
ធ្វើបុណ្យចែកផលដល់ខ្ញុំផង ទឹកឈ្មោះម្ដងៗដូចធម្មតា ។
១៣៨- មានម្ដាយអាពុករស់រូបរាង នោមជុះដុសលាងត្រូវល្មើបល្អា
ព្រះពុទ្ធចាកផុតផ្ដួលសង្សារ ប្រាថ្នារកផ្លូវទៅនិព្វាន ។



www.elibraryofcambodia.org

១៣៩-រលាយកងទុក្ខអកុសលកម្ម រលត់ខន្ធប្រាំលែងស្រេកឃ្លាន
យើងនៅសង្ខារនិងវិញ្ញាណ ទោសទុក្ខតែងមានតែរលត់គ្នា ។

១៤០-ខ្ញុំទូលបង្គំដើមឈ្មោះ**អ៊ី** ពូជពង្សអំបូរខ្មែរអ្នកជា
អាពុកឈ្មោះ**អ៊ុក**មានសក្តិងារ ចៅពញាធម្មធារាធ្វើមេស្រុក ។

១៤១-ក្នុងខែត្រភ្នំពេញឃុំកំបូល ពូជពង្សត្រកូលម្ចាស់អង្គប៉ុក
អាពុកអ្នកម្តាយឈ្មោះពញា**ម៉ឺន** គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។

១៤២-អ្នកម្តាយអាពុកបងប្អូនជិត ដីទួតមួយពាក់ពួងចិត្តជា
ជួនគាត់ផ្សំផ្គុំជាដំណ បង្កកើតខ្ញុំទូលបង្គំ ។

១៤៣-បង្កើតអំពីក្នុងគំនិត ភ័យភិតខ្លាចបាបចង់បានបុណ្យ
បានរៀនរៀងច្បាប់ប្រាប់មហាជន ប្អូនច្បាប់ពីមុនជូនរាជការ ។

១៤៤-ព្រោះខ្ញុំសៀវភៅតែសព្វសាយ ម៉ាដីមួយហ៊ានលោកថ្វាយព្រះករុណា
មិនបានថ្វាយផ្ទាល់ដល់ហត្ថា សូមទ្រង់មេត្តាប្រោសប្រណី ។

១៤៥-ខ្ញុំនកាយប្រណម្យសុំអនុញ្ញាត ក្រាបក្រោមព្រះបាទព្រះបារមី
តែងច្បាប់បរមត្ថអត្ថបាលី សេចក្តីតែងចប់ប៉ុណ្ណេះហើយហោង ។

៚ ៚
៚

# បញ្ជីឯកសារយោង

## BIBLIOGRAPHIE


១-ឯកសារភាសាជាតិ

- គិម-ប៊ិល (ធម្មករសលោ), *វិនយសង្គហៈ*, កំពង់ចាម, ១៩៨២, ១៥១ទំព័រ ។

- គង់សុខុម, *ចាស់មិនទាន់ទុំ*, សមាគមអ្នកនិពន្ធខ្មែរ, រង្វាន់១៩៧២, ១៣៨ទំព័រ (បោះពុម្ពឡើងវិញនៅភ្នំពេញ, បណ្ណាគារអង្គរធំ, ២០០២) ។

- ឃឹងហុកឌី, «បទពិសោធន៍ខ្លះៗនៃការសិក្សាលើអត្ថបទវិជ្ជា», *សមូហកម្មអក្សរសិល្ប៍នូហាច*, លេខ២, ២០០៤, ទំព័រ៩២-៩៦ ។

- ឃឹងហុកឌី, «អ្នកស្រីស៊ុយហ្សានការប៉ឺឡែស និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ», *សិក្សាចក្រ* លេខ៨-៩, ២០០៦-២០០៧, ទំព័រ១៨៩-១៩៦ ។

- ឃឹងហុកឌី, *អក្សរសិល្ប៍ខ្មែរសតវត្សទី២០, កវីនិពន្ធនិងកម្រងអត្ថបទ*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧, ៦១២ទំព័រ ។

- ចៅ-សំអាន, *អតីតប្រតិទិនបារាំងខ្មែរ*, ព.ស. ២៤២៨-២៥០៩, ច.ស. ១២៤៧-១៣២៨, គ.ស.១៨៨៦-១៩៦៧, ភ្នំពេញ, ១៩៦៧ ។

- ឆាយ ច័ន្ទនិដានិងនៅវណ្ណាទិន, «អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរនិងកវីត្រូវបានផ្ដើរលើកនៅក្នុងរាជធានី», *ឌីភែមបូឌាដេលីថ្ងៃសុក្រទី២២ខែកុម្ភៈឆ្នាំ២០០៨* ទំព័រ៦ ។

- ជួន-ណាត (ព្រះគ្រូសង្ឃសត្ថា), ហួត-តាត (ព្រះគ្រូសង្ឃវិជ្ជា), អ៊ុំ-សូរ (ព្រះគ្រូវិបុលបញ្ញា), *សមណវិន័យ*, ភ្នំពេញ, ព្រះរាជបណ្ណាល័យ, ១៩២៨, ៦៤ទំព័រ ។

- ឌិក-គាម, *ប្រតិទិន១០៦ឆ្នាំសុរិយគតិនិងចន្ទគតិ*, ភ្នំពេញ, ១៩៦៤, ១២១ទំព័រ ។

- ឌិក-គាម និងឡឹក-អំ, *ភូមិកំរប្ញាន*, ភ្នំពេញ, ១៩៧១, ៩៣ទំព័រ (បោះពុម្ពឡើងវិញដោយក្រសួងអប់រំភ្នំពេញ, គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ, ១៩៨៧) ។




www.elibraryofcambodia.org

-ប៉ែន វណ្ណផុន, *ក្បួនតែងក្រមុំ*, សមាគមអ្នកនិពន្ធខ្មែរ, រង្វាន់ក្រមង៉ុយ ១៩៧២, ១៦៨ ទំព័រ (បោះពុម្ពឡើងវិញនៅភ្នំពេញ, បណ្ណាគារអង្គរធំ, ២០០២) ។

-ហួង-ទួន, *បញ្ជាក់សករាជ ពី គ.ស.១ ទៅ ៤០០០ ឆ្នាំ*, បាន ពិនិត្យ ដោយ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណ មហានិកាយ ជ.ណ., ភ្នំពេញ, បណ្ណាគារ ជឹង-ហ៊ួ-ហួត, ១៩៥៧, ៩០ ទំព័រ ។

-ភិរម្យង៉ុយ, *ច្បាប់ក្រមង៉ុយ ៖ ច្បាប់ល្បើកថ្មី, ច្បាប់កេរកាលថ្មី, សេចក្តីរំលឹកដាស់តឿន, ពាក្យកាព្យប្រដៅជនប្រុសស្រី*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពផ្សាយលើកទី៧, ១៩៧៣, ១២០ ទំព័រ (ច្បាប់ក្រមង៉ុយទាំងបួនបោះពុម្ពផ្សាយដំបូងផ្សេងៗគ្នា នៅរាជបណ្ណាល័យ នាឆ្នាំ១៩៣២-១៩៣៣) ។

-ភិរម្យង៉ុយ, *ពាក្យកាព្យប្រដៅជនប្រុសស្រី*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពលើកទី៨, ១៩៦១, ២៣ ទំព័រ (បោះពុម្ពលើកទី១ នៅឆ្នាំ១៩៣២) ។

-ដ- , *ច្បាប់ល្បើកថ្មី*, ភ្នំពេញ, Impr. du Gouvernement, 1932, In-32°, 84 p.

-ដ- , *សេចក្តីរំលឹកដាស់តឿន*, ភ្នំពេញ, ព្រះរាជបណ្ណាល័យ, ១៩៣៣, ៣៩ ទំព័រ ។

-ដ- , «ល្បើកច្បាប់សង្ខេប», *កម្ពុជសុរិយា*, លេខ (?), ឆ្នាំ (រវាងឆ្នាំ ១៩៣២-១៩៣៥ ?), ទំព័រ ១០៨-១២៥ ។

-ដ- , *បណ្តាំក្រមង៉ុយ*, ជីវប្រវត្តិអ្នកនិពន្ធដោយលី-ធាមតេង, សម្រាប់កម្មវិធីថ្នាក់ទី៦ទំនើប, ភ្នំពេញ, សេង-ងួនហួត, ១៩៦៨, ២៣ ទំព័រ ។

-ដ- , *បណ្តាំក្រមង៉ុយ, ច្បាប់ដាស់តឿនកូនចៅ*, ភ្នំពេញ, គិម-សេង, គ្មានកាលបរិច្ឆេទ, ៩២ ទំព័រ (ខ្នាតតូច) ។

-លីធាមតេង, *អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី*, ភ្នំពេញ, សមាគមអ្នកនិពន្ធខ្មែរ, ១៩៧២, ៣២ ទំព័រ ។

-ដ- , *អ្នកនិពន្ធខ្មែរ, ភិរម្យ-ង៉ុយ*, ភ្នំពេញ, សេងងួនហួត, ១៩៦៦, ៦៨ ទំព័រ ។

-ដ- , *អក្សរសាស្ត្រខ្មែរ*, ភ្នំពេញ, បណ្ណាគារសេង-ងួនហួត, ១៩៦០, ២១៣



www.elibraryofcambodia.org

ទំព័រ ។

- វចនានុក្រមខ្មែរ, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត, ១៩៦៧-៦៨, ២ ភាគ ។

- រិន គីម, *អ្នកទោសកោះត្រឡាច*, ភ្នំពេញ, សមាគមអ្នកនិពន្ធខ្មែរ, រង្វាន់ក្របផ្ទុយ ១៩៧២, ២ ភាគ, ២៦៧ ទំព័រ (បោះពុម្ពឡើងវិញនៅប៉ារីស, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ, ១៩៨២ មានលំនាំដើមដោយ ហ៊ិង ហុកឌី) ។

- ហួត-តាត (សម្តេចព្រះមហាសុមេធាធិបតី), *កល្យាណមិត្តរបស់ខ្ញុំ*, ភ្នំពេញ, ១៩៧០, ៧០ ទំព័រ ។

- អ៊ុំ-ស៊ុង, *ច្បាប់សំបូន្មានបព្វជិតគ្រហស្ថ*, ភ្នំពេញ, ១៩៥៥, (បោះពុម្ពលើកទី ៨ នាឆ្នាំ ១៩៥៨) ៣៦ ទំព័រ ។

- អ៊ុំ-ស៊ុង, *ច្បាប់គោរពមាតាបិតា*, ភ្នំពេញ, គឹមសេង, ១៩៥៥ (បោះពុម្ពលើកទី ២ នាឆ្នាំ ១៩៦៧) ៤៧ ទំព័រ ។

- អ៊ុំ-ស៊ុរ (ព្រះគ្រូវិមលបញ្ញា) និងជួន-ណាត (ព្រះគ្រូសង្ឃសត្ថា), *ក្រៅប្រណាមសង្ខេប និងគិហិវិន័យសង្ខេប*, ភ្នំពេញ, ១៩៦៦, ៩៦ ទំព័រ (បោះពុម្ពលើកទី ២០) ។

២-ឯកសារភាសាបរទេស

- BOUILLEVAUX C.E., *Voyage dans l'Indo-chine (1848-1856)*, Paris, V. Plamé, 1858, 376 p. + cartes.

- CHANDLER David P., "The Assassination of Resident Bardez (1925): A Premonition of Revolt in colonial Cambodia", *Journal of The Siam Society*, 1982, vol. 70 parts 1+2, p. 35-49.

- COMTE M., "Rapports de classes et relations inter-ethniques dans le Cambodge précolonial", *ASEMI*, VII (1976), 1, p. 55-90.

- CONDOMINAS Georges, "Littérature orale: Introduction", *Asie du Sud-Est et Monde insulindien (ASEMI)*, V, 1974, 4, p. 1-29.

- COMMISSION DE MŒURS ET COUTUMES DU CAMBODGE, *La vie du paysan khmer*, Phnom-Penh, Institut bouddhique, 1969, 103 p.

- DELVERT Jean, *Le paysan cambodgien*, Paris, Mouton, 1961, 740 p.

- FOREST Alain, "Les portraits du Cambodgien", *ASEMI*, IV (1973), 2, p. 81-107.



www.elibraryofcambodia.org

- GUESDON, Joseph *Dictionnaire cambodgien-français*, Paris, Plon, 1930, 2 vol.

- JACOB Judith M., "Some Features of Khmer Versification", *In Memory of J.R. Firth*, edited by Charles Ernest Bazell et al., London, Longmane, 1966, p. 227-241.

- JENNER Philip N., "The Relative Dating of Some Khmer Cpa'pa'", *Austroasiatic Studies* (Honolulu, University Press of Hawaii, 1976), II, pp. 693-710.

- JOURNAL OFFICIEL DU CAMBODGE, 37 (numéro spécial), 19 septembre, 1958.

- KENG Vannsak, *Quelques aspects de la littérature khmère*, Phnom Penh, Faculté des Lettres, 1966, 24 p.

- id. , "Réflexion sur la littérature khmère", *Revue française*, n° 20, 1986, p. 31-34.

- KHING Hoc Dy, *Ecrivains et expressions littéraires du Cambodge au XXème siècle*, Paris, L'Harmattan, 1993, 275 p.

- *id.* , *L'œuvre littéraire de Nan, auteur cambodgien de la fin du XVIIIe siècle et du début du XIXe* , thèse de doctorat de 3ème cycle, Université Paris 3, 1974, 2 vol.

- *id.* , "Quelques traits bouddhiques dans Bhogakulakumār, roman cambodgien en vers du début du XIXe siecle", *Cahiers de l'Asie du Sud-Est*, 1, 1977, p. 59-77.

- KHING Hoc Dy et KHING Jacqueline, "Les recommandations de Kram Ngoy", *Mon-Khmer Studies* VII, University Press of Hawaii, 1978, p. 141-181.

- *id.* , *Les recommandations de Kram Ngoy*, Paris, Cedoreck, 1981, 52 p.

- KHY Phanra, *La communauté vietnamienne au Cambodge à l'époque du protectorat français (1863-1953)*, thèse de doctorat de 3ème cycle, Paris, Université Paris 3, 1974, 556 p.

- LECLERE, A., *Le bouddhisme au Cambodge*, Paris, E. Leroux, 1899, 535 p.

- LEROI-GOURHAN, A. *L'homme et la matière*, 2e édition, Paris, Albin Michel, 1971, 348 p.

- LEWITZ S., "Notes sur la translittération du cambodgien", *Bulletin de l'Ecole Française d'Extrême-orient*, LV, 1969, p. 163-169.



www.elibraryofcambodia.org

- *Id.* ,"The infix /-b-/ in khmer, *Austroasiatic Studies*, (Honolulu, The University Press of Hawaii, 1976) II, p. 741-760
- NEPOTE, Jacques, *Parenté et organisation sociale dans le Cambodge moderne et contemporain*, Genève, Editions Olizane, 1992, 255 p.
- NEPOTE Jacques et KHING Hoc Dy, "L'organisation du champ de la couleur en cambodgien", in TORNAY S. (éd.), *Voir et nommer les couleurs*, Laboratoire d'ethnologie et de Sociologie de Paris X, Nanterre, p. 83-107.
NYANATILOKA, *Vocabulaire bouddhique de termes et doctrines du canon pâli*, Paris, Adyar, 1961, 336 p.
POU. S. et JENNER Philip N., "Les *cpāp'* ou 'codes de conduite' khmers, I: *cpāp'* kerti käl, *BEFEO*, LXII (1975), p. 369-394.
- id. ,"Some Chinese Loanwords in Khmer", *Journal of Oriental Studies* (Hong Kong), XI (1973), 1, 90 p.
URBA, *Musique khmère*, Phnom Penh, 1969, 129 p.
RŒSKE J., "Métrique khmère, bat et kalabat", *Anthropos*, VIII (1913), 4-5, p. 670-687 et 1026-1043.
- SAN Sarin, *Les textes liturgiques fondamentaux du bouddhisme cambodgien actuel*, thèse de l'Ecole Pratique des Hautes Etudes, IVème section, Paris, 1975, 225 p.
- *id.* , "Phirum Ngoy, poète khmer d'après Ly Theam Téng", *Cambodge Nouveau*, 16 (1971), p. 25-35.
-SIN Kim Suy, *Les Chinois du Cambodge: Etude sociologique*, thèse de doctorat de 3ème cycle, Paris, INALCO, 1985, 302 p.
-THAY Sok, *Traité de morale des Cambodgiens*, thèse d'université, Paris, Sorbonne, 1964, 204 f. dactylographiées.
THIERRY Solange, *Etude d'un corpus de contes cambodgiens traditonnels: Essai d'analyse thématique et morphologique*, thèse de doctorat d'Etat, Université de Paris V, 1976, 553 p.
-*id.*- , *Le Cambodge des contes*, Paris, L'Harmattan, 1985, 295 p.
-*id* , *Le bétel, I - Inde et Asie du Sud-Est*, Paris, Musée de l'Homme, 1969.
-*id.*- , "La place des textes de sagesse dans la littérature cambodgienne traditionnelle", *Revue de l'Ecole Nationale des Langues Orientales*, V, 1968, p. 163-184.
- VANDY Kaonn, *Réflexion sur la littérature khmère*, Phnom Penh, Institut de sociologie, 1981, 83 p.



www.elibraryofcambodia.org

- VOLLMAN, W:, "Notes sur les relations inter-ethniques au Cambodge du XIXème siècle", *ASEMI*, IV (1973), 2, p. 171-208.
- WILLMOTT W.E., *The Political Structure of Chinese community in Cambodia*, University of London, The Athlone Press,1970, 211 p.
- id. , *The Chinese in Cambodia*, Vancouver, University of British Columbia, 1967, 111 p.

ឃ- ប្រភពព័ត៌មានតាមវេបសាយ (Site Web)

- http://www.Cambodianbuddhist.org/doc/boran.htm
- http://khmerization.blogspot.com/2008/01/biography-of-krom-ngoy-father-of-khmer.html
- Yi Thon . http://Khmercenter.ch/Bandam%20Kromngoy/History.htm ("Krom Ngoy (1865-1936), The Father of Khmer Poetry", compilé par YI Thonn *in:* http://en.wikipedia.org/wiki/krom_ngoy).



www.elibraryofcambodia.org

# រូបភាព



www.elibraryofcambodia.org



សិស្សសាលាពុទ្ធិកនៅដើមសតវត្សទី២០



www.elibraryofcambodia.org



រូបថតក្រុមង៉ុយ លើក្របសៀវភៅលោកលី-ធាមតេង



www.elibraryofcambodia.org





ប្រលោមលោកទទួលរង្វាន់ក្រមង៉ុយ ឆ្នាំ១៩៧២



www.elibraryofcambodia.org




ក្រដាសប្រាក់៥០០០រៀល (គ.ស ១៩៧៤-៧៥)



www.elibraryofcambodia.org



រូបគំនូរក្របខ្ញុំ ដោយ ចាន់-អៀង (គ.ស.១៩៧៩)



www.elibraryofcambodia.org




ប័ណ្ណប្រកាសរាត្រីសមោសរ ដោយក្លឹប ៤៣០ ក្រុមងុយ នៅប្រទេសបារាំងនា ឆ្នាំ១៩៨៧



www.elibraryofcambodia.org



Kram Ngoy, poète populaire

គំនូរពណ៌រូបក្រមង៉ុយនៅមជ្ឈមណ្ឌលក្រមង៉ុយ



www.elibraryofcambodia.org




មជ្ឈមណ្ឌលក្រមង៉ុយ



រូបសំណាកក្រុមហ៊ុនសរស្ដ្រាតមវើខក្ស ២០០៨

យើងខ្ញុំជាកូន ខ្ញៅ យុនសំរ៉ង ខ្ញៅ យ៉ាតណៃ ខ្ញៅសុខផល ខ្ញៅ វិសាល ខ្ញៅ រ៉ាមុន
ខ្ញៅ ភារាដា ខ្ញៅ ចំរើន ខ្ញៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ គីម វាសនា

កក្កដា ឆ្នាំ ២០១៥


បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។


សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

**ក្រមង៉ុយ** (១៨៦៥-១៩៣៦) កើតនៅឃុំកំបូលស្រុកភ្នំពេញសព្វថ្ងៃស្រុកអង្គស្នួលក្នុងខេត្តកណ្ដាលមាននាមដើម «អ៊ុក-អ៊ូ» ប៉ុន្តែ មាតាបិតា លោកហៅក្រៅថា ង៉ុយៗ ក៏ជាប់រហូតមក ។

ក្នុងការរស់នៅជាកសិករ ង៉ុយមានប្រជាប្រិយភាពខ្លាំងខាង វោហារ និង ល្បិចលើកកំណាព្យភ្លាមៗ ច្រៀងឡើងនិងសំនៀងសាដៀវយ៉ាងពិរោះព្រមទាំងមានចំណេះខាងធម៌អាថ៌យ៉ាងខ្ពង់ខ្ពស់ ដែលធ្វើឲ្យកសិករឯទៀតរាប់អានស្រឡាញ់ទុកលោកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយអ្នកភូមិស្រុកហៅលោកថា «ភិរម្យង៉ុយ» បន្ទាប់ មករដ្ឋអំណាចបានតាំងលោកជា «ក្រម» គឺជាភារៈជនដែលធ្វើ ទំនាក់ទំនងរវាងរដ្ឋបាល និង ប្រជាជនក្នុងឃុំ ។

ពេលរដូវវំហើយក្រោយពីកិច្ចការច្រូតកាត់ក្រមង៉ុយតែងទេសនាប្រៀនប្រដៅច្រៀងកំណាព្យបន្ទរដោយសំនៀងសាដៀវដ៏ក្រលួចពីភូមិមួយទៅភូមិមួយ ដោយយំស្រណោះអាណិតខ្មែរគ្នាឯង ពីភាព ខ្សត់ខ្សោយ ក្រី ក្រ ល្ងង់ ខ្លៅ ឈ្លោះគ្នាឯងបែកសាមគ្គី ។ល។ ផ្ទុយ នឹង ទម្ងន់ពន្ធដារ នៃរដ្ឋអំណាចបារាំង ភាពរហ័សរហួន ឆ្លាតវៃ ការកេងបន្លំជនបរទេសមានចិនយួនជាដើម ។

**ឃីងហុកឌី** បណ្ឌិតរដ្ឋផ្នែកអក្សរសាស្ត្រ និង មនុស្សសាស្ត្រនៅសកលវិទ្យាល័យស័របោន (ប៉ារីស), អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រប្រទេសបារាំង, សមាជិករាជបណ្ឌិតសភាកម្ពុជាបានបោះពុម្ពផ្សាយ ជាសៀវភៅនិង អត្ថបទសិក្សាលើវប្បធម៌ និង អក្សរសិល្ប៍ខ្មែរនៅអាស៊ី, អឺរ៉ុបនិងសហរដ្ឋអាមេរិក ។

រូបក្របក្រៅ ៖ រូបសំណាកសំរឹទ្ធក្រមង៉ុយសម្ពោធនា ឆ្នាំ២០០៨ ក្រោមអធិបតីភាពឯកឧត្តមកែបជុតិមា ចៅហ្វាយក្រុងភ្នំពេញ ។

N-97899950204

គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ Editions Angkor

ផ្ទះលេខ143Eo ផ្លូវខេមរភូមិន្ទ (St.130) ភ្នំពេញ

9 789995 020491

elibraryofcambodia.org